# បទដ្ឋានបច្ចេកទេស
# ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបទ្កលក្ខណៈងាយស្រួល
# សម្រាប់ជនមានពិការភាព





សម្របសម្រួលរៀបចំដោយ:

អគ្គលេខាធិការដ្ឋាន
ក្រុមប្រឹក្សាសកម្មភាពជនពិការ



ឆ្នាំ ២០១៨


រក្សាសិទ្ធិគ្រប់យ៉ាង

ចូលរួមឧបត្ថម្ភការបោះពុម្ពដោយ៖

ACCESS
Sustainable quality services for all

Australian Aid

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ...២៤៧...សអប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការដាក់ឱ្យអនុវត្តនូវបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព

**ឧបនាយករដ្ឋមន្ត្រី** **រដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/០០៧ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការ

រៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- យោងតាមការចាំបាច់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យប្រើប្រាស់បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.-**

បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព ត្រូវបានអនុវត្តចំពោះគម្រោងសាងសង់ និងការកែសម្រួលហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ សំណង់ អគារផ្ដល់សេវាជូនសាធារណជន និងលំហសាធារណៈ ដូចជា បណ្ដាញផ្លូវ ផ្លូវថ្មើរជើង ចិញ្ចើមផ្លូវ សួនច្បារ ចំណតយានយន្ត ស្ថានីយ៍រថភ្លើង ព្រលានយន្តហោះ អគាររដ្ឋបាលសាលារៀន គ្រឹះស្ថានអប់រំ មន្ទីរពេទ្យ និងមណ្ឌលសុខភាព និងគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ សំណង់បុរី លំនៅឋាន សណ្ឋាគារ ភោជនីយដ្ឋាន ផ្សារ រោងចក្រ និងអគារឯកជនផ្សេងៗទៀតសម្រាប់ជនមានពិការភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពគ្រប់ប្រភេទអាចចល័តទីចេញ-ចូល ឡើង-ចុះ និងប្រើប្រាស់ដោយងាយស្រួល ប្រកបដោយសុវត្ថិភាពនិងគ្មានឧបសគ្គ។

**ប្រការ៣.-**

ស្ថាប័ន ឬអង្គភាព ដែលមានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់ ត្រូវតម្រូវឱ្យម្ចាស់សំណង់រៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពគ្រប់ប្រភេទអាចចេញ-ចូល ឡើង-ចុះ និងប្រើប្រាស់បានដូចជា ច្រកផ្លូវដែលភ្ជាប់ផ្លូវមួយទៅផ្លូវមួយទៀត បន្ទះដែក គំនូសឆ្នូតដែលមានរំលេចព័ណ៌នៅតាមផ្លូវ ជម្រាល ផ្លូវជម្រាល ផ្លូវដើរ បង្កាន់ដៃសុវត្ថិភាព កាំជណ្ដើរ ទ្វារនិងដៃទ្វារ ជណ្ដើរ យោងនិងទ្វារប៊ូតុងបញ្ជាជណ្ដើរយោង ជណ្ដើរយន្ត ជណ្ដើររត់ដឹកអ្នកដំណើរ ឧបករណ៍ប្រាប់ដំណឹងជាសូរសំឡេង ច្រកដើរខាងក្នុង ទំនប់ខណ្ឌមាត់ទ្វារ កន្លែងសម្រាក ស្លាកសញ្ញា ភ្លើងសញ្ញា បញ្ជរផ្ដល់សេវា បង្គន់បែបទីក្រុង និងបែបជនបទ បង្គន់នោម ចានសម្រាប់លាងដៃ (ឡាវ៉ាបូ)

ប្រភពទឹក អណ្តូងស្អប់និងអណ្តូងដៃ កន្លែងសម្រាប់ងូតទឹក សម្ភារបរិក្ខារនៅក្នុងថ្នាក់រៀន ឬសាលប្រជុំ និងបរិក្ខារជំនួយសុវត្ថិភាពផ្សេងៗ ស្របតាមបទដ្ឋានបច្ចេកទេស ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនមានពិការភាព អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ**

ជា សុផារ៉ា

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**និងជាអនុប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ**

វង សូត

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ

| ក្រុមការងាររៀបចំ | |
|---|---|
| **អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា សកម្មភាពជនពិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** |
| ១. ឯកឧត្តម **ឯម ច័ន្ទមករា** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាសកម្មភាពជនពិការ | ១. លោកជំទាវ **ទិត្យ ច័ន្ទតារីន** អនុរដ្ឋលេខាធិការ |
| ២. ឯកឧត្តម **អ៊ឹង សម្បត្តិ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា សកម្មភាពជនពិការ | ២. ឯកឧត្តម **យស់ យោមណារ៉ាឌី** អនុរដ្ឋលេខាធិការ |
| ៣. លោក **ឈន អក្ខរា** ប្រធានផ្នែកអភិវឌ្ឍសេវាពិការភាព នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា សកម្មភាពជនពិការ | ៣. លោក **អេ ប៊ុនធឿន** ប្រធាននាយកដ្ឋាននីតិកម្ម |
| ៤. មន្ត្រីផ្នែកអភិវឌ្ឍសេវាពិការភាព នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាសកម្មភាពជនពិការ | ៤. លោក **ជិម វណ្ណថា** អនុប្រធានការិយាល័យ កិច្ចការគតិយុត្ត |

# មាតិកា


ផ្នែកទី១ អំពីផ្លូវនិងច្រកចេញចូល (PATHWAY AND ENTRANCES)............... ១

**១.១. អំពីផ្លូវសម្រាប់ទាំងអស់គ្នា (Access Routes)**.................................. ៣

១.១.១. ច្រកផ្លូវដែលភ្ជាប់ពីផ្លូវមួយទៅមួយទៀត

(Pathway, Connection Paths) ................................................ ៦

១.១.២. លូបង្ហូរទឹកនិងបន្ទះដែក (Drainage and Gratings)................... ៨

១.១.៣. បង្កាន់ដៃការពារ (Guardrails)................................................ ៩

**១.២. អំពីការចុះឡើង (Changes in Level)** ............................................ ១០

១.២.១. ជម្រាល (Ramps)និងចំណោត (Slopes).............................. ១៣

*១.២.១.១. ជម្រាលនៅខាងក្រៅ (External Ramps)...................... ១៣*

*១.២.១.២. ជម្រាលនៅខាងក្នុង (Internal Ramps)......................... ១៦*

*១.២.១.៣. ជម្រាលចល័ត (Mobile Ramps)................................. ១៩*

*១.២.១.៤. ចំណោត (Slopes) ...................................................... ២០*

១.២.២. បង្កាន់ដៃជម្រាលនិងចំណោត

(Handrails for Ramps and Slopes)....................................... ២២

១.២.៣. ផ្ទៃជម្រាលនិងគែមសម្រាប់ការពារ

(Ramp Surface and Edge Protection).................................. ២៥

១.២.៤. ជណ្ដើរនៅខាងក្រៅ (External Stairs)................................... ២៦

១.២.៥. ជណ្ដើរនៅខាងក្នុង (Internal Stairs).................................... ៣១

១.២.៦. ជណ្ដើរយោង (Passenger Lift)............................................ ៣៣

១.២.៧. ជណ្ដើរយោងជម្លៀសពេលមានអាសន្ន (Evacuation Lifts)... ៤០

១.២.៨. ឧបករណ៍យោងចាប់ជាប់បង្កាន់ដៃជណ្តើរ (Stair Lifts)......... ៤១
១.២.៩. ជណ្តើរយន្ត (Escalators)...................................................... ៤១
១.២.១០. ជណ្តើររត់ដឹកអ្នកដំណើរ (Travelators)............................... ៤៤
**១.៣. សម្ភារៈសម្រាប់ក្រាលផ្ទៃ (Surface Materials)............................... ៤៥**
**១.៤. គ្រឿងសង្ហារឹមនៅតាមផ្លូវ (Street Furniture)................................. ៤៦**
១.៤.១. អំពូលភ្លើងនិងស្លាកសញ្ញា (Lighting and Signage) .............. ៤៧
១.៤.២. ការបំពាក់សង្ហារឹមនៅតាមផ្លូវ
(Placement of Street Furniture)............................................ ៤៨
១.៤.៣. ធុងសំរាម (Bins) ................................................................... ៥០
១.៤.៤. បង្គោលការពារ (Bollards) ...................................................... ៥១
១.៤.៥. ច្រកទ្វារ (Gates) ...................................................................... ៥២
១.៤.៦. កន្លែងទឹកអាចហូបបាន (Drinking Fountains)........................ ៥២
១.៤.៧. កន្លែងអង្គុយ (Seating)......................................................... ៥៣
១.៥. ចំណុចថ្មើរជើងឆ្លងកាត់ (Pedestrian Crossing Points).............. ៥៦
**១.៦. ផ្ទៃបាតនៃផ្លូវថ្មើរជើងដែលប៉ះអាចដឹងបាន**
**(Tactile Paving Surfaces) .......................................................... ៥៩**
១.៦.១. ផ្ទៃពកនៅត្រង់ផ្លូវឆ្លងកាត់
(Blister Surface for Pedestrian Crossing Points)................... ៦១
១.៦.២. ផ្លូវដែលមានឥដ្ឋពណ៌ឆ្នូតៗសម្រាប់ការប្រុងប្រយ័ត្ន
(Corduroy Paving for Hazards) ............................................. ៦៥

**១.៧. ច្រកចូល (Entrances)** ........................................................................ ៦៧

១.៧.១. ផ្លូវចូលទៅកាន់កន្លែងទទួលភ្ញៀវ (Entrance Lobbies)........... ៦៨

១.៧.២. កន្លែងទទួលភ្ញៀវនិងកន្លែងរង់ចាំ

(Reception and Waiting Areas)............................................. ៧០

១.៧.៣. កន្លែងតម្រង់ជួរនិងឧបសគ្គបណ្តោះអាសន្ន

(Queuing Areas and Temporary Barriers)............................ ៧២

**១.៨. ច្រកផ្លូវ (Horizontal Circulation)** .................................................. ៧៣

១.៨.១. ច្រករបៀង (Corridors) ......................................................... ៧៤

១.៨.២. កន្លែងរង់ចាំខាងក្នុង (Internal Lobbies)................................ ៧៧

**១.៩. ទ្វារ (Doors)** ........................................................................................ ៧៨

១.៩.១. ទ្វារចូល (Entrance Doors).................................................... ៨០

១.៩.២. ទ្វាររិល (Revolving Doors).................................................... ៨៣

១.៩.៣. ទ្វារចូលដែលមានគន្លាក់ (Turnstile).................................... ៨៤

១.៩.៤. ទ្វារខាងក្នុង (Internal Doors)................................................. ៨៤

១.៩.៥. គ្រឿងផ្គុំរបស់ទ្វារ (Door Ironmongery)................................. ៨៥

*១.៩.៥.១. ត្រចៀកទ្វារ (Hinges)*.................................................... *៨៥*

*១.៩.៥.២. ដៃទ្វារ គន្លឹះទ្វារនិងសោទ្វារ*

*(Handles, Latches and Locks)*................................... *៨៦*

*១.៩.៥.៣. ដៃទ្វារទាញនិងផ្លូវរត់របស់ទ្វារ*

*(Pull Handles and Rails)*........................................... *៨៧*

*១.៩.៥.៤. ទ្វារគ្មានដៃ (Finger Plate and Kick Plates)*.................. *៨៨*



១.៩.៥.៥. ឧបករណ៍បិទទ្វារ (Door-Closing Devices).................. ៨៩

១.៩.៥.៦. គ្រឿងផ្គុំរបស់ទ្វារច្រកចេញពេលមានអាសន្ន (Emergency Exit Door Ironmongery) ......................... ៩០

១.៩.៥.៧. គ្រឿងផ្គុំរបស់ទ្វារផ្សេងៗទៀត (Other Ironmongery)..... ៩១

១.៩.៥.៨. ប្រព័ន្ធស្វ័យប្រវត្តិរបស់ទ្វារ (Automatic Door Systems)....៩២

១.៩.៥.៩. សុវត្ថិភាពរបស់ទ្វារនិងប្រព័ន្ធចេញចូល (Door Security and Entry Systems) ...........................៩៣

**ផ្នែកទី២ អំពីការរៀបចំចំណតយានយន្ត (CAR PARK ENVIRONMENTS)...... ៩៥**

**២.១. ទិដ្ឋភាពទូទៅ (General)** ........................................ ៩៨

**២.២. ចំនួនរថយន្ត (Number of Vehicles)**........................................៩៩

**២.៣. ទំហំចំណត (Car Parking Spaces and Dimension)** ................. ១០០

**២.៤. ស្លាកសញ្ញាចំណត (Car Parking Signage)** ............................... ១០៤

**២.៥. ទីតាំងចំណត (Parking Location)** ........................................ ១០៥

**២.៦. ខឿនចំណត (Parking Curb)** ........................................ ១០៨

**២.៧. ចំណតក្រោមដីនិងច្រើនជាន់ (Multi-Story and Underground Car Parks)** ............................... ១០៩

**២.៨. ចំណតបង់ប្រាក់ (Paid Parking)** ........................................ ១១១

**២.៩. កន្លែងភ្ញៀវចុះនិងឡើងរថយន្ត (Drop-off Areas)** ...................... ១១៣

**២.១០. ផ្ទៃនៃទីធ្លាចំណត (Surface)** ........................................ ១១៤

**២.១១. ចំណតតាក់ស៊ី (Taxi Ranks)**........................................ ១១៥

**២.១២. ចំណតដែលមានស្រាប់ ( Existing Constructions )** ........... ១១៦



២.១៣. ចំនួនចំណតធៀបទៅនឹងផ្ទៃក្រឡាអគារ........................... ១១៨

**ផ្នែកទី៣ អំពីប្រភេទអគារ (BUILDING TYPES)** ......................................... ១២១

**៣.១. អគារការិយាល័យ (Office Buildings)**....................................... ១២៣

៣.១.១. ច្រកចូលនិងផ្លូវបត់បែនខាងក្នុង (Entrances and Circulation) .............................................. ១២៤

៣.១.២. ទិដ្ឋភាពខាងក្នុង (Internal Environment)........................... ១២៥

៣.១.៣. កន្លែងធ្វើការនិងកន្លែងទុកសម្ភារៈ (Workstations and Storage) .............................................. ១២៦

**៣.២. អគារសម្រាប់មធ្យោបាយដឹកជញ្ជូន (Transport Buildings)** ... ១២៧

៣.២.២. ទំហំនិងការរៀបចំ (Size and Layout) ............................... ១២៩

៣.២.៣. ទីកន្លែងសម្រាប់អ្នកដំណើរ (Passenger Facilities).......... ១៣០

៣.២.៤. ព័ត៌មានអំពីការធ្វើដំណើរ (Travel Information)................. ១៣១

**៣.៣. អគារមជ្ឈមណ្ឌលផ្សារទំនើបនិងកន្លែងលក់ដូរ (Retail Outlets and Shopping Centers)** .................................. ១៣៣

៣.៣.១. ផ្លូវបត់បែនខាងក្នុង (Internal Circulation)....................... ១៣៣

៣.៣.២. កន្លែងដាក់តាំងលក់និងកន្លែងទុកសម្ភារៈនៅក្នុងហាង (Display and Storage in Shops) ....................................... ១៣៤

៣.៣.៣. បញ្ជរនិងកន្លែងបង់ប្រាក់មុនចេញ (Counters and Checkouts) ............................................... ១៣៥

៣.៣.៤. បន្ទប់លសំលៀកបំពាក់ (Fitting Rooms).......................... ១៣៦

៣.៣.៥. ឧបករណ៍បរិក្ខារនិងជំនួយនៅក្នុងហាង (Equipment and Assistance in Shops)............................. ១៣៧




**៣.៤. អគារភោជនីយដ្ឋាន បារនិងហាងកាហ្វេ**

**(Restaurants, Bars and Cafés)........................................... ១៣៨**

៣.៤.១. ការដាក់តាំងនិងកន្លែងអង្គុយនៅក្នុងបារនិងភោជនីយដ្ឋាន

(Layout and Seating in Bars and Restaurants)................ ១៣៨

៣.៤.២. កន្លែងទទួលសេវាដោយខ្លួនឯង (Self-Service Facilities).. ១៤០

៣.៤.៣. សេវាកម្មនិងការគ្រប់គ្រងអតិថិជន

(Customer Service and Management)............................... ១៤១

៣.៤.៤. កន្លែងជក់បារីនៅខាងក្រៅ (Outdoor Smoking Areas) ....... ១៤២

៣.៥. អគារសារមន្ទីរ សាលពិព័រណ៍និងបណ្ណាគារ

(Museums, Galleries and Libraries)................................... ១៤២

៣.៥.១. ព័ត៌មាននិងការបកប្រែ (Information and Interpretation)... ១៤៣

៣.៥.២. ការដាក់តាំងនិងពិព័រណ៍ (Displays and Exhibits) ............. ១៤៤

៣.៥.៣. កន្លែងសិក្សា (Study Areas)............................................... ១៤៥

៣.៥.៤. ធ្នើរនៃបណ្ណាល័យ (Library Shelving)................................. ១៤៧

**៣.៦. អគារសម្រាប់កម្សាន្ត សាលប្រជុំនិងបណ្តុះបណ្តាល**

**(Entertainment, Conference and Lecture Facilities)............... ១៤៨**

៣.៦.១. កន្លែងអង្គុយសម្រាប់អ្នកទស្សនា (Audience Seating)....... ១៤៩

៣.៦.២. កន្លែងសម្រាប់អ្នកសម្តែង (Performers’ Facilities)............. ១៥១

៣.៦.៣. កន្លែងសម្រាប់វាគ្មិនឬគ្រូឧទ្ទេស (Speakers’ Facilities) ..... ១៥១

**៣.៧. អគារសាសនា (Religious Buildings)........................................ ១៥២**

៣.៧.១. កន្លែងសម្រាប់អ្នកអង្គុយឬអ្នកបួងសួង

(Facilities for Seating and Prayer)..................................... ១៥៣

៣.៧.២. កន្លែងផ្សេងៗទៀតនៅក្នុងអគារសាសនា

(Other Facilities in Religious Buildings) ............................ ១៥៤

**៣.៨. អគារសណ្ឋាគារ ផ្ទះសំណាក់និងអគារស្នាក់នៅ**

**(Hotel, Guest and Residential Accommodation)** ..................... ១៥៥

៣.៨.១. បន្ទប់គេង (Bedrooms)........................................................ ១៥៦

៣.៨.២. បន្ទប់ងូតទឹក (Bathrooms)................................................ ១៦២

**៣.៩. អគារលំនៅឋាន (Housing)**..................................................... ១៦៣

៣.៩.១. ទិដ្ឋភាពខាងក្រៅលំនៅឋាន (External Environment)....... ១៦៣

៣.៩.២. ច្រកចូលលំនៅឋាន (Entrances)..................................... ១៦៤

៣.៩.៣. ច្រកផ្លូវដើរនៅក្នុងលំនៅឋាន

(Horizontal Circulation in Housing) ................................... ១៦៥

៣.៩.៤. ច្រកឡើងចូលលំនៅឋាន

(Vertical Circulation in Housing)......................................... ១៦៧

៣.៩.៥. សេវាកម្មផ្សេងៗនៅក្នុងលំនៅឋាន (Services in Housing)... ១៦៨

៣.៩.៦. បន្ទប់ជាលក្ខណៈបុគ្គល (Individual Rooms) ..................... ១៦៩

**៣.១០. អគារនិងទីតាំងប្រវត្តិសាស្ត្រ (Historic Buildings and Sites) ...** ១៧០

៣.១០.១. គោលការណ៍គ្រឹះអំពីការអភិរក្ស

(Conservation Principles)................................................... ១៧១

៣.១០.២. ការកែសម្រួលអគារប្រវត្តិសាស្ត្រ

(Making Changes to Historic Buildings) ............................ ១៧២

៣.១០.៣. ការឌីហ្សាញលម្អិតអំពីអគារប្រវត្តិសាស្ត្រ

(Detailed Design of Historic Buildings).............................. ១៧២

*៣.១០.៣.១. ច្រកចូល ( Entrances ) ................................... ១៧៣*

*៣.១០.៣.២. ទ្វារ ( Doors ) ................................................ ១៧៤*

*៣.១០.៣.៣. ជម្រាល ( Ramps )......................................... ១៧៦*

*៣.១០.៣.៤. ជណ្តើរ ( Staircases ) ..................................... ១៧៧*

*៣.១០.៣.៥. ផ្ទៃបាតនៃជណ្តើរយោងឬជណ្តើរប្រអប់*

*( Platform Lifts) ................................................ ១៧៩*

**៣.១១. ទិដ្ឋភាពខាងក្រៅអគារ (Outdoor Access)............................១៨១**

៣.១១.១. ប្រភេទទិដ្ឋភាព (Types of Landscape) ..................... ១៨១

*៣.១១.១.១. ទិដ្ឋភាពធម្មជាតិ ( Natural Landscape ) .............. ១៨១*

*៣.១១.១.២. ទិដ្ឋភាពច្នៃប្រឌិត ( Tempered Landscape )......... ១៨៣*

*៣.១១.១.៣. ទិដ្ឋភាពនៅតាមទីប្រជុំជន ( Urban Landscape ) ... ១៨៥*

*៣.១១.១.៤. ទិដ្ឋភាពនៅតាមជនបទ ( Tamed Landscape )...... ១៨៥*

៣.១១.២. តំបន់ភ្នំ (Mountains) .....................................................១៨៧

៣.១១.៣. តំបន់ដីដែលសម្បូរព្រៃឈើ ( Peatlands ) ...................១៨៨

៣.១១.៤. តំបន់ឆ្នេរ (Beaches) ..............................................១៨៨

៣.១១.៥. តំបន់អភិរក្ស (Conservation Areas) ................................ ១៨៩

៣.១១.៦. កន្លែងគយគន់ទេសភាព (Viewing Points)..................... ១៩០

៣.១១.៧. ឧទ្យានតាមជនបទ (Country Parks).............................. ១៩០

៣.១១.៨. តំបន់ដែលសម្បូររុក្ខជាតិនិងដើមឈើធំៗ

(Woodlands and Arboreta)................................................ ១៩១

៣.១១.៩. កន្លែងសម្រាកបរិភោគអាហារ (Picnic Areas)................. ១៩២

៣.១១.១០. ទីតាំងបោះជំរុំនិងឧទ្យានផ្សេងៗ

(Campsites and Caravan Parks)........................................ ១៩២

៣.១១.១១. ផ្លូវជាប់មាត់ទឹក (Waterways) ......................................១៩៣

៣.១១.១២. តំបន់បុរាណវិទ្យា (Archaeological Sites)..................... ១៩៤

៣.១១.១៣. កន្លែងរៀបចំពិធីបណ្តោះអាសន្ន

(Temporary Events) .................................................. ១៩៥

៣.១១.១៤. ឧទ្យាន (Parks) ........................................................... ១៩៦

៣.១១.១៥. កន្លែងបញ្ចុះសព (Cemeteries) .................................. ១៩៦

៣.១១.១៦. សួនកុមារ កន្លែងលេងនិងឧបករណ៍ផ្សេងៗ

(Playgrounds, Play Structures and Equipment) .............១៩៧

៣.១១.១៧. សួនច្បារនិងទីធ្លា (Gardens and Courtyards).............. ១៩៨

**៣.១២. ស្លាកសញ្ញាទូទៅ (General Signage)..................................... ១៩៨**

១. ស្លាកសញ្ញាអន្តរជាតិ ( International Symbol of Accessibility )... ២០០

២. ស្លាកសញ្ញាប្រាប់ទិស ( Direction Signs ) ...............................២០០

៣. ស្លាកសញ្ញាផែនទីនិងផ្ទាំងព័ត៌មាន

( Maps and Information Panels ) ..................................២០០

៤. ការបំពាក់ស្លាកសញ្ញា ( Installation ) .................................. ២០១

៥. ទម្រង់នៃស្លាកសញ្ញា ( Shape of Signboard ) .........................២០២

៦. ពណ៌នៃស្លាកសញ្ញា ( Colour ) ...........................................២០២

៧. ផ្ទៃនៃស្លាកសញ្ញា ( Surface ) ............................................ ២០៣

៨. អក្សរនៅលើស្លាកសញ្ញា ( Lettering ) ................................. ២០៣

៩. ទំហំស្លាកសញ្ញា ( Size ) ..................................................២០៤

១០. ការណែនាំទូទៅអំពីស្លាកសញ្ញា ( General Guide ) .............. ២០៤

១១. គំរូអំពីស្លាកសញ្ញាសំខាន់ៗមួយចំនួន ( Some Important Signage ) ....................................... ២០៥

ផ្នែកទី៤ អំពីបរិក្ខារនៅក្នុងអគារ (FACILITIES IN BUILDINGS).................... ២០៩

**៤.១. តុទទួលភ្ញៀវនិងបញ្ជរផ្តល់សេវា (Reception Desks and Service Counters)** .......................... ២១១

**៤.២. កន្លែងអង្គុយរង់ចាំ (Waiting Areas and General Seating)** .... ២១៤

**៤.៣. ឃ្លាំងឬកន្លែងស្តុក (Storage Facilities)** ...................................... ២១៥

**៤.៤. ទូរស័ព្ទសាធារណៈ (Public Telephones)** ............................ ២១៧

៤.៤.១. ទូរស័ព្ទបង់ប្រាក់ (Payphones) ........................................ ២១៧

៤.៤.២. ទូរស័ព្ទលើតុ (Textphones) ............................................... ២១៩

៤.៤.៣. រោងទូរស័ព្ទ (Telephone Booths) ...................................... ២២០

**៤.៥. ម៉ាស៊ីនប្រើកាក់និងកាត (Coin and Card-Operated Machines)**... ២២១

៤.៥.១. ម៉ាស៊ីនទុកនិងលក់សំបុត្រ (Ticket Dispensers and Vending Machines) ...................... ២២២

**៤.៥.២.ម៉ាស៊ីនដកនិងដាក់ប្រាក់ដោយស្វ័យប្រវត្តិ (Automated Teller Machines(ATMs)** ....................................... ២២៣

**៤.៦. ផ្ទះបាយនិងកន្លែងទទួលទានអាហារ (Kitchen and Refreshment Facilities)**...................................... ២២៥

៤.៦.១. កន្លែងដាក់អាហារនិងកន្លែងចម្អិន (Layout and Work Surfaces) .............................................. ២២៦

៤.៦.២. ឃ្លាំងស្តុកនៅក្នុងផ្ទះបាយនិងកន្លែងទទួលទានអាហារសម្រន់
(Storage in Kitchen and Refreshment Areas) ............... ២២៨
៤.៦.៣. កន្លែងលាងចាននិងឧបករណ៍ផ្ទះបាយ
( Sinks and Appliances ) ..........................................២២៩
៤.៦.៤. កុងតាក់និងព្រីភ្លើង (Switches and Socket Outlets) ....... ២៣៣
**៤.៧. បង្អួច (Windows)** ........................................................ ២៣៤
**៤.៨. គំនិតច្នៃប្រឌិតសម្រាប់ថ្នាក់រៀនមេត្រី**
**(Appropriate Concept in an Inclusive Class)**......................... ២៣៧
**ផ្នែកទី៥ អំពីបរិក្ខារអនាម័យ** (SANITARY FACILITIES).............................. ២៤១
**៥.១. បង្គន់សម្រាប់ភេទតែមួយ (Single-Sex Toilets)**......................... ២៤៣
**៥.១.១. កន្លែងងូតទឹកក្នុងបង្គន់ (Accessible Toilet Cubicles)**........... ២៤៤
៥.១.២. កន្លែងងូតទឹកដែលទូលាយ ( Enlarged Cubicles ) .........២៤៦
៥.១.៣. បង្គន់នោមសម្រាប់បុរស ( Urinals ) .............................២៤៧
**៥.២. បង្គន់សម្រាប់ភេទច្រើន (Unisex Toilets)** ................................ ២៤៩
៥.២.១. បង្គន់សម្រាប់ភេទច្រើនប្រើប្រាស់បាន
(Unisex Accessible Toilet) ................................................ ២៤៩
៥.២.២. ចានបង្គន់និងបាសាំងទឹក ( WC Pans and Cisterns ) .... ២៥៣
៥.២.៣. បង្គន់ភេទច្រើនដែលទូលាយនិងមានបាសាំងលាងដៃ
(Enlarged Unisex Toilet with Standing Height Washbasin) ..២៥៥
៥.២.៤. បង្គន់សម្រាប់គ្រួសារ (Family Toilets) .............................. ២៥៦
៥.២.៥. កន្លែងផ្លាស់សម្លៀកបំពាក់ទារក
(Baby-Changing Facilities)................................................២៥៧

**៥.៣. បង្គន់សម្រាប់អ្នកត្រូវការជំនួយ**

**(Toilets for People who Need Assistance)**............................... ២៥៨

៥.៣.១. បង្គន់សម្រាប់ភេទច្រើនប្រើប្រាស់មានអ្នកជំនួយ

(Unisex Peninsular-Arrangement Toilet for Assisted Use) .....២៥៨

៥.៣.២. បង្គន់សម្រាប់ភេទច្រើនប្រើប្រាស់មានបង់និងឧបករណ៍ស្ទូចដែលអាចផ្លាស់ប្តូរបាន (Unisex Peninsular-Arrangement Toilet with Adjustable Changing Bench and Hoist Facilities) .....២៦០

**៥.៤. បន្ទប់ទឹកនិងបន្ទប់ងូតទឹក (Shower Rooms and Bathrooms)** ...២៦១

៥.៤.១. ផ្កាឈូកងូតទឹកដែលអាចប្រើបានដោយខ្លួនឯង

(Self-Contained Accessible Shower) ................................២៦២

៥.៤.២. ផ្កាឈូកងូតទឹកនៅក្នុងបង្គន់

(Accessible Shower with WC).......................................... ២៦៦

៥.៤.៣. ផ្កាឈូកងូតទឹកនិងបង្គន់សម្រាប់ភេទច្រើនប្រើប្រាស់មានអ្នកជំនួយ (Shower and Peninsular Arrangement WC for Assisted Use)..............................................................២៦៧

៥.៤.៤. បន្ទប់ទឹកសម្រាប់អ្នកអាចប្រើប្រាស់ខ្លួនឯងបាន

(Bathroom for Independent Use) ..................................... ២៦៨

៥.៤.៥. ចានសម្រាប់លាងដៃ( ឡាវ៉ាបូ ) (Washbasin) ............... ២៧០

៥.៤.៦. បង្គន់និងចានលាងដៃសម្រាប់កុមារនៅសាលារៀនឬមណ្ឌលសុខភាព (Toilet and Washbasin for Children at Schools and Health Facilities)........................................២៧០

៥.៤.៧ .បង្គន់បែបទីក្រុង (City Toilet) ........................................... ២៧២

៥.៤.៨. បង្គន់បែបជនបទ (Local Toilet)........................................ ២៧៣
៥.៤.៩. បង្គន់ដែលមានលក្ខណៈច្នៃប្រឌិតថ្មី
(Toilet Innovation in Rural Areas) ...................................... ២៧៥
**៥.៥. កន្លែងផ្លាស់សម្លៀកបំពាក់ (Changing Areas)**........................... ២៧៥
៥.៥.១. កន្លែងដែលគេអាចផ្លាស់ប្តូរសម្លៀកបំពាក់ដោយខ្លួនឯងបាន
(Self-Contained Accessible Changing Area) ..................... ២៧៦
៥.៥.២. កន្លែងដែលគេអាចផ្លាស់ប្តូរសម្លៀកបំពាក់និងផ្កាឈូក
ងូតទឹករួមគ្នា (Communal Changing and Shower Areas) ... ២៧៧
**៥.៦. លំនៅឋាន (Dwellings)**.................................................................. ២៧៨
៥.៦.១. បង្គន់លំនៅឋាន (Dwelling Toilets) .................................. ២៧៨
៥.៦.២. បន្ទប់ទឹកតាមផ្ទះ (Domestic Bathrooms)........................... ២៨០
**៥.៧. លម្អិតអំពីការឌីហ្សាញបរិក្ខារនិងទីកន្លែងអនាម័យ**
**(Detailed Design of Sanitary Facilities)**.................................... ២៨១
៥.៧.១. ឧបករណ៍បន្លឺសំឡេងរោទិ៍ជាជំនួយ (Assistance Alarms) .. ២៨១
៥.៧.២. ទំពក់ព្យួរសម្លៀកបំពាក់ (Clothes Hooks) ..................... ២៨៣
៥.៧.៣. ទ្វារនិងគន្លឹះទ្វារ (Doors and Locks).................................. ២៨៣
៥.៧.៤. ការបន្លឺសំឡេងរោទិ៍ពេលមានអគ្គិភ័យ (Fire Alarm).......... ២៨៥
៥.៧.៥. ផ្ទាក់ដៃ (Grabrails)............................................................ ២៨៦
៥.៧.៦. ឧបករណ៍ផ្លុំសម្ងួតសក់ (Hair Dryers) ................................ ២៨៧
៥.៧.៧. ឧបករណ៍សម្ងួតដៃ (Hand-Drying Facilities)...................... ២៨៨
៥.៧.៨. ឧបករណ៍កម្តៅ (Heating) ................................................... ២៨៩

៥.៧.៩. អំពូលភ្លើង (Lighting) ........................................................ ២៨៩
៥.៧.១០. សោសុវត្ថិភាព (Lockers)................................................ ២៩០
៥.៧.១១. កញ្ចក់ឆ្លុះមុខ (Mirrors) ............................................២៩១
៥.៧.១២. ធ្នើរ (Shelves)................................................................ ២៩២
៥.៧.១៣. ស្លាកសញ្ញា (Signage) .................................................. ២៩២
៥.៧.១៤. កន្លែងដាក់សាប៊ូ (Soap Dispensers) ......................... ២៩៣
៥.៧.១៥. ផ្ទៃបាត (Surfaces) ........................................................ ២៩៤
៥.៧.១៦. កន្លែងព្យួរក្រដាសអនាម័យ (Toilet Paper Dispensers) .. ២៩៤
៥.៧.១៧. ម៉ាស៊ីនលក់ទំនិញ (Vending Machines)......................... ២៩៥
៥.៧.១៨. ធុងសំរាម (Waste Disposal) ........................................... ២៩៦
៥.៧.១៩. ប្រព័ន្ធទឹក (Water Supply) ............................................. ២៩៧
៥.៧.២០. អណ្តូងស្នប់ (Hand Pump)............................................ ២៩៧
៥.៧.២១. អណ្តូងយោង (Tube Wells)........................................... ៣០១
៥.៧.២២. កំពង់ទឹកនៅទន្លេ បឹងនិងស្រះ (Ports)........................... ៣០៤

# ផ្នែកទី១ អំពីផ្លូវនិងច្រកចេញចូល (PATHWAY AND ENTRANCES)





## ១.១. អំពីផ្លូវសម្រាប់ទាំងអស់គ្នា (Access Routes)

ផ្លូវសម្រាប់ទាំងអស់គ្នាគឺសំដៅទៅលើផ្លូវដែលជនមានពិការភាពគ្រប់ប្រភេទអាចប្រើប្រាស់បាន ទាំងថ្មើរជើងនិងរទេះរួមទាំងតួផ្លូវ ទ្រូងផ្លូវ ចិញ្ចើមផ្លូវ ផ្លូវឆ្លងកាត់និងខឿនផ្លូវ។



*រូបភាព ១.១.១. អ្នកប្រើប្រាស់រទេះកំពុងតែប្រើប្រាស់ផ្លូវដែលមានទីធ្លាអាចចៀសគ្នានិងបត់បែនបាន*



*រូបភាព ១.១.២. អ្នកប្រើប្រាស់រទេះកំពុងតែប្រើប្រាស់ផ្លូវធម្មតា*



*រូបភាព ១.១.៣. អ្នកប្រើប្រាស់រទេះកំពុងតែប្រើប្រាស់ផ្លូវចន្លោះអគារ*

❖ ស្តង់ដានិងការណែនាំអំពីផ្លូវសម្រាប់ទាំងអស់គ្នា

- ធានាថាផ្លូវសម្រាប់ទាំងអស់គ្នាមានទទឹងធំល្មមទៅតាមការរំពឹងទុកនៃចំនួនមនុស្សឆ្លងកាត់

- ត្រូវធានាថាទទឹងផ្លូវមានទំហំ២០០០ម.មនិងគ្មានឧបសគ្គបាំងផ្លូវនៅគ្រប់កន្លែង
- ត្រូវធ្វើកន្លែងចៀសគ្នាក្នុងករណីដែលទទឹងផ្លូវតិចជាង២០០០ម.ម
- ត្រូវរៀបចំឱ្យមានកន្លែងសម្រាកឱ្យបានចន្លោះពីមួយទៅមួយទៀងទាត់បើផ្លូវនោះវែង
- ធានាថាទទឹងផ្លូវមិនតិចជាង១២០០ម.មសម្រាប់ផ្នែកដែលរួមតូចខ្លីៗ
- ធ្វើឱ្យទូលាយផ្លូវដើរមុខហាងនិងនៅត្រង់ចំណតរថយន្តក្រុង
- តាមផ្លូវត្រូវរៀបបាតឱ្យរឹងមាំនិងរាបស្មើដែលមានភាពទេរខ្ពស់បំផុត១/៥០
- ជៀសវាងចន្លោះប្រហោងនិងការរៀចទ្រេតរវាងដុំឥដ្ឋធំជាង៥ម.ម
- រក្សាឥដ្ឋឱ្យស្មើនៅតាមផ្ទៃឬចន្លោះពីមួយទៅមួយដូចជា ជិតបំពង់បង្ហូរទឹកមិនត្រូវលើសពី១០ម.មនិងស៊ីគ្នាទៅនឹងបន្ទាត់ទឹកហូរ
- រៀបចំបង្ការគ្រោះថ្នាក់នៅតាមកន្លែងផ្លាស់ប្តូរកម្ពស់ដោយមានជម្រាលនិងធ្នាក់ដៃសមរម្យ
- ទទឹងផ្លូវសម្រាប់ទាំងអស់គ្នាត្រូវមានទំហំសមស្របដើម្បីឱ្យអ្នកប្រើប្រាស់អាចចល័តបានគ្រប់ទិសនិងចៀសគ្នាដោយស្រួល
- ទទឹងផ្លូវត្រូវមានទំហំ២០០០ម.មយ៉ាងតិចអាចឱ្យរទេះចៀសគ្នាបានស្រួលទំហំនេះអាចត្រូវបង្កើន ក្នុងករណីដែលផ្លូវធ្វើនៅក្នុងតំបន់ដែលមានអ្នកប្រើប្រាស់ច្រើន
- ក្នុងករណីចង្អៀតខ្លាំងដែលផ្លូវមានទំហំតូចជាង២០០០ម.មត្រូវរៀបចំឱ្យមានកន្លែងចៀសគ្នាដែល មានផ្ទៃក្រឡា២០០០ម.ម x ២០០០ម.ម ក្នុងចម្ងាយរៀងរាល់២៥ម៉ែត្រម្តង

- ក្នុងករណីផ្លូវមានប្រវែងឆ្ងាយកន្លែងចៀសគ្នាអាចធ្វើរៀងរាល់៣០ម៉ែត្រម្តង
- ក្នុងករណីផ្លូវមានឧបសគ្គដោយដើមឈើ បង្គោលភ្លើង ជញ្ជាំងគេអាចបន្ថយមកនៅត្រឹម១២០០ម.មនិងត្រូវអនុញ្ញាតតែរទេះមួយឆ្លងកាត់

*រូបភាព ១.១.៤. ការរៀបចំផ្លូវនៅទីប្រជុំជនសម្រាប់ថ្មើរជើង*




- ចិញ្ចើមផ្លូវត្រូវមានទទឹងតិចបំផុត២០០០ម.ម
- ចំណតរថយន្តនៅមុខហាងត្រូវមានចិញ្ចើមផ្លូវ៣០០០ម.មទៅ៤៥០០ម.ម

## ១.១.១. ច្រកផ្លូវដែលភ្ជាប់ពីផ្លូវមួយទៅមួយទៀត

(Pathway, Connection Paths)

ច្រកផ្លូវគឺជាផ្លូវនៅខាងក្រៅចិញ្ចើមផ្លូវ ជាកន្លែងសម្រាប់ថ្មើរជើងដើរដែលនៅជិតផ្លូវថ្នល់ ផ្លូវដើរខាងក្នុងភ្ជាប់ជាមួយអគារផ្សេងៗឬលំនៅឋាន។ល។

*រូបភាព ១.១.១.១. កន្លែងភ្ជាប់រវាងខឿននៃផ្លូវថ្មើរជើងនិងផ្លូវយានជំនិះត្រង់កន្លែងឆ្លងកាត់*



❖ ស្តង់ដានិងការណែនាំអំពីច្រកផ្លូវដែលភ្ជាប់ផ្លូវមួយទៅផ្លូវមួយទៀត

(Standards and Guidelines for Pathway, Connecting Paths)

- ទទឹងអប្បបរមាសម្រាប់ច្រកផ្លូវគឺ១៥០០ម.មទៅ១៨០០ម.ម



- ទទឹងអប្បបរមាសម្រាប់ច្រកផ្លូវនៅក្នុងតំបន់ដែលមានមនុស្សច្រើនឆ្លងកាត់ដូចជា ផ្លូវទៅកាន់មន្ទីរពេទ្យ ស្ថានីយរថភ្លើង សាលារៀន ទីទួលសុវត្ថិភាពពីទឹកជំនន់គឺ២៥០០ម.ម
- ទទឹងអប្បបរមារបស់កូនផ្លូវភ្ជាប់ទៅកាន់ច្រកផ្លូវតភ្ជាប់ឬច្រកដើរខាងក្នុងគឺ១២០០ម.ម
- ពុំមានឧបសគ្គអ្វីបាំងដើម្បីឱ្យអ្នកប្រើប្រាស់ទាំងអស់មានភាពងាយស្រួល
- ទាំងផ្លូវនិងជម្រាលសម្រាប់ដើរត្រូវតែរាបស្មើតែមិនរអិលទោះបីសើមឬភ្លៀងក៏ដោយ ប្រសិនបើត្រូវឱ្យមានភាពគ្រើមមិនត្រូវលើសពី២០ម.ម ព្រោះអាចបណ្ដាលឱ្យជាប់កង់រទេះ
- មាត់លូដែលចំហខាងលើត្រូវមានបន្ទះបេតុង/ថ្ម ដើម្បីភ្ជាប់កុំឱ្យមានប្រហោងដោយត្រូវមានទទឹង ១២០០ម.ម នៅក្នុងចន្លោះមួយរៀងរាល់ចម្ងាយ៣០ម៉ែត្រម្ដងសម្រាប់អ្នកប្រើប្រាស់រទេះរុញសម្រាក
- ត្រូវក្រាលឥដ្ឋនៅលើផ្លូវចូលទៅកាន់បង្គន់ កន្លែងងូតទឹក ជម្រកសុវត្ថិភាពលំនៅឋាន
- កន្លែងប្រើប្រាស់ទឹក អគារសាធារណៈ ហាងលក់ដូរ ជម្រាលតភ្ជាប់នៅខាងលើនិងខាងក្រោម ជណ្ដើរ ដើម្បីបង្ការកុំឱ្យមានភក់/ខ្សាច់ធ្លាក់ចុះដោយសារតែច្រោះដីជាពិសេសនៅពេលមានភ្លៀងធ្លាក់
- ទាំងនៅតាមផ្លូវរាបស្មើឬផ្លូវមានចំណោតត្រូវរៀបឱ្យមានគំនូសឆ្នូតៗក្នុងទម្រង់ធម្មតា
- ចំណោតអតិបរមាសម្រាប់ច្រាំងច្រកផ្លូវគឺ១/៥ (២%)

## ១.១.២. លូបង្ហូរទឹកនិងបន្ទះដែក (Drainage and Gratings)





❖ ស្តង់ដានិងការណែនាំអំពីលូបង្ហូរទឹក

- ដើម្បីបង្ការកុំឱ្យទឹកដក់នាំឱ្យខូចផ្លូវឬបញ្ហាផ្សេងៗទៀតត្រូវរៀបចំឱ្យមានលូនៅតាមផ្លូវ
- មាត់លូខាងលើមានទទឹងទំហំ១២០០ម.ម ដែលជាបន្ទះថ្មឬបេតុង ត្រូវភ្ជាប់កុំឱ្យមានប្រហោង
- ត្រូវរៀបចំមាត់លូបង្ហូរទឹកអាស្រ័យទៅតាមស្ថានភាពផ្លូវឬរៀងរាល់៣០ម៉ែត្រម្តង
- ប្រើលូឬបំពង់សម្រាប់បង្ហូរទឹក ដើម្បីបង្ការកុំឱ្យទឹកដក់នៅតាមបណ្តោយផ្លូវឬជម្រាលដែលមានប្រព័ន្ធ បង្ហូរទឹកនៅខាងក្រោម
- សន្លឹកសំណាញ់ដែលត្រូវយកមកផ្សារធ្វើគម្របលូត្រូវមានទំហំ១០ម.ម x ២០ម.ម
- ប្រហោងចន្លោះពីបន្ទះសំណាញ់ដែកមួយទៅមួយត្រូវតូចជាង១២ម.ម ជៀសវាងចូលកង់រទេះជនមានពិការភាព
- បន្ទះសំណាញ់ដែកនេះអាចរចនាជារាងទ្រវែង ជ្រុងឬមូលអាស្រ័យទៅតាមទំហំមាត់លូ
- បន្ទះសំណាញ់ដែកត្រូវចាប់ឱ្យជាប់ទៅនឹងបន្ទះស៊ុមដែក



- ត្រូវធានាថាបន្ទះសំណាញ់ដែកដែលដាក់នៅតាមមាត់លូនេះមិនត្រូវបង្កការលំបាកដល់ការធ្វើដំណើរគ្រប់ប្រភេទ
- បន្ទះសំណាញ់ដែក អាចដកចេញបាននៅពេលត្រូវការលាងសំអាត/ជួសជុលលូ
- ធានាថាលូបង្ហូរទឹកអាចឱ្យទឹកហូរចូលបានដោយគ្មានឧបសគ្គ
- លូបង្ហូរទឹកនិងបន្ទះដែកប្រើសម្រាប់បង្ហូរទឹក ដើម្បីបង្ការកុំឱ្យទឹកហូរដក់ឬហូរទៅចុងជម្រាលនិងចំណោតនៅផ្នែកខាងលើជម្រាលនិងចំណោតឬនៅតាមគ្រលុកនៃច្រកផ្លូវដែលមិនរាបស្មើ





### ១.១.៣. បង្កាន់ដៃការពារ (Guardrails)

បង្កាន់ដៃការពារសំដៅដល់ឧបករណ៍ចាប់ភ្ជាប់នៅតាមបណ្តោយផ្លូវ ជណ្តើរស្ពាន ជម្រាលនិងទីតាំងផ្សេងៗទៀត ដើម្បីការពារកុំឱ្យអ្នកប្រើប្រាស់គ្រោះថ្នាក់។





❖ ស្តង់ដានិងការណែនាំអំពីបង្កាន់ដៃការពារ

- បង្កាន់ដៃការពារត្រូវមានកម្ពស់១២០០ម.មនិងមានពណ៌ដិតជួយដល់ជនមានពិការភាពខ្សោយគំហើញ
- ទំហំដែកឬវត្ថុយកទៅធ្វើបង្កាន់ដៃការពារត្រូវមានទំហំ៤០ម.ម ទៅ ៥០ម.ម រាងមូល
- បង្កាន់ដៃការពារមិនត្រឹមតែប្រើប្រាស់សម្រាប់ដើរប៉ុណ្ណោះទេ ប៉ុន្តែអាចប្រើតោងងើបឬទប់ខ្លួននៅពេល ចុះឬឡើងជម្រាល ចំណោតឬជណ្តើរ

### ១.២. អំពីការចុះឡើង (Changes in Level)

ការចុះឡើងសំដៅដល់ផ្លូវឬទីតាំងដែលត្រូវធ្វើដំណើរមានការប្រែប្រួលកម្ពស់ទៅតាមស្ថានភាពទីតាំងនិងរចនាបទនៃការសាងសង់ដែលពេលខ្លះមានផ្លូវជម្រាល ចំណោតនិងជណ្តើរនៅជាមួយគ្នា។



*រូបភាព ១.២.១. ឧទាហរណ៍អំពីការលំបាកនិងគ្រោះថ្នាក់ដែលអាចជួបប្រទះនៅតាមអគារដែលមិនបានរៀបចំសម្រាប់ជនមានពិការភាព*

អគារដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពគួរតែមានជម្រាលអមជាមួយជណ្តើរ។

*រូបភាព ១.២.២. គំរូអំពីការកំណត់រូបស្លាកសញ្ញាកន្លែងសម្រាប់អ្នកមានកម្សោយផ្នែកចលនា*




❖ ស្តង់ដានិងការណែនាំអំពីការចុះឡើង

*រូបភាព ១.២.៣. គំរូអំពីជម្រាលនៅខាងក្រៅដែលមានជណ្ដើរអម*



- ជម្រាលដែលមានជើងទេរខ្នាត១/២០ ដែលមានទទឹងទំហំ១២០០ម.ម និងកន្លែងបង្វិលរទេះចុះ ឡើងប្រវែងតិចជាង៩ម៉ែត្រ
- កន្លែងសម្រាកត្រូវមានទទឹង១៣០០ម.ម
- ត្រូវបំពាក់បង្កាន់ដៃខាងលើជម្រាលទាំងសងខាងកម្ពស់៩០០ម.មទៅ ១០០០ម.ម នៅតាមបណ្តោយ ជម្រាលទាំងអស់និងកម្ពស់៩០០ម.ម ទៅ១១០០ម.ម នៅគ្រប់កន្លែងសម្រាក
- ត្រូវបំពាក់បង្កាន់ដៃខាងក្រោមដែលមានកម្ពស់៦០០ម.មទៅ៧៥០ម.ម នៅតាមបណ្តោយជម្រាល ទាំងអស់សម្រាប់មនុស្សទាបនិងកុមារ
- បង្កាន់ដៃត្រូវចាប់ជាប់ជញ្ជាំងដោយទុកចន្លោះ១៥០ម.មពីជញ្ជាំង
- ត្រូវរៀបចំទីធ្លាទំហំ១៨០០ម.ម x ១៨០០ម.ម នៅរាល់កន្លែងចាប់ផ្តើម និងចុងបញ្ចប់នៃជម្រាល
- គួរមានជណ្តើរស្របគ្នាជាមួយជម្រាលសម្រាប់ជាជម្រើសសម្រាប់អ្នក ប្រើប្រាស់
- ត្រូវរៀបចំខឿនសងខាងជម្រាលកម្ពស់៧៥ម.ម
- ផ្ទៃជម្រាលមិនត្រូវឱ្យរអិលទេព្រោះអាចបណ្តាលឱ្យគ្រោះថ្នាក់បាន
- ធានាថាផ្លូវរវាងច្រកចូលបរិវេណនិងច្រកចូលអគារឬរវាងចំណតក្នុង បរិវេណនិងក្នុងអគារគឺធ្វើ សម្រាប់មនុស្សគ្រប់រូបប្រើប្រាស់បាន
- ត្រូវគិតឱ្យបានគ្រប់ជ្រុងជ្រោយនៅពេលឌីហ្សាញសំណង់គ្រាដំបូង
- ពេលឌីហ្សាញផ្លូវគឺធ្វើយ៉ាងណាឱ្យងាយយល់ ងាយប្រើនិងមានជម្រើស ប្រើប្រាស់
- ធានាថាជម្រាលនិងជណ្តើរនៅតាមផ្លូវ ត្រូវមានសញ្ញាប្រាប់និងអាចមើល ឃើញច្បាស់សម្រាប់មនុស្សគ្រប់ៗគ្នា

### ១.២.១. ជម្រាល (Ramps)និងចំណោត (Slopes)



| | | | | |
|---|---|---|---|---|
| ជម្រាលងាយស្រួលបំផុត | <៤%ឬ<១:២៥ ជម្រាលងាយស្រួល | <៥%ឬ<១:២០ ជម្រាលសមរម្យ | <៨%ឬ<១:១២ ជម្រាលពិបាក | <១២%ឬ<១:០៨ ជម្រាលគ្រោះថ្នាក់ |

#### ១.២.១.១. ជម្រាលនៅខាងក្រៅ (External Ramps)

ជម្រាលនៅខាងក្រៅសំដៅដល់ជម្រាលផ្លូវ ច្រកចេញចូល ច្រកចុះឡើងអគារ ខឿន( ចិញ្ចើមផ្លូវឬចំណត )និងទីធ្លាដែលមានភាពទេរប្រែប្រួលស្ថិតនៅខាងក្រៅអគារភាគច្រើនមានប្រវែងឆ្ងាយជាងជម្រាលនៅខាងក្នុង។ ជម្រាលនៅខាងក្រៅគឺជាផ្ទៃបាតដែលមានកម្ពស់ខ្ពស់ជាងគ្នាពីចំណុចមួយទៅចំណុចមួយ។






❖ ស្តង់ដានិងការណែនាំអំពីជម្រាលនៅខាងក្រៅ

*រូបភាព ១.២.១.១. គំរូអំពីខ្នាតជម្រាលខាងក្រៅ*




- ជម្រាលដែលមានភាពទេរអតិបរមា១/១២( សម្រាប់កម្ពស់១ឯកតាត្រូវមានកម្លាំងចំណោត១២ឯកតា )សម្រាប់ជម្រាលខ្លីៗ
- ជម្រាលដែលល្អបំផុត១/២០( សម្រាប់កម្ពស់១ឯកតាត្រូវមានកម្លាំងចំណោត២០ឯកតា )សម្រាប់ជម្រាលវែងៗ
- ក្នុងករណីជម្រាលមានកម្ពស់លើសពី២០០០ម.មត្រូវតែមានជណ្តើរឡើងជំនួស( ដូចជាជណ្តើរយោង ជណ្តើរប្រអប់ ប្រដាប់លើកដាក់ )
- ជម្រាលត្រូវមានទទឹងអប្បបរមា១២០០ម.ម( ដោយមិនគិតទំហំគែមជម្រាល )សម្រាប់ផ្លូវមិនមមាញឹក
- ជម្រាលត្រូវមានទទឹងអប្បបរមា២៥០០ម.ម( ដោយមិនគិតទំហំគែមជម្រាល )សម្រាប់ផ្លូវមមារញឹក ដូចជាច្រកចូលមន្ទីរពេទ្យ ស្ថានីយរថភ្លើង សាលារៀន ភោជនីយដ្ឋាន។ល។
- នៅរៀងរាល់កម្ពស់៧៥០ម.មពីចំណុចទាបដំបូងម្តង ដែលស្មើនឹងប្រវែងជម្រាល៩០០០ម.ម( ៧៥០ម.ម x ១២ឯកតា )ត្រូវធ្វើអោយមានផ្ទៃរាបស្មើប្រវែង១៥០០ម.មម្តង សម្រាប់ការសម្រាកឬនៅពេលមានការផ្លាស់ប្តូរទិសដៅម្តង ត្រូវធ្វើសម្រាប់ទាំងជម្រាលឡើងនិងជម្រាលចុះ
- គ្រប់ជម្រាលត្រូវមានគែមទប់កង់ឡើង៥០ម.ម នៅសងខាងជម្រាល

*រូបភាព ១.២.១.២. គំរូអំពីខ្នាតជម្រាលខាងក្រៅដែលមានជាប់ជញ្ជាំងអគារ និងជណ្តើរអម*




- គ្រប់ជម្រាលទាំងអស់ ទាំងផ្ទៃចោតនិងផ្ទៃរាបស្មើត្រូវធ្វើមិនឱ្យរអិលត្រូវរៀបចំគំនូសឆ្នូតៗដែលមានពណ៌លេចច្បាស់ទទឹងទំហំ៣០០ម.មនៅចំកណ្តាលនិងនៅតាមបណ្តោយជម្រាលសម្រាប់ផ្លូវឯកទិសនិងចំកណ្តាលស្របគ្នាសម្រាប់ផ្លូវទ្វេទិស



*រូបភាព ១.២.១.៣. គំរូអំពីជម្រាលដែលរៀបចំផ្ទៃបាតសម្រាប់ជនមានពិការភាពភ្នែកអាចប្រើបាន*

ត្រូវធ្វើគំនូសលើផ្ទៃបាតដែលផុស(មិនមែនឆ្នូត)អាចឱ្យគេដឹងបានសម្រាប់ប្រាប់ព័ត៌មានជាមុនអំពី ការចាប់ផ្តើម ការឡើង ការបត់បែនឬចុងបញ្ចប់នៃចំណោត ដែលមានទំហំ៣០០ម.ម ដាក់នៅពេលចំណុចខាងលើ

*រូបភាព ១.២.១.៤. គំរូជម្រាលក្នុងករណីមានទីធ្លាធំ*






*រូបភាព ១.២.១.៥. ការកែច្នៃជម្រាលក្នុងករណីទីធ្លាចង្អៀត*

### ១.២.១.២. ជម្រាលនៅខាងក្នុង (Internal Ramps)

ជម្រាលនៅខាងក្នុងសំដៅដល់ជម្រាលផ្លូវ ច្រកចេញចូល ច្រកចុះឡើងអគារឬបន្ទប់ ដែលមានភាពទេរប្រែប្រួលនិងនៅខាងក្នុងបរិវេណអគារភាគច្រើនមានប្រវែងជិតជាងជម្រាលនៅខាងក្រៅនិងចំណោត។

❖ ស្តង់ដានិងការណែនាំអំពីជម្រាលនៅខាងក្នុង

| ប្រភេទ | ភាពចោតឬទេរ | ប្រវែងជម្រាលអតិបរមា |
|---|---|---|
| ជម្រាលទេរល្អបំផុត | តិចជាង៥% | ១២ម៉ែត្រ |
| ជម្រាលទេរមធ្យម | ៥%-៨% | ៦ម៉ែត្រ |
| ជម្រាលចោត | ៨%-១២% | ៣ម៉ែត្រ |
| ជម្រាលចោតបំផុត | លើសពី១២% | 0.៥ម៉ែត្រ |

- ជម្រាលខាងក្នុងមានប្រយោជន៍សម្រាប់ការរុញរទេះទារកឬអីវ៉ាន់និងរទេះជនមានពិការភាព
- គេអាចប្រើជម្រាលខាងក្នុងជាផ្លូវសម្រាប់គេចពេលមានអាសន្ន
- ជម្រាលខាងក្នុងអាចជាកន្លែងតភ្ជាប់ពីអគារមួយទៅអគារមួយ ជាពិសេសអគារធំៗដូចជា សារមន្ទីរ កន្លែងមកដល់ក្នុងព្រលានយន្តហោះ ផ្សារទំនើប។ល។ ដោយសារតែទីធ្លានោះមិនត្រូវការជណ្តើរជើងឬជណ្តើរយោង
- ជម្រាលខាងក្នុងមិនត្រូវមានចំណោតចោតជាង១/២០ដែលមានកម្ពស់ខ្ពស់បំផុត៤៥០ម.មនិងប្រវែង មិនលើសពី៩ម៉ែត្រ

*រូបភាព ១.២.១.២.១. គំរូជម្រាលក្នុងករណីទីធ្លាតូច*



- គ្រប់ករណីទាំងអស់ជម្រាលខាងក្នុងមិនត្រូវតូចជាង១៥០០ម.ម ប្រសិនបើកន្លែងមមាញឹកត្រូវមានទទឹងតូចបំផុត១៨០០ម.ម
- កន្លែងសម្រាកនៃជម្រាលត្រូវមានទំហំ២៤៤០ម.ម x ២៤៤០ម.ម ដើម្បីអាចបត់រទេះបាន
- ដោយសារជម្រាលគឺជាផ្លូវចេញចូលនិងចុះឡើងចាំបាច់នៅគ្រប់ទីកន្លែង ដូច្នេះប្រសិនបើមានកន្លែង គ្រប់គ្រាន់គួរតែសាងសង់ជម្រាលជំនួសជណ្ដើរ
- ដើម្បីឱ្យជម្រាលអាចប្រើប្រាស់បានស្រួលគឺភាពចោតឬទេរមិនត្រូវលើសពី៨%ឡើយ
- ផ្ទៃរបស់ជម្រាលត្រូវមាំមិនរអិល
- ត្រូវមានសញ្ញាដូចជាសញ្ញាផុសៗឬលាបពណ៌នៅចុងខាងក្រោមនិងចុងខាងលើគ្រប់ជម្រាលសម្រាប់អ្នកខ្សោយគំហើញឬជនមានពិការភាពភ្នែក
- ប្រសិនបើជម្រាលវែងត្រូវធ្វើកន្លែងសម្រាករៀងរាល់៦ម៉ែត្រម្ដង
- អាចធ្វើកន្លែងសម្រាកនេះនៅត្រង់គ្រប់កន្លែងផ្លូវបត់ដែលមានបណ្ដោយតិចបំផុត១៥០០ម.ម
- គ្រប់ជម្រាលទាំងអស់ត្រូវមានទំនប់គែមផ្លូវដែលមានកម្ពស់៥០ម.មទៅ១០០ម.ម នៅខាងក្រោម បង្កាន់ដៃជៀសវាងកង់រទេះរអិលធ្លាក់ចេញពីជម្រាល



### ១.២.១.៣. ជម្រាលចល័ត (Mobile Ramps)

ជម្រាលចល័តសំដៅដល់ជម្រាលច្រកចេញចូល ច្រកចុះឡើង អគារឬបន្ទប់ដែលមានភាពទេរប្រែប្រួល ភាគច្រើនធ្វើពីលោហៈឬឈើព្រោះងាយចល័ត។ ជម្រាលនេះជាទូទៅគេធ្វើបណ្ដោះអាសន្នសម្រាប់ពិធីអ្វីមួយ តែមួយរយៈដែលទីកន្លែងនោះគ្មានជម្រាលស្រាប់ដូចជា វេទិកាតន្ត្រីខាងក្រៅ វេទិកាសិក្ខាសាលា វេទិកាអាពាហ៍ពិពាហ៍ ពិធីបុណ្យនិងពិធីផ្សេងៗ។ល។ ដែលសង់ជាខឿនខ្ពស់ពីដីទាំងនៅខាងក្នុងនិងខាងក្រៅ។




- ជម្រាលចល័តអាចធ្វើសម្រាប់ទីកន្លែងដែលមិនអាចធ្វើជម្រាលជាប់ជាប្រចាំបាន




• អាចរៀបចំជម្រាលចល័តពីលោហៈឬពីឈើទៅតាមតម្រូវការដោយគោរពតាមការណែនាំនិងស្តង់ដានៃជម្រាលផ្សេងៗទៀតដែរ

*រូបភាព ១.២.១.៣.១. គំរូអំពីជម្រាលចល័តដែលមានសសរសងខាង*




### ១.២.១.៤. ចំណោត (Slopes)







ចំណោតសំដៅដល់ផ្លូវឬជម្រាលដែលមានភាពទេរប្រែប្រួលភាគច្រើនមានទទឹងទំហំធំជាងជម្រាល( ខាងក្នុងនិងខាងក្រៅ ) ជាទូទៅចំណោតស្ថិតនៅតាមតំបន់ភ្នំ ជ្រលងភ្នំ តំបន់ឆ្នេរ តំបន់ខ្ពង់រាប ចំណោត ផ្លូវរវាងផ្លូវទាបនិងផ្លូវខ្ពស់ ចំណោតចុះឡើងស្ពាន ចំណោតចុះឡើងចំណតលើអគារនិងក្រោមដី។ល។ ទាំង នៅទីក្រុងនិងជនបទដែលអាចកើតឡើងដោយធម្មជាតិឬការកែច្នៃ។

• ចំណោតកាច់ចុះកាច់ឡើងវែងៗដែលមានភាពទេរ១:២០
• ទទឹងអប្បបរមារបស់ចំណោតគឺ១៨០០ម.ម សម្រាប់ផ្លូវឯកទិស ២៥០០ម.ម សម្រាប់ផ្លូវទ្វេទិស

- ត្រូវរៀបចំកន្លែងសម្រាករាបស្មើប្រវែង២៥០០ម.មនៅរៀងរាល់ពេលដែលមានការផ្លាស់ប្តូរទិសដៅឬរៀងរាល់៩០០០ម.មម្តង
- ត្រូវធានាថាចំណោតមានផ្ទៃមិនរអិលព្រោះអាចបណ្តាលឱ្យមានគ្រោះថ្នាក់
- គ្រប់ចំណោតត្រូវមានគែមទប់កង់កម្ពស់៥០ម.ម នៅសងខាងចំណោត
- គែមចំណោតត្រូវស្មើនឹងផ្ទៃដីខាងលើ ដើម្បីកុំឱ្យមានគ្រោះថ្នាក់ដោយសារជំពប់
- ការក្រាលឥដ្ឋនៅតាមគែមចំណោតជួយបង្ការការច្រោះដីនិងធ្វើឱ្យគែមមានកម្ពស់ស្មើគ្នា
- ក្នុងករណីផ្លូវចុះឡើងចំណោតត្រូវតែមានទំហំ១/៣៣និង១/២៥ ប្រសិនបើផ្លូវឆ្ងាយ
- សម្រាប់ផ្លូវដែលមានភាពទេរ១/២៥ គួរមានចម្ងាយ១៩មនិងផ្លូវដែលមានភាពទេរ១/៣៣ គួរមាន ចម្ងាយ២៥ម៉ែត្រទើបមានការផ្លាស់ប្តូរកម្ពស់ម្តង
- នៅពេលដែលធ្វើចំណោត គួរតែអមដោយជណ្តើរដែលមានបង្កាន់ដៃ



## ១.២.២. បង្កាន់ដៃជម្រាលនិងចំណោត (Handrails for Ramps and Slopes)

 

❖ ស្តង់ដានិងការណែនាំអំពីបង្កាន់ដៃ

- ត្រូវមានបង្កាន់ដៃទាំងសងខាងបន្តជាប់រហូត ហើយទាំងកន្លែងចុះឡើង និងកន្លែងឈប់សម្រាកក៏ត្រូវ មានបង្កាន់ដៃដែរ
- ត្រូវបំពាក់បង្កាន់ដៃសងខាងទោះបីម្ខាងទៀតជាប់ជញ្ជាំងក៏ដោយគ្រប់ជម្រាលនិងចំណោតទាំងអស់
- ត្រូវមានបង្កាន់ដៃ២តង់គ្រប់ជម្រាលនិងចំណោតទាំងអស់ដែលមានប្រវែងចាប់ពី៤០០ម.មឡើងទៅ
- បង្កាន់ដៃថ្នាក់ខាងលើគួរមានកម្ពស់៩០០ម.មទៅ១១០០ម.ម ពីបាតជម្រាល
- បង្កាន់ដៃថ្នាក់ខាងក្រោមត្រូវមានកម្ពស់៦០០ម.មទៅ៧៥០ម.ម ពីផ្ទៃបាតជម្រាល
- បង្កាន់ដៃគួរមានរាងមូលងាយស្រួលចាប់កាន់ដែលមានអង្កត់ផ្ចិតពី ៤០ម.មទៅ៥០ម.ម
- បង្កាន់ដៃថ្នាក់ខាងក្រោមត្រូវមានអង្កត់ផ្ចិតប្រហែល២៥ម.មទៅ៣២ម.ម ដែលធ្វើឱ្យកុមារងាយស្រួល ចាប់កាន់បាន
- ចំពោះបង្កាន់ដៃទាំងសងខាងគួរចាប់នៅចម្ងាយពីជញ្ជាំងពីចន្លោះ៥០ម.ម ទៅ៧៥ម.មតាមបណ្តោយបង្កាន់ដៃទាំងអស់

- ឧបករណ៍ទ្របង្កាន់ដៃបន្ថែមគួរដាក់នៅកណ្តាលផ្នែកខាងក្រោម ដើម្បីឱ្យគេអាចអូសដៃកាន់ឧបករណ៍ នោះតាមបណ្តោយបង្កាន់ដៃដោយគ្មានឧបសគ្គ ប្រសិនបើតម្រូវឱ្យអ្នកកាន់ដកដៃចេញបន្តិចដោយសារតែមានអ្វីទើសនោះគេមានអារម្មណ៍ថាគ្មានសុវត្ថិភាព
- ចុងសងខាងរបស់បង្កាន់ដៃធ្វើជារាងមូលនិងធ្វើឱ្យគ្រើម ហើយបន្តប្រវែង ៣០០ម.ម ផុតពីផ្នែកខាងលើនិងខាងក្រោមជម្រាល
- នៅចន្លោះបង្កាន់ដៃបញ្ឈរផ្នែកខាងក្រោមនិងឧបករណ៍ទ្របង្កាន់ដៃបន្ថែមគួរមានទំហំ៥០ម.ម នៅចុង បញ្ចប់នៃបង្កាន់ដៃត្រូវមានសញ្ញាប្រាប់ពេលបានទៅដល់នៅផ្នែកខាងលើនិងខាងក្រោមនៃបង្កាន់ដៃជម្រាល ដែលត្រូវធ្វើនៅលើបង្កាន់ដៃដែលបត់ទៅជញ្ជាំងឬបត់ចុះក្រោមទំហំ១៥០ម.ម

*រូបភាព១.២.២.១. ខ្នាតបង្កាន់ដៃនៃជម្រាលខាងក្រៅនិងចំណោត*



*រូបភាព១.២.២.២. ខ្នាតបង្កាន់ដៃនៃជម្រាលខាងក្នុង*




**សម្គាល់៖** ខ្នាតទាំងអស់គិតជា មម

- ចន្លោះពីបង្កាន់ដៃទៅជញ្ជាំងទំហំ៥០ម.ម ប្រសិនបើជញ្ជាំងរលោងនិង ៧៥ម.ម ប្រសិនបើជញ្ជាំងគ្រើម
- បង្កាន់ដៃ គួរតែមានពណ៌ផ្ទុយពីផ្ទៃបាតនិងត្រូវមើលឃើញច្បាស់ការជ្រើសរើសឧបករណ៍មកធ្វើជា បង្កាន់ដៃមានសារៈសំខាន់ណាស់ព្រោះអាចមានផលប៉ះពាល់ជាវិជ្ជមាននិងអវិជ្ជមានដល់អ្នកប្រើប្រាស់ទៅតាមប្រភេទពិការផ្សេងៗ
- បើអាចជៀសវាងបានមិនគួរយកលោហៈធ្វើជាបង្កាន់ដៃទេ ព្រោះវាប្រែប្រួលតាមសីតុណ្ហភាពលឿន ពេកទៅតាមរដូវកាល (ក្ដៅពេកឬត្រជាក់ពេក) ដែលជនមានពិការភាពខ្លះអាចមានអារម្មណ៍ថាឈឺចាប់

## ១.២.៣. ផ្ទៃជម្រាលនិងគែមសម្រាប់ការពារ

(Ramp Surface and Edge Protection)

❖ ស្តង់ដានិងការណែនាំអំពីផ្ទៃជម្រាលនិងគែមសម្រាប់ការពារ




- ផ្ទៃជម្រាលគឺជាតួបាតជម្រាលខាងក្រោមដែលអ្នកប្រើប្រាស់ដើរឬបង្វិលរទេះពីលើនិងគែមការពារគឺ ជាស៊ុមព័ទ្ធសងខាងនិងមានកម្ពស់ខ្ពស់ជាងបាតជម្រាលដើម្បីការពារកុំឱ្យកង់រទេះធ្លាក់ចុះ
- ផ្ទៃបាតនៃជម្រាលមិនត្រូវឱ្យរអិលទាំងក្នុងស្ថានភាពសើមនិងស្ងួត
- ភាពទេរនៃជម្រាលត្រូវលាបពណ៌ឱ្យច្បាស់នៅចំកណ្តាលដើម្បីជំនួយដល់ជនមានពិការភាពខ្សោយគំហើញ
- ត្រូវបំពាក់ប្រព័ន្ធភ្លើងបំភ្លឺសម្រាប់ប្រើប្រាស់នៅពេលងងឹតឬយប់
- គែមការពារត្រូវមានកម្ពស់៥០ម.មទៅ១០០ម.ម
- គែមជម្រាលខាងក្រោមត្រូវស្មើនឹងផ្ទៃដីដើម្បីកុំឱ្យមានការជំពប់

### ១.២.៤. ជណ្ដើរនៅខាងក្រៅ (External Stairs)

ជណ្ដើរនៅខាងក្រៅគឺជាឧបករណ៍មានកាំជាជាន់ៗឬជាថ្នាក់ៗភ្ជាប់ទៅនឹងមេទាំងសងខាងសម្រាប់ដើរជាន់ជាមធ្យោបាយចុះឡើងដោយជើងផ្ទាល់វាអាចធ្វើពីថ្ម ឈើ លោហៈ ប្លាស្ទិក។ល។



*រូបភាព ១.២.៤.១. គំរូអំពីឥដ្ឋឆ្នូតៗ រំលេចពណ៌ចុងខាងលើជណ្ដើរនិងបង្កាន់ដៃពីរជាន់ដែលមានពណ៌ផ្ទុយពីផ្ទៃ*



*រូបភាព ១.២.៤.២. គំរូអំពីជណ្ដើរខាងក្រៅ ផ្ទៃឆ្នូតៗ ចុងខាងលើនិងចុងខាងក្រោមនៃជណ្ដើរដែលមាន ពណ៌ឆ្នូតៗទាំងនៅតាមបង្កាន់ដៃនិងកន្លែងសម្រាក*



*រូបភាព ១.២.៤.៣. គំរូអំពីការរៀបចំឥដ្ឋឆ្នូតៗសម្រាប់ជនមានពិការភាពភ្នែកនៅចំណុចចាប់ផ្ដើមនិងចុងបញ្ចប់ នៃជណ្ដើរ នៅខាងក្រៅ*



*រូបភាព ១.២.៤.៤. គំរូអំពីកាំជណ្ដើរនីមួយៗនៅខាងក្រៅដែលមានបង្កាន់ដៃជាប់រហូត*

❖ ស្តង់ដានិងការណែនាំអំពីជណ្តើរនៅខាងក្រៅ

*រូបភាព ១.២.៤.៥. ខ្នាតនៃជណ្តើរខាងក្រៅ*




*រូបភាព ១.២.៤.៦. គំរូខ្នាតផ្ទៃដែលប្រាប់អំពីឧបសគ្គនៅខាងមុខ*



- ផ្ទៃដែលប្រាប់អំពីឧបសគ្គនៅខាងមុខត្រូវមានពណ៌ផ្ទុយអំពីផ្ទៃរាបធម្មតា ប៉ុន្តែមិនត្រូវមានពណ៌ក្រហមទេ
- ជណ្តើរនៅខាងក្រៅគេអាចធ្វើភ្ជាប់នៅមួយកន្លែងឬចល័តទៅតាមតម្រូវការនៃការប្រើប្រាស់ វាអាចធ្វើ អំពីឈើ ថ្ម ដែកឬឥដ្ឋ។ល។
- ត្រូវរៀបចំឱ្យមានជណ្តើរស្របគ្នានិងជម្រាល
- ធានាថាខ្នាតទំហំនិងរាងជណ្តើរពីមួយកាំទៅមួយកាំដូចៗគ្នាដូចក្នុងរូបខាងក្រោមនេះ

*រូបភាព ១.២.៤.៧. ការមើលឃើញច្រមុះជណ្តើរ*



- ត្រូវលាបពណ៌នៅគ្រប់គែមនៃកាំជណ្ដើរនីមួយៗ
- ត្រូវរៀបឱ្យមានកាំដូចៗគ្នានិងស្មើគ្នាពីកន្លែងសម្រាកមួយទៅកន្លែងសម្រាកមួយទៀត
- ជៀសវាងមានជណ្ដើរតែមួយកន្លែងនៅតាមផ្លូវ
- ត្រូវរៀបចំឱ្យមានកន្លែងទំនេរទូលាយនៅចំណុចដំបូងនិងចុងបញ្ចប់នៃជណ្ដើរដែលអាចមានទទឹងស្មើនិងមួយកាំជណ្ដើរ
- កន្លែងទំនេរទូលាយនៅចំណុចដំបូងនិងចុងបញ្ចប់នៃជណ្ដើរត្រូវមានសញ្ញាប្រាប់ដំណឹងដូចក្នុងរូបខាងក្រោមនេះ

*រូបភាព ១.២.៤.៨. ជណ្ដើរខាងក្រៅដែលមានផ្ទៃប្រាប់ដំណឹងនៅចំណុចចាប់ផ្ដើមនិងចុងបញ្ចប់*




- ត្រូវបំពាក់បង្កាន់ដៃនៅគ្រប់ជណ្ដើររួមទាំងកន្លែងសម្រាកផងដែរ
- ត្រូវបំពាក់បង្កាន់ដៃនៅកណ្ដាលក្នុងករណីដែលជណ្ដើរមានទទឹងវែងជាង ២០០០ម.ម
- ត្រូវការពារផ្ទៃក្រោមជណ្ដើរដែលមានទំហំតូចជាង២១០០ម.ម
- ពន្លឺនៅតាមផ្ទៃកាំជណ្ដើរនិងកន្លែងសម្រាកគឺ១៥០លុច ជណ្ដើរនៅខាងក្រៅគួរតែត្រូវធ្វើអមជាមួយ ជម្រាលដើម្បីជាជម្រើសសម្រាប់ការប្រើប្រាស់

*រូបភាព ១.២.៤.៩. ជណ្តើរខាងក្រៅ*




- ទំហំនៃកាំជណ្តើរគួរតែដូចៗគ្នាតាំងពីចាប់ផ្តើមរហូតដល់បញ្ចប់
- កាំជណ្តើរដែលមានកម្ពស់ស្មើគ្នា/ដូចគ្នា( កម្ពស់កាំជណ្តើរ )គឺ១៥០ម.ម និងជម្រៅចូលទៅក្នុង( ជម្រៅកាំជណ្តើរ )គឺ៣០០ម.ម
- ពុំមានប្រឡោះចំហាចន្លោះកាំជណ្តើរ( ដូចជាកាំជណ្តើរឈើរបស់ផ្ទះឈើនៅជនបទ )
- ត្រូវធ្វើឱ្យមានផ្ទុតទទឹង៥០ម.ម ស្របតាមបណ្តោយកាំជណ្តើរនៅគែមខាងមុខនិងមានពណ៌លេចច្បាស់នៅគ្រប់គែមនៃកាំជណ្តើរនីមួយៗ

- ទទឹងកាំជណ្តើរនីមួយៗត្រូវមានប្រវែងខ្លីបំផុត១២០០ម.មនិងមិនត្រូវដាក់អ្វីបាំង
- ត្រូវរៀបចំឱ្យមានកន្លែងសម្រាកដែលមានទំហំតូចបំផុត១២០០ម.ម x ១២០០ម.ម រៀងរាល់១០កាំជណ្តើរ ម្តងនិងអាចនៅគ្រប់កន្លែងដែលមានការផ្លាស់ប្តូរទិសដៅ
- នៅចំណុចចាប់ផ្តើមនិងចុងបញ្ចប់នៃកាំជណ្តើរត្រូវរៀបចំឱ្យមានឆ្នូតប្រាប់ជាមុនដែលផុសចេញអាចឱ្យគេដឹងបានទំហំ៣០០ម.ម x ៣០០ម.ម ត្រូវដាក់មុននិងក្រោយគ្រប់ជណ្តើរទាំងអស់
- កាំជណ្តើរនីមួយៗត្រូវធ្វើឱ្យត្រង់ ជៀសវាងកុំឱ្យទេរធ្លាក់ចុះមកខាងមុខ
- ជ្រុងខាងចុងនៃកាំជណ្តើរនីមួយៗត្រូវធ្វើកុំឱ្យមូលពេកព្រោះបង្ការខ្លាចរអិលពេលចុះជណ្តើរ
- គ្រប់ជណ្តើរទាំងអស់ដែលមានកម្ពស់ចាប់ពី៤៥០ម.ម ស្មើនឹង៣កាំឡើងទៅ ត្រូវបំពាក់បង្កាន់ដៃកម្ពស់ ២តង់ខាងលើ៨៥០ម.មទៅ៩០០ម.ម និងខាងក្រោម៦០០ម.មទៅ៧០០ម.ម( សម្រាប់កុមារ ) ចាប់គិតពីដីទៅផ្ទៃខាងលើនៃបង្កាន់ដៃ។

### ១.២.៥. ជណ្តើរនៅខាងក្នុង (Internal Stairs)

ជណ្តើរនៅខាងក្នុងគឺជាឧបករណ៍មានកាំជាជាន់ៗឬជាថ្នាក់ៗភ្ជាប់ទៅនឹងមេទាំងសងខាងសម្រាប់ ដើរជាន់ជាមធ្យោបាយចុះឡើងវាអាចធ្វើពីថ្ម ឈើ លោហៈឬប្លាស្ទិក។ល។



*រូបភាព ១.២.៥.១. គំរូអំពីផ្ទៃពកប្រាប់ដំណឹងនៅចំណុចចាប់ផ្តើមនិងចុងបញ្ចប់*

❖ ស្តង់ដានិងការណែនាំអំពីជណ្តើរខាងក្នុង

- ត្រូវរៀបចំកន្លែងសម្រាកមិនលើសពីជណ្តើរ១០កាំម្តង
- នៅចំណុចចាប់ផ្តើមនិងដល់ទីនៃជណ្តើរត្រូវមានកន្លែងសម្រាកទូលាយតូចបំផុត១២០០ម.មនិងគ្មាន ការរំខានដោយការបើកឬបិទទ្វារ

*រូបភាព ១.២.៥.២ ជណ្តើរខាងក្នុង*



### ១.២.៦. ជណ្ដើរយោង (Passenger Lift)

ជណ្ដើរយោងសំដៅដល់ឧបករណ៍ដែលប្រើប្រាស់ប្រព័ន្ធអគ្គិសនីមានរាងជាប្រអប់បួនជ្រុងសម្រាប់ជាមធ្យោបាយឡើងនិងចុះរវាងទីទាបនិងទីខ្ពស់វាគឺជាមធ្យោបាយដ៏ប្រសើរសម្រាប់ចុះឡើងពីជាន់ក្រោមទៅ លើនិងពីលើចុះក្រោមសម្រាប់អ្នកមិនអាចនិងមិនចង់ប្រើប្រាស់ជណ្ដើរជើងឬអគារមានច្រើនជាន់។

❖ ស្តង់ដានិងការណែនាំអំពីជណ្ដើរយោង

*រូបភាព ១.២.៦.១. ខ្នាតគំរូនៃជណ្ដើរយោង*









❖ ចំណុចគួរពិចារណាក្នុងការបំពាក់ជណ្តើរយោង

- ត្រូវបំពាក់ជណ្តើរយោងនៅទីកន្លែងដែលសមរម្យបំផុត
- ជណ្តើរយោងដែលបំពាក់គឺត្រូវតែអាចប្រើបានសម្រាប់មនុស្សគ្រប់រូប ដូចជា ធំទូលាយ រាបស្មើ មានសំឡេង មានអក្សរស្ទាបនិងមានសញ្ញាសម្គាល់គ្រប់គ្រាន់ឬអាចនិយាយបានថាជាការរចនាឡើងជាសាកល
- ជណ្តើរយោងត្រូវបំពាក់អមជាមួយជណ្តើរជើង
- ចំណុះរបស់ជណ្តើរនៅតាមអគារសាធារណៈដូចជាស្ថានីយរថភ្លើង ព្រលានយន្តហោះ សណ្ឋាគារ ត្រូវតែរៀបចំឱ្យអាចដាក់បានច្រើនសមរម្យ
- ជណ្តើរយោងនៅតាមមន្ទីរពេទ្យត្រូវតែធំទូលាយគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ជាមួយឧបករណ៍ផ្សេងៗ
- ជាទូទៅជណ្តើរយោងត្រូវមានទំហំ២០០០ម.ម x ១៨០០ម.ម
- ប្រសិនបើទីកន្លែងតូចជណ្តើរយោងអាចមានទំហំទទឹង២០៣០ម.មនិងជម្រៅ១៥២៥ម.ម
- ប្រសិនបើមិនអាចធ្វើទំហំខាងលើបានជណ្តើរអាចមានទំហំទទឹង១១០០ម.មនិងជម្រៅ១៤០០ម.ម
- គួរមានទីធ្លាដែលទំនេរនៅមុខទ្វារនិងប៊ូតុងជណ្តើរយោងទំហំ១៨០០ម.ម x ១៨០០ម.ម (តិចបំផុត១៥០០ម.ម x ១៥០០ម.ម)
- ជៀសវាងធ្វើឱ្យមានគែមស្រួចនៅគ្រប់កន្លែងព្រោះងាយមុតគ្រោះថ្នាក់
- ចំពោះអគារដែលមានជណ្តើរយោងច្រើនជាង៣ ការបង្កលក្ខណៈងាយស្រួលគួរធ្វើឡើងនៅគ្រប់ជាន់ ទាំងអស់ដោយជាន់នីមួយៗយ៉ាងហោចណាស់មានជណ្តើរយោងមួយដែលមានទំហំខ្នាតផ្ទៃខាងក្នុងតូចបំផុត ២០០០ម.ម x ១១០០ម.ម ដោយមានច្រកចូលដែលគ្មានឧបសគ្គនិងទទឹងតូចបំផុត៩០០ម.ម
- ការប្រើប្រាស់ជញ្ជាំងផុសដែលជះពន្លឺនិងសំឡេងឡងអាចបង្កភាពមិន

ងាយស្រួលសម្រាប់អ្នកខ្សោយ គំហើញនិងការស្តាប់

❖ ផ្ទៃបាត

- ផ្ទៃបាតជណ្តើរយោងត្រូវមានកម្ពស់១០ម.មទៅ២០ម.ម ពីផ្ទៃខាងក្រៅនៅពេលឈប់ដាក់មនុស្ស
- ផ្ទៃបាតនៃជណ្តើរយោងមិនត្រូវរអិលឬចាំងទេគឺគ្រើមនិងទន់ៗតែមិនត្រូវមានពណ៌ខ្មៅនិងងងឹតទេ

❖ ជញ្ជាំង

- ជណ្តើរយោងដែលមានជញ្ជាំងកញ្ចក់និងជញ្ជាំងធម្មតាមានគុណសម្បត្តិនិងគុណវិបត្តិផ្សេងៗគ្នាដូច្នេះ ការធ្វើឱ្យមានជញ្ជាំងទាំងពីរប្រភេទនេះគឺអាចទទួលយកបាន
- ជញ្ជាំងខាងក្នុងជណ្តើរត្រូវមានពណ៌ខុសពីដំបូលនិងផ្ទៃខាងក្រៅជៀសវាងមានចំណាំងផ្លាត

*រូបភាព ១.២.៦.២. គំរូអំពីពណ៌ផ្សេងគ្នារវាងផ្ទៃបាត ជញ្ជាំងនិងទ្វារ*



- ប្រសិនបើជណ្តើរមានទ្វារតែមួយកញ្ចក់ឆ្លុះអាចដាក់នៅផ្នែកខាងក្រោយ
- កញ្ចក់ត្រូវតែមានសុវត្ថិភាពនិងចាប់កម្ពស់៩០០ម.មពីដី
- មិនត្រូវចាប់កញ្ចក់ពេញផ្ទៃជញ្ជាំងទេនាំឱ្យច្រឡំ
- ប្រសិនបើជញ្ជាំងជណ្តើរធ្វើពីកញ្ចក់ថ្លាត្រូវមានគំនូសឬបិទចំណាំនៅកម្រិតណាមួយអាចនៅកម្ពស់ពី៨៥០ម.មទៅ១០០០ម.មឬពី១៤០០ម.មទៅ១៦០០ម.មពីដីដែលមានពណ៌ផ្ទុយគ្នា

❖ ទ្វារ

- ទ្វារជណ្តើរយោងគួរតែជាប្រភេទរុញឬបិទបើកទៅចំហៀងប្រតិបត្តិដោយថាមពលនិងបញ្ជាដោយស្វ័យប្រវត្តិ
- ទ្វារជណ្តើរយោងត្រូវទូលាយទំហំតូចបំផុត៩៥០ម.ម
- ទ្វារត្រូវបើកចំហយ៉ាងតិច៨វិនាទីនិងច្រើនជាងនេះសម្រាប់មនុស្សចាស់និងជនមានពិការភាព
- ទ្វារជណ្តើរយោងត្រូវតែមានពណ៌ផ្ទុយពីជញ្ជាំង
- គេអាចធ្វើទ្វារជណ្តើរយោងសងខាងដោយមិនចាំបាច់ត្រឡប់ក្រោយពេលចេញវិញដែលល្អសម្រាប់
- ជណ្តើរយន្តទំហំតូច ទទឹង១១០០ម.ម ជម្រៅ១៤០០ម.ម សម្រាប់តែអគារទាបៗ
- ប្រព័ន្ធសង្គ្រោះបន្ទាន់ត្រូវរៀបចំឱ្យបានល្អសម្រាប់អ្នកពិការទាំងសំឡេងនិងអក្សរ
- ឧបករណ៍អង្កេតស្វ័យប្រវត្តិគួរតែបំពាក់ក្នុងជណ្តើរយោងដើម្បីឱ្យទ្វារជណ្តើរបើកម្តងទៀតនៅពេលមានការប៉ះទង្គិចជាមួយឧបសគ្គអ្វីមួយ
- ឧបករណ៍អង្កេតស្វ័យប្រវត្តិ គួរតែដាក់នៅកម្ពស់ចន្លោះពី៥០០ម.មទៅ៦០០ម.មពីផ្ទៃបាតនៃជណ្តើរយោង
- ប្រព័ន្ធបញ្ជាទ្វារជណ្តើរយោងគួរកំណត់ដោយទុកពេលវេលាគ្រប់គ្រាន់

សម្រាប់ជនពិការនិងចាស់ជរា

❖ ប៊ូតុងខាងក្រៅ

- ប៊ូតុងចុចបញ្ជាជណ្តើរនៅខាងក្រៅត្រូវដាក់ទទឹងចម្ងាយ៥០០ម.ម ពីជណ្តើរក្នុងកម្ពស់៩០០ម.មទៅ១២០០ម.មពីផ្ទៃបាតនៃជណ្តើរយោង
- ប៊ូតុងចុចបញ្ជាត្រូវមានអង្កត់ផ្ចិតទំហំ៥០ម.មឬ៥០ម.មបួនជ្រុង
- អក្សរស្ទាប (អក្សរប្រៃយ៍) និងគំនូសផុសដែលអាចស្ទាបដឹងបានគួរតែដាក់នៅពីលើឬនៅខាងឆ្វេងនៃ ប៊ូតុងបញ្ជា
- អក្សរប្រៃយ៍និងគំនូសផុសដែលអាចស្ទាបដឹងទាំងនេះ គួរធ្វើជាលេខអង់គ្លេសឬខ្មែរ / ឬក៏និមិត្តសញ្ញា ណាមួយ
- គំនូសផុសដែលអាចស្ទាបដឹង គួរមានកម្ពស់ទាបបំផុត១៥ម.ម ហើយផុសចេញទាបបំផុត១ម.ម

❖ ប៊ូតុងខាងក្នុង

- ប៊ូតុងដែលអាចបញ្ជាបិទបើកត្រូវដាក់នៅខាងក្នុងដើម្បីអាចបញ្ជាបិទបើកបាន
- លេខជាន់នីមួយៗនៃជណ្តើរត្រូវច្បាស់និងអាចស្ទាបបានអមដោយសំឡេងផង




*រូបភាព ១.២.៦.៣. គំរូអំពីប៊ូតុងចុចបញ្ជាជណ្តើរយោង*

❖ ផ្ទាក់ដៃ

- ក្រៅពីផ្នែកខាងទ្វារជញ្ជាំងទាំង៣ខាងទៀតត្រូវមានផ្ទាក់ដៃ ដែលត្រូវចាប់ផ្ដេកស្របជញ្ជាំងក្នុងកម្ពស់ ៩០០ម.មពីដី
- ផ្ទាក់ដៃត្រូវមានទំហំ៣០ម.មទៅ៤៥ម.មនិងចាប់ទុកចន្លោះ៣០ម.មទៅ៥០ម.មពីជញ្ជាំង
- កន្លែងចាប់កាន់នៃផ្ទាក់ដៃគួរមានកម្ពស់ពី៨៥០ម.មទៅ៩៥០ម.ម

❖ ប៊ូតុងនិងទូរស័ព្ទហៅករណីមានអាសន្នក្នុងជណ្ដើរយោង

- ទូរស័ព្ទសម្រាប់ហៅរកជំនួយត្រូវចាប់នៅកម្ពស់៩០០ម.មទៅ១២០០ម.មពីដីនិងចម្ងាយ៥០០ម.ម ពីជ្រុងទ្វារ
- ខ្សែទូរស័ព្ទត្រូវមានប្រវែងយ៉ាងតិច៩០០ម.ម
- ចុចប្រកាសអាសន្នដែលមានសំឡេងរោទ៍ ភ្លើងសញ្ញាប្រាប់ដំណឹងនិងប្រព័ន្ធបញ្ជូនព័ត៌មានគួរតែបំពាក់នៅគ្រប់ជណ្ដើរយោងនីមួយៗហើយដែលបានតភ្ជាប់ទៅកាន់ការិយាល័យគ្រប់គ្រងនៃអគារឬបន្ទប់អ្នកថែទាំ
- ក្នុងករណីមានជណ្ដើរយោងមានច្រើនប្រអប់នៅកន្លែងតែមួយប៊ូតុងចុចបញ្ជាគួរតភ្ជាប់ជាប្រព័ន្ធ

❖ ស្លាកសញ្ញាសម្គាល់

- ស្លាកសញ្ញាត្រូវដាក់នៅជិតជណ្ដើរនិងនៅក្នុងជណ្ដើរដែលងាយមើលនិងងាយយល់
- ស្លាកសញ្ញាដែលអាចមើលឃើញល្អគឺចាប់នៅកម្ពស់ពី១៨០០ម.មទៅ២៥០០ម.មពីដី

❖ សំឡេង

- សញ្ញាបន្លឺជាសូរសំឡេងគួរតែបំពាក់ក្នុងជណ្ដើរយោង ដើម្បីផ្ដល់សញ្ញាឱ្យអ្នកប្រើប្រាស់បានដឹងនៅពេលប្រើប្រាស់
- ជណ្ដើរយោងត្រូវមានសំឡេងច្បាស់លាស់ទាំងចុះនិងឡើង

- សញ្ញាសំឡេងដែលអាចស្តាប់បានគឺពី៣៥ dB (A) ទៅ ៦៥ dB (A)
- គួរបំពាក់ឧបករណ៍បន្លឺសំឡេងភ្លើងសញ្ញាប្រាប់ដំណឹង (គ្រប់ជណ្តើរនីមួយៗ) ហើយនិងប្រព័ន្ធបញ្ជូន ព័ត៌មានដែលភ្ជាប់ទៅនឹងជណ្តើរយោង
- ភ្លើងសញ្ញាប្រាប់ដំណឹង គួរមានទម្រង់ជាភ្លើងភ្លឺបភ្លែតនៅជិតឧបករណ៍បំពងសំឡេងសម្រាប់បញ្ជូន ព័ត៌មាន និងកំណាត់សម្គាល់មួយ។ នៅពេលភ្លើងលោតភ្លឺបភ្លែតៗវាបញ្ជាក់ថាការប្រកាសអាសន្នរបស់ អ្នកត្រូវបានគេទទួលហើយ។ ព័ត៌មានជាភាសាអង់គ្លេសនិងខ្មែរ គួរដាក់នៅក្បែរភ្លើងសញ្ញាភ្លឺបភ្លែត
- ប្រព័ន្ធនេះគួរបំពាក់ថាមពលដោយប្រព័ន្ធផ្គត់ផ្គង់ថាមពលអគ្គិសនីជំនួយបន្ទាន់ ក្នុងករណីថាមពលអគ្គិសនីចម្បងត្រូវកាត់ផ្តាច់

❖ ភ្លើងនិងពន្លឺ

- ការបំពាក់ភ្លើងនៅក្នុងជណ្តើរគួរមានការប្រុងប្រយ័ត្នជៀសវាងចាំងគឺក្នុងកម្រិតពន្លឺ១០០លុច



*រូបភាព ១.២.៦.៤. គំរូអំពីពន្លឺនៅក្នុងជណ្តើរយោង*

❖ កៅអីបត់បាន

- កៅអីដែលអាចបត់ទៅរកជញ្ជាំងបានគួរត្រូវបានបំពាក់នៅក្នុងជណ្តើរយោងសម្រាប់ជាការចំបាច់
- កៅអីនោះត្រូវមានទំហំជម្រៅ៣០០ម.មទៅ៤០០ម.ម ទទឹងពី៤០០ម.មទៅ៥០០ម.មនិងត្រូវចាប់ កម្ពស់៥០០ម.មពីដី ហើយអាចទ្រទម្ងន់បាន១០០គីឡូក្រាម

### ១.២.៧. ជណ្តើរយោងជម្លៀសពេលមានអាសន្ន (Evacuation Lifts)

❖ ស្តង់ដានិងការណែនាំអំពីជណ្តើរយោងជម្លៀសពេលមានអាសន្ន

- រៀបចំឱ្យមានជណ្តើរយោងសម្រាប់ជម្លៀសពេលមានអាសន្ន
- ជណ្តើរយោងជម្លៀសពេលមានអាសន្នត្រូវបានរៀបចំឡើងក្នុងករណីមានអគ្គិភ័យជាដើម
- ជណ្តើរនេះផ្តល់អាទិភាពសម្រាប់មនុស្សចាស់ ស្ត្រីមានផ្ទៃពោះ ជនមានពិការភាពនិងកុមារពេលមានអាសន្ន
- ជណ្តើរនេះគួរតែមានភ្លើងអគ្គិសនីជាប្រចាំ
- ប៊ូតុងបញ្ជាគួរតែរៀបចំឡើងសម្រាប់តែអ្នកមានសិទ្ធិប្រើប្រាស់តែប៉ុណ្ណោះ
- ត្រូវមានស្លាកសញ្ញាបង្ហាញពីទីតាំងជណ្តើរនេះច្បាស់លាស់និងងាយយល់ពីគ្រប់កន្លែង
- ចំណុះនិងទំហំនៃជណ្តើរនេះត្រូវស្របទៅតាមទីតាំងដែលត្រូវបំពាក់
- សម្រាប់ខ្នាតផ្ទៃបាត,ជញ្ជាំង,ទ្វារ,ប៊ូតុងខាងក្រៅ,ប៊ូតុងខាងក្នុង,ផ្ទាក់ដៃ,ប៊ូតុងនិងទូរស័ព្ទហៅករណី មានអាសន្នក្នុងជណ្តើរយោង,ស្លាកសញ្ញាសម្គាល់,សំឡេង,ភ្លើង,ពន្លឺនិងកៅអីបត់បានដូចគ្នាទៅនឹងជណ្តើរយោងខាងលើដែរ

### ១.២.៨. ឧបករណ៍យោងចាប់ជាប់បង្កាន់ដៃជណ្តើរ (Stair Lifts)



*រូបភាព ១.២.៨.១. គំរូអំពីកៅអីចាប់ភ្ជាប់ទៅនឹងបង្កាន់ដៃជណ្តើរសម្រាប់ចុះឡើង*

❖ ស្តង់ដានិងការណែនាំអំពីឧបករណ៍យោងចាប់ជាប់បង្កាន់ដៃជណ្តើរ

- បំពាក់ឧបករណ៍នេះសម្រាប់តែអគារចាស់មានស្រាប់ តែប៉ុណ្ណោះក្នុងករណីជណ្តើរផ្សេងៗមិនអាចបំពាក់បាន
- ត្រូវបិទការណែនាំប្រើប្រាស់ឱ្យបានច្បាស់លាស់និងងាយៗ
- ត្រូវមានទីធ្លាទទឹងទំហំ៨៩០ម.មនិងបណ្តោយ១៥២៥ម.ម
- ឧបករណ៍បញ្ជាត្រូវតែសាមញ្ញនិងងាយស្រួលប្រើ
- ឧបករណ៍ចាប់ជាប់ត្រូវតែរឹងមាំនិងមានសុវត្ថិភាពបំផុត
- ចាប់នៅកម្ពស់ពី៦០០ម.មទៅ១១០០ម.មពីដី
- ឧបករណ៍ទាំងអស់អាចដកចេញនិងដាក់ចូលវិញបាន
- ត្រូវធានាថាឧបករណ៍នេះអាចទ្រទម្ងន់បានយ៉ាងតិច១០០គីឡូក្រាម

### ១.២.៩. ជណ្តើរយន្ត (Escalators)



❖ ស្តង់ដានិងការណែនាំអំពីជណ្តើរយន្ត

- ជណ្តើរយន្តត្រូវបានប្រើប្រាស់ចុះឡើងអគារជាពិសេសអគារធំៗដូចជា ផ្សារទំនើប ព្រលានយន្តហោះ ស្ថានីយរថភ្លើង ។ល។
- ចម្ងាយគ្រប់គ្រាន់សម្រាប់ការបោះជំហានក្នុងការបម្លាស់ទីពីលើចុះក្រោម សម្រាប់អ្នកដំណើរគឺចាំបាច់ត្រូវគិតគូរ ដើម្បីធានាថាអ្នកដំណើរជា ពិសេសពេលបោះជំហានចេញពីជណ្តើរយន្តគួរមានគម្លាតនិងរយៈពេល គ្រប់គ្រាន់ដើម្បីដើរចេញដោយសុវត្ថិភាព



*រូបភាព ១.២.៩.១. គំរូអំពីជណ្តើរយន្តដែលបំពាក់ភ្លើងនៅបង្កាន់ដៃចល័ត*

- ជណ្តើរយន្តផ្តល់ជាមធ្យោបាយសម្រាប់ដឹកជញ្ជូនអ្នកដំណើរតាមលក្ខណៈបញ្ឈរ (ឡើងចុះ )នៅក្នុងអគារ
- មិនត្រូវចាត់ទុកជណ្តើរយន្តជាផ្លូវសម្រាប់ដើរធម្មតានោះទេ គ្រោះថ្នាក់អាចនឹងកើតមានជាយថាហេតុនិងគ្រប់ពេលហេតុ ដូច្នេះការដាក់សញ្ញាគ្រោះថ្នាក់ ការណែនាំនិងដាក់មនុស្សការពារគឺជាការប្រសើរ
- បង្កាន់ដៃចល័តនៃជណ្តើរយន្តត្រូវមានកម្ពស់ពី៩០០ម.មទៅ១១០០ម.ម ពីកាំជណ្តើរ
- បង្កាន់ដៃនេះត្រូវធ្វើលើសកាំជណ្តើរយ៉ាងតិច៧០០ម.ម ទាំងខាងក្រោមនិងខាងលើ
- បង្កាន់ដៃត្រូវមានពណ៌ផ្សេងពីពណ៌នៅជុំវិញវា

- ល្បឿនរិលនៃបង្កាន់ដៃត្រូវស្របគ្នានិងល្បឿននៃកាំជណ្តើរដែរ
- ជណ្តើរយន្តត្រូវមានទទឹងតូចបំផុត៥៨០ម.មនិងធំបំផុត១១០០ម.ម
- ជណ្តើរមួយកាំៗត្រូវមានកម្ពស់ខ្ពស់បំផុត២៤០ម.ម
- កន្លែងជាន់កាំនីមួយៗត្រូវរឹងមាំ មិនរអិលនិងមិនចាំង
- នៅចុងកាំនីមួយៗត្រូវលាបពណ៌ទំហំទទឹង៥៥ម.ម
- ចំពោះជណ្តើរយន្តដែលមមាញឹកត្រូវមានទីធ្លាទូលាយខាងមុខប្រហែល ៥ម៉ែត្រ
- ផ្នែកដែលចល័តខាងលើត្រូវមានបណ្តោយយ៉ាងតិច២០០០ម.មនិងខាងក្រោមបណ្តោយយ៉ាងតិច ១៦០០ម.ម
- ត្រូវមានសំឡេងនៅចំណុចចាប់ផ្តើមនិងចំណុចដល់ទី
- ល្បឿននៃជណ្តើរត្រូវកំណត់ត្រឹម០.៧៥ម៉ែត្រក្នុង១វិនាទី
- ត្រូវកំណត់ល្បឿនកាន់តែយឺតប្រសិនបើជណ្តើរកំពុងមានអ្នកប្រើច្រើន
- ជណ្តើរត្រូវដាក់ក្នុងមុំទ្រេត ពី៣០-៣៥ដឺក្រេ
- កន្លែងប៊ូតុងបញ្ឈប់បន្ទាន់ពេលមានអាសន្នគួរតែដាក់ឱ្យមានត្រឹមត្រូវដែលអាចឈោងដល់



*រូបភាព ១.២.៩.២. គំរូអំពីជណ្តើរយន្តដែលបង្ហាញពីទិសដៅឡើងចុះផ្សេងគ្នាមានប៊ូតុងបញ្ឈប់ភ្លាមៗចាប់ភ្ជាប់នឹងមានជណ្តើរជើងនៅកណ្តាល*

- ត្រូវដាក់សញ្ញាបង្ហាញឱ្យបានច្បាស់លាស់
- ធានាថាទិសដៅនៃជណ្តើរត្រូវបានកំណត់ច្បាស់លាស់
- ធានាថាកន្លែងដាក់ជើងចុះនិងឡើងមានពណ៌ត្រឹមត្រូវ

- រៀបចំកន្លែងចល័តដែលរាបស្មើតិចបំផុត២០០០ម.មនៅខាងលើនិង ១៦០០ម.ម នៅខាងក្រោម

### ១.២.១០. ជណ្តើររត់ដឹកអ្នកដំណើរ (Travelators)

❖ ស្តង់ដានិងការណែនាំអំពីជណ្តើររត់ដឹកអ្នកដំណើរ

- ជណ្តើរនេះត្រូវមានទទឹងតូចបំផុត ១៥០០ម.មនិងទីធ្លាទំនេរមុខជណ្តើរ ២៣០០ម.ម
- ជណ្តើររត់ដឹកអ្នកដំណើរនេះ គឺជាផ្នែកមួយនៃផ្លូវចល័តត្រូវបានរៀបចំនៅតាមទីធ្លាឬអគារធំៗនៅលើផ្លូវរាបស្មើនិងវែងៗដូចជាអាកាសយានដ្ឋាន ស្ថានីយរថភ្លើងធំៗសម្រាប់អ្នកមិនអាចដើរបានច្រើនឬមានអីវ៉ាន់ធ្ងន់ៗ
- ទិសដៅនៃផ្លូវនេះត្រូវកំណត់ឱ្យបានច្បាស់ មានស្លាកសញ្ញានិងការណែនាំផ្សេងៗ
- បង្កាន់ដៃត្រូវមានពណ៌ផ្សេងពីគេ
- ត្រូវមានសញ្ញាប្រាប់មុនយ៉ាងតិច៦០០០ម.មនៅចុងជណ្តើរនីមួយៗ
- ផ្ទៃដើរទាំងមូលមិនត្រូវចាំងឬរអិលទេ



*រូបភាព ១.២.១០.១. គំរូអំពីជណ្តើររត់ដឹកអ្នកដំណើរ*

- ល្បឿននៃជណ្តើរត្រូវរក្សាឱ្យយឺតបំផុត ល្បឿនដែលល្អគឺ០.៥ម៉ែត្រ (ច្រើនបំផុត០.៧៥ម៉ែត្រ )ក្នុង១វិនាទី
- ប៊ូតុងបញ្ឈប់ភ្លាមៗត្រូវដាក់ឱ្យបានត្រឹមត្រូវនិងឈោងដល់
- ប្រសិនបើមានចំណោតគឺក្នុងកម្រិត១/២០



*រូបភាព ១.២.១០.២. គំរូអំពីជណ្តើររត់ដឹកអ្នកដំណើរមានសញ្ញាសម្គាល់*

- បង្គោលការពារត្រូវដាក់ឱ្យបានត្រឹមត្រូវនៅចុងជណ្តើរនិងមានពណ៌លេចច្បាស់
- ត្រូវបំពាក់សំឡេងនៅចំណុចចាប់ផ្តើម ពាក់កណ្តាលនិងចុងជណ្តើរ

## ១.៣. សម្ភារៈសម្រាប់ក្រាលផ្ទៃ (Surface Materials)





❖ ស្តង់ដានិងការណែនាំអំពីសម្ភារៈសម្រាប់ក្រាលផ្ទៃ

- ត្រូវប្រើប្រាស់និងកែច្នៃសម្ភារៈដែលត្រឹមត្រូវដើម្បីធានាថាទិដ្ឋភាពខាងក្រៅសមរម្យបំផុត
- ធានាថាគ្រប់ផ្ទៃទាំងអស់រឹងមាំនិងមិនរអិល
- ជៀសវាងផ្ទៃរលាក់និងធូរលុងឬទន់ជ្រាយ
- ត្រូវដឹងថាផ្ទៃខ្លះប្រើយូរទៅរលោងនាំឱ្យចាំងពន្លឺ
- ជៀសវាងផ្ទៃមានពណ៌ដិតពេកឬមានបន្ទាត់ដែលរំខានដល់ការមើលនិងនាំឱ្យច្រឡំ
- ត្រូវគិតទុកមុនអំពីភាពងាយស្រួលប្រើនិងតម្រូវការជួសជុលពេលអនាគត

## ១.៤. គ្រឿងសង្ហារឹមនៅតាមផ្លូវ (Street Furniture)





❖ ស្តង់ដានិងការណែនាំអំពីគ្រឿងសង្ហារឹមនៅតាមផ្លូវ

- គ្រឿងសង្ហារឹមនៅតាមផ្លូវរួមមាន បង្គោលភ្លើងបំភ្លឺ កៅអី តុ ផ្ទាំងព័ត៌មាន ភ្លើងសញ្ញាចរាចរ ប្រអប់សំបុត្រ ប្រអប់កុងទ័រភ្លើង សសរឬប្រអប់ខ្សែភ្លើង បង្គោលការពារឬបែងចែកផ្លូវនិងផ្ទាំងផ្សាយពាណិជ្ជកម្ម។ល។ តែងតែត្រូវបានដាក់ឬបំពាក់នៅតាមដងផ្លូវសាធារណៈ ដែលនាំឱ្យរំខានដល់ការធ្វើដំណើរប្រសិនបើគ្មានការរៀបចំបានត្រឹមត្រូវ
- រាល់គ្រឿងសង្ហារឹមទាំងអស់ត្រូវដាក់ឬបំពាក់ក្នុងបន្ទាត់ត្រង់
- ត្រូវដាក់សម្ភារៈនៃគ្រឿងសង្ហារឹមតាមផ្លូវនៅត្រង់ឬខាងក្រោយព្រំប្រទល់ផ្លូវ
- ធានាថាស្លាកសញ្ញានៅខាងលើនិងកន្លែងចាប់ភ្ជាប់មានចន្លោះ ២៣០០ម.ម ចាប់ពីផ្លូវទៅ
- ធានាថាគ្រប់គ្រឿងសង្ហារឹមនៅតាមផ្លូវទាំងអស់មានពណ៌ខុសពីផ្ទៃខាងក្រោយ
- ត្រូវបំពាក់បន្ទះដែលជំនួយការមើលនៅគ្រប់សសរឬបង្គោលតាមដងផ្លូវ
- ត្រូវដាក់សញ្ញាទទឹងនៅកន្លែងណាដែលមានបង្គោល ដើម្បីបង្ការកុំឱ្យមានគ្រោះថ្នាក់ដល់អ្នកថ្មើរជើង ដែលមានបញ្ហាលំបាកមើល
- មិនត្រូវភ្ជាប់បង្គោលការពារជាមួយនឹងច្រវ៉ាក់ឬខ្សែឡើយ

- ត្រូវដាក់កន្លែងទឹកអាចហូបបានឱ្យជិតកន្លែងអង្គុយឬឈរ
- រៀបចំកន្លែងអង្គុយឆ្ងាយពីមួយទៅមួយឱ្យបានទៀងទាត់និងឆ្ងាយពីផ្លូវយានយន្ត
- ត្រូវដាក់តុលំហែដែលងាយប្រើនៅតាមផ្លូវ
- កន្លែងជើងនៃបង្គោលត្រូវរៀបបាតខ្ពស់ជាងផ្ទៃផ្លូវធម្មតាកម្ពស់១០០ម.ម
- ប្រសិនបើខានមិនបានឧបករណ៍ដែលលៀនចូលមកផ្លូវត្រូវតែមានកម្ពស់តិចបំផុត២០០០ម.ម
- សញ្ញាប្រាប់ពីគ្រោះថ្នាក់ដែលស្ទាបអាចដឹងបាននៅលើផ្លូវជុំវិញឧបករណ៍ដែលអាចបង្កគ្រោះថ្នាក់

### ១.៤.១. អំពូលភ្លើងនិងស្លាកសញ្ញា (Lighting and Signage)








❖ ស្តង់ដានិងការណែនាំអំពីអំពូលភ្លើងនិងស្លាកសញ្ញា

- សសរភ្លើងនិងសញ្ញាត្រូវចាប់ជាប់អគារឬជញ្ជាំងតាមទីតាំងជាក់ស្តែងដើម្បីកាត់បន្ថយការរំខានដល់ការប្រើប្រាស់ផ្លូវ
- ក្នុងករណីមិនអាចធ្វើបានសសរភ្លើងនិងសញ្ញាត្រូវដាក់ឱ្យនៅខាងក្រោយផ្លូវក្នុងចម្ងាយឆ្ងាយបំផុត២៧៥ម.មពីផ្នែកខាងមុខនៃបង្គោលនិងស្លាកសញ្ញានោះ។ ប្រសិនបើសសរភ្លើងនិងសញ្ញាត្រូវបានដាក់នៅជិតផ្លូវគឺចម្ងាយតិចបំផុត៥០០ម.មពីគែមខឿនឬ៦០០ម.ម ប្រសិនបើផ្លូវនោះមានរាងកោងឬចោត

- ស្លាកសញ្ញានិងបង្គោលភ្លើងគួរដាក់ចន្លោះតិចបំផុត១០០០ម.មពីគ្នា
- ការដាក់ព្យួរស្លាកសញ្ញានិងវត្ថុផ្សេងៗនៅលើផ្លូវដូចជាអំពូលភ្លើងជាប់ជញ្ជាំងឬជាប់ដើមឈើគួរដាក់បញ្ឈរក្នុងកម្ពស់២៣០០ម.មពីដី
- ពេលខ្លះផ្លូវដើរឯកទិសនៅស្ថានីយរថភ្លើងឬចំណតរថយន្តក្រុងត្រូវដាក់ស្លាកសញ្ញាកម្ពស់២១០០ម.ម ប៉ុន្តែប្រសិនបើទីតាំងនោះមានអ្នកជិះយានជំនិះប្រើប្រាស់ផងដែរត្រូវដាក់ស្លាកសញ្ញាកម្ពស់២៣០០ម.ម
- ប្រសិនបើមានមែកឈើឬគុម្ពឈើលយចេញទៅរកផ្លូវត្រូវកាត់ចោលដើម្បីឱ្យផ្លូវនៅតែទូលាយមានកម្ពស់៣០០០ម.ម

### ១.៤.២. ការបំពាក់សង្ហារឹមនៅតាមផ្លូវ (Placement of Street Furniture)






❖ ស្តង់ដានិងការណែនាំអំពីការបំពាក់សង្ហារឹមនៅតាមផ្លូវ



## *រូបភាព ១.៤.២.១. ឧបករណ៍ដែលត្រូវបំពាក់នៅតាមផ្លូវ*







**ចំណុចសំខាន់ៗ៖**

A. ឧបករណ៍ដែលត្រូវបំពាក់នៅតាមផ្លូវ

B. មិនចាំបាច់មានឧបករណ៍ការពារគ្រោះថ្នាក់ប្រសិនបើឧបករណ៍បំពាក់នៅតែម ខាងក្រោមកម្ពស់ ៣០០មម និងតែមខាងមុខ កម្ពស់១២០០មម ពីដី

C. មិនចាំបាច់មានឧបករណ៍ការពារគ្រោះថ្នាក់ប្រសិនបើឧបករណ៍បំពាក់តាមជងផ្លូវនៅចន្លោះពី ៣០០មម និង២១០០មមពីដីដោយមិនលើសពី១០០មមឬមិនលើសពី១០០មមពីខាងមុខឧបករណ៍ នោះនិងឧបករណ៍ដែលដាក់នោះមិនច្រើនជាង១០០មមពីផ្លូវ

D. ឧបករណ៍ការពារដាក់នៅពីមុខ




**ចំណុចសំខាន់ៗ៖**

A. គ្រោះថ្នាក់ដោយសារៈការបើកបង្អួច ផាងទូរស័ព្ទ អគារ

B. កន្លែងការពារឈើច្រត់នៅពេលដែលឧបករណ៍លយចូលផ្លូវ ពី៣០០មមទៅ២១០០មមពីដីដោយមិនលើសពី១០០មមឬមិន លើសពី១០០មម ពីខាងមុខឧបករណ៍នោះនិងឧបករណ៍ដែល ដាក់នោះមិនច្រើនជាង១០០មមពីផ្លូវ

C. ការពារឧបករណ៍ទាំងសងខាងដោយដាក់បន្ថែមកន្លែងការពារ ឈើច្រត់

D. មិនឱ្យលយចេញ១០០មម ខាងមុខឧបករណ៍និងបង្គោលការពារ

E. ផ្នែកខាងក្រោមនៃបង្គោលការពារមិនត្រូវខ្ពស់ជាង១៥០មមពីដី សម្រាប់ឈើច្រត់

ឯកសារយោង៖ ខ្នាត[illegible] ជប៉ុន

- គ្រប់គ្រឿងសង្ហារឹមតាមផ្លូវទាំងអស់ត្រូវមានពណ៌ផ្ទុយពីផ្ទៃទាំងខាងក្រោម និងចំហៀង
- មិនត្រូវដាក់ពណ៌ប្រផេះទេព្រោះវាអាចមើលទៅឃើញដូចផ្ទៃទូទៅ
- វត្ថុផ្សេងៗដែលចាប់ជាប់បង្គោលឬសសរបញ្ឈរ គួរតែដាក់ពណ៌ដោយដាក់ទំហំ១៥០ម.មដូចជាស្លាកសញ្ញាផ្សេងៗត្រូវដាក់កម្ពស់១៥០០ម.ម ពីដីដែលអាចមើលឃើញផ្ទុយពីបង្គោលឬសសរបញ្ឈរទាំងនោះ
- បង្គោលអាចលាបពណ៌ដោយដាក់អំពូលភ្លើងនៅត្រង់កំពូល
- គ្រឿងសង្ហារឹមគួរតែបន្តទៅដល់ជាន់ផ្ទាល់ដី
- ត្រូវជៀសវាងដាក់វត្ថុដែលដាក់នៅតាមដងផ្លូវដើរដូចជា ធុងសំរាម ទូរស័ព្ទ ប្រអប់សំបុត្រ ដោយសារតែអាចរំខានដល់អ្នកថ្មើរជើង
- វត្ថុផ្សេងៗដែលចាប់ភ្ជាប់គួរតែដាក់បែរមុខទៅខាងមនុស្សធ្វើដំណើរដើម្បីងាយមើល
- វត្ថុដែលដាក់តាមផ្លូវដូចជាផែនទីដែលអាចដាក់បញ្ឈរជើងពីរ គួរដាក់ជើងនៅកម្ពស់២៥០ម.មទៅ៤០០ម.មពីដីដែលអាចជួយមិនឱ្យអ្នកថ្មើរជើងដើរជល់ឬទង្គិច
- ស្លាកសញ្ញា គួរតែមិនលើសពី១៥០ម.មនៅខាងក្រោយបង្គោលនិងបង្គោលនោះត្រូវមានពណ៌ផ្ទុយពីផ្ទៃចំហៀងនិងខាងក្រោម

### ១.៤.៣. ធុងសំរាម (Bins)





❖ ស្តង់ដានិងការណែនាំអំពីធុងសំរាម

- ធុងសំរាមគួរតែមានកម្ពស់ជាទូទៅប្រហាក់ប្រហែល១៣០០ម.ម ហើយគួរដាក់គម្របនៅកម្ពស់១០០ម.មពីដី
- ត្រូវដាក់ធុងសំរាមឱ្យបានច្រើនដែលមានទំហំ ពណ៌ ទីតាំងនិងចំនួនមនុស្សប្រើប្រាស់ផ្សេងគ្នាឱ្យបានសមរម្យ
- ធុងសំរាមត្រូវមានគម្របជានិច្ចកាល
- ត្រូវមានស្លាកសញ្ញាឬអក្សរសម្គាល់អំពីធុងសំរាម

### ១.៤.៤. បង្គោលការពារ (Bollards)



❖ ស្តង់ដានិងការណែនាំអំពីបង្គោលការពារ

- បង្គោលនេះអាចធ្វើជារាងផ្សេងៗគ្នា (ត្រង់ កោងឬបត់បែន) ទៅតាមចំណង់ចំណូលចិត្ត
- ជានិច្ចកាលបង្គោលការពារតែងតែត្រូវបានដាក់ដើម្បីបញ្ឈប់រថយន្តពីផ្លូវថ្មើរជើង ហើយបែងចែកផ្លូវ ថ្មើរជើងនិងផ្លូវចរាចរឬគោលបំណងផ្សេងៗទៀត
- ប្រសិនបើដាក់បង្គោលការពារនេះមិនបានត្រឹមត្រូវ វាអាចជាឧបសគ្គសម្រាប់អ្នកប្រើរទេះឬអ្នកមាន រទេះទារកនិងអាចគ្រោះថ្នាក់ដល់អ្នកមានកម្សោយគំហើញ
- ប្រសិនបើចាំបាច់ដែលត្រូវដាក់នៅត្រង់ផ្លូវសុវត្ថិភាព បង្គោលការពារគួរងាយមើលដោយប្រើពណ៌ ផ្ទុយនិងត្រូវមានកម្ពស់១០០០ម.មនិងអង្កត់ផ្ចិតទំហំ៧០ម.មទៅ២០០ម.ម
- ផ្លូវឆ្លងកាត់ចន្លោះពីបង្គោលមួយទៅមួយគិតពីគែមខឿនគួរមានទំហំទទឹង១២០០ម.មនៅសងខាង

- មិនត្រូវភ្ជាប់បង្គោលការពារជាមួយខ្សែឬច្រវ៉ាក់ទេដោយសារតែអាចធ្វើឱ្យគ្រោះថ្នាក់ ដល់ជនមាន ពិការភាពកម្សោយគំហើញឬបើចាំបាច់ត្រូវលាបពណ៌ច្រវ៉ាក់នោះឱ្យខុសពីពណ៌បង្គោលនិងផ្ទៃខាង ក្រោមច្រវ៉ាក់ត្រូវលាបពណ៌បង្គោលនេះឱ្យខុសពីពណ៌ផ្ទៃ( ពណ៌លេចជាងជាការប្រសើរ )

### ១.៤.៥. ច្រកទ្វារ (Gates)



❖ ស្តង់ដានិងការណែនាំអំពីច្រកទ្វារ

- ពេលខ្លះច្រកទ្វារមានត្រចៀកទ្វារ ឬរ៉ឺស័រដើម្បីឱ្យទ្វារអាចបិទដោយខ្លួនឯង តែត្រូវធានាថាទ្វារមិនបិទ ខ្លាំងនិងលឿនពេកដែលនាំឱ្យរំខានដល់អ្នកចេញចូល
- ប្រព័ន្ធបើកទ្វារគួរតែរឹងមាំនិងងាយស្រួលប្រើ ដែលគន្លងត្រូវពង្រីកដល់ ៥០០ម.មនៅសងខាងដោយ មានគន្លឹះដើម្បីឱ្យកាន់តែស្រួលបើកទ្វារ
- ទីធ្លាខាងមុខនិងខាងក្រោយទ្វារគួរមានបណ្តោយ២០០០ម.មនិងធានាថាគ្មានឧបសគ្គ

### ១.៤.៦. កន្លែងទឹកអាចហូបបាន (Drinking Fountains)



*រូបភាព ១.៤.៦.១. គំរូស្លាកសញ្ញាប្រាប់ពីទីកន្លែងទឹកអាចហូបបាន*

❖ ស្តង់ដានិងការណែនាំអំពីកន្លែងទឹកអាចហូបបាន

- នៅទីណាដែលមានកន្លែងទឹកអាចហូបបាន កន្លែងនោះគួរតែងាយរកងាយយល់ ងាយប្រើនិងអាច ប្រើបានសម្រាប់មនុស្សទាំងអស់គ្នា

- កន្លែងទឹកអាចហូបបាន គួរតែមានចន្លោះខាងក្រោមទំនេរសម្រាប់អ្នកប្រើរទេះចូលហូបទឹកនិងឆ្ងាយ ពីជញ្ជាំង៤៣០ម.មទៅ៥០០ម.មនិងកម្ពស់ចំពួយទឹកត្រូវមានកម្ពស់៧៥០ម.មទៅ៩១៥ម.ម
- ទីណាដែលមានកន្លែងទឹកអាចហូបបានពីរត្រូវដាក់កម្ពស់ផ្សេងគ្នា ដើម្បីងាយប្រើសម្រាប់មនុស្សខ្ពស់និងមនុស្សទាប
- នៅជុំវិញឬខាងមុខកន្លែងទឹកអាចហូបបានត្រូវមានទីធ្លាទំហំ៨០០ម.ម x ១៣០០ម.ម ដើម្បីមនុស្សគ្រប់រូបអាចចេញចូលប្រើប្រាស់បានងាយស្រួល
- ជាការល្អគួរតែដាក់កន្លែងទឹកអាចហូបបាននៅក្នុងកន្លែងមួយដែលមិនមានឧបសគ្គនិងគ្រោះថ្នាក់ដល់អ្នកមកហូបទឹក
- ចំពួយទឹកគួរដាក់បែរទៅរកផ្នែកខាងមុខក្នុងកម្ពស់១០០ម.មពីផ្ទៃថាសដែលគេអាចត្រងទឹកបាន យកទៅប្រើ
- កន្លែងបិទបើកទឹកគួរតែងាយប្រើនិងដាក់បែរទៅខាងមុខនិងសងខាងដើម្បីឱ្យប្រើបានទាំងអ្នកប្រើ ដៃស្តាំនិងអ្នកប្រើដៃឆ្វេង
- ទឹកដែលហៀរទៅត្រូវមានទុយោចូលទៅក្នុងប្រព័ន្ធទឹកជៀសវាងហូរទៅដី

### ១.៤.៧. កន្លែងអង្គុយ (Seating)





❖ ស្តង់ដានិងការណែនាំអំពីកន្លែងអង្គុយ

- កៅអី/បង់សាធារណៈទាំងខាងក្រៅនិងខាងក្នុងត្រូវឌីហ្សាញឱ្យមានធ្នាក់ដៃ ដើម្បីសម្រួលដល់ការ អង្គុយនិងក្រោកឈរដែលមានខ្នាតដូចខាងក្រោម៖
  - កម្ពស់៤០០ម.មទៅ៤៥០ម.ម
  - កម្ពស់បង្អែក៧៥០ម.មទៅ៧៩០ម.ម
  - ជម្រៅកន្លែងអង្គុយ៤០០ម.មទៅ៤៥០ម.ម
  - មុំរវាងកន្លែងអង្គុយនិងបង្អែក១០០ទៅ១០៥ដឺក្រេ
  - កម្ពស់ធ្នាក់ដៃ២២០ម.មទៅ៣០០ម.មពីកន្លែងអង្គុយ
  - ធ្នាក់ដៃលយទៅមុខ៧៥ម.ម
  - របារទទឹងកៅអីខាងក្រោមកន្លែងអង្គុយកម្ពស់១៥០ម.មពីដី



- កន្លែងអង្គុយ គួរតែរៀបចំឱ្យមានចន្លោះទៀងទាត់ពីមួយទៅមួយនៅតាមដងផ្លូវតាមជាក់ស្តែងដោយ ស៊ីគ្នាជាមួយកម្ពស់និងទីតាំងផ្លូវដូចជាជណ្តើរខាងក្រៅនិងជម្រាល
- នៅតាមតំបន់កំសាន្តនិងជនបទ កន្លែងអង្គុយត្រូវដាក់នៅតាមរោងសម្រាកនិងនៅកន្លែងណាដែល រៀបចំសម្រាប់អ្នកថ្មើរជើង
- កៅអីគួរដាក់នៅ៦០០ម.មនៅមុខកន្លែងអង្គុយ
- ផ្ទៃដែលត្រូវរៀបដាក់កៅអីគួរតែអាចឱ្យទឹកហូរបាន មានភាពរឹងមាំនិងមានលំនឹង
- ផ្ទៃក្រឡាទំហំ៩០០ម.ម នៃផ្លូវរឹងមាំដែលនៅជិតកៅអីអាចឱ្យអ្នកប្រើរទេះអង្គុយបានដូចមនុស្សទូទៅ ហើយអាចឱ្យអ្នករុញរទេះទារកចតឬទុករទេះទារកនោះបាននៅក្បែរនោះ
- កៅអីគួរមានកម្ពស់តិចបំផុត៤៥០ម.មនិងទទឹង៥០០ម.ម
- ការដាក់កន្លែងអង្គុយនៃកៅអីកម្ពស់៥០០ម.មទៅ៧៥០ម.មអាចងាយស្រួលប្រើសម្រាប់មនុស្សខ្លះនិងអាចជាជម្រើសសម្រាប់មនុស្សខ្លះ
- កន្លែងដាក់កែងជើងមានជម្រៅតិចបំផុត១០០ម.មអាចឱ្យអ្នកអង្គុយងើបបានស្រួល
- កៅអីដែលមានបង្អែកពិតជាមានប្រយោជន៍អាចផ្អែកបាននិងផ្ទាក់ដៃដែលបានចាប់ប្រហែល២០០ម.មពីកន្លែងអង្គុយអាចជួយក្នុងការដាក់គូទចុះនិងច្រត់ងើបឡើង
- ការរៀបកៅអីជាជួរគួរត្រូវធ្វើដូចៗគ្នាដូចជាកៅអីមានផ្ទាក់ដៃឬកៅអីគ្មានផ្ទាក់ដៃ
- ការរៀបចំកៅអីដែលខុសគ្នាក្នុងជួរតែមួយ អាចបណ្តាលឱ្យមានការយល់ច្រឡំជាពិសេសអ្នកខ្សោយគំហើញ
- តុសម្រាប់ហូបបាយ គួរតែដាក់នៅកន្លែងមានសុវត្ថិភាពកន្លែងសមរម្យ

និងសមស្របដែលអាចនៅជិតចំណតយានយន្ត
- គួរតែត្រូវរៀបចំតុសម្រាប់ហូបបាយនៅក្នុងរោងមួយនិងមានផ្លូវចេញចូលបានងាយស្រួល
- ការធ្វើតុនិងកៅអីគួរតែមិនងាយដួលនៅពេលដែលគ្មានលំនឹង
- កម្ពស់តុ៧០០ម.មចាប់ពីបាតខាងក្រោមនិង៧៥០ម.មទៅ៨៥០ម.មពីបាតខាងលើទៅដី គឺអាចប្រើ ប្រាស់បានជាសាកល
- ក្នុងករណីដែលតុនិងកៅអីជាប់គ្នាគេមិនត្រូវក្រឡងចូលអង្គុយទេ មិនតែប៉ុណ្ណោះទីធ្លាជុំវិញត្រូវតែរៀបចំ ឱ្យបានធំសម្រាប់អ្នកមានឈើច្រត់ឧបករណ៍ជំនួយដើរនិងរទេះ
- តុអាហារដែលរឹងមាំនិងមានទទឹងទំហំ២០០០ម.ម អាចងាយស្រួលប្រើប្រាស់សម្រាប់មនុស្សគ្រប់គ្នា ដោយមិនគិតពីអាយុ ទំហំ លទ្ធភាពរបស់គេម្នាក់ៗឡើយ

| ស្តង់ដាចម្ងាយនៃការដាក់កន្លែងអង្គុយពីមួយទៅមួយនៅតាមផ្លូវសាធារណៈ | |
|---|---|
| **សម្រាប់អ្នកប្រើប្រាស់ជា** | **ចម្ងាយគិតជាម៉ែត្រ ( ម )** |
| ជនមានពិការភាពភ្នែក | ១៥០ ម |
| ជនមានពិការភាពប្រើប្រាស់រទេះ | ១៥០ ម |
| ជនមានពិការភាពដើរបានដោយគ្មានឧបករណ៍ជំនួយ | ១០០ ម |
| ជនមានពិការភាពប្រើប្រាស់ឈើច្រត់ឬគ្រឿងជំនួយដើរផ្សេងៗទៀត | ៥០ ម |

### ១.៥. ចំណុចថ្មើរជើងឆ្លងកាត់ (Pedestrian Crossing Points)

❖ ស្តង់ដានិងការណែនាំអំពីចំណុចថ្មើរជើងឆ្លងកាត់

រូបភាព ១.៥.១. ចំណុចថ្មើរជើងឆ្លងកាត់នៅលើផ្លូវមិនទាល់
ចំណោតចុះនៃខឿននិងផ្ទៃពណ៌ក្រហមនៅត្រង់ចំណុចមានភ្លើងចរាចរ



រូបភាព ១.៥.២. ចំណុចថ្មើរជើងឆ្លងកាត់នៅលើផ្លូវទាល់
ចំណោតចុះនៃខឿននិងផ្ទៃពណ៌ក្រហមនៅត្រង់ចំណុចមានភ្លើងចរាចរ



រូបភាព ១.៥.៣. ចំណុចថ្មើរជើងឆ្លងកាត់នៅលើផ្លូវមិនទាល់
ចំណោតចុះនៃខឿននិងផ្ទៃពណ៌ត្នោតនៅត្រង់ចំណុចគ្មានភ្លើងចរាចរ



*រូបភាព ១.៥.៤. ចំណុចថ្មើរជើងឆ្លងកាត់នៅលើផ្លូវទាល់ចំណោតចុះនៃខឿននិងផ្ទៃពណ៌ត្នោតនៅត្រង់ចំណុចគ្មានភ្លើងចរាចរ*



- ការរៀបចំផ្លូវថ្មើរជើងឆ្លងកាត់ ដើម្បីសម្រួលសុវត្ថិភាពនិងឯករាជ្យភាពរបស់មនុស្សទូទៅរួមទាំងជនមានពិការភាព ប្រើប្រាស់និងផ្តល់ដល់អ្នកប្រើប្រាស់មានភាពងាយស្រួល ងាយយល់និងអាចប្រើប្រាស់បាន។ ផ្លូវថ្មើរជើងឆ្លងកាត់អាចនៅគ្រប់ចំណុចទាំងអស់នៃផ្លូវតូច ផ្លូវធំ មហាវិថី ថេរវិថី។ល។
- រៀបចំចំណុចឆ្លងកាត់ដោយមានការពិគ្រោះយោបល់ជាមួយអ្នកជំនាញខាងផ្លូវថ្នល់
- ត្រូវដាក់ចំណុចឆ្លងកាត់ត្រង់ណាដែលមានសុវត្ថិភាពនិងសមរម្យទៅនឹងចំនួនអ្នកប្រើប្រាស់
- ត្រូវធ្វើឱ្យមានកន្លែងទាបខ្ពស់និងបង្ហូរទឹកនៅចំណុចឆ្លងកាត់នៅគ្រប់កន្លែងដែលត្រូវឆ្លងកាត់
- ធានាថាចំណុចឆ្លងកាត់មានចំណោតខឿនដូចក្នុងរូបខាងលើ
- ត្រូវធានាថាទទឹងចំណុចឆ្លងកាត់ទំហំ១២០០ម.មនៅផ្នែកខាងក្រោយផ្លូវ
- ធានាថាចំណុចឆ្លងកាត់អាចហូរទឹកបានស្រួលគឺចំណោតត្រូវធ្វើឡើងក្នុងកម្រិត១/៥០




## ១.៦. ផ្ទៃបាតនៃផ្លូវថ្មើរជើងដែលប៉ះអាចដឹងបាន (Tactile Paving Surfaces)





❖ ស្តង់ដានិងការណែនាំអំពីផ្ទៃបាតនៃផ្លូវថ្មើរជើងដែលប៉ះអាចដឹងបាន

- គ្រប់ផ្លូវថ្មើរជើង ( ទាំងខាងក្នុងនិងខាងក្រៅ ) ផ្លូវច្រករបៀង ( ទាំងខាងក្នុងនិងខាងក្រៅ ) ជម្រាលខាងក្រៅ ជម្រាលខាងក្នុង ជម្រាលចល័តនិងចំណោតត្រូវរៀបឥដ្ឋពណ៌សម្រាប់ជនមានពិការភាពភ្នែក



ឥដ្ឋសម្គាល់ការធ្វើដំណើរទៅមុខត្រង់



ឥដ្ឋសម្គាល់ការធ្វើដំណើរត្រូវឈប់ឬដល់ទី

- ផ្លូវសម្រាប់ជនមានពិការភាពភ្នែកខាងលើនេះត្រូវប្រើពណ៌ដិត (អ្វីក៏បាន )តែត្រូវផ្ទុយពីពណ៌ផ្ទៃផ្លូវ
- ត្រូវប្រើផ្ទៃបាតនៃផ្លូវថ្មើរជើងដែលប៉ះអាចដឹងបានបន្ទាប់ពីពិគ្រោះយោបល់ជាមួយជនមានពិការភាពខ្សោយគំហើញនិងពិការភ្នែក
- ត្រូវប្រើផ្ទៃបាតនៃផ្លូវថ្មើរជើងដែលប៉ះអាចដឹងបានឱ្យបានជាប់គ្នានិងតាមការណែនាំ
- ត្រូវប្រើផ្ទៃបាតនៃផ្លូវថ្មើរជើងពកៗដែលប៉ះអាចដឹងបានដើម្បីប្រាប់ថាគ្មានខឿនទេ
- ត្រូវប្រើផ្ទៃបាតនៃផ្លូវថ្មើរជើងពកៗ ដែលប៉ះអាចដឹងបានពណ៌ក្រហមនៅកន្លែងឆ្លងកាត់ដែលមានភ្លើងសញ្ញាចរាចរ
- ត្រូវប្រើផ្ទៃបាតនៃផ្លូវថ្មើរជើងពកៗ ដែលប៉ះអាចដឹងបានពណ៌ត្នោតនៅកន្លែងឆ្លងកាត់ដែលមិនមានភ្លើងសញ្ញាចរាចរ
- ផ្លូវផ្ទៃបាតជាប្រភេទបន្ទាត់ បង្ហាញពីសញ្ញាផ្លូវដែលត្រូវធ្វើដំណើរទៅមុខត្រង់រហូត
- ផ្លូវផ្ទៃបាតជាប្រភេទពកមូលៗ បង្ហាញពីសញ្ញាផ្លូវមុនពេលបត់ឆ្វេងឬស្តាំមុនដល់ទីឬមានអ្វីពីមុខ
- ផ្លូវផ្ទៃបាតជាប្រភេទពកៗត្រូវមានប្រវែង៣០០ម.ម ហើយត្រូវដាក់គំលាត៣០០ម.មមុននិងក្រោយ ច្រកផ្លូវចូល ជណ្តើរនិងជម្រាល
- ផ្លូវផ្ទៃបាតជាប្រភេទបន្ទាត់ដែលមានប្រវែង៣០០ម.ម ត្រូវដាក់នៅពេញប្រវែងច្រកផ្លូវខាងក្រៅជណ្តើរនិងជម្រាល។ ប្រសិនបើមិនមានកម្រាលជាផ្លូវនោះទេឬក៏ថ្លៃពេកគេអាចបង្កើតជាស៊ុមឈើឬស៊ុមដែក ហើយប្រើសម្រាប់ជាពុម្ពសង្កត់លើស៊ីម៉ង់ត៍រួចលាបពណ៌ទៅតាមតម្រូវការ
- កម្ពស់ឬកម្រាស់នៃផ្លូវផ្ទៃបាតជាបន្ទាត់និងគំនូសឆ្នូតៗចំណុចតូចៗត្រូវមានកម្ពស់ខ្ពស់បំផុត គឺត្រឹមតែ ៥ម.ម។ ប្រសិនបើប្រើកម្ពស់ខ្ពស់ជាង

នេះនឹងបណ្តាលឱ្យជំពប់ដែលបណ្តាលឱ្យមានគ្រោះថ្នាក់

- ចំពោះជនមានពិការភាពនិងជនដែលមិនពិការ






## ១.៦.១. ផ្ទៃពកនៅត្រង់ផ្លូវឆ្លងកាត់

(Blister Surface for Pedestrian Crossing Points)





❖ ស្តង់ដានិងការណែនាំអំពីផ្ទៃពកនៅត្រង់ផ្លូវឆ្លងកាត់



*រូបភាព ១.៦.១.១. គំរូអំពីឥដ្ឋពណ៌ក្រហម សម្រាប់រៀបនៅចំណុចឆ្លងកាត់មានភ្លើងចរាចរ*



- ផ្លូវឆ្លងកាត់ដែលមានឥដ្ឋពណ៌សម្រាប់ជនមានពិការភាពភ្នែកដើរមានផ្ទៃពកៗគឺត្រូវបានប្រើប្រាស់ដើម្បីជាសញ្ញា
ប្រាប់អ្នកថ្មើរជើងដែលមានកម្សោយគំហើញ ជាពិសេសនៅចុងផ្លូវនិងចំណុចចាប់ផ្តើម នៃផ្លូវមួយទៀតនៅកន្លែងដែលគ្មានខឿន
- ផ្លូវនេះត្រូវបានប្រើប្រាស់នៅចំណុចឆ្លងថ្នល់ កន្លែងចុះ/ឡើងខឿននិងនៅតាមដងផ្លូវសម្រាប់ថ្មើរជើង ខ្លះៗដែលមានការបែងចែកគ្នារវាងផ្លូវថ្មើរជើង និងផ្លូវម៉ូតូដោយប្រើពណ៌និងសម្ភារៈផ្សេងគ្នា
- នៅត្រង់ចំណុចឆ្លងកាត់ដែលមានភ្លើងចរាចរការដាក់ឥដ្ឋពណ៌មានកំពកមូលៗ អាចជាការនាំផ្លូវដល់ អ្នកខ្សោយគំហើញទៅរកចំណុចឆ្លងថ្នល់
- រូបភាពខាងក្រោមបញ្ជាក់ពីផ្ទៃពកមូលៗនៃឥដ្ឋពណ៌



*រូបភាព ១.៦.១.២. បង្ហាញអំពីពណ៌និងទំហំនៃចំណុចពកមូល*

- ផ្ទៃកំពកមូលៗពណ៌ក្រហមត្រូវដាក់តែនៅត្រង់ផ្លូវឆ្លងកាត់ដែលមានភ្លើងចរាចរតែប៉ុណ្ណោះ
- ផ្ទៃកំពកមូលៗពណ៌ត្នោតគួរត្រូវបានដាក់នៅត្រង់ផ្លូវឆ្លងកាត់ដែលគ្មានភ្លើងចរាចរ
- នៅគ្រប់កន្លែងទាំងអស់ផ្ទៃនៃផ្លូវត្រូវមានពណ៌ផ្ទុយពីឥដ្ឋពណ៌ពកមូលៗជាសញ្ញាជួយដល់ជនមាន ពិការភាពភ្នែកក្នុងការធ្វើដំណើរ
- នៅត្រង់ផ្លូវឆ្លងកាត់ដែលមានភ្លើងចរាចរ ពេលមានចំណោតខឿនដែលស្របតាមផ្លូវយានយន្តឥដ្ឋពណ៌ ពកមូលៗពណ៌ក្រហមត្រូវដាក់ឱ្យមានប្រវែង១២០០ម.មនិងទទឹងពេញផ្លូវទាំងអស់ត្រង់ចំណោតឡើង ចុះខឿន
- នៅត្រង់ផ្លូវឆ្លងកាត់ដែលមានភ្លើងចរាចរឥដ្ឋពណ៌ក្រហម ត្រូវដាក់ឱ្យ

លើសមកខាងចំហៀងទំហំ ប្រហែល៨០០ម.ម

- នៅត្រង់ផ្លូវឆ្លងកាត់ដែលមានភ្លើងចរាចរ ផ្លូវបំបែកនៃផ្ទៃតដ្ឋពណ៌ពកមូលៗមានទទឹង១២០០ម.ម ត្រូវ ពង្រីកចេញពីចំណោតខឿនទៅក្រោយរហូតដល់ផ្នែកខាងក្រោយនៃផ្លូវឬរហូតដល់បន្ទាត់អគារ ដើម្បីអាចនាំអ្នកដំណើរដល់ចំណុចឆ្លងកាត់
- នៅត្រង់ផ្លូវឆ្លងកាត់ដែលគ្មានភ្លើងចរាចរ ផ្ទៃនៃតដ្ឋពណ៌ត្នោតត្រូវពង្រីកដល់ពេញទទឹងផ្លូវនៃចំណោត ចុះឡើងខឿន
- ជម្រៅនៃផ្ទៃតដ្ឋពណ៌ពកមូលៗគឺអាស្រ័យលើថាតើផ្លូវថ្មើរជើងស្របគ្នាជាមួយផ្លូវយានយន្តឬទេ
- ប្រសិនបើផ្លូវថ្មើរជើងស្របគ្នាជាមួយផ្លូវយានយន្តផ្ទៃនៃតដ្ឋពណ៌ត្រូវតែមានជម្រៅ១២០០ម.ម ប៉ុន្តែ ប្រសិនបើផ្លូវឆ្លងកាត់មិនស្របគ្នាជាមួយផ្លូវយានយន្តទេ ផ្ទៃតដ្ឋពណ៌គួរមានទទឹងតែ៤០០ម.ម



*រូបភាព ១.៦.១.៣. គំរូអំពីផ្ទៃពណ៌ត្នោតនៅត្រង់ផ្លូវឆ្លងកាត់គ្មានភ្លើងចរាចរ*



*រូបភាព ១.៦.១.៤. ជនមានពិការភាពភ្នែកកំពុងប្រើឈើច្រត់នាំផ្លូវនៅលើផ្ទៃពណ៌ពកមូល*

*រូបភាព ១.៦.១.៥. គំរូអំពីផ្ទៃផ្លូវរៀបឥដ្ឋពកមូលៗពណ៌ក្រហម*





- កំពកខាងចុងនៃឥដ្ឋពណ៌ពកមូលៗនីមួយៗ ត្រូវបានប្រើប្រាស់ដើម្បីប្រាប់ពីគែមនៅតាមខឿននៃ ចំណតរថភ្លើងនិងអាចបញ្ជាក់ថាចុងផ្លូវផងដែរ
- គួរកត់សម្គាល់ថាកំពកខាងចុងនៃឥដ្ឋពណ៌ពកមូលៗនីមួយៗមានសារៈសំខាន់ណាស់ បន្ទាត់នៃឥដ្ឋ ពណ៌នោះត្រូវតែស្របគ្នាជាមួយគែមនៃខឿននិងត្រូវតែដាក់ប្រហែល៥០០ម.មខាងក្រោយឆ្ងាយពីគែម



*រូបភាព ១.៦.១.៦. គំរូអំពីឥដ្ឋពណ៌ត្នោតពកមូលៗនិងឆ្នូត*

- នៅផ្នែកខាងក្រោយគែមនៃផ្ទៃឥដ្ឋពណ៌ទាំងអស់ ទោះនៅផ្លូវឆ្លងដែលមានភ្លើងសញ្ញាចរាចរឬគ្មាន ត្រូវតែកែងគ្នាជាមួយបន្ទាត់នៃផ្លូវយានយន្តដែលអាចឱ្យសម្រួលខ្លួនទៅនឹងគែមខាងក្រោយនៃផ្លូវនិងទិសដៅនៃផ្លូវឆ្លង

## ១.៦.២. ផ្លូវដែលមានឥដ្ឋពណ៌ឆ្នូតៗសម្រាប់ការប្រុងប្រយ័ត្ន

(Corduroy Paving for Hazards)





❖ ស្តង់ដានិងការណែនាំអំពីផ្លូវដែលមានឥដ្ឋពណ៌ឆ្នូតៗសម្រាប់ការប្រុងប្រយ័ត្ន

- ផ្លូវដើរមានផ្ទៃឆ្នូតៗ គឺប្រើសម្រាប់ជាសញ្ញាប្រាប់ដល់អ្នកថ្មើរជើងថាគេអាចនៅជិតឬទៅជិតដល់កន្លែង ដែលមានគ្រោះថ្នាក់ដូចនេះត្រូវដើរដោយប្រុងប្រយ័ត្ន
- វាត្រូវបានកំណត់ពីកន្លែងដែលត្រូវប្រយ័ត្ននៅខាងមុខមានដូចជា ជណ្តើរ ដែលផ្លូវធម្មតាឬផ្លូវរៀបឥដ្ឋ ផ្សើរួមគ្នានៅកន្លែងឆ្លងកាត់និងនៅផ្នែកខាងក្រោមនៃជម្រាលឆ្ពោះទៅរកផ្លូវថ្នល់
- ផ្លូវដែលរៀបឥដ្ឋមានផ្ទៃឆ្នូតៗ មិនគួរត្រូវបានប្រើប្រាស់នៅលើជម្រាលកន្លែងឡើងរថយន្តក្រុងឬដើម្បីកុំឱ្យមានឧបសគ្គក្នុងការដំណើរការ
- ឥដ្ឋមានផ្ទៃឆ្នូតៗដែលក្រាលត្រូវមានពណ៌ផ្ទុយពីផ្ទៃផ្លូវដើរ ប៉ុន្តែមិនគួរដាក់ពណ៌ក្រហមនោះទេចំពោះ ផ្លូវឆ្លងកាត់
- ចំពោះរបាំងឥដ្ឋមានផ្ទៃឆ្នូតៗគួរតែនៅគ្រប់ទិសដៅនៃការធ្វើដំណើរនិងគ្រប់ស្ថានភាពទាំងអស់

*រូបភាព ១.៦.២.១. គំរូអំពីផ្ទៃប្រាប់សញ្ញានៅផ្នែកខាងនៃកាំជណ្ដើរ*



- សញ្ញាសម្គាល់គ្រោះថ្នាក់ដាក់នៅពាក់កណ្ដាលកំណាត់ផ្លូវដែលស្ថិតនៅកម្ពស់៦ម.មនៃកម្រាលផ្លូវ ដើម្បីសម្គាល់កន្លែងមានគ្រោះថ្នាក់ដូចជាបាត/កម្ពស់នៃកាំជណ្ដើរនិងនៅតាមថ្នល់ត្រូវដាក់ឱ្យស្របគ្នា
- របារដែលដាក់នៅតាមផ្លូវនីមួយៗត្រូវស្របគ្នាជានិច្ច

*រូបភាព ១.៦.២.២. គំរូអំពីសញ្ញាគ្រោះថ្នាក់និងផ្លូវយានជំនិះ*



*រូបភាព ១.៦.២.៣. ផ្ទៃផ្លូវពកនិងឆ្នូតស្របតាមបណ្តោយផ្លូវយានជំនិះ(រូបខាងស្តាំ)និងផ្លូវថ្មើជើង(រូបខាងឆ្វេង)*





- សញ្ញាប្រាប់គ្រោះថ្នាក់នៅតាមកាំជណ្តើរ ត្រូវដាក់ពេញប្រវែងទទឹងនៃកាំនីមួយៗយ៉ាងហោចណាស់ ៤០០ម.ម ពីផ្នែកម្ខាងតាមដែលអាចធ្វើទៅបាន ទោះបីជាយ៉ាងណាការក្រាលឥដ្ឋឆ្នូតៗមិនត្រូវដាក់នៅជាប់ជម្រាលនោះទេ
- ផ្លូវដែលមានឥដ្ឋពណ៌ឆ្នូតៗ គួរដាក់នៅប្រវែង៤០០ម.មពីជណ្តើរទី១និងពន្លាតជម្រៅ៨០០ម.ម ប្រសិន បើជណ្តើរមិនមានការកាច់បត់ឬ៤០០ម.ម ប្រសិនបើការរចនានោះបានការបង្វែររហូតដល់៩០ដឺក្រេ
- ខ្នាតទាំងនេះអាចធ្វើឱ្យមនុស្សយល់ដឹងពីគ្រោះថ្នាក់និងផ្តល់ពេលវេលាគ្រប់គ្រាន់

## ១.៧. ច្រកចូល (Entrances)



*រូបភាព ១.៧.១. គំរូអំពីដំបូលច្រកចូលអគារ*

❖ ស្តង់ដានិងការណែនាំអំពីច្រកចូល

- ច្រកចូលត្រូវមើលឃើញច្បាស់និងមានភាពលេចធ្លោ
- ត្រូវប្រាកដថារាល់ផ្លូវចូលនៅតាមអគារថ្មីៗត្រូវបានរចនាឡើងជាសាកល
- ផ្លូវចេញ/ចូលអគារត្រូវរចនាឡើងជាសាកល
- ត្រូវមានទំហំគ្រប់គ្រាន់ចំពោះផ្លូវចេញ/ចូលទាំងក្នុងនិងក្រៅទ្វារ
- កន្លែងចតនៅខាងក្រៅផ្លូវចូលត្រូវមានទំហំទូលាយ២៤៤០ម.ម x ២៤៤០ម.ម
- នៅមុខទ្វារចេញ/ចូលត្រូវរៀបចំឱ្យទូលាយដើម្បីអាចឈប់នៅខាងមុខបាន
- ទំនប់ខណ្ឌមាត់ទ្វារមិនត្រូវឱ្យមានកម្រាស់លើសពី១០ម.ម នោះទេដែលធ្វើជាជម្រាល
- ត្រូវទុកទំហំ៦០០ម.ម ចំពោះផ្នែកម្ខាងៗនៃទ្វារ
- ច្រកចូលអគារដែលមនុស្សគ្រប់គ្នាអាចប្រើបាន គួរតែធំនិងភ្ជាប់ពីផ្លូវផ្សេងៗឱ្យបានសមស្របដូចជាពី ផ្លូវថ្នល់មកអគារឬពីចំណតមកអគារហើយត្រូវមានសញ្ញាឬពណ៌ដើម្បីងាយរក
- ត្រូវរក្សាកន្លែងទំនេរនៅមុខច្រកចូលយ៉ាងតិច១៤០០ម.ម x ១៤០០ម.ម សម្រាប់អ្នកប្រើរទេះ

### ១.៧.១. ផ្លូវចូលទៅកាន់កន្លែងទទួលភ្ញៀវ (Entrance Lobbies)



*រូបភាព ១.៧.១.១. គំរូអំពីទ្វារបើកចូលកន្លែងទទួលភ្ញៀវ*



*រូបភាព ១.៧.១.២. គំរូអំពីទ្វារចូលដែលបិទបើកទៅចំហៀងដោយស្វ័យប្រវត្តិនៅកន្លែងទទួលភ្ញៀវ*



*រូបភាព ១.៧.១.៣. គំរូអំពីច្រកចូលកន្លែងទទួលភ្ញៀវដែលមានកម្រាល*

❖ ស្តង់ដានិងការណែនាំអំពីផ្លូវចូលទៅកាន់កន្លែងទទួលភ្ញៀវ

*រូបភាព ១.៧.១.៤. គំរូខ្នាតនៃទីធ្លាបរិវេណកន្លែងទទួលភ្ញៀវ*




__ប្រភព:__ ខ្នាតទាំងអស់គិតជា មម

- ផ្លូវចូលទៅកាន់កន្លែងរង់ចាំត្រូវនៅទីតាំងណាដែលសំខាន់
- ខាងក្នុងនិងខាងក្រៅទ្វារត្រូវងាយស្រួលប្រើនិងចេញចូលបានយ៉ាងងាយ
- ទ្វារទាញត្រូវធ្វើឡើងនៅទំហំចន្លោះ១៦០០ម.មទៅ១៩០០ម.ម
- នៅតាមផ្លូវទៅកាន់កន្លែងរង់ចាំមិនត្រូវឱ្យមានការរាំងឬដាក់អ្វីបាំងនោះទេ
- ត្រូវដាក់ភ្លើងបំភ្លឺទាំងក្នុងនិងក្រៅពីកន្លែងមួយទៅកាន់កន្លែងមួយ
- កញ្ចក់ឬទ្វារត្រូវរំលេចពណ៌ច្បាស់ៗបង្ការគ្រោះថ្នាក់

### ១.៧.២. កន្លែងទទួលភ្ញៀវនិងកន្លែងរង់ចាំ (Reception and Waiting Areas)



*រូបភាព ១.៧.២.១. គំរូអំពីតុទទួលភ្ញៀវដែលមានពីរថ្នាក់*



*រូបភាព ១.៧.២.២. ជម្រើសផ្សេងទៀតនៃតុទទួលភ្ញៀវដែលមានពីរថ្នាក់*



*រូបភាព ១.៧.២.៣. គំរូអំពីការដាក់ស្លាកសញ្ញាមានផ្តល់សេវាឧបករណ៍ជំនួយការស្តាប់នៅលើតុទទួលភ្ញៀវ*




*រូបភាព ១.៧.២.៤. គំរូអំពីស្លាកសញ្ញាឧបករណ៍ជំនួយការស្តាប់*



*រូបភាព ១.៧.២.៥. គំរូអំពីតុទទួលភ្ញៀវមានពន្លឺធម្មតា*



*រូបភាព ១.៧.២.៦. គំរូអំពីកន្លែងរង់ចាំ*

ជាធម្មតាកៅអីដែលចាប់ជាប់គ្នាច្រើនមានការលំបាកក្នុងការរៀបចំ ព្រោះវាធ្ងន់ដូច្នេះការដាក់កៅអីដាច់ៗ ពីគ្នាគឺជាជម្រើសប្រសើរជាង។



*រូបភាព ១.៧.២.៧. គំរូអំពីទូរស័ព្ទបង់ប្រាក់ដែលមានពីរថ្នាក់*

❖ ស្តង់ដានិងការណែនាំអំពីកន្លែងទទួលភ្ញៀវនិងកន្លែងរង់ចាំ

- កន្លែងទទួលភ្ញៀវនិងកន្លែងរង់ចាំត្រូវតែមើលឃើញនិងដឹងបានយ៉ាងងាយស្រួល
- តុទទួលភ្ញៀវត្រូវមើលឃើញច្បាស់ដោយស្ថិតនៅចំច្រកចូល
- តុទទួលភ្ញៀវត្រូវមានលក្ខណៈជាតុរិល
- ដាក់ភ្លើងបំភ្លឺច្បាស់ៗដើម្បីបង្កើនប្រសិទ្ធភាពក្នុងការទំនាក់ទំនង
- ជៀសវាងកុំឱ្យចាំងពន្លឺដែលបណ្តាលឱ្យពិបាកក្នុងការគ្រប់គ្រង
- ចំពោះតុទទួលភ្ញៀវត្រូវដាក់នៅជាន់ណាដែលរឹងមាំនិងមិនរអិល
- ដាក់កៅអីណាដែលងាយស្រួលអង្គុយមានទំហំធំទូលាយសម្រាប់អ្នកជិះរទេះ ឪពុកម្តាយដែលរុញរទេះ កូនក្មេង អ្នកដែលខ្សោយគំហើញនិងអ្នកដែលប្រើប្រាស់ឈើច្រត់
- ត្រូវសង់បង្កន់ឱ្យនៅជិតកន្លែងទទួលភ្ញៀវ
- ត្រូវលាបពណ៌នៅកន្លែងណាដែលសំខាន់ៗដោយមានការរចនាល្អ មានស្លាកសញ្ញាច្បាស់ៗ
- ទូរស័ព្ទលើតុដែលយើងដាក់ឱ្យប្រើប្រាស់រួមគ្នាត្រូវងាយស្រួលប្រើប្រាស់

### ១.៧.៣. កន្លែងតម្រង់ជួរនិងឧបសគ្គបណ្តោះអាសន្ន

(Queuing Areas and Temporary Barriers)



*រូបភាព ១.៧.៣.១. គំរូអំពីការដាក់បង្គោលមានខ្សែសម្រាប់មនុស្សតម្រង់ជួរ*

❖ ស្តង់ដានិងការណែនាំអំពីកន្លែងតម្រង់ជួរនិងឧបសគ្គបណ្តោះអាសន្ន

- នៅតាមជាន់នីមួយៗកន្លែងតម្រង់ជួរនិងឧបសគ្គបណ្តោះអាសន្នត្រូវធ្វើឡើងឱ្យបានល្អប្រសើរដោយមានទទឹងចំហៀងប្រវែង១១០០ម.ម

- កន្លែងតម្រង់ជួរនិងឧបសគ្គបណ្ដោះអាសន្នត្រូវមានបង្កាន់ដៃរឹងមាំនិងមានពណ៌ផ្ទុយពីផ្ទៃដើមរបស់វា
- កំណត់លើឧបករណ៍ណាដែលមានឧបសគ្គក្នុងការប្រើប្រាស់
- ត្រូវដាក់កៅអីនៅតាមកន្លែងតម្រង់ជួរ

## ១.៨. ច្រកផ្លូវ (Horizontal Circulation)



*រូបភាព ១.៨.១. គំរូអំពីផ្ទៃផ្ទួតៗសម្រាប់ជនមានពិការភាពភ្នែកនៅចំណុចចាប់ផ្ដើមនិងចុងបញ្ចប់នៃជណ្ដើរ*

❖ ស្តង់ដានិងការណែនាំអំពីច្រកផ្លូវ

- ច្រកផ្លូវត្រូវមានប្លង់ឱ្យត្រឹមត្រូវតាមដែលអាចធ្វើទៅបាន
- ជៀសវាងនៅការផ្លាស់ប្ដូរប្លង់ណាមួយនៅតាមច្រកផ្លូវ
- រក្សាផ្លូវចូលដោយការប្រុងប្រយ័ត្នបំផុតនិងរក្សាមិនឱ្យមានអ្វីជាឧបសគ្គឡើយ
- ច្រកផ្លូវត្រូវមានប្លង់បង្ហាញឱ្យច្បាស់លាស់ដែលងាយស្រួលរក
- បង្កាន់ដៃដែលនៅសងខាងផ្លូវដើរត្រូវមានកៅអីដាក់នៅចន្លោះស្មើៗគ្នា

### ១.៨.១. ច្រករបៀង (Corridors)

*រូបភាព ១.៨.១.១. គំរូអំពីច្រករបៀងនៅក្នុងសាកលវិទ្យាល័យ*







❖ ស្តង់ដានិងការណែនាំអំពីច្រករបៀង

*រូបភាព ១.៨.១.២. គំរូខ្នាតអំពីតម្រូវការទីធ្លាសម្រាប់ច្រករបៀង*




- ផ្លូវរបៀងនៅតាមអគារសាធារណៈទំហំទទឹងទូលាយ២០០០ម.ម
- ផ្លូវរបៀងនៅតាមអគារផ្សេងៗទំហំទទឹងទូលាយ១៥០០ម.ម
- កន្លែងដែលមានទំហំបណ្តោយ២០០០ម.ម x ទទឹង១៨០០ម.ម ផ្លូវរបៀងត្រូវមានទទឹងតិចជាង ១៨០០ម.ម




- ក្នុងករណីចង់បង្រួមផ្លូវឱ្យតូចទទឹងមិនត្រូវតិចជាង១២០០ម.មនោះទេ
- កន្លែងសម្រាកត្រូវធ្វើនៅជិតជញ្ជាំងតាមដែលអាចធ្វើទៅបាន
- កន្លែងណាដែលលយចេញក៏ដោយត្រូវធ្វើឱ្យមានទទឹងគ្រប់គ្រាន់
- ត្រូវដាក់បង្កាន់ដៃចំពោះប្រភេទអគារដែលមានផ្លូវរបៀងបណ្ដោយ២០ម៉ែត្រ
- ត្រូវដាក់កៅអីនៅតាមផ្លូវរបៀងដែលមានបណ្ដោយមិនវែងជាង២០ម៉ែត្រនោះទេ
- ផ្លូវរបៀងត្រូវមានទំហំទូលាយគ្រប់គ្រាន់ដើម្បីសម្រួលការធ្វើដំណើរទៅមក
- ផ្លូវត្រូវមានទទឹងទំហំពី១៤០០ម.មទៅ១៩០០ម.ម បើមានមនុស្សចេញចូលញឹកញាប់
- ខាងលើផ្លូវកម្ពស់២១០០ម.មត្រូវតែទំនេរនិងនៅតាមដងផ្លូវមិនត្រូវដាក់អីនាំឱ្យរំខាន



*រូបភាព ១.៨.១.៣. គំរូផ្លូវបៀងនៅអគារជាន់ខាងលើដែលរទេះ២អាចចៀសគ្នាបាន*

### ១.៨.២. កន្លែងរង់ចាំខាងក្នុង (Internal Lobbies)

❖ ស្តង់ដានិងការណែនាំអំពីកន្លែងរង់ចាំខាងក្នុង

- កន្លែងរង់ចាំខាងក្នុងអាចធ្វើឡើងបានតែក្នុងករណីណាដែលចាំបាច់
- ការធ្វើកន្លែងរង់ចាំគឺស្របតាមខ្នាតនៅក្នុងរូបខាងក្រោមនេះ

*រូបភាព ១.៨.២.១. គំរូខ្នាតអំពីតម្រូវការទីធ្លាសម្រាប់កន្លែងរង់ចាំ*




*ចំណាំ:* ខ្នាតទាំងអស់គិតជា មម

- ផ្ទៃដែលធ្វើឡើងត្រូវរឹងមាំ
- ចំណុចប្រសព្វនៃចុងបញ្ចប់កម្រាលនីមួយៗត្រូវមានទំនប់ខណ្ឌកម្ពស់សមរម្យ

### ១.៩. ទ្វារ (Doors)




❖ ស្តង់ដានិងការណែនាំអំពីទ្វារ

- ទ្វារគឺជាច្រកមានសន្ទះឬរនាំងសម្រាប់បើកបិទចេញចូលដូចជា ទ្វារផ្ទះ ទ្វាររបង ទ្វារបន្ទប់ ជាដើម
- ទ្វារមានច្រើនប្រភេទដូចជា ទ្វារប្រអប់ ទ្វាររូតចុះឡើង ទ្វាររូតឆ្វេងស្តាំ ទ្វារបន្ទះ ទ្វារបើកចេញ ទ្វារបើកចូល។ល។ ដែលអាចប្រើប្រាស់ដោយដៃនិងដោយប្រព័ន្ធស្វ័យប្រវត្តិ
- ទ្វារមួយសន្លឹកមានទទឹងតូចបំផុត៩០០ម.មនិងមានកម្ពស់យ៉ាងតិច ២០០០ម.ម
- រាល់ទ្វាររបងចូលអគារដែលអាចប្រើប្រាស់បានទាំងអស់គ្នាគួរតែមានទំហំធំសមស្របអាស្រ័យទៅតាមភាពចាំបាច់នៃការប្រើប្រាស់អគារនោះ
- ចំពោះទ្វារដែលបិទបើកដោយដៃមិនត្រូវតឹងពេកទេការកកិតនេះអាស្រ័យដោយត្រចៀកទ្វារនិងទំហំនៃការកកិតរវាងទ្វារនិងផ្ទៃកម្រាល

- ចំពោះទ្វារដែលបិទដោយស្វ័យប្រវត្តិ ត្រូវធានាថាប្រព័ន្ធបញ្ជាបិទដំណើរការបានល្អ
- សម្រាប់ទ្វារដែលមានច្រើនសន្លឹក មួយសន្លឹកត្រូវមានទំហំយ៉ាងតិច ៩០០ម.ម
- គ្រប់បន្ទប់ទាំងអស់ (បន្ទប់ទទួលភ្ញៀវ បន្ទប់ការិយាល័យ បន្ទប់គេង បន្ទប់ទទួលទានអាហារ
- បន្ទប់ទឹក។ល។) មិនត្រូវធ្វើទំនប់ខណ្ឌមាត់ទ្វារឡើយ
- ប្រសិនបើចាំបាច់ត្រូវរៀបចំឱ្យមានទំនប់ខណ្ឌមាត់ទ្វារកម្ពស់ខ្ពស់បំផុត ១២ម.ម
- រាល់ទំនប់ខណ្ឌមាត់ទ្វារដែលខ្ពស់ជាង១២ម.ម គួរមានអមនៅជម្រាលសងខាង( តាមស្តង់ដាជម្រាល )ដើម្បីឱ្យគេអាចផ្លាស់ទីឆ្លងកាត់បានដោយមិនមានអ្វីទាក់/ឬរំខាន
- គ្រប់ទ្វារទាំងអស់មិនត្រូវធ្វើទំនប់នៅផ្ទៃខាងក្រោមដែលរំខានដល់ការចេញចូលដូចជាជំពប់ជើងឬរទេះឡើងមិនរួច
- ប្រសិនបើមិនអាចជៀសវាងបានទំនប់នោះអាចធ្វើបានតែកម្ពស់ត្រឹម ១២ម.ម ក្នុងករណីខ្ពស់ជាង១២ម.ម ត្រូវធ្វើជាជម្រាល







### ១.៩.១. ទ្វារចូល (Entrance Doors)



*រូបភាព ១.៩.១.១. គំរូអំពីទ្វារចូល*



*រូបភាព ១.៩.១.២. គំរូអំពីការបិទពណ៌នៅទ្វារកញ្ចក់ជៀសវាងការច្រឡំ*

❖ ស្តង់ដានិងការណែនាំអំពីទ្វារចូល

*រូបភាព ១.៩.១.៣. ប្រភេទទ្វារបើកផ្សេងៗ*



*រូបភាព ១.៩.១.៤. ផ្ទាំងដែលអាចមើលខាងក្នុងនិងខាងក្រៅបាន*



*រូបភាព ១.៩.១.៥. ការបិទពណ៌នៅលើកញ្ចក់ដើម្បីសុវត្ថិភាព*




- នៅតាមអគារថ្មីៗទ្វារចូលត្រូវមានទំហំ១០០០ម.ម
- នៅតាមទ្វារចូលរបស់អគារមិនត្រូវតូចជាងទំហំ៨៥០ម.ម
- ត្រូវមានទំហំគ្រប់គ្រាន់នៅសងខាងទ្វារចូល

*រូបភាព ១.៩.១.៦. គំរូទំហំខ្នាតទីធ្លាដែលគ្មានឧបសគ្គនៅតាមច្រកទ្វារខាងក្នុង*



- ទ្វារម្ខាងៗត្រូវមានទំហំទូលាយ៩០០ម.ម
- ត្រូវបំពាក់បន្ទះដែលអាចជួយសម្រាប់អ្នកមានបញ្ហាគំហើញនៅគ្រប់ផ្លូវចូលអគារនិងទ្វារចូលកន្លែងរង់ចាំ
- ដាក់ពណ៌ពីរផ្សេងគ្នាចំពោះទ្វារកញ្ចក់ទាំងអស់
- ត្រូវធានាថាទ្វារចូលត្រូវមានពណ៌ផ្ទុយពីជញ្ជាំងឬកញ្ចក់
- ត្រូវដាក់ពណ៌ឆ្នូតៗនៅលយចេញនៅគ្រប់ជ្រុងទាំងអស់នៃទ្វារកញ្ចក់ដែលគ្មានស៊ុម
- ត្រូវមានការការពារចំពោះទ្វារកញ្ចក់ដែលទាបជាង៤០០ម.ម

### ១.៩.២. ទ្វារវិល (Revolving Doors)

*រូបភាព ១.៩.២.១. គំរូអំពីទ្វារវិលដែលមានគ្រទៀកស្វ័យប្រវត្តិនៅសងខាង*





❖ ស្តង់ដានិងការណែនាំអំពីទ្វារវិល

- ជៀសវាងការប្រើប្រាស់ទ្វារវិលនៅទីតាំងណាដែលមិនសមស្រប
- ក្នុងករណីណាដែលមានទ្វារវិលត្រូវមានទ្វារទាញឬទ្វាររុញអមជាមួយផងជាជម្រើស
- ត្រូវផ្លាស់ប្តូរទ្វារវិលចេញទោះបីវិលដោយរុញដៃឬស្វ័យប្រវត្តិនិងជំនួសវិញដោយទ្វារដែលងាយ ស្រួល បំផុតសម្រាប់មនុស្សគ្រប់ៗគ្នាអាចប្រើបាន

### ១.៩.៣. ទ្វារចូលដែលមានគន្លាក់ (Turnstile)




*រូបភាព ១.៩.៣.១. គំរូអំពីទ្វារចូលមានគន្លាក់ដែលអមដោយច្រកចូលរទេះ*

❖ ស្តង់ដានិងការណែនាំអំពីទ្វារចូលដែលមានគន្លាក់

- ទីតាំងណាដែលមានច្រកទ្វារត្រូវបំពាក់ទ្វារចូលដែលមានគន្លាក់
- ច្រកទ្វារចូលដែលមានទទឹងទូលាយ៩៥០ម.ម
- ច្រកទ្វារចូលត្រូវមានពណ៌ផ្ទុយពីពណ៌ដែលនៅជុំវិញនោះហើយច្បាស់

### ១.៩.៤. ទ្វារខាងក្នុង (Internal Doors)



*រូបភាព ១.៩.៤.១. ទ្វារដែលមានបន្ទះអាចមើលបាន*

❖ ស្តង់ដានិងការណែនាំអំពីទ្វារខាងក្នុង

- ទ្វារខាងក្នុងដែលមានទទឹងសមរម្យគឺ៩០០ម.ម
- ទាំងទ្វារបើកចូលក្នុងនិងបើកចេញក្រៅត្រូវបើកទៅខាងជញ្ជាំង
- ធានាថាទិសដៅដែលត្រូវបើកទ្វារដូចគ្នាទាំងអស់នៅក្នុងអគារទាំងមូល
- ត្រូវធានាថាទ្វារត្រូវមានពណ៌ផ្ទុយពីផ្ទៃជញ្ជាំង
- ត្រូវបំពាក់បន្ទះដែលអាចជួយអ្នកមានបញ្ហាគំហើញនៅតាមទីកន្លែងដែលចាំបាច់

## ១.៩.៥. គ្រឿងផ្សំរបស់ទ្វារ (Door Ironmongery)



### ១.៩.៥.១. ត្រចៀកទ្វារ (Hinges)



❖ ស្តង់ដានិងការណែនាំអំពីគ្រឿងផ្សំរបស់ទ្វារ-ត្រចៀកទ្វារ

- ប្រើប្រាស់ត្រចៀកទ្វារណាដែលបើកបិទមានការកកិតតិច ជៀសវាងប្រើកម្លាំងខ្លាំងប្រឹងបិទបើក
- ត្រូវគិតអំពីត្រចៀកទ្វារណាដែលពិបាកក្នុងការបិទបើក ហើយវាមិនត្រូវគ្នាជាមួយប្រព័ន្ធទ្វារបិទបើកស្វ័យប្រវត្តិ

### ១.៩.៥.២. ដៃទ្វារ គន្លឹះទ្វារនិងសោទ្វារ

### (Handles, Latches and Locks)

❖ ស្តង់ដានិងការណែនាំអំពីដៃទ្វារ គន្លឹះទ្វារនិងសោទ្វារ

*រូបភាព ១.៩.២.១. គ្រឿងផ្សំរបស់ទ្វារ*




- ដៃទ្វារគឺជាវត្ថុចាប់ភ្ជាប់ទៅនឹងទ្វារងាយស្រួលចាប់កាន់បិទបើកនិងប្រើប្រាស់ទ្វារ។ ប្រភេទរូបរាងឬទំហំ នៃវត្ថុដែលយកមកប្រើប្រាស់និងទីកន្លែងដែលចាប់ភ្ជាប់នឹងវត្ថុនោះ មានការប្រែប្រួលទៅតាមគោលបំណងនិងទីកន្លែងនៃទ្វារ
- ត្រូវបំពាក់សោឬដៃទ្វារទាំងអស់ដែលមានរាងជាអក្សរ D ឬអក្សរ L ដើម្បីងាយស្រួលក្នុងការប្រើប្រាស់

- ត្រូវដាក់ដៃទ្វារនៅកម្ពស់ចន្លោះពី៨៥០ម.ម និង១១០០ម.មពីផ្ទៃបាត
- ជៀសវាងប្រើដៃទ្វារកាច់ដោយសារតែវាអាចលំបាកសម្រាប់អ្នកដែលមានការលំបាកក្នុងការប្រើប្រាស់ដៃ
- ប៊ូតុងរុញសម្រាប់ទ្វារស្វ័យប្រវត្តិនិងជណ្តើរយន្តគួរមានកម្ពស់អតិបរមា ១២០០ម.ម
- ទ្វារកញ្ចក់គួរមានសញ្ញាសម្គាល់ដោយប្រើពណ៌ខុសពីពណ៌ទ្វារដាក់នៅកម្ពស់១២០០ម.មពីផ្ទៃបាត
- លាបពណ៌ទ្វារដោយប្រើពណ៌លេចខុសពីជញ្ជាំង ដើម្បីងាយស្រួលសម្គាល់ដល់អ្នកដែលមានកម្សោយ ផ្នែកគំហើញ
- ក្នុងករណីទ្វារបើកឬបិទដោយការទាញឬរុញត្រូវរក្សាកន្លែងទំនេរទំហំចន្លោះពី៤៥០ម.មទៅ៦០០ម.មផុតពីគែមទ្វារ ដើម្បីឱ្យអ្នកដែលប្រើរទេះរុញអាចបង្វិលនិងទៅដល់ដៃទ្វារបាន
- ផ្ទៃឥដ្ឋទំហំ១៥០០ម.ម x ១៥០០ម.មនៅខាងទាញនិង១២០០ម.ម x ១២០០ម.មនៅខាងរុញ
- ក្នុងករណីទ្វារបើកឬបិទដោយការទាញឬរុញត្រូវបំពាក់រនាំងផ្តេកដែលអាចចាប់កាន់បានសម្រាប់ទាញមានប្រវែងយ៉ាងហោចណាស់ ៦០០ម.មនិងកម្ពស់៧០០ម.ម នៅខាងក្នុងនិងខាងក្រៅទ្វារ

### ១.៩.៥.៣. ដៃទ្វារទាញនិងផ្លូវរត់របស់ទ្វារ (Pull Handles and Rails)





❖ ស្តង់ដានិងការណែនាំអំពីដៃទ្វារទាញនិងផ្លូវរត់របស់ទ្វារ

- ការប្រើកម្ពស់ដៃទ្វារដែលមានរាងមូលជាកន្លែងដែលធ្វើឱ្យទទឹងទ្វារអាចការពារដៃទ្វារបាន
- ផ្លូវរត់របស់ទ្វារត្រូវនៅជិតកន្លែងបើកចេញចូលរបស់ទ្វារ

### ១.៩.៥.៤. ទ្វារគ្មានដៃ (Finger Plate and Kick Plates)




*រូបភាព ១.៩.៥.៤. គំរូអំពីទ្វារដែលអាចបើកដោយដៃនិងដោយយករទេះទៅរុញបិទបើក*

❖ ស្តង់ដានិងការណែនាំអំពីទ្វារគ្មានដៃ

- ចំពោះទ្វារដែលគ្មានដៃត្រូវដាក់នៅចំហៀង
- ទទឹងទ្វារត្រូវមានទំហំធំនិងមានកម្ពស់៤០០ម.ម

### ១.៩.៥.៥. ឧបករណ៍បិទទ្វារ (Door-Closing Devices)



*រូបភាព ១.៩.៥.៤.១. គំរូអំពីទ្វារដែលភ្ជាប់ជាមួយប្រព័ន្ធសញ្ញាការពារអគ្គិភ័យស្វ័យប្រវត្តិ*



*រូបភាព ១.៩.៥.៤.២. រូបភាពអំពីឧបករណ៍ដែលចាប់ទប់ទ្វារឱ្យបើករហូត*

❖ ស្តង់ដានិងការណែនាំអំពីឧបករណ៍បិទទ្វារ

- ឧបករណ៍ដែលប្រើប្រាស់សម្រាប់បិទទ្វារត្រូវដាក់នៅកន្លែងណាដែលចាំបាច់
- ឧបករណ៍បិទទ្វារត្រូវមានការត្រួតពិនិត្យឱ្យបានត្រឹមត្រូវ
- ទ្វារដែលនៅជិតបន្ទប់ត្រូវបន្ថយកម្លាំងបើកបន្តិច
- ត្រូវបង្កឱ្យមានភាពងាយស្រួលចំពោះគ្រឿងអេឡិចត្រូនិចទាំងអស់ក្នុងការបើកបិទទ្វារ

## ១.៩.៥.៦. គ្រឿងផ្សំរបស់ទ្វារច្រកចេញពេលមានអាសន្ន

(Emergency Exit Door Ironmongery)



❖ ស្តង់ដានិងការណែនាំអំពីគ្រឿងផ្សំរបស់ទ្វារច្រកចេញពេលមានអាសន្ន



- ច្រកទ្វារចេញពេលមានអាសន្នត្រូវងាយស្រួលប្រើប្រាស់បានដោយបំពាក់ឧបករណ៍ដូចរូបខាងលើ

### ១.៩.៥.៧. គ្រឿងផ្សំរបស់ទ្វារផ្សេងៗទៀត

(Other Ironmongery)



❖ ស្តង់ដានិងការណែនាំអំពីគ្រឿងផ្សំរបស់ទ្វារផ្សេងៗទៀត

- ទីតាំងដែលត្រូវដាក់បន្ទះអក្សរត្រូវមានកម្ពស់៩០០ម.មពីផ្ទៃ
- គ្រឿងផ្សំរបស់ទ្វារមានច្រើននិងអាចលើសពីរូបភាពខាងលើ

## ១.៩.៥.៨. ប្រព័ន្ធស្វ័យប្រវត្តិរបស់ទ្វារ (Automatic Door Systems)



*រូបភាព ១.៩.៥.៨.១. ឧទាហរណ៍អំពីទ្វារពីរសន្លឹកបិទបើកចេញក្រៅចូលក្នុងនៅច្រកទ្វារចូល*



*រូបភាព ១.៩.៥.៨.១. គំរូអំពីទ្វារអគ្គិសនីចុចបើក*

❖ ស្តង់ដានិងការណែនាំអំពីប្រព័ន្ធស្វ័យប្រវត្តិរបស់ទ្វារ

- ទ្វារទាំងសងខាងត្រូវមានទំហំគ្រប់គ្រាន់
- ជៀសវាងធ្វើផ្លូវចូលចង្អៀតទៅកាន់ទ្វារបិទបើកដោយស្វ័យប្រវត្តិ
- ធានាថាប្រព័ន្ធដំណើរការនិងសុវត្ថិភាពអាចការពារចំពោះមនុស្សមានចលនាយឺតឬអ្នកដែលដួល
- ធានាថាប្រព័ន្ធដំណើរការទ្វាររៀបចំឱ្យបើកដោយស្វ័យប្រវត្តិត្រូវមានចម្ងាយឆ្ងាយពីមនុស្ស១៤០០ម.ម
- ត្រូវធានាថារយៈពេលនៃការបើកទ្វារសមស្របចំពោះមនុស្សដែលមានចលនាយឺត
- ត្រូវដាក់ប្រព័ន្ធបញ្ជាទ្វារស្វ័យប្រវត្តិឬបញ្ជាដោយដៃនៅទីតាំងដែលអាចលូកដល់មានសញ្ញានិងអាចមើលឃើញច្បាស់

- គួរគិតគូរពីតម្រូវការបន្ថែមឧបករណ៍សុវត្ថិភាពសម្រាប់ទ្វារដែលត្រូវប្រើ ថាមពលជាជំនួយ
- ត្រូវដាក់ប្រព័ន្ធការពារការគាបម្រាមដៃនិងគាបខ្លួនដែលអាចកើតឡើង ដោយយថាហេតុ
- ត្រូវដាក់រនាំងការពារចំពោះទ្វារពីរសន្លឹកដែលអាចនៅជិតគ្នាពីម្ខាងទៅម្ខាង

### ១.៩.៥.៩. សុវត្ថិភាពរបស់ទ្វារនិងប្រព័ន្ធចេញចូល (Door Security and Entry Systems)

❖ ស្តង់ដានិងការណែនាំអំពីសុវត្ថិភាពរបស់ទ្វារនិងប្រព័ន្ធចេញចូល

- បំពាក់ប្រព័ន្ធទ្វារចូលនៅទីតាំងដែលអាចឈោងដល់បានទាំងអស់គ្នា នៅខាងដៃបិទបើកទ្វារដោយ បន្ថែមសញ្ញាជាអក្សរប្រាប់ផង
- គួរពិចារណាដាក់ប្រព័ន្ធវីដេអូជាជំនួយដល់ការកំណត់អត្តសញ្ញាណនិង ការទំនាក់ទំនង
- ត្រូវដាក់កន្លែងប្រើកាតឆូតទាំងអស់បញ្ឈរ
- ត្រូវដាក់ប៊ូតុងចុចនិមិត្តសញ្ញាណាដែលផុសលេខនិងអក្សរក្នុងក្តាចុច តែមួយ
- គ្រប់ឧបករណ៍ទាំងអស់ត្រូវមានពណ៌ផ្ទុយគ្នាដើម្បីងាយស្រួលចំណាំ
- ត្រូវបំពាក់កណ្តឹងនិងប៊ូតុងចុចហៅដែលមានលេខច្បាស់ក្នុងការប្រើប្រាស់

# ផ្នែកទី២ អំពីការរៀបចំចំណតយានយន្ត (CAR PARK ENVIRONMENTS)







ចំណតយានយន្តគឺជាទីកន្លែងដែលបានរៀបចំសម្រាប់ចតយានជំនិះគ្រប់ប្រភេទនៅតាមទីតាំងផ្សេងៗគ្នាដែលងាយស្រួលនិងនៅជិតបំផុត។ ចំណតយានយន្តជនមានពិការភាពគឺមានលក្ខណៈខុសពីចំណតយានយន្តធម្មតា។ ចំណតយានយន្តអាចធ្វើនៅជាន់ផ្ទាល់ដី ក្រោមដីនិងជាន់ខាងលើដែលអាចនៅក្នុងឬក្រៅអគារ។ ចំណតយានយន្តត្រូវតែអាចប្រើប្រាស់បានងាយស្រួលនិងមានទំហំសមរម្យតាមរយៈការឌីហ្សាញប្រកបដោយវិជ្ជាជីវៈដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់របស់មនុស្សគ្រប់រូប។ ចំណតយានយន្តនៅគ្រប់ទីកន្លែងទាំងអស់មុននឹងសាងសង់ឬរៀបចំត្រូវពិចារណាដល់ការប្រើប្រាស់របស់មនុស្សទូទៅរួមមានឪពុកម្តាយ អ្នកបីទារក អ្នកលើកដាក់វត្ថុធ្ងន់ៗ អ្នកដើរផ្សារ អ្នកមិនអាចដើរបានឆ្ងាយ អ្នកមិនអាចកាន់វត្ថុធ្ងន់បានឆ្ងាយ អ្នកដែលខ្សោយគំហើញ អ្នកដែលខ្សោយការស្តាប់ អ្នកមានរបួសមិនទាន់ជាស្ត្រីមានផ្ទៃពោះចាស់ជរានិងអ្នកប្រើប្រាស់យានយន្តធំៗរួមមានឡានទេសចរណ៍ដែលមានឧបករណ៍លើកដាក់ជនមានពិការភាពជិះរទេះនៅពីខាងក្រោយ។



## ២.១. ទិដ្ឋភាពទូទៅ (General)



❖ ស្តង់ដានិងការណែនាំអំពីទិដ្ឋភាពទូទៅ




- ធានាថាទីកន្លែងចំណតរៀបចំស្របទៅតាមចំនួនយានជំនិះដែលត្រូវចត
- ត្រូវរៀបចំឱ្យមានទីធ្លាចំណតសម្រាប់មនុស្សផ្សេងៗគ្នារួមទាំងសម្រាប់អ្នកមានកូនតូចនិងកុមារផង
- រៀបចំឱ្យមានទីធ្លាសមរម្យសម្រាប់អ្នកដែលត្រូវការចំណតទូលាយនិងចំណតនៅជិត
- ការរៀបចំចំណតដែលសមស្របត្រូវធ្វើទាំងចំណតខាងក្នុងចំណតខាងក្រៅចំណតក្រោមដីនិងចំណតលើអគារ

- ប្រសិនបើចំណតខាងក្នុងមានច្រើនជាន់យ៉ាងហោចណាស់មួយជាន់មានជណ្ដើរយោងមួយ
- ចំណតយានយន្តគួរតែសមស្របងាយស្រួលប្រើប្រាស់និងគួរមានទីធ្លាគ្រប់គ្រាន់តាមរយៈការឌីហ្សាញពីដំបូងដើម្បីឆ្លើយតបនិងតម្រូវការរបស់មនុស្សផ្សេងៗគ្នា
- ការរៀបចំចំណតយានយន្តសម្រាប់ជនមានពិការភាពត្រូវគិតអំពីចំនួនកន្លែងចត ទីតាំងចត ទំហំចំណតនិងលក្ខណៈពិសេសនៃទីធ្លានីមួយៗ
- ស្លាកសញ្ញាប្រាប់អំពីទីតាំងចំណតនិងកន្លែងចតសម្រាប់យានយន្តនីមួយៗដូចជាស្លាកសញ្ញាការអនុញ្ញាតនិងមិនអនុញ្ញាតចតដោយបានគិតគូរទាំងអ្នកបើកបរនិងអ្នករួមដំណើរដូចជាអ្នករបួសបណ្ដោះអាសន្នស្ត្រីមានផ្ទៃពោះ អ្នកជំងឺផ្សេងៗនិងអ្នកដែលមិនអាចដើរឆ្ងាយបានដោយសារស្ថានភាពជំងឺ
- អ្នកឌីហ្សាញឬអ្នកសាងសង់ត្រូវគិតឱ្យបានហ្មត់ចត់ដល់តម្រូវការមនុស្សគ្រប់រូបដែលប្រើប្រាស់ចំណតប្រកបដោយភាពងាយស្រួលនិងសុវត្ថិភាព

### ២.២. ចំនួនរថយន្ត (Number of Vehicles)

❖ ស្តង់ដានិងការណែនាំអំពីចំនួនរថយន្ត

- សម្រាប់ចំណតដែលមានតិចជាង១០យានយន្តត្រូវមានកន្លែងចតមួយដែលមានការបង្កលក្ខណៈងាយស្រួលនៅគ្រប់ចំណត
- សម្រាប់ចំណតដែលមានច្រើនបំផុត៤០កន្លែងចត( ប្រអប់ )ត្រូវគិតថា១០ប្រអប់មាន១ប្រអប់សម្រាប់ជនមានពិការភាព( ១/១០ )
- សម្រាប់ចំណតយានយន្តដែលមានច្រើនជាង៤០កន្លែង ត្រូវគិតចំនួន៨ប្រអប់ម្ដងមានចំណតជនមានពិការភាព១ប្រអប់( ១/៨ )

## ២.៣. ទំហំចំណត (Car Parking Spaces and Dimension)



*រូបភាព ២.៣.១. គំរូអំពីសារៈសំខាន់នៃការរៀបចំទីធ្លានៅផ្នែកចំហៀងនៃចំណតយានយន្តសម្រាប់ជនមានពិការភាព*

❖ ស្តង់ដានិងការណែនាំអំពីទំហំចំណត




- កន្លែងចតមួយត្រូវមានទទឹងតូចបំផុត ៣៦០០ម.មទៅ៣៩០០ម.ម



- ស្លាបម្ខាងមានទទឹង១២០០ម.មដែលអាចនៅចន្លោះរវាងចំណតធម្មតា២
- សម្រាប់ចំណតខាងក្នុងដែលខ្ពស់ស្រឡះអាចចតឡានទេសចរណ៍បានគឺ២៤០០ម.ម



- សម្រាប់កន្លែងចតនៅកាច់ជ្រុងត្រូវបន្ថែមទីធ្លានៅបន្ទាត់ចុងស្លាបសម្រាប់ជនមានពិការភាព

- ចំណតយានយន្តធម្មតាមានទំហំ៤៨០០ម.ម x ២៤០០ម.ម
- ចំណតយានយន្តជនមានពិការភាពត្រូវបន្ថែមទំហំ១២០០ម.មជុំវិញ



ចំណតយានយន្តធម្មតាដើម្បីទុកបើកទ្វារឱ្យបានធំងាយស្រួលសម្រាប់ជនមានពិការភាពប្រើប្រាស់រទេះចុះឡើងយានយន្ត

- ទំហំស្តង់ដានៃចំណតយានយន្តជនមានពិការភាពត្រូវមានទំហំតិចបំផុត ៦០០០ម.មទៅ៣៦០០ម.ម

*រូបភាព ២.៣.២. គំរូអំពីចំណតយានយន្តនិងទីធ្លាបន្ថែមសម្រាប់រទេះជនមានពិការភាព*




- ចំពោះចំណតសម្រាប់យានយន្តជនមានពិការភាពដែលអ្នកបើកបរនិងអ្នករួមដំណើរប្រើប្រាស់រទេះទាំងពីរនាក់ត្រូវបន្ថែមទំហំដល់៥៧០០ម.ម x ៤២០០ម.ម

*រូបភាព ២.៣.៣. គំរូអំពីទីធ្លាបន្ថែមសម្រាប់ការចត*

*រូបភាពនេះបង្ហាញថាហេតុអ្វីបានជាទំហំបន្ថែមនៅផ្នែកចំហៀងនៃចំណត ត្រូវការសម្រាប់ចំណតយានយន្តជនមានពិការភាព។*




- គ្រប់ចំណតយានយន្តទាំងសាធារណៈឬឯកជនត្រូវរក្សាទុកឱ្យមានចំណតយានយន្តសម្រាប់ជនមានពិការភាពមួយកន្លែងរាល់ចំណតទាំងឡាយដែលអាចចតបាន១០កន្លែង
- សម្រាប់ចំណតនៅខាងក្រៅអគារត្រូវរៀបចំឱ្យស្ថិតនៅ៣០ម៉ែត្រពីផ្លូវចូលធំ
- រៀបចំឱ្យមានផ្លូវសុវត្ថិភាពពីផ្លូវចូលធំមកចំណតយានយន្តតាមស្តង់ដា
- ត្រូវរៀបចំបំពាក់ឧបករណ៍សមស្របដើម្បីឱ្យជនមានពិការភាពអាចចូល និងចេញពីចំណតបានស្រួល

- រៀបចំសម្រាប់អ្នកថ្មើរជើងចេញចូលដោយងាយស្រួលដូចជាច្រកដើរនិងពន្លឺ។ល។



*រូបភាព ២.៣.៤. គំរូអំពីទីធ្លាសមស្របសម្រាប់ចំណតយានយន្ត*



*រូបភាព ២.៣.៥. គំរូអំពីទីធ្លាសមល្មមសម្រាប់ការចតយានយន្តជនមានពិការភាពនីមួយៗ គួរកត់សម្គាល់ថារូបភាពនេះមិនបានដាក់ស្លាកសញ្ញាអន្តរជាតិសម្គាល់ទីតាំងចំណតនិងជម្រាលចុះឡើងខឿន។*



*រូបភាព ២.៣.៦. គំរូអំពីការរៀបចំឱបា្យញទំហំចំណតសមស្របសម្រាប់ជនមានពិការភាព*

- កន្លែងចតរថយន្តក្នុងអគារដែលមានច្រើនជាន់យ៉ាងហោចណាស់មួយជាន់គួរតែត្រូវរៀបចំជណ្តើរយន្តមួយទៅតាមស្តង់ដា
- ចំណតនៅខាងក្នុងអគារគួរតែធ្វើនៅជិតជណ្តើរយន្ត ជណ្តើរយោងនិងច្រកចេញ
- ចំណតយានយន្តសម្រាប់ជនមានពិការភាពគួរតែរៀបចំនៅខាង
- ត្រូវទុកចន្លោះទំនេរទទឹងតិចបំផុត១២០០ម.ម ពីឡានមួយទៅឡានមួយដើម្បីឱ្យជនមានពិការភាពអាចដាក់រទេះចុះនិងឡើងរថយន្តបាន
- ត្រូវរៀបចំឱ្យមានចន្លោះតិចបំផុត៩០០ម.មពីកំណោល់កង់រថយន្តនិងផ្លូវ

- ត្រូវរៀបចំឱ្យមានកន្លែងឡើងនិងចុះពីយានយន្តដែលមានទំហំតិចបំផុត ៦០០ម.មនិងបន្ថែម១២០០ម.មទៀតដើម្បីអាចដាក់រថយន្ត២បាន
- ជម្រាលឡើងខឿនចំណតយានយន្តមិនត្រូវធ្វើលើសពីស្តង់ដាពី១/១២ សម្រាប់ជម្រាលខ្លីនិងមិនត្រូវលើស១/២០ឡើយសម្រាប់ជម្រាលវែងៗ
- ប្រសិនបើចំណតមានខឿនខ្ពស់ពីដីត្រូវតែរៀបចំឱ្យមានជម្រាលតាមស្តង់ដាដើម្បីឱ្យជនមានពិការភាពជិះរទេះអាចប្រើប្រាស់បានពេលចុះនិងឡើងពីផ្លូវទៅរថយន្ត
- ក្នុងករណីចំណតមានខឿនខ្ពស់ពីដីការរៀបចំជម្រាលខឿនត្រូវមានទំហំដែលជនមានពិការភាពអាចបង្វិលបត់បែនរទេះបាន

## ២.៤. ស្លាកសញ្ញាចំណត (Car Parking Signage)



*រូបភាព ២.៤.១. គំរូអំពីរូបសញ្ញាអន្តរជាតិសម្រាប់ជនមានពិការភាព*




*រូបភាព ២.៤.២. គំរូអំពីសញ្ញាប្រាប់ពីទីតាំងចំណតយានយន្តសម្រាប់ជនមានពិការភាព*



*រូបភាព ២.៤.៣. គំរូអំពីជម្រើសបន្ទាប់បន្សំនៃសញ្ញាដែលអាចប្រើប្រាស់សម្រាប់ប្រាប់ពីទីតាំងចំណតយានយន្តជនមានពិការភាព*

❖ ស្តង់ដានិងការណែនាំអំពីស្លាកសញ្ញាចំណត

- ត្រូវប្រើរូបសញ្ញាអន្តរជាតិនៅគ្រប់ចំណតទាំងអស់
- ចំណតសម្រាប់ជនមានពិការភាពគួរតែមានសញ្ញាសម្គាល់ជាលក្ខណៈអន្តរជាតិនិងមានសញ្ញាព្រួញប្រាប់មុនចាប់តាំងពីផ្លូវចូលមក
- ត្រូវអនុញ្ញាតប្រើប្រាស់សម្រាប់តែអ្នកចាំបាច់ប៉ុណ្ណោះ
- គ្រប់ចំណតយានយន្តទាំងនៅខាងក្រៅនិងនៅខាងក្នុងត្រូវបំពាក់ដោយស្លាកសញ្ញាដែលមានពណ៌និងពន្លឺគ្រប់គ្រាន់អាចមើលឃើញច្បាស់និងគ្រប់ពេល
- ប្រសិនបើចំណតឡាននិងផ្លូវមានកម្ពស់ស្មើគ្នាត្រូវរក្សាកន្លែងទំនេរទំហំតិចបំផុត៦០០ម.មរវាងផ្លូវនិងចំណតយានយន្តដែលមានពណ៌ផ្សេងគ្នាឬគំនូសឆ្នូតៗ

## ២.៥. ទីតាំងចំណត (Parking Location)

❖ ស្តង់ដានិងការណែនាំអំពីទីតាំងចំណត

- ចំពោះចំណតខាងក្រៅកន្លែងចតយានយន្តសម្រាប់ជនមានពិការភាពត្រូវដាក់ចម្ងាយមិនលើសពី៥០ម៉ែត្រពីច្រកចូលអគារ
- ចំពោះចំណតខាងក្នុងកន្លែងចតយានយន្តសម្រាប់ជនមានពិការភាពត្រូវដាក់នៅចំពីមុខជណ្តើរយោងឬជិតផ្លូវចេញបំផុតតាមដែលអាចធ្វើទៅបាន
- ចុងបន្ទាត់ទាំងឡាយគឺងាយស្រួលសម្រាប់រថយន្តទេសចរណ៍ដែលមានឧបករណ៍លើកដាក់ជនមានពិការភាពជិះរទេះ
- ត្រូវរៀបចំឱ្យមានការកំណត់ចន្លោះកន្លែងចតយានយន្តសម្រាប់អ្នកមានកូននិងកុមារឱ្យបាននៅជិតច្រកចូលអគារឬទីតាំងសំខាន់

- ធានាថាផ្លូវរវាងចំណតនិងច្រកចូលទៅអគារឬទីតាំងអាចប្រើបានងាយស្រួល
- ត្រូវរៀបចំស្លាកសញ្ញាឱ្យបានច្បាស់ដើម្បីបញ្ជាក់ពីទីកន្លែងដែលត្រូវចតនៅតាមចំណតនីមួយៗ
- ធានាឱ្យមានទីធ្លាខុសពីផ្លូវដែលមានទំហំ២៤០០ម.ម x ១២០០ម.ម នៅសងខាងចំណត
- រៀបចំឱ្យមានទីធ្លានៅលើផ្លូវទំហំទទឹង៣៦០០ម.ម x បណ្តោយ ៧០០០ម.ម
- ត្រូវប្រុងប្រយ័ត្នកុំឱ្យមានគ្រឿងសង្ហារឹមតាមផ្លូវជាឧបសគ្គផ្លូវថ្មើរជើងនៃវិថីធំៗ
- ត្រូវរៀបចំកន្លែងខ្ពស់ឬទាបសម្រាប់ផ្លូវទឹកហូរ
- ត្រូវរៀបផ្ទៃឱ្យមានកម្ពស់ខ្ពស់សមរម្យនិងមានភាពទេរមិនលើសពី១/៥០
- សម្រាប់ចំណតដែលនៅកែងនីមួយៗគួរតែបន្ថែមទីធ្លានៅចុងបញ្ចប់នៃចំណតនីមួយៗស្មើនឹងទំហំដែលទុកសម្រាប់រទេះជនមានពិការភាពគឺ ១២០០ម.ម
- ត្រូវរក្សាទំហំ១២០០ម.មចន្លោះពីរថយន្តមួយទៅរថយន្តមួយទៀត
- ស្លាកសញ្ញាបង្ហាញអំពីចំណតត្រូវមានទំហំតូចបំផុត៣០០ម.ម x ៤៥០ម.មដាក់នៅកម្ពស់១៥០០ម.មទៅ២៥០០ម.មពីដីនិងនៅចំកណ្តាលចំណត
- ស្លាកសញ្ញាប្រាប់ផ្លូវត្រូវដាក់កម្ពស់តិចបំផុត១៤០០ម.ម



## *រូបភាព ២.៥.១. ការរៀបចំចំណតសម្រាប់ជនមានពិការភាព មនុស្សចាស់និងកុមារនៅលើផ្លូវ*




**ចំណុចសំខាន់ៗ:**

A. ជម្រាលឡើងចុះខឿនដែលធ្វើអំពីឥដ្ឋដែលមានដុំពកមូលៗអាចស្ទាបបាន

B. ផានាតំបន់មានសុវត្ថិភាពនៅតាមខឿនចញ្ចើមថ្នល់

**សម្គាល់:** ខ្នាតទាំងអស់គិតជា មម

## *រូបភាព ២.៥.២. ការរៀបចំចំណតនៅជាប់ចញ្ចើមផ្លូវ*




**ចំណុចសំខាន់ៗ:**

A. ផ្លូវសម្រាប់រទេះចុះឡើងរថយន្តដែលអាចមានខឿននៅចំហៀងចៀសវាងបង្វិលរទេះតាមក្រោយរថយន្ត

B. ខឿនចញ្ចើមផ្លូវដែលមានជម្រាលចុះឡើង

C. ស្តង់ដាទំហំកន្លែងចតរថយន្តមួយ គិតបំផុត២៤០០មម×៤៨០០មម

D. ទំហំទទឹង១២០០មមជាតំបន់សុវត្ថិភាពសម្រាប់លើកដាក់អីវ៉ាន់ឬឧបករណ៍ស្ទូចមិនប៉ះពាល់ដល់ផ្លូវចរាចរសាធារណៈ

E. ទទឹងទំហំ១២០០មមចន្លោះរវាងកន្លែងចតរយន្តនីមួយៗ

**សម្គាល់:** ខ្នាតទាំងអស់គិតជា មម

## ២.៦. ខឿនចំណត (Parking Curb)

❖ ស្តង់ដានិងការណែនាំអំពីខឿនចំណត

- ប្រសិនបើមានខឿនត្រូវមានជម្រាលចុះឡើងខឿននោះដែលភ្ជាប់ពីទីតាំងកន្លែងចតទៅផ្លូវដើរ






- ប្រសិនបើគ្មានខឿនផ្ទៃកម្រាលពណ៌ដែលមានទំហំទទឹង៦០០ម.មដើម្បីឱ្យមើលឃើញខុសគ្នារវាងផ្លូវដើរនិងកន្លែងចតយានយន្ត បើមិនដូច្នេះទេត្រូវប្រើបង្គោលការពារ។ ដុំទប់កង់(ថ្មឬដំរ)ក៏អាចប្រើបានដើម្បីចែកដាច់ពីគ្នារវាងផ្លូវដើរដែលមានទទឹង៩០០ម.ម






## ២.៧. ចំណតក្រោមដីនិងច្រើនជាន់ (Multi-Story and Underground Car Parks)



*រូបភាព ២.៧.១. គំរូអំពីការកំណត់កន្លែងចតរថយន្តបានសមស្រប*



*រូបភាព ២.៧.២. ជម្រើសផ្សេងទៀតនៃគំរូអំពីការកំណត់កន្លែងចតរថយន្តបានសមស្រប*



*រូបភាព ២.៧.៣. គំរូអំពីការកំណត់កន្លែងចតយានយន្តសម្រាប់ជនមានពិការភាពនិងអ្នកជិតស្និទ្ធរបស់គេមុនចូលផ្សារ*



*រូបភាព ២.៧.៤. ច្រកចូលពីចំណតទៅក្នុងផ្សារ*



*រូបភាព ២.៧.៥. គំរូអំពីតារាងព័ត៌មានអំពីស្ថានភាពនិងទិដ្ឋភាពទូទៅនៃចំណតជាទៀងទាត់*





*រូបភាព ២.៧.៦. ទីធ្លាដែលបង្ហាញថាកន្លែងចតរថយន្តមានកម្ពស់សមរម្យ*



*រូបភាព ២.៧.៧. គំរូអំពីកន្លែងបង់ប្រាក់ថ្លៃចតរថយន្តដែលដាក់នៅកម្ពស់ផ្សេងៗគ្នា*

❖ ស្តង់ដានិងការណែនាំអំពីចំណតក្រោមដីនិងច្រើនជាន់

- រៀបចំទីធ្លាកន្លែងចតយានយន្តទៅតាមកន្លែងដែលសមស្របនិងស្របទៅតាមទីតាំងនៃច្រកចូលនិងច្រកចេញនៃអគារ
- ធានាថាចំណតយានយន្តដែលនៅខ្ពស់មានជណ្តើរយោង/ប្រអប់គ្រប់ជាន់
- ត្រូវមានចន្លោះទំនេរទំហំ២៦០០ម.មនៅតាមចំណតនីមួយៗ
- ម៉ាស៊ីនចុចយកសំបុត្រទាំងអស់ត្រូវបំពាក់ប្រព័ន្ធបញ្ជានិងអាចមើលឃើញ
- ត្រូវរៀបចំម៉ាស៊ីនបង់ប្រាក់មុនសម្រាប់អ្នកប្រើរទេះឬឱ្យមានកម្ពស់ផ្សេងគ្នា
- សម្រាប់ចំណតនៅខាងក្នុងដំបូលគួរមានកម្ពស់ដែលទូលាយអប្បបរមា២៦០០ម.ម
- ចំណតក្រោមដីនិងច្រើនជាន់គួរតែរៀបចំឱ្យមានជណ្តើរយោងនិងមានឧបករណ៍ស្រូបផ្សែងនៅគ្រប់ជាន់
- ក្នុងករណីចំណតក្រោមដីផ្លូវពីចំណតទៅកាន់ផ្លូវចូលអគារគួរតែងាយស្រួលសម្រាប់អ្នកប្រើប្រាស់យានយន្តគ្រប់ប្រភេទ

- ស្លាកសញ្ញាគួរតែច្បាស់លាស់ដែលប្រាប់អំពីទីតាំងចត ទីតាំងសម្រាប់ឪពុកម្ដាយនិងកុមារ ទីកន្លែងម៉ាស៊ីនយកសំបុត្រ ជណ្ដើរយោងឬប្រអប់លេខចំនួនជាន់ ផ្លូវចេញចុងក្រោយនិងផ្លូវចូលអគារ
- ម៉ាស៊ីនចុចយកសំបុត្រគួរតែដាក់នៅកន្លែងសមស្របទាំងកម្ពស់និងស្លាកសញ្ញាងាយយល់និងងាយស្រួលប្រើប្រាស់សម្រាប់អ្នកបើកបរទាំងអស់

## ២.៨. ចំណតបង់ប្រាក់ (Paid Parking)




*រូបភាព ២.៨.១. គំរូអំពីម៉ាស៊ីនយកប័ណ្ណផ្ញើរថយន្តដែលដាក់នៅកម្ពស់ពីរផ្សេងៗគ្នា*



*រូបភាព ២.៨.២. គំរូអំពីឧបករណ៍ហៅរកអ្នកជួយតាមរយៈសំឡេង ទំនាក់ទំនងរបស់អ្នកចតរថយន្ត*



*រូបភាព ២.៨.៣. គំរូអំពីម៉ាស៊ីនយកប័ណ្ណផ្ញើរថយន្តដែលដាក់នៅកន្លែងងាយស្រួលនៃច្រកចេញចូលចំណត*

❖ ស្តង់ដានិងការណែនាំអំពីចំណុចបង់ប្រាក់

- កន្លែងបង់ប្រាក់ឬម៉ាស៊ីនលក់សំបុត្រគួរតែដាក់នៅកន្លែងសមស្របទាំងកម្ពស់និងស្លាកសញ្ញាងាយយល់និងងាយស្រួលប្រើប្រាស់សម្រាប់អ្នកបើកបរទាំងអស់
- ត្រូវរក្សាកន្លែងទំនេរនៅមុខកន្លែងបង់ប្រាក់ឬម៉ាស៊ីនលក់សំបុត្រទំហំ១៨៥០ម.ម x ២១០០ម.ម

*រូបភាព ២.៨.៤. ម៉ាស៊ីនយកប័ណ្ណផ្ញើរថយន្ត*




- កន្លែងដាក់កាក់កាត កន្លែងចុចប៊ូតុង កន្លែងយកសំបុត្រនិងកន្លែងបញ្ជាផ្សេងៗទៀតគួរដាក់នៅកម្ពស់៧៥០ម.មទៅ១២០០ម.មពីដីនិងមានប្រើប្រាស់ពណ៌សម្រួលដល់អ្នកខ្សោយគំហើញ
- ត្រូវឱ្យមានមនុស្សម្នាក់នៅជាប្រចាំក្នុងករណីដែលអ្នកបើកបរត្រូវការជំនួយ

- សំបុត្រគួរតែអាចយកបានដោយមិនត្រូវការចុះពីឡាន
- ប្រសិនបើអាចសំបុត្រគួរអាចទិញតាមអនឡាញ

### ២.៩. កន្លែងភ្ញៀវចុះនិងឡើងរថយន្ត (Drop-off Areas)




❖ ស្តង់ដានិងការណែនាំអំពីកន្លែងភ្ញៀវចុះនិងឡើងរថយន្ត

- កន្លែងចុះឡើងរថយន្តមានប្រយោជន៍សម្រាប់ទទួលយកនិងដាក់អ្នកដំណើរឡើងចុះពីរថយន្ត
- កន្លែងចុះឡើងរថយន្តគួរតែរៀបចំឱ្យមាននៅកន្លែងរថយន្តឈប់ចត ដូចជាចំណតរថយន្តក្រុងនិងមិនត្រូវលើសពី៣០ម៉ែត្រពីច្រកចេញចូលអគារឡើយ
- កន្លែងចុះឡើងរថយន្តត្រូវមានទទឹងតូចបំផុត៣.៦០ម៉ែត្រដែលមានស្លាបទំហំ១.២០ម៉ែត្រដើម្បីឱ្យប្រើបានចំពោះបណ្តោយគួរតែអាចដាក់រថយន្តបាន២

- ត្រូវមានជម្រាលចុះឡើងខឿនដើម្បីសម្រួលការធ្វើដំណើរឆ្លងកាត់ផ្ទៃផ្លូវ
- ប្រសិនបើគ្មានខឿនបែងចែកផ្លូវរវាងផ្លូវថ្មើរជើងនិងតំបន់សម្រាប់យានយន្តការដាក់សញ្ញាដើម្បីជួយដល់អ្នកខ្សោយគំហើញគឺជាការចាំបាច់បំផុតដូចជាបង្គោលការពារកម្រាលពកដែលអាចស្ទាបដឹងបានទំហំទទឹង៦០០ម.មអាចធ្វើនៅតាមគែមផ្លូវដើម្បីជាដំណឹងអំពីកន្លែងយានយន្តត្រូវឈប់
- រោងឬដំបូលការពារដែលមានកន្លែងអង្គុយសមរម្យត្រូវរៀបចំនៅគ្រប់កន្លែងមានអ្នកដំណើរច្រើន
- ស្លាកសញ្ញាគ្រប់ប្រភេទត្រូវតែបានបំពាក់ដើម្បីកំណត់អំពីកន្លែងចុះឡើងរថយន្ត
- ត្រូវតែរៀបចំឱ្យមានកន្លែងភៀវចុះនិងឡើងរថយន្តដែលនៅជិតច្រកចូលអគារបំផុត
- ធានាថាកន្លែងភៀវចុះនិងឡើងរថយន្តមានដំបូលទំនេរកម្ពស់២៦០០ម.ម
- ធានាថាផ្ទៃនៃផ្លូវរាបស្មើដូចគ្នានិងច្រកឬផ្លូវថ្មើរជើងតាមវិថីរួមទាំងមានផ្លូវសម្រាប់ជនមានពិការភាពភ្នែកផងដែរ

## ២.១០. ផ្ទៃនៃទីធ្លាចំណត (Surface)

❖ ស្តង់ដានិងការណែនាំអំពីផ្ទៃនៃទីធ្លាចំណត

- ផ្ទៃគ្រប់ចំណតយានយន្តគួរតែដូចៗគ្នានិងរលោងសមរម្យ
- ចំណោតនៃជម្រាលចំណតទាំងអស់មិនត្រូវលើសពី១/២០

## ២.១១. ចំណតតាក់ស៊ី (Taxi Ranks)






- ស្តង់ដានិងការណែនាំអំពីចំណតតាក់ស៊ី
  - ត្រូវរៀបចំចំណតសម្រាប់តាក់ស៊ីនៅកន្លែងសមរម្យ
  - ត្រូវមានការណែនាំចំណតតាក់ស៊ីដើម្បីឱ្យអ្នកដំណើរដឹងមុននឹងចុះក្បែរនោះ
  - ធានាថាមានផ្លូវថ្មើរជើងទំហំ៤០៤០ម.មដើម្បីអាចធ្វើជម្រាលសម្រាប់រទេះនិងកន្លែងបត់រទេះបាន
  - ត្រូវរៀបចំឱ្យមានកៅអីនៅគ្រប់កន្លែងរង់ចាំ
  - ចំណតតាក់ស៊ីត្រូវតែរៀបចំនៅជិតផ្លូវរថភ្លើង ស្ថានីយរថយន្តក្រុងនិងកន្លែងដាក់អ្នកដំណើរចុះដូចជាច្រកចេញច្រកចូលព្រលានយន្តហោះ និងគួរនៅជិតផ្លូវចេញចូលធំនិងគួរមានសញ្ញាប្រាប់ច្បាស់លាស់ទាំងនៅខាងក្នុងនិងខាងក្រៅ
  - ចំណតតាក់ស៊ីគួរតែមានព័ត៌មានបង្ហាញច្បាស់លាស់ដើម្បីឱ្យអ្នកដំណើរអាចជ្រើសរើសរកតាក់ស៊ីដែលនៅជិតជាងគេ
  - ត្រូវរក្សាទំហំផ្លូវសម្រាប់ចំណតតាក់ស៊ីទទឹងតូចបំផុត៤០០០ម.ម សម្រាប់អ្នកប្រើប្រាស់រទេះ



- នៅពេលរៀបចំចំណតតាក់ស៊ីត្រូវគិតដល់អ្នករុញរទេះ ជនមានពិការភាពភ្នែក អ្នកខ្សោយគំហើញនិងអ្នកប្រើឈើច្រត់
- ផ្លូវឆ្លងកាត់សម្រាប់ថ្មើរជើងដែលមានជម្រាលខឿននិងផ្ទៃស្ទាបអាចដឹងបានគួររៀបចំនៅជិតចំណតតាក់ស៊ីបំផុត
- នៅគ្រប់កន្លែងតម្រង់ជួរគួរតែមានដំបូលនិងកន្លែងអង្គុយនៅជិតចំណតតាក់ស៊ី
- រៀបចំចំណតតាក់ស៊ីនៅទីកន្លែងសមស្របបំផុត

## ២.១២. ចំណតដែលមានស្រាប់ (Existing Constructions)

- ប្រសិនបើទីធ្លាចំណតមានចម្ងាយច្រើនជាង៥០ម៉ែត្រពីច្រកចូលអគារ កន្លែងភ្ញៀវចុះឡើងយានយន្តត្រូវធ្វើចម្ងាយ៣០ម៉ែត្រពីច្រកចូលអគារឬទីកន្លែងចតត្រូវដាក់នៅជិតច្រកចូលជាងនេះ

ប្រសិនបើគ្មានចំណតសម្រាប់ជនមានពិការភាពត្រូវអនុវត្តវិធានការដូចខាងក្រោម៖

ក. ត្រូវបំពាក់បង្គោលការពារដើម្បីរក្សាទីធ្លាទំនេរសម្រាប់ចុះឡើងរថយន្ត (ហាមចតនៅទីនេះ)



ខ. ដាក់បង្គោលនៅចំកណ្ដាលដើម្បីបែងចែកកន្លែងចតយានយន្តពីរសងខាង




គ. ស្លាបចំណតសងខាងរក្សាទុកសម្រាប់ជនមានពិការភាព



- សម្រាប់ទីធ្លាចំណតខាងក្នុងត្រូវមានកម្ពស់ទូលាយតិចជាង២៤០០ម.ម គឺជាការផ្តល់ជាចំណតខាងក្រៅសម្រាប់រថយន្តទេសចរណ៍ដែលដឹកជនមានពិការភាពមានរទេះ

## ២.១៣. ចំនួនចំណតធៀបទៅនឹងផ្ទៃក្រឡាអគារ

ចំនួនចំណតធៀបទៅនឹងផ្ទៃក្រឡានៃប្រភេទអគារផ្សេងៗនៅទីនេះសំដៅដល់ចំណតយានជំនិះទូទៅមិនមែនចំណតសម្រាប់ជនមានពិការភាពទេ។

- អគារលំនៅឋានដែលមានផ្ទៃក្រឡាចាប់ពី១០០ម$^{២}$-១៥០ម$^{២}$ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារពាណិជ្ជកម្មដែលមានផ្ទៃក្រឡាចាប់ពី២០ម$^{២}$-៥០ម$^{២}$ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារឧស្សាហកម្មដែលមានផ្ទៃក្រឡាចាប់ពី២៥០ម$^{២}$-២០០០ម$^{២}$ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារសិក្សាធិការ អប់រំ កីឡាដែលមានផ្ទៃក្រឡាចាប់ពី១០០ម$^{២}$-៣០០ម$^{២}$ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារសុខភាពដែលមានផ្ទៃក្រឡាចាប់ពី១០០ម$^{២}$-១២០ម$^{២}$ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារមហោស្រព សាលប្រជុំ ពិធី រោងភាពយន្ត មានផ្ទៃក្រឡាចាប់ពី៣០ម$^{២}$-៣០០ម$^{២}$ត្រូវមានចំណតរថយន្តតូច១កន្លែង និងធំ១កន្លែង
- អគារសណ្ឋាគារ៥បន្ទប់ត្រូវមានចំណតរថយន្តតូច១កន្លែង៣០បន្ទប់ចំណតរថយន្តធំ១កន្លែង

- ផ្ទះសំណាក់ដែលមាន១០បន្ទប់ត្រូវមានចំណតរថយន្តតូច១កន្លែង ៣០បន្ទប់ត្រូវមានចំណតរថយន្តធំ១កន្លែង
- ស្ថានីយប្រេងឥន្ធនៈដែលមានផ្ទៃក្រឡាចាប់ពី១០ម²ត្រូវមានចំណតរថយន្តតូច១កន្លែង
- ស្ថានីយប្រេងឥន្ធនៈដែលមាន១០០ម²ត្រូវមានចំណតរថយន្តតូច១និងធំ១កន្លែង
- អគារដឹកជញ្ជូនដែលមានផ្ទៃក្រឡាចាប់ពី១០០ម²ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារដឹកជញ្ជូនដែលមានផ្ទៃក្រឡាចាប់ពី៥០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង
- អគារផ្សេងៗដែលមានផ្ទៃក្រឡាចាប់ពី១៥០ម²ត្រូវមានចំណតរថយន្តតូច១កន្លែងនិងផ្ទៃក្រឡាចាប់ ពី៥០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង

# ផ្នែកទី៣ អំពីប្រភេទអគារ (BUILDING TYPES)





## ៣.១. អគារការិយាល័យ (Office Buildings)

អគារការិយាល័យសំដៅដល់បន្ទប់ការងារនៃអគារកិច្ចការរដ្ឋបាលដែលផ្តល់សេវាជាសាធារណៈរួមទាំងអគាររបស់រដ្ឋ ឯកជន អង្គការមនុស្សធម៌ ការងារស្ម័គ្រចិត្តឬអគារពាណិជ្ជកម្មជាដើម។



## ៣.១.១. ច្រកចូលនិងផ្លូវបត់បែនខាងក្នុង (Entrances and Circulation)





❖ ស្តង់ដានិងការណែនាំអំពីអគារការិយាល័យ

- ធានាថាច្រកចូលទៅការិយាល័យអាចប្រើប្រាស់បានទាំងអស់គ្នាទាំងអ្នកផ្តល់សេវា( មន្ត្រី បុគ្គលិក អ្នកហាត់ការ ) និងអ្នកទៅទទួលសេវាជាជនមានពិការភាពនិងមិនពិការ
- ធានាថាផ្លូវបត់បែនខាងក្នុងមានទទឹងសមរម្យសម្រាប់អ្នកប្រើរទេះមើលឃើញច្បាស់និងមិនមានដាក់អ្វីនាំឱ្យទើស
- ត្រូវមានពណ៌នៅតាមផ្លូវចូលទៅការិយាល័យសម្រាប់អ្នកខ្សោយគំហើញ
- ប្រសិនបើមានអ្វីសំខាន់ចំបាច់ត្រូវដាក់នៅតាមផ្លូវសូមដាក់សញ្ញាប្រាប់ឱ្យដឹងផង







## ៣.១.២. ទិដ្ឋភាពខាងក្នុង (Internal Environment)





❖ ស្តង់ដានិងការណែនាំអំពីទិដ្ឋភាពខាងក្នុង

- ត្រូវឱ្យមានខ្យល់បរិសុទ្ធចេញចូលពន្លឺនិងកម្តៅសមរម្យ



- ធានាថាទីតាំងទាំងអស់ត្រូវបានថែទាំយ៉ាងប្រសើរ
- ត្រូវរៀបចំឱ្យមានពន្លឺចេញចូលច្បាស់និងឱ្យមានកន្លែងបញ្ជាតាមតម្រូវការម្នាក់ៗ

- រៀបចំបន្ទប់ដែលនៅឆ្ងាយពីកន្លែងដែលមានសំឡេងរំខានទាំងខាងក្នុង និងខាងក្រៅ
- រៀបចំបរិស្ថានខាងក្នុងដែលមានសំឡេងសមស្រប
- បន្ទប់ឬកន្លែងធ្វើការនីមួយៗត្រូវឌីហ្សាញទៅតាមគោលបំណងសម្រាប់ការងារដូចជាសម្រាប់ធ្វើការជាប្រចាំ សម្រាប់ប្រជុំ សម្រាប់សិក្ខាសាលា បណ្ដុះបណ្ដាលសម្រាប់ពិគ្រោះយោបល់។ល។
- បន្ទប់ធ្វើការជាក្រុម បន្ទប់ឯកត្តបុគ្គល( បុគ្គលិក មន្ត្រី មន្ត្រីជាន់ខ្ពស់ ថ្នាក់ដឹកនាំ )

### ៣.១.៣. កន្លែងធ្វើការនិងកន្លែងទុកសម្ភារៈ (Workstations and Storage)





❖ ស្តង់ដានិងការណែនាំអំពីកន្លែងធ្វើការនិងកន្លែងទុកសម្ភារៈ



- ធានាថាកន្លែងបំពេញការងារឬធ្វើការមានលក្ខណៈសមស្របសម្រាប់មនុស្សគ្រប់រូប
- រៀបចំសម្ភារៈបរិក្ខារនិងសង្ហារឹមផ្សេងៗទៅតាមតម្រូវការមនុស្សផ្សេងៗគ្នា
- កន្លែងធ្វើការនីមួយៗត្រូវតែអាចរៀបចំឬកែសម្រួលបាន
- សម្ភារៈបរិក្ខារនៅកន្លែងធ្វើការ( កៅអី តុ ទូ )ត្រូវមានរាងជាអក្សរអិល L (ជ្រុង )




- បើអាចជៀសវាងបានមិនត្រូវផ្តល់កន្លែងសម្រាប់ដាក់តុឱ្យបុគ្គលិកគ្រប់ៗគ្នាដែលនាំឱ្យចង្អៀតក្នុងករណីទីតាំងមិនសមាមាត្រទៅនឹងចំនួនបុគ្គលិក
- ធានាថាកន្លែងទុកសម្ភារៈគឺរចនាឡើងរឹងមាំ មានលំនឹង មានគែមមិនស្រួចងាយមុត មានពណ៌ ងាយមើល មានពន្លឺគ្រប់គ្រាន់ មានកម្ពស់និងទំហំសមរម្យដែលបុគ្គលិកទាំងអស់អាចចេញចូលនិងប្រើប្រាស់បាន
- បើមានទូឬឧបករណ៍ទុកដាក់សម្ភារៈច្រើនត្រូវឃ្លាតពីគ្នាយ៉ាងតិច១៤០០ម.មនិង១២០០ម.មដោយមិនគិតពីកន្លែងចូលជង្គង់
- មិនត្រូវមានអ្វីជាឧបសគ្គដាក់នៅតាមផ្លូវចេញចូលកន្លែងទុកសម្ភារៈឡើយ

## ៣.២. អគារសម្រាប់មធ្យោបាយដឹកជញ្ជូន (Transport Buildings)

អគារសម្រាប់មធ្យោបាយដឹកជញ្ជូនសំដៅដល់អគារដែលយានជំនិះឬមធ្យោបាយធ្វើដំណើរបម្រើជាសាធារណៈឈប់សំចតនិងចេញដំណើរដូចជាស្ថានីយរថយន្តក្រុង ស្ថានីយរថភ្លើង កំពង់ផែនិងព្រលានយន្តហោះជាដើម។ ការផ្តល់សេវាធ្វើដំណើរដែលរចនាឡើងជាសាកលគឺមិនមែនគិតត្រឹមតែចំណុច

មាត់ទ្វារនៃយានជំនិះដូចជារថយន្តក្រុង រថភ្លើង នាវានិងយន្តហោះនោះទេតែត្រូវគិតតាំងពីចំណុចដែលអ្នកដំណើរជាជនមានពិការភាពចាប់ផ្តើមចេញពីគេហដ្ឋាននៅក្នុងឬកំពុងជិះយានជំនិះនិងរហូតទៅដល់គោលដៅដែលគេចង់ទៅទោះនៅក្នុងចម្ងាយណាក៏ដោយ។



*រូបភាព ៣.២.១. បង្ហាញពីកៅអីអង្គុយរង់ចាំក្នុងស្ថានីយនិងចំណតរថយន្តក្រុង*



## ៣.២.១. ទីតាំង (Location)





❖ ស្តង់ដានិងការណែនាំអំពីទីតាំង

- សូមពិចារណាអំពីទីតាំងគឺត្រូវទាក់ទងទៅនឹងទីតាំងផ្សេងៗនិងសេវាសាធារណៈដែលមាននៅក្នុងសហគមន៍នោះដូចជាតំបន់មនុស្សច្រើនឬតំបន់គ្មានមនុស្សរស់នៅ
- ធានាថាអគារមធ្យោបាយធ្វើដំណើរផ្សេងៗគ្នាអាចនឹងត្រូវបានដាក់ឱ្យនៅជិតៗគ្នា
- គួរគិតគូរពីចំណតតាក់ស៊ីគ្រប់ប្រភេទនិងចំណតបន្ថែមផ្សេងៗទៀត
- ត្រូវធ្វើកន្លែងចតរថយន្តសម្រាប់ជនមានពិការភាពនៅស្ថានីយរថភ្លើងកំពង់ផែនិងព្រលានយន្តហោះ

### ៣.២.២. ទំហំនិងការរៀបចំ (Size and Layout)





❖ ស្តង់ដានិងការណែនាំអំពីទំហំនិងការរៀបចំ

- ធានាថាអគារត្រូវបានរៀបចំត្រូវទីតាំងមានលក្ខណៈសាមញ្ញ ងាយយល់និងជៀសវាងការធ្វើដំណើរវែងឆ្ងាយរបស់អ្នកដំណើរ




- ត្រូវប្រាកដថាសេវាកម្មនិងទីតាំងផ្សេងៗត្រូវបានរៀបចំនិងមើលឃើញបានច្បាស់
- រៀបចំកន្លែងអ្នកដំណើរនៅចំកណ្ដាលបំផុតតាមដែលអាចធ្វើបាន
- ធានាថាចំណតមកដល់មានដំបូលការពារភ្លៀងនិងកម្ដៅថ្ងៃខ្លាំង
- ត្រូវភ្ជាប់ជាមួយគ្រប់កន្លែងខាងក្រៅទាំងអស់រួមទាំងទីតាំងបរិវេណទាំងមូលនិងច្រកចូលត្រូវមានផ្លូវដែលអាចប្រើប្រាស់បានគ្រប់អ្នកដំណើរ (ធំទូលាយនិងមានសុវត្ថិភាព)

### ៣.២.៣. ទីកន្លែងសម្រាប់អ្នកដំណើរ (Passenger Facilities)



❖ ស្តង់ដានិងការណែនាំអំពីទីកន្លែងសម្រាប់អ្នកដំណើរ

- ត្រូវរៀបចំឱ្យមានកន្លែងអង្គុយសមរម្យនៅគ្រប់កន្លែងរង់ចាំទាំងអស់
- ធានាថាកន្លែងសម្រាប់ដាក់វ៉ាលីដែលភ្លេចគឺអាចមើលឃើញគ្រប់អ្នកដំណើរ( ស្លាកសញ្ញាធំ )
- ត្រូវសង់បង្គន់សម្រាប់ជនមានពិការភាពនៅកន្លែងដែលមានមនុស្សច្រើនជិតកន្លែងចេញដំណើរនិងកន្លែងមកដល់
- ត្រូវសង់បង្គន់ធំទូលាយដែលអ្នកដំណើរមានវ៉ាលីនិងមានកូនតូចៗអាចចូលប្រើប្រាស់បានស្រួល
- រៀបចំកន្លែងដែលអាចផ្លាស់ប្តូរសំលៀកបំពាក់ឬឧបករណ៍ជំនួយផ្សេងៗបាន
- នៅតាមបង្គន់គួរមានបិទប្រព័ន្ធអាសយដ្ឋាននិងព័ត៌មានសាធារណៈសំខាន់ៗ

### ៣.២.៤. ព័ត៌មានអំពីការធ្វើដំណើរ (Travel Information)



❖ ស្តង់ដានិងការណែនាំអំពីព័ត៌មានអំពីការធ្វើដំណើរ

- ត្រូវផ្តល់ព័ត៌មាននៃការធ្វើដំណើរគ្រប់ទម្រង់តាមដែលអាចធ្វើទៅបាន (សំឡេង រូបភាព...)
- ធានាថាព័ត៌មាននៃការធ្វើដំណើរទាំងអស់សាមញ្ញនិងងាយយល់បំផុត
- ធានាថាកាលវិភាគនៃការធ្វើដំណើររៀបចំបានជាក់លាក់ច្បាស់លាស់និងងាយមើល
- ត្រូវដាក់កាលវិភាគនៃការធ្វើដំណើរនៅតាមកន្លែងដែលសមរម្យបំផុត (ទីតាំង កម្ពស់និងទំហំ...)
- ត្រូវផ្តល់ព័ត៌មាននៃការធ្វើដំណើរតាមទម្រង់ជាជម្រើសរួមទាំងមានជាអក្សរធំៗតាមរយៈសេវាកម្មទូរស័ព្ទដៃនិងទូរស័ព្ទលើតុ
- ធានាថាតារាងតម្លៃនិងព័ត៌មាននៃការបង់ប្រាក់អាចមើលឃើញយ៉ាងច្បាស់
- ធានាភាពងាយយល់នៃព័ត៌មានអំពីកន្លែងរង់ចាំចេញដំណើរមាននៅគ្រប់កន្លែង ជាពិសេសមុនពេលចេញដំណើរក្នុងពេលសមរម្យមួយ
- ធានាថាព័ត៌មានអំពីកន្លែងមកដល់និងកន្លែងផ្ទេរជើងធ្វើដំណើរអាចរកបាននៅគ្រប់កន្លែង
- ធានាថាការផ្លាស់ប្តូរចុងក្រោយនៃព័ត៌មានធ្វើដំណើរមាននៅគ្រប់ទីកន្លែងនិងគ្រប់ទម្រង់
- រៀបចំពេលវេលាឱ្យសមរម្យសម្រាប់អ្នកដំណើរដែលត្រូវផ្ទេរជើងធ្វើដំណើរបន្ត
- ត្រូវមានរថយន្តតូចឬមធ្យោបាយផ្សេងទៀតសម្រាប់ដឹកអ្នកដំណើរនៅតាមកន្លែងមកដល់ដែលអាចជួយដល់អ្នកលំបាកដើរ កុមារនិងអ្នកដែលខ្សោយ

## ៣.៣. អគារមជ្ឈមណ្ឌលផ្សារទំនើបនិងកន្លែងលក់ដូរ

(Retail Outlets and Shopping Centers)






### ៣.៣.១. ផ្លូវបត់បែនខាងក្នុង (Internal Circulation)




❖ ស្តង់ដានិងការណែនាំអំពីផ្លូវបត់បែនខាងក្នុងនៃអគារមជ្ឈមណ្ឌលផ្សារទំនើបនិងកន្លែងលក់ដូរ

- រៀបចំកន្លែងលក់ដូរដែលមានផ្លូវចេញចូលសមរម្យ
- ធានាថាផ្លូវដើរទាំងអស់មិនមានឧបសគ្គនិងរៀបចំបានត្រឹមត្រូវ
- ធានាថាកន្លែងដែលអាចបណ្ដាលឱ្យមានគ្រោះថ្នាក់ត្រូវបានបង្ហាញឱ្យឃើញច្បាស់ជាសញ្ញាឬអក្សរ
- ធានាថាកន្លែងដាក់តាំងលក់និងកន្លែងផ្សេងៗទៀតមនុស្សគ្រប់គ្នាអាចចេញចូលនិងប្រើប្រាស់បាន

## ៣.៣.២. កន្លែងដាក់តាំងលក់និងកន្លែងទុកសម្ភារៈនៅក្នុងហាង

(Display and Storage in Shops)



*រូបភាព ៣.៣.២.១. បង្ហាញពីធ្នើរនៅតាមផ្សារទំនើប*



*រូបភាព ៣.៣.២.២. បង្ហាញពីផ្នែកខាងមុខទូទឹកកកនៅតាមផ្សារទំនើប*

❖ ស្តង់ដានិងការណែនាំអំពីកន្លែងដាក់តាំងលក់និងកន្លែងទុកសម្ភារៈនៅក្នុងហាង

- ធានាថាកន្លែងដាក់តាំងលក់រឹងមាំ មានលំនឹងនិងមានពន្លឺត្រឹមត្រូវ
- ប្រើទូទឹកកកនិងទូក្លាស្សេដែលមានទ្វាររូតបិទបើកដើម្បីងាយបើកយករបស់របរខាងក្នុង
- ជៀសវាងការប្រើប្រាស់កន្លែងដាក់តាំងដែលបញ្ឈរខ្ពស់ពេក
- រៀបចំដាក់តាំងនៅកន្លែងដែលគេអាចយកបានទាំងពេលអង្គុយនិងពេលឈរ

## ៣.៣.៣. បញ្ជរនិងកន្លែងបង់ប្រាក់មុនចេញ (Counters and Checkouts)



*រូបភាព ៣.៣.៣.១. បង្ហាញពីជនមានពិការភាពពិនិត្យអីវ៉ាន់នៅតាមផ្សារទំនើប*



*រូបភាព ៣.៣.៣.២. គំរូអំពីច្រកចេញដែលមានបញ្ជរពីរ*

❖ ស្តង់ដានិងការណែនាំអំពីបញ្ជរនិងកន្លែងបង់ប្រាក់មុនចេញ

- រចនាបញ្ជរផ្តល់សេវាដែលអាចឱ្យបុគ្គលិកនិងអតិថិជនអង្គុយនិងឈរទទួលនិងផ្តល់សេវាបាន
- រៀបចំឱ្យមានបញ្ជរផ្តល់សេវាដែលមានកម្ពស់ផ្សេងៗគ្នាសម្រាប់មនុស្សទាបនិងខ្ពស់ប្រើបាន
- ត្រូវមានទីធ្លាទំនេរទំហំ២៤០០ម.ម x ២៤០០ម.មនៅខាងមុខបញ្ជរផ្តល់សេវា
- ធានាថាគែមនៃបញ្ជរបង់ប្រាក់មានពណ៌ផ្សេងពីគេដើម្បីងាយចំណាំ
- ធានាថាច្រកចេញធំសមល្មមសម្រាប់គ្រប់អតិថិជននិងសម្រួលឱ្យមានកន្លែងយកអីវ៉ាន់បានទាំងខាងឆ្វេងនិងខាងស្តាំ
- រៀបចំប្រព័ន្ធបន្លឺសំឡេងនៅគ្រប់បញ្ជរបង់ប្រាក់

## ៣.៣.៤. បន្ទប់លសំលៀកបំពាក់

(Fitting Rooms)



❖ ស្តង់ដានិងការណែនាំអំពីបន្ទប់លសំលៀកបំពាក់

- ធានាថាបន្ទប់លសំលៀកបំពាក់មនុស្សគ្រប់គ្នាអាចចេញចូលប្រើប្រាស់បាន
- ត្រូវរៀបចំឱ្យមានបន្ទប់លសំលៀកបំពាក់ដែលអាចប្រើបានទាំងបុរសនិងស្ត្រីដូចក្នុងរូបភាព

*រូបភាព ៣.៣.៤.១. បង្ហាញពីប្លង់និងខ្នាតនៃបន្ទប់លសំលៀកបំពាក់*



- ត្រូវឱ្យមានទីធ្លាគ្រប់គ្រាន់នៅសងខាងទ្វារបន្ទប់លសំលៀកបំពាក់
- ត្រូវដាក់កញ្ចក់ពេញជំហរនិងទំពក់ព្យួរសម្លៀកបំពាក់ក្នុងកម្ពស់សមល្មម

### ៣.៣.៥. ឧបករណ៍បរិក្ខារនិងជំនួយនៅក្នុងហាង

(Equipment and Assistance in Shops)

*រូបភាព ៣.៣.៥.១. គំរូអំពីរទេះរុញប្រើថាមពលដែលមានចាប់កន្ត្រកដាក់អីវ៉ាន់នៅខាងមុខ*





❖ ស្តង់ដានិងការណែនាំអំពីឧបករណ៍បរិក្ខារជំនួយនៅក្នុងហាង

- ធានាថារទេះសម្រាប់រុញដឹកអីវ៉ាន់នៅក្នុងផ្សារអាចប្រើបានគ្រប់អតិថិជន
- ត្រូវគិតគូរត្រៀមឱ្យមានរទេះប្រើថាមពលនិងមានកន្ត្រកដាក់អីវ៉ាន់សម្រាប់អតិថិជនខ្ចីប្រើ
- ធានាថារទេះសម្រាប់រុញដឹកអីវ៉ាន់ថែទាំបានល្អ ស្អាតនិងស្ងួតជានិច្ច
- ត្រូវមានជញ្ជីងដែលអតិថិជនអាចថ្លឹងបានដោយខ្លួនឯងនិងធានាថាងាយប្រើប្រាស់
- ធានាឱ្យមានអ្នកជំនួយផ្ទាល់ខ្លួននៅពេលដែលអតិថិជនត្រូវការ

## ៣.៤. អគារភោជនីយដ្ឋាន បារនិងហាងកាហ្វេ

(Restaurants, Bars and Cafés)





អគារភោជនីយដ្ឋាន បារនិងហាងកាហ្វេសំដៅដល់ទីកន្លែងដែលអតិថិជនចូលទទួលទាននិងកម្សាន្តមានជាអាទិ៍ ហាងកាហ្វេ ភោជនីយដ្ឋាន កន្លែងទទួលទាន កន្លែងរាំ អាហារដ្ឋាន បារសាធារណៈនិងកន្លែងជួបជុំនៅក្នុងសណ្ឋាគារ។

### ៣.៤.១. ការដាក់តាំងនិងកន្លែងអង្គុយនៅក្នុងបារនិងភោជនីយដ្ឋាន

(Layout and Seating in Bars and Restaurants)



❖ ស្តង់ដានិងការណែនាំអំពីការដាក់តាំងនិងកន្លែងអង្គុយនៅក្នុងបារនិងភោជនីយដ្ឋាន

- ត្រូវរៀបចំកន្លែងដាក់តាំងឱ្យបានត្រឹមត្រូវដែលធានាបានដល់ការផ្តល់និងទទួលសេវាសម្រាប់មនុស្សគ្រប់គ្នា
- ធានាថាផ្លូវនិងច្រកដើររវាងកន្លែងអង្គុយមិនមានឧបសគ្គនិងមើលឃើញច្បាស់
- ដាក់សម្ភារៈបរិក្ខារនៅកម្ពស់ស្មើគ្នាដែលមានជាន់ថ្នាក់សមរម្យអាចប្រើបាន
- ធានាថាទាំងកន្លែងអង្គុយទាបនិងកន្លែងអង្គុយខ្ពស់ត្រូវមានជម្រាលនិងជណ្តើរ
- ត្រូវប្រាកដថាកន្លែងអង្គុយគ្រប់ប្រភេទអាចអង្គុយបានសម្រាប់មនុស្សគ្រប់គ្នា
- ត្រូវផ្តល់ជម្រើសដល់អតិថិជនគ្រប់រូបក្នុងការជ្រើសរើសកន្លែងអង្គុយតាមចំណង់របស់គេ
- ត្រូវមានតុនិងកៅអីដែលមានទំហំទទឹងត្រូវជាមួយអតិថិជនគ្រប់គ្នា
- ត្រូវប្រើកៅអីដែលអាចដោះដាក់បានប្រសិនបើប្រើជាមួយតុដែលចាប់ជាប់មួយកន្លែង
- ធានាថាតុនិងកៅអីមានពណ៌ខុសពីផ្ទៃជុំវិញ ( ជញ្ជាំងនិងកម្រាល )
- ត្រូវមានកៅអីខ្លះដែលមានធ្នាក់ដៃ

## ៣.៤.២. កន្លែងទទួលសេវាដោយខ្លួនឯង (Self-Service Facilities)




❖ ស្តង់ដានិងការណែនាំអំពីកន្លែងទទួលសេវាដោយខ្លួនឯង

- ធានាថាកន្លែងទទួលសេវាដោយខ្លួនឯងរៀបចំនៅកន្លែងសមស្របសម្រាប់បម្រើអតិថិជនដូចរូបនេះ



- គួររៀបចំឱ្យមានខ្សែគំនូសបន្ទាត់ឬបង្កាន់ដៃតម្រៀបជួរក្នុងករណីមានអតិថិជនច្រើនមកទទួលសេវា
- ត្រូវរៀបចំកន្លែងដាក់ថាសឬស្តុកសម្រាប់ដួសអាហារកម្ពស់៨៥០ម.មពីដី
- ត្រូវដាក់តាំងមុខម្ហូបគ្រប់មុខកម្ពស់១៣៧០ម.ម
- ទីធ្លាកន្លែងរង់ចាំទទួលយកអាហារត្រូវមានទំហំទទឹង១១០០ម.ម

### ៣.៤.៣. សេវាកម្មនិងការគ្រប់គ្រងអតិថិជន

(Customer Service and Management)



❖ ស្តង់ដានិងការណែនាំអំពីសេវាកម្មនិងការគ្រប់គ្រងអតិថិជន

- ធានាថាបុគ្គលិកទាំងអស់ត្រូវបានបណ្តុះបណ្តាលអំពីការស្វាគមន៍អតិថិជន
- ធានាថាផ្លូវនិងច្រកដើររវាងតុនីមួយៗទូលាយនិងមិនមានឧបសគ្គ
- បង្គន់ត្រូវឱ្យមានអនាម័យនិងមានសម្ភារៈប្រើប្រាស់ខាងក្នុងដូចជាក្រដាសអនាម័យ សាប៊ូនិងកន្សែង
- ត្រូវប្រើទូរស័ព្ទលើតុសម្រាប់ការទទួលកក់គ្រប់យ៉ាង
- ធានាថាបុគ្គលិកត្រូវបានបង្រៀនឱ្យចេះប្រើប្រាស់ទូរស័ព្ទលើតុនិងការបញ្ជាទូរស័ព្ទនោះ

### ៣.៤.៤. កន្លែងជក់បារីនៅខាងក្រៅ (Outdoor Smoking Areas)




*រូបភាព ៣.៤.៤.១. គំរូអំពីស្លាកសញ្ញាប្រាប់ទីតាំងកន្លែងជក់បារី*

- ស្តង់ដានិងការណែនាំអំពីកន្លែងជក់បារីនៅខាងក្រៅ
  - ធានាថាកន្លែងជក់បារីនៅខាងក្រៅអាចប្រើប្រាស់បានទាំងអស់គ្នានិងត្រូវមានទំហំតូចបំផុត២៤៤០ម.ម x ២៤៤០ម.ម
  - ធានាថាកន្លែងជក់បារីនៅខាងក្រៅងាយស្រួលចេញចូលបានដោយមានសញ្ញាងាយមើលឃើញច្បាស់

### ៣.៥. អគារសារមន្ទីរ សាលពិព័រណ៍និងបណ្ណាគារ

(Museums, Galleries and Libraries)





❖ ស្តង់ដានិងការណែនាំអំពីអគារសារមន្ទីរ សាលពិព័រណ៍និងបណ្ណាគារ

- ធានាថាការរៀបចំនិងរចនាអគារមានភាពងាយយល់ដោយមិនមានភាពស្មុគស្មាញ
- ធានាថាកន្លែងទុកដាក់សៀវភៅឬឯកសារងាយយកប្រើប្រាស់ទាំងបុគ្គលិកនិងភ្ញៀវ
- រៀបចំឱ្យមានកន្លែងដូចជាកន្លែងរង់ចាំ កន្លែងសម្រាកនិងកន្លែងទទួលទានអាហារសម្រន់ដែលអាចប្រើបានសម្រាប់គ្រប់គ្នា
- ធានាថាកន្លែងប្រើប្រាស់និងកន្លែងដាក់តាំងផ្សេងៗទៀតអាចប្រើបានគ្រប់ៗគ្នា
- ត្រូវមានការជូនដំណឹងជាមុនសម្រាប់ផ្លូវដែលវែងរវាងអគារមួយទៅអគារមួយ
- ត្រូវមានរទេះរុញជនមានពិការភាពសម្រាប់ឱ្យខ្ចីប្រើប្រាស់ក្នុងអគារ
- ត្រូវរៀបចំឱ្យមានកន្លែងអង្គុយស្មើគ្នាពីមួយទៅមួយតាមបណ្តោយផ្លូវខាងក្នុងអគារ
- ធានាថាព័ត៌មានដែលផ្តល់ជូនភ្ញៀវតាមទម្រង់ផ្សេងៗដែលអាចទទួលយកបាន

### ៣.៥.១. ព័ត៌មាននិងការបកប្រែ (Information and Interpretation)



❖ ស្តង់ដានិងការណែនាំអំពីព័ត៌មាននិងការបកប្រែ

- ធានាថាមានព័ត៌មានគ្រប់ទម្រង់អំពីទីកន្លែងបានរៀបចំសម្រាប់ភ្ញៀវជាជនមានពិការភាពគ្រប់ប្រភេទ
- ត្រូវមានផែនទីអគារនិងទីតាំងផ្សេងៗទៀតដែលមានការបញ្ជាក់ឈ្មោះនិងកន្លែងច្បាស់លាស់
- គួរឱ្យមានផែនទីដែលជនមានពិការភាពភ្នែកអាចស្ទាបដឹងបាននិងអាចជួយណែនាំផ្លូវដល់គេ
- ត្រូវមានការណែនាំជាសំឡេងដើម្បីជួយដល់ជនមានពិការភាពភ្នែកនិងមនុស្សមួយចំនួនទៀតដែលត្រូវការ
- រៀបចំប្រព័ន្ធបន្ថែមបន្លយសំឡេងសម្រាប់មនុស្សផ្សេងៗដែលត្រូវការ
- ដាក់ឧបករណ៍បំពងសំឡេងនៅតាមទីតាំងដែលសមស្របនឹងទីតាំងនិងស្ថានភាពអគារ
- គួរពិចារណាប្រើប្រាស់ប្រព័ន្ធសំឡេងផ្សេងៗគ្នាដើម្បីជាជម្រើសសម្រាប់មនុស្សផ្សេងគ្នាទៅតាមទីតាំង

### ៣.៥.២. ការដាក់តាំងនិងពិព័រណ៍ (Displays and Exhibits)





❖ ស្តង់ដានិងការណែនាំអំពីការដាក់តាំងនិងពិព័រណ៍

- ត្រូវបំពាក់កញ្ចក់ដែលមិនចាំងផ្លាតនៅក្នុងបន្ទប់ដាក់តាំង
- ត្រូវប្រើភ្លើងបណ្តោះអាសន្ននៅតាមផ្លូវទៅកាន់កន្លែងដែលងងឹត
- គួរពិចារណាប្រើពន្លឺភ្លើងឆ្នូតៗនៅតាមកម្រាល
- ត្រូវមានកន្លែងដាក់ជើងសម្រាប់អ្នកប្រើរទេះអាចប្រើប្រាស់ឧបករណ៍ខាងក្នុងបាន
- ត្រូវចាប់វត្ថុដាក់តាំងឬឧបករណ៍ទាំងឡាយលើផ្ទាំងរាងទេរនិងមិនខ្ពស់ជាង១០០០ម.មពីដី
- ធានាថាឡាបែល( ស្លាកឃីហោ )ពិព័រណ៍ទាំងអស់ងាយអាននិងមិនត្រូវឱ្យបាំងទេ
- ត្រូវចាប់ឡាបែលតាមកន្លែងដាក់តាំងនៅកម្ពស់៤៥ដឺក្រេ
- អក្សរដែលសរសេរនៅក្នុងឡាបែលគឺត្រូវសរសេរទំហំតូចបំផុត១៨ជាអក្សរតូចនិងទំហំ១៤ជាអក្សរធំ
- ត្រូវសរសេរអក្សរផុសឱ្យបានច្រើនកន្លែងតាមដែលអាចធ្វើបាន
- ការសរសេរគួរតែមានគ្រប់ទម្រង់ជាការប្រសើរ
- គួរតែមានកញ្ចក់ពង្រីកចំនួនច្រើនសម្រាប់ខ្វីប្រើប្រាស់ពេលត្រូវការ
- គួររៀបចំឱ្យមានរូបភាព ក្រាហ្វិកនិងព័ត៌មានផុសអាចស្ទាបដឹងបាន

### ៣.៥.៣. កន្លែងសិក្សា (Study Areas)



*រូបភាព ៣.៥.៣.១. គំរូអំពីកន្លែងសិក្សា*

❖ ស្តង់ដានិងការណែនាំអំពីកន្លែងសិក្សា

- រៀបចំកន្លែងសិក្សាដែលអាចប្រើបានទាំងអស់គ្នាគឺនៅជិតសៀវភៅនិងឯកសារស្រាវជ្រាវផ្សេងៗទៀត
- គ្រប់តុទាំងអស់ត្រូវតែអាចប្រើប្រាស់បានទាំងអស់គ្នាគឺដូចរូបនេះ




- តុសិក្សាដែលអាចអង្គុយទល់មុខគ្នាត្រូវមានទំហំអប្បបរមាបណ្ដោយ ១៨០០ម.ម x ទទឹង១១០០ម.ម
- តុសិក្សាដែលអាចអង្គុយបានតែម្នាក់ត្រូវមានទំហំអប្បបរមាបណ្ដោយ ១៨០០ម.ម x ទទឹង៦០០ម.ម
- តុសិក្សាត្រូវមានកម្ពស់៧០០ម.មទៅ៨០០ម.មលៃយ៉ាងណាឱ្យអ្នកប្រើរទេះអាចអង្គុយបាន
- ត្រូវទុកចន្លោះពីតុទៅជញ្ជាំងឬទូសៀវភៅទំហំ១០៥០ម.មសម្រាប់រទេះចេញចូល
- ត្រូវរក្សាចន្លោះរវាងពីតុមួយទៅតុមួយទំហំ១៥៥០ម.ម
- ត្រូវគិតពីសម្ភារៈដែលប្រើដោយចន្លោះអគ្គិសនីត្រូវគ្នានឹងកម្ពស់តុ

- ត្រូវមានព្រីភ្លើងនិងអំពូលនៅតាមកន្លែងសិក្សាស្រាវជ្រាវទាំងអស់
- ធានាថាកញ្ចក់កុំព្យូទ័រអាចសម្រួលទាបខ្ពស់ចុះឡើងបានតាមមនុស្សត្រូវការ
- គួរតែពិចារណាផ្តល់នូវបច្ចេកវិទ្យាជំនួយផ្សេងៗ

### ៣.៥.៤. ធ្នើរនៃបណ្ណាល័យ (Library Shelving)



*រូបភាព ៣.៥.៤.១. គំរូអំពីការរៀបចំដាក់តាំងទូសៀវភៅ*



*រូបភាព ៣.៥.៤.២. គំរូជម្រើសផ្សេងទៀតនៃការរៀបចំដាក់តាំងទូសៀវភៅ*

❖ ស្តង់ដានិងការណែនាំអំពីធ្នើរនៃបណ្ណាល័យ

- ត្រូវរៀបចំធ្នើរបណ្ណាល័យជាជួរស្របៗគ្នានិងឱ្យមានចន្លោះសមរម្យពីមួយទៅមួយ
- គម្លាតរវាងធ្នើរមួយទៅធ្នើរមួយ ពីថ្នាក់មួយទៅថ្នាក់មួយ ពីធ្នើរទៅជញ្ជាំង និងពីធ្នើរទៅកន្លែងដាក់វត្ថុផ្សេងៗគួរតែមានចន្លោះ១៤០០ម.ម
- អ្នកឌីហ្សាញគួរតែដឹងពីការរៀបចំកម្ពស់ធ្នើរនិងថ្នាក់នីមួយៗ
- ត្រូវមានកន្លែងចូលជង្គង់សម្រាប់អ្នកប្រើរទេះទំហំ១២០០ម.ម

## ៣.៦. អគារសម្រាប់កម្សាន្ត សាលប្រជុំនិងបណ្តុះបណ្តាល

(Entertainment, Conference and Lecture Facilities)

អគារសម្រាប់កម្សាន្ត សាលប្រជុំនិងសាលបណ្តុះបណ្តាលសំដៅលើអគារមហោស្រព រោងភាពយន្ត អគារប្រគុំតន្ត្រីនិងអគារបណ្តុះបណ្តាលដែលគ្រប់អគារទាំងនេះត្រូវមានកន្លែងអង្គុយទស្សនាឬស្តាប់ទីកន្លែងសម្រាប់វាគ្មិនឬអ្នកសម្តែងនិងទីតាំងគាំទ្របន្ទាប់បន្សំមួយចំនួនទៀតនៅពីមុខ ពីចំហៀងឬពីក្រោយឆាក។




❖ ស្តង់ដានិងការណែនាំអំពីអគារសម្រាប់កម្សាន្ត សាលប្រជុំនិងសាលបណ្តុះបណ្តាល
- ទីកន្លែងសម្រាប់ទស្សនិកជន អ្នកចូលរួមប្រតិភូនិងសមាជិកទាំងអស់ដូចជា៖ គ្រូឧទ្ទេស គ្រូបណ្តុះបណ្តាល អ្នកសម្តែង បុគ្គលិកគាំទ្របច្ចេកទេស អ្នកទស្សនា ត្រូវតែឱ្យបាញសម្រាប់ជាសាកល
- ការរៀបចំកន្លែងគាំទ្របន្ទាប់បន្សំដូចជាបង្គន់ កន្លែងអាហារសម្រន់ កន្លែងទទួលភ្ញៀវ ផ្នែកខាងក្រោយឆាក/វេទិកាត្រូវតែរៀបចំសម្រាប់ការចូលរួមបានពេលពេញរបស់មនុស្សគ្រប់រូប

- គ្រប់ឆាកឬវេទិកាដែលសង់ខ្ពស់ពីដីត្រូវមានជម្រាល( ជាប់ឬចល័ត ) សម្រាប់ចុះឡើងបានស្រួល
- គ្រប់ទីតាំង/បន្ទប់ប្រើប្រាស់នៃអគារទាំងអស់ខាងលើត្រូវរៀបចំប្រព័ន្ធសំឡេងដើម្បីជាជំនួយក្នុងការស្តាប់

### ៣.៦.១. កន្លែងអង្គុយសម្រាប់អ្នកទស្សនា (Audience Seating)



❖ ស្តង់ដានិងការណែនាំអំពីកន្លែងអង្គុយសម្រាប់អ្នកទស្សនា

- ធានាឱ្យមានកន្លែងអង្គុយតាមជួរបន្ទាត់និងស្ថានភាពត្រឹមត្រូវ
- ធានាផ្លូវទៅកាន់កន្លែងអង្គុយមិនមានឧបសគ្គនិងមានសញ្ញាច្បាស់លាស់
- ត្រូវរៀបចំឱ្យមានច្រកចេញចូលឱ្យដល់សម្រាប់អ្នកជិះរទេះ
- រៀបកន្លែងផ្សេងៗគ្នាទៅតាមទីតាំងទស្សនាដើម្បីជាជម្រើសសម្រាប់ទស្សនិកជន
- រៀបចំឱ្យមានកន្លែងអាចអង្គុយ២នាក់បានសម្រាប់អ្នកប្រើរទេះដូចក្នុងរូបភាពនេះ

*រូបភាព៣.៦.១.១. បង្ហាញពីទំហំសមរម្យសម្រាប់អ្នកប្រើរទេះប្រើប្រាស់*




- ធានាថាកន្លែងទស្សនាអាចមើលឃើញទាំងអស់គ្នាគឺក្រោយខ្ពស់មុខទាប
- ត្រូវមានបង្កាន់ដៃការពារនៅគ្រប់កន្លែងដែលចុះឬឡើងទាំងអស់
- ធានាថាមានទីធ្លាសមរម្យអាចចេញចូលនិងប្រើប្រាស់បង្គន់នៅគ្រប់ជាន់នៃអគារ
- ធានាថាកៅអីឬកន្លែងអង្គុយគ្រប់កន្លែងត្រូវមានពណ៌ផ្ទុយគ្នាជាមួយនឹងបរិវេណជុំវិញ
- ត្រូវរៀបចំឱ្យមានកៅអីដែលអាចដោះចេញឬបត់ចុះឡើងបានសម្រាប់មនុស្សគ្រប់រូបប្រើបាន
- គួររៀបចំឱ្យមានបង្គន់បានច្រើនសម្រាប់មនុស្សច្រើនប្រើជាពិសេសនៅពេលសម្តែង
- ធានាថាបង្គន់ទាំងអស់មានសញ្ញាបង្ហាញច្បាស់លាស់និងមានអនាម័យ

## ៣.៦.២. កន្លែងសម្រាប់អ្នកសម្តែង

(Performers' Facilities)



❖ ស្តង់ដានិងការណែនាំអំពីកន្លែងសម្រាប់អ្នកសម្តែង

- ធានាថាផ្នែកខាងក្រោយនៃឆាកសម្តែងត្រូវបានរចនាឡើងជាសាកល
- ធានាថាច្រកចូលឬទ្វារចេញចូលផ្នែកខាងក្រោយនៃឆាកសម្តែងមនុស្សគ្រប់គ្នាប្រើបាន
- ធានាថាទីតាំងច្រកផ្លូវរវាងផ្ទះនិងផ្នែកខាងក្រោយឆាកមានលក្ខណៈងាយស្រួលនិងមានសញ្ញាច្បាស់
- គួរផ្តល់ឱ្យមានបន្ទប់ផ្លាស់សំលៀកបំពាក់និងបន្ទប់អនាម័យដែលមនុស្សគ្រប់គ្នាអាចប្រើបាន

## ៣.៦.៣. កន្លែងសម្រាប់វាគ្មិនឬគ្រូឧទ្ទេស (Speakers' Facilities)



❖ ស្តង់ដានិងការណែនាំអំពីកន្លែងសម្រាប់វាគ្មិនឬគ្រូឧទ្ទេស

- ត្រូវមានតុសម្រាប់ឈរបង្រៀនដែលមានកម្ពស់អាចលើកឡើងដាក់ចុះបានមានបាតសម្រាប់ដាក់សៀវភៅរាងទ្រេតបន្តិចនិងគែមខាងមុខមានកម្ពស់ពី៨០០ម.មទៅ១១០០ម.ម
- ធានាថាតុសម្រាប់ដាក់កុំព្យូទ័រយួរដៃនិងម៉ាស៊ីនបញ្ចាំងស្លាយមិនត្រូវខ្ពស់ជាង៨០០ម.មទេ
- ត្រូវមានតុសម្រាប់វាគ្មិនឬគ្រូឧទ្ទេសដែលមានកម្ពស់បាតខាងលើ៧៦០ម.មនិងទុកខាងក្រោមប្រហោងត្រឹម៧០០ម.មចុះក្រោមសម្រាប់អ្នកប្រើផ្សេងៗគ្នា
- ធានាថាកន្លែងដែលវាគ្មិនឬគ្រូឧទ្ទេសឡើងនិយាយ(Platforms and Podiums) មានជម្រាលឬជណ្តើរដែលអាចប្រើបានគ្រប់ៗគ្នា
- ធានាថាក្រណាត់បញ្ចាំងដាក់នៅកម្ពស់និងចម្ងាយសមរម្យដែលអាចមើលឃើញគ្រប់គ្នា

## ៣.៧. អគារសាសនា (Religious Buildings)

  

❖ ស្តង់ដានិងការណែនាំអំពីអគារសាសនា

- រៀបចំអគារនិងទីតាំងសាសនាដើម្បីឱ្យសាសនិកជនគ្រប់គ្នាអាចចូលរួមគ្រប់សកម្មភាពសាសនាតាមជំនឿរបស់គេម្នាក់ៗ
- គ្រប់វត្តអារ៉ាមនិងវិហារសាសនាទាំងអស់ត្រូវមានជម្រាលនៅគ្រប់កន្លែងដែលសង់ខ្ពស់ពីដី
- កន្លែងផ្សេងៗទៀតដូចជាកន្លែងរង់ចាំ សួនច្បារ កន្លែងទទួលទាន ចំណតយានយន្ត បន្ទប់ទឹក បង្គន់។ល។ ត្រូវសាងសង់សម្រាប់មនុស្សគ្រប់រូបអាចប្រើបានរួមទាំងជនមានពិការភាព មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះនិងកុមារផង
- ត្រូវរៀបចំឱ្យមានកន្លែងផ្សេងគ្នាទៅតាមទម្រង់នៃការប្រតិបត្តិសាសនាតាមជំនឿជាពិសេសសម្រាប់អគារសាសនាចាស់ៗគួរកែសម្រួលឬកាត់បន្ថយឧបសគ្គឱ្យបានជាអតិបរមា
- គួរប្រើកៅអីដែលដកដាក់បានដើម្បីផ្តល់ជម្រើសនិងឱកាសដល់មនុស្សគ្រប់រូបចូលរួមបាន

### ៣.៧.១. កន្លែងសម្រាប់អ្នកអង្គុយឬអ្នកបួងសួង

(Facilities for Seating and Prayer)





❖ ស្តង់ដានិងការណែនាំអំពីកន្លែងសម្រាប់អ្នកអង្គុយឬអ្នកបួងសួង

- គួរផ្តល់ជម្រើសស្ថានភាពកន្លែងអង្គុយដល់គ្រប់សាសនិកជនគ្រប់គ្នា
- ត្រូវបន្ថែមទីធ្លាសម្រាប់អ្នកប្រើប្រាស់រទេះ ឪពុកម្តាយដែលមានរទេះទារក និងអ្នកប្រើឧបករណ៍ជំនួយដើរ
- ត្រូវរៀបចំឱ្យមានកន្លែងទាបនៅក្នុងអគារបន់ស្រន់ដើម្បីឱ្យអ្នកដែលអង្គុយ បន់ស្រន់បានដូចអ្នកឈរដែរ

### ៣.៧.២. កន្លែងផ្សេងៗទៀតនៅក្នុងអគារសាសនា

(Other Facilities in Religious Buildings)



❖ ស្តង់ដានិងការណែនាំអំពីកន្លែងផ្សេងៗទៀតក្នុងអគារសាសនា

- រៀបចំវេទិកាសម្រាប់ឈរនិយាយនិងតុឈរតាមស្តង់ដា
- រៀបចំប្រព័ន្ធសំឡេងសម្រាប់ស្តាប់តាមស្តង់ដា
- រៀបចំបង្គន់តាមស្តង់ដា

## ៣.៨. អគារសណ្ឋាគារ ផ្ទះសំណាក់និងអគារស្នាក់នៅ

(Hotel, Guest and Residential Accommodation)

 

❖ ស្តង់ដានិងការណែនាំអំពីអគារសណ្ឋាគារ ផ្ទះសំណាក់និងអគារស្នាក់នៅ

- ធានាថាគ្រប់ទីតាំងទាំងអស់នៅតាមអគារស្នាក់នៅអាចប្រើប្រាស់បានសម្រាប់គ្រប់ៗគ្នា
- ក្នុងករណីអគារមានបន្ទប់ស្នាក់នៅច្រើនគួរតែរៀបចំឱ្យមនុស្សគ្រប់គ្នាអាចប្រើបាន
- គួរតែរចនាបន្ទប់ស្នាក់នៅដែលមានទ្វារចេញចូលពីបន្ទប់មួយទៅបន្ទប់មួយទៀតជាជម្រើសភ្ញៀវ
- ធានាថាទីកន្លែងធ្វើការរបស់បុគ្គលិកត្រូវបានរចនាជាសាកល
- ធានាថាត្រូវមានកន្លែងចម្អិនអាហារដោយខ្លួនឯងសម្រាប់ភ្ញៀវនៅតាមបន្ទប់ស្នាក់នៅនីមួយៗ
- ត្រូវមានចំណតសម្រាប់ជនមានពិការភាពតាមការកំណត់
- ផ្លូវពីចំណតទៅកន្លែងទទួលភ្ញៀវងាយស្រួលសម្រាប់ទាំងអស់គ្នា
- ផ្លូវពីកន្លែងទទួលភ្ញៀវទៅបន្ទប់គេងងាយស្រួល
- ត្រូវមានរទេះជនមានពិការភាពរក្សាទុកសម្រាប់ភ្ញៀវខ្ចីប្រើប្រាស់អំឡុងពេលស្នាក់នៅ

- ត្រូវបំពាក់ស្លាកសញ្ញាច្បាស់ៗដែលអាចមើលឃើញទាំងពេលថ្ងៃនិងយប់ ដើម្បីបង្ហាញអំពីទីតាំងនីមួយៗនិងដាក់នៅគ្រប់ទីកន្លែង
- ធានាថាអាងហែលទឹកសាធារណៈជនមានពិការភាពគ្រប់ប្រភេទនិងកុមារអាចប្រើប្រាស់បាន

### ៣.៨.១. បន្ទប់គេង (Bedrooms)





❖ ស្តង់ដានិងការណែនាំអំពីបន្ទប់គេង

*រូបភាព ៣.៨.១.១. គំរូអំពីការរៀបចំបន្ទប់គេងដែលមានគ្រែពីរ*



- ចំណុច A ជាទីធ្លាសម្រាប់រទេះបត់បែននិងឡើងចុះគ្រែដែលមានទំហំ ១៨០០ម.ម x ១៨០០ម.ម
- ចំណុច B មានទំហំ២២៥០ម.ម x ២១០០ម.មជាទីធ្លាបន្ថែមសម្រាប់ប្រើប្រាស់ឧបករណ៍ស្ទូច ជនមានពិការភាពចុះឡើងពីរទេះទៅគ្រែ
- ចំណុច C គឺជាបង្អួចដែលត្រូវរៀបចំនៅកម្ពស់៨០០ម.មទៅ១០០០ម.ម ដើម្បីអាចមើលខាងក្នុងនិងខាងក្រៅបាន
- ចំណុច D គឺជាតុនៅក្នុងបន្ទប់គេងដែលមានកម្ពស់៧០០ម.ម ទៅ៨០០ម.មនិងធានាថាជនមានពិការភាពជិះរទេះអាចចូលជង្គង់បាន
- ចំណុច E គឺជាទូសម្រាប់ដាក់សម្លៀកបំពាក់ដែលមានខណ្ឌជាថ្នាក់ៗ
- ចំណុច F គឺជាទីធ្លាទំនេរទំហំទទឹង៦០០ម.មពីទ្វារមកជញ្ជាំងបន្ទប់ទឹក
- ចំណុច G គឺជាបន្ទប់ទឹកដែលបានបង្កលក្ខណៈងាយស្រួលសម្រាប់ទាំងអស់គ្នា
- ចំណុច H គឺជាទីធ្លាទំនេររវាងគ្រែមួយទៅគ្រែមួយដែលមានទំហំ ៩០០ម.ម សម្រាប់រទេះចូលឬសម្រាប់អ្នកជួយលើកដាក់ជនមានពិការភាព

*រូបភាព ៣.៨.១.២ គំរូអំពីការរៀបចំបន្ទប់ងូតទឹកដែលមានចានបង្គន់ខាងក្នុង*



- ចំណុច A គឺជាផ្ទាក់ដៃអង្កត់ផ្ចិត៤ទំហំ៣៥ម.មផ្ដេកស្របតាមជញ្ជាំង
- ចំណុច B គឺជាខ្សែទាញប្រកាសអាសន្ន។
- ចំណុច C គឺជាកៅអីដែលអាចបត់បាននៅក្នុងកន្លែងងូតទឹក
- ចំណុច D គឺជាផ្ទាក់ដៃអាចបត់បាននៅជិតបង្គន់ជុះ
- ចំណុច E គឺជាវាំងននបាំងកន្លែងងូតទឹក
- ចំណុច F គឺជាផ្ទាក់ដៃអង្កត់ផ្ចិត៤ទំហំ៣៥ម.មបញ្ឈរស្របតាមជញ្ជាំង
- ចំណុច G គឺជាធ្នើរកម្ពស់៩៥០ម.មដាក់នៅជិតជញ្ជាំងសម្រាប់ដាក់អីវ៉ាន់
- ចំណុច H គឺជាបាសាំងទឹកសម្រាប់ចានបង្គន់
- ចំណុច I គឺជាផ្ទាក់ដៃចាប់ផ្ដេកភ្ជាប់ជាមួយទ្វារសម្រាប់ទាញទ្វារបិទ
- ចំណុច J គឺជាទំពក់សម្រាប់ព្យួរសម្លៀកបំពាក់ចាប់ជាប់ជញ្ជាំងកម្ពស់ ១០៥០ម.មទៅ១៧០០ម.ម
- ចំណុច K គឺជាកន្លែងព្យួរកន្សែងចាប់ជាប់ជញ្ជាំងកម្ពស់១០៥០ម.មទៅ ១៧០០ម.ម
- ចំណុច L គឺជាបាសាំងលាងដៃ
- ធានាឱ្យមានជម្រើសសម្រាប់រាល់ទម្រង់នៃបន្ទប់គេងទៅតាមតម្រូវការភ្ញៀវ
- គ្រប់សណ្ឋាគារឬផ្ទះសំណាក់ដែលមានបន្ទប់ចាប់ពី១៥បន្ទប់ត្រូវមាន បន្ទប់គេងធំមួយសម្រាប់អ្នកប្រើរទេះឬអ្នកប្រើឧបករណ៍ជំនួយដើរ។ល។

*រូបភាព ៣.៨.១.៣. គំរូអំពីជម្រើសផ្សេងៗទៀតនៃការរៀបចំបន្ទប់គេងដែលមានបង្គន់ខាងក្នុង*




- ចំណុច A ជាទីធ្លាសម្រាប់រទេះបត់បែននិងឡើងចុះគ្រែដែលមានទំហំ ១៨០០ម.ម x ១៨០០ម.ម
- ចំណុច B មានទំហំ២២៥០ម.ម x ២១០០ម.មជាទីធ្លាបន្ថែមសម្រាប់ប្រើប្រាស់ឧបករណ៍ស្ទូច ជនមានពិការភាពចុះឡើងពីរទេះទៅគ្រែ
- គ្រែគេងគួរមានកម្ពស់ពី៤៥០ម.មទៅ៤៨០ម.ម( គិតពីដីទៅផ្នែកខាងលើនៃកម្រាលពូក )គ្រែនោះត្រូវមានតែមរឹង
- ក្នុងករណីដែលមានបន្ទប់សម្រាប់អ្នកប្រើរទេះច្រើនជាង១ គួររៀបចំឱ្យមានបន្ទប់សម្រាប់អ្នកប្រើឆ្វេងនិងបន្ទប់អ្នកប្រើស្តាំជាជម្រើសផង
- ធានាថាបន្ទប់នីមួយៗស្អាត មានអនាម័យ មានសុវត្ថិភាពនិងងាយស្រួលដូចៗគ្នាទាំងអស់
- រៀបចំកែសម្រួលបន្ទប់គេងដែលមានស្រាប់សម្រាប់ជនមានពិការភាពអាចប្រើបាន ជាពិសេសគឺមានជណ្តើរយោងនៅជិត
- ធានាថាបន្ទប់គេងមិនមានសំឡេងរំខានដូចជាសំឡេងយានយន្តនិងម៉ាស៊ីនផ្សេងៗ
- ធានាឱ្យមានពន្លឺថ្ងៃ ខ្យល់ចេញចូលនិងអាចមើលទៅក្រៅបានតាមបង្អួច

នៃបន្ទប់គេងនីមួយៗ
- ត្រូវចាប់ដៃទ្វារបង្អួចកម្ពស់ពី៨០០ម.មទៅ១០០០ម.មពីដីនិងធានាថាវាធូរងាយបិទបើក
- មិនត្រូវដាក់របាររាំងននទៅដល់ដីទេដោយរក្សាទុកត្រឹមកម្ពស់៩០០ម.មទៅ១២០០ម.ម
- ត្រូវបំពាក់ពន្លឺសិប្បនិម្មិតដែលមានពណ៌ស្អាតនិងងាយស្រួលអាចបន្ថែមបន្ថយបាន
- បំពាក់អំពូលភ្លើងសម្រាប់អានឬធ្វើការនៅជិតតុទាំងអស់រួមទាំងទូសម្លៀកបំពាក់ផង
- ធានាថាគ្រប់ពន្លឺទាំងអស់មានកន្លែងបិទបើកដែលមានសុវត្ថិភាពបំផុត
- ចំពោះអំពូលភ្លើងធម្មតាត្រូវរៀបឱ្យមានប្រព័ន្ធបិទបើក២កន្លែងដែលគេអាចបិទបើកបាននៅពេលចូលបន្ទប់ដំបូងនិងអាចបិទបើកបាននៅឯគ្រែគេង
- ធានាថាឧបករណ៍និងសេវាទាំងអស់នៅក្នុងបន្ទប់អាចបញ្ជាបានក្នុងស្ថានភាពអង្គុយនិងងាយប្រើប្រាស់
- គួររៀបចំឱ្យមានឧបករណ៍បញ្ជាពីចម្ងាយសម្រាប់គ្រប់ឧបករណ៍ដែលប្រើអគ្គិសនីទាំងអស់
- ធានាឱ្យមានខ្យល់បរិសុទ្ធចេញចូលនៅគ្រប់បន្ទប់គេង
- ធានាថាគ្រប់ទ្វារបន្ទប់គេងទាំងអស់ងាយស្រួលបិទបើកសម្រាប់មនុស្សគ្រប់គ្នា
- គួរប្រើកាតបិទបើកទ្វារ (ប្រើអគ្គិសនី)និងទ្វារបិទបើកស្វ័យប្រវត្តិ
- ជ្រើសរើសគ្រែគេងសម្រាប់បន្ទប់គេងឱ្យបានត្រឹមត្រូវដែលអ្នកប្រើរទេះងាយផ្ទេរពីរទេះ ជាពិសេសអ្នកមានបញ្ហាផ្លាស់ទី
- គួររៀបចំកន្លែងព្យួរសម្លៀកបំពាក់នៅកម្ពស់ដែលមនុស្សគ្រប់រូបអាចប្រើបាន

- ត្រូវមានឧបករណ៍ជំនួយស្តាប់ពេលមើលទូរទស្សន៍នៅពេលមានការស្នើសុំ
- បំពាក់ឧបករណ៍ជំនួយពេលមានសញ្ញាអាសន្ននៅគ្រប់បន្ទប់គេង

### ៣.៨.២. បន្ទប់ទឹក (Bathrooms)



❖ ស្តង់ដានិងការណែនាំអំពីបន្ទប់ងូតទឹក

- រៀបចំឱ្យមានបន្ទប់ងូតទឹកដែលអាចប្រើបានសម្រាប់ទាំងអស់គ្នានៅតាមបន្ទប់គេងនីមួយៗ
- ប្រសិនបើនៅក្នុងបន្ទប់គេងគ្មានបន្ទប់ងូតទឹកសម្រាប់មនុស្សស្រីនិងប្រុសទេចូររៀបចំឱ្យមាននៅជិតបន្ទប់គេងបំផុត
- គួររៀបចំបន្ទប់អនាម័យសម្រាប់បុគ្គលិកនៅដាច់ពីបន្ទប់អនាម័យសម្រាប់ភ្ញៀវ
- នៅគ្រប់កន្លែងទាំងអស់ ទាំងបន្ទប់គេង បន្ទប់ទទួលភ្ញៀវនិងបន្ទប់ទឹកគឺត្រូវតែងាយចេញចូលពីផ្លូវខាងក្រៅ
- ប្រសិនបើមានរៀបចំបន្ទប់ទឹករួមច្រើនកន្លែងត្រូវមានបន្ទប់ខ្លះសម្រាប់អ្នកប្រើប្រាស់រទេះនិងជនមានពិការភាពប្រើឧបករណ៍ជំនួយដើរ
- សូមមើលបន្ថែមលម្អិតអំពីស្តង់ដាបន្ទប់ទឹក

## ៣.៩. អគារលំនៅឋាន (Housing)





អគារលំនៅឋានសំដៅដល់គ្រប់អគារលំនៅឋានថ្មី អគារលំនៅឋានកំពុងជួសជុលនិងអគារលំនៅឋានកែលម្អបន្ថែមត្រូវតែមានការរចនាជាសាកលដែលសមស្របទៅតាមតម្រូវការប្រើប្រាស់ផ្សេងៗគ្នារបស់អ្នកស្នាក់នៅឬភ្ញៀវ។

### ៣.៩.១. ទិដ្ឋភាពខាងក្រៅលំនៅឋាន (External Environment)

❖ ស្តង់ដានិងការណែនាំអំពីទិដ្ឋភាពខាងក្រៅផ្ទះ

- ប្រសិនបើផ្ទះនីមួយៗមានច្រកចូលខាងមុខរបងច្រកនោះគួរមានទំហំទីធ្លាសម្រាប់បិទបើកទ្វារដូចខាងក្រោម៖

| ខ្នាតទទឹងតូចបំផុតនៃទ្វារធំពេលបើក | ទិសនៃការបិទបើកទ្វារនិងទទឹងនៃផ្លូវដើរ |
|---|---|
| ៨០០ ម.ម | បិទបើកទៅមកត្រង់ |
| ៨០០ ម.ម | បិទបើកចេញពីជ្រុងខាងស្តាំទៅផ្លូវដើរទទឹងតូចបំផុត ១៥០០ម.ម |
| ៨២៥ ម.ម | បិទបើកចេញពីជ្រុងខាងស្តាំទៅផ្លូវដើរទទឹងតិចបំផុត ១២០០ម.ម |
| ៩០០ ម.ម | បិទបើកចេញពីជ្រុងខាងស្តាំទៅផ្លូវដើរទទឹងតិចបំផុត៩០០ម.ម |

- គួរផ្តល់លទ្ធភាពងាយស្រួលរាល់ផ្លូវឆ្ពោះទៅកាន់ទ្វារច្រកចូល
- គួរមានផ្លូវងាយស្រួលពីកន្លែងនៅផ្ទាល់ខ្លួនទៅកន្លែងរួម
- បើមិនមានអ្វីច្រើនគួរតែមានផ្លូវទេរឬជម្រាលនៅតាមផ្លូវថ្មើរជើង
- ធានាថាផ្លូវថ្មើរជើងនៅខាងក្រៅ ជម្រាលនិងជណ្តើរជើងត្រូវបានរចនាឡើងតាមស្តង់ដា
- ធានាថាផ្លូវទៅកាន់អគារលំនៅឋាននីមួយៗមានទំហំទទឹងតូចបំផុត ៩០០ម.ម
- បំពាក់ទ្វារតាមច្រកដែលមានទទឹងសម្រាប់បើកទូលាយដូចក្នុងតារាងខាងលើ

### ៣.៩.២. ច្រកចូលលំនៅឋាន (Entrances)



❖ ស្តង់ដានិងការណែនាំអំពីច្រកចូលលំនៅឋាន

- ធានាថាគ្រប់ច្រកចូលទាំងអស់ងាយមើលនិងងាយប្រើប្រាស់
- ធានាថាគ្រប់ច្រកចូលទាំងអស់មានពន្លឺនៅខាងក្រៅ
- ធានាថាគ្រប់ច្រកចូលទាំងអស់មានទម្រង់ដែលអាចការពារពីអាកាសធាតុបាន

- ត្រូវរៀបចំកន្លែងសម្រាកដែលមានទំហំតូចបំផុត១៥០០ម.ម x ១៥០០ម.ម នៅខាងមុខច្រកចូលផ្ទះនីមួយៗ
- ត្រូវរៀបចំកន្លែងសម្រាកដែលមានទំហំតូចបំផុត២៤០០ម.ម x ២៤០០ម.ម នៅខាងមុខច្រកចូលនៃអគារលំនៅឋានរួម
- ធានាថាច្រកចូលអគារនៃផ្ទះនីមួយៗមានទំហំតូចបំផុត១៥០០ម.ម x ១៥០០ម.ម
- ធានាថាច្រកចូលកន្លែងទទួលភ្ញៀវត្រូវបានឪហ្សាញទ្បើងតាមស្តង់ដា
- ត្រូវបំពាក់កណ្តឹងទ្វារមិនឱ្យខ្ពស់ជាង១២០០ម.មពីដីឡើយ
- ធានាថាច្រកចូលនិងទ្វារខាងក្រៅទាំងអស់មានទំនប់ខណ្ឌមាត់ទ្វារដែលសមរម្យបំផុត
- ធានាថាទ្វារចូលទៅផ្ទះនីមួយៗមានទទឹងទំហំ៩០០ម.ម ទំនេរនិង៣០០ម.មចន្លោះពីរបង

### ៣.៩.៣. ច្រកផ្លូវដើរនៅក្នុងលំនៅឋាន (Horizontal Circulation in Housing)






ពាំៈ ខ្នាត់ទាំងអស់គិតជា មម

❖ ស្តង់ដានិងការណែនាំអំពីច្រកផ្លូវដើរនៅក្នុងលំនៅឋាន

- ទំហំទទឹងទ្វារដែលជាស្តង់ដាសម្រាប់ផ្ទះល្វែងនីមួយៗមានដូចខាងក្រោម៖

| ស្តង់ដាទទឹងទ្វារ | ទិសដៅបិទបើកទ្វារនិងទទឹងនៃផ្លូវ |
|---|---|
| ៨០០ ម.ម | បិទបើកទ្វារទៅមកត្រង់ |
| ៨០០ ម.ម | បិទបើកទ្វារពីខាងស្តាំទៅរកផ្លូវដើរ ( ច្រករបៀង ) ទ្វារត្រូវមានទទឹងយ៉ាងហោច១១០០ម.ម |
| ៨៥០ ម.ម | បិទបើកទ្វារពីខាងស្តាំទៅរកផ្លូវដើរ ( ច្រករបៀង ) ទ្វារត្រូវមានទទឹងតិចជាង១១៥០ម.ម |

- ធានាថាអគារលំនៅឋាននិងផ្ទះល្វែងត្រូវបានរៀបចំនិងរចនាសម្រាប់មនុស្សគ្រប់រូបប្រើបាន
- ធ្វើបែបណាឱ្យមានទីធ្លាគ្រប់គ្រាន់សម្រាប់អ្នកប្រើរទេះ កង់ម៉ាស៊ីន រទេះទារកនិងអ្នកប្រើឧបករណ៍ជំនួយដើរអាចចេញចូលនិងបត់បាន៣៦០ដឺក្រេ
- ធានាថាផ្លូវរបៀង ( Corridors ) រវាងផ្ទះមួយល្វែងទៅមួយល្វែងមានទទឹងតូចបំផុត៩០០ម.ម
- ធានាថាផ្លូវរបៀងនៅតាមអគារលំនៅឋានដែលមានមនុស្សច្រើនមានទំហំទទឹងតូចបំផុត១២០០ម.ម
- ធានាថាទទឹងទ្វារនិងផ្លូវរបៀងមានដូចតារាងខាងលើ
- ធានាថាគ្រប់ទ្វារទាំងអស់រវាងល្វែងនៃផ្ទះមួយទៅមួយសល់ទំហំ៣០០ម.មទៅគែមទ្វារខាងមុខ
- ធានាថាទ្វារដែលបើកចូលទៅបន្ទប់មានត្រចៀកបើកទៅជញ្ជាំង
- ឱហ្យាញទ្វារបន្ទប់ទឹកនិងបង្គន់ដែលអាចបើកចេញក្រៅនិងងាយស្រួលពេលមានអាសន្ន
- ជញ្ជាំងនៅតាមបន្ទប់ទឹកនិងបន្ទប់គេងត្រូវរឹងមាំដើម្បីអាចចាប់បង្កាន់ដៃដោយសុវត្ថិភាព

- ពិដានទាំងអស់ត្រូវមាំដើម្បីងាយស្រួលបំពាក់ឬចាប់ឧបករណ៍ស្ទូចលើកដាក់






### ៣.៩.៤. ច្រកឡើងចូលលំនៅឋាន (Vertical Circulation in Housing)

❖ ស្តង់ដានិងការណែនាំអំពីច្រកឡើងចូលលំនៅឋាន

- ឌីហ្សាញជណ្តើរនិងកាំជណ្តើរទៅតាមស្តង់ដា
- ត្រូវមានជណ្តើរយោងឬប្រអប់ដែលអាចដាក់មនុស្សបានច្រើន (ជាពិសេសជណ្តើរសម្រាប់ជិះពេល មានអាសន្ន)សម្រាប់អគារលំនៅឋានដែលមានកម្ពស់ចាប់ពី៣ជាន់ឡើង
- ធានាថាមានជណ្តើរយោងឬប្រអប់នៅគ្រប់ជាន់រួមទាំងចំណតក្រោមដីនិងកន្លែងផ្សេងៗទៀត
- គួរមានជណ្តើរយោងឬប្រអប់បញ្ឈរមួយសម្រាប់អគារដែលមាន២ ឬ៣ជាន់
- ត្រូវឌីហ្សាញជណ្តើរយោងឬប្រអប់ទៅតាមស្តង់ដា
- ប្រសិនបើមិនទាន់បំពាក់ជណ្តើរយោងឬប្រអប់ទេត្រូវរក្សាកន្លែងសេវាកម្មនិងធ្វើយ៉ាងណាអាចបំពាក់បាននៅពេលអនាគតដោយគ្មានឧបសគ្គ
- ឌីហ្សាញផ្ទះនីមួយៗដែលអាចបំពាក់ជណ្តើរយោងឬឧបករណ៍សម្រាប់លើកដាក់បាននៅពេលអនាគត

## ៣.៩.៥. សេវាកម្មផ្សេងៗនៅក្នុងលំនៅឋាន (Services in Housing)



- ស្តង់ដានិងការណែនាំអំពីសេវាកម្មនៅក្នុងលំនៅឋាន
  - ត្រូវបំពាក់ព្រីភ្លើងនិងខ្សែភ្លើងដែលអាចយកភ្លើងប្រើបាននៅពេលអនាគត ដើម្បីដំឡើងឧបករណ៍ចាំបាច់និងអំពូលភ្លើងនៅពេលចាំបាច់
  - ដាក់សម្ភារៈប្រើប្រាស់និងកុងទ័រនៅកម្ពស់ពី១២០០ម.មទៅ១៤០០ម.ម ដែលងាយប្រើប្រាស់
  - បំពាក់ឧបករណ៍បិទបើកភ្លើងនៅគ្រប់កន្លែងត្រឹម៤០០ម.មពីដីលើកលែងតែបន្ទប់ដែលមានដាក់ឧបករណ៍ផ្លាស់ប្តូរកម្តៅ
  - ដាក់វ៉ានធំសម្រាប់បិទបើកទឹកនៅទីតាំងនិងកម្ពស់សមរម្យដែលងាយប្រើប្រាស់
  - ឌីហ្សាញព្រីភ្លើង កុងតាក់បិទបើកនិងឧបករណ៍បញ្ជាផ្សេងៗទៀតទៅតាមស្តង់ដា

### ៣.៩.៦. បន្ទប់ជាលក្ខណៈបុគ្គល (Individual Rooms)



❖ ស្តង់ដានិងការណែនាំអំពីបន្ទប់ជាលក្ខណៈបុគ្គល

- ត្រូវរៀបចំឱ្យមានបន្ទប់គេងច្រើនប្រភេទនៅតាមអគារនៃផ្ទះនីមួយៗ
- ត្រូវដាក់បន្ទប់ទទួលភ្ញៀវ ផ្ទះបាយនិងបង្គន់នៅជិតផ្លូវចូលជាចាំបាច់
- អាចរៀបចំកន្លែងគេងនៅក្នុងបន្ទប់ទទួលភ្ញៀវក្នុងករណីចាំបាច់ម្តងម្កាល
- ត្រូវមានបង្គន់និងបន្ទប់ទឹកដែលងាយស្រួលនិងអាចងូតទឹកបាន
- ធានាថាផ្ទះបាយ បន្ទប់ទទួលភ្ញៀវនិងយ៉ាងហោចណាស់បន្ទប់គេង១ ដែលអ្នកប្រើរទេះ កង់ម៉ាស៊ីននិងអ្នកប្រើឧបករណ៍ជំនួយដើរអាចប្រើបាន

## ៣.១០. អគារនិងទីតាំងប្រវត្តិសាស្ត្រ (Historic Buildings and Sites)




❖ ស្តង់ដានិងការណែនាំអំពីអគារនិងទីតាំងប្រវត្តិសាស្ត្រ

- ធានាថាអគារនិងទីតាំងប្រវត្តិសាស្ត្រ អាចចេញចូលនិងប្រើប្រាស់បានដោយមនុស្សគ្រប់គ្នារួមទាំងជនមានពិការភាព កុមារ មនុស្សចាស់ជរានិងស្ត្រីមានផ្ទៃពោះ
- យ៉ាងហោចណាស់ផ្នែកខ្លះនៃទីតាំងប្រវត្តិសាស្ត្រត្រូវបានរៀបចំសម្រាប់ជនមានពិការភាពប្រសិនបើទីតាំងទាំងមូលមិនអាចកែសម្រួលបាន
- ធានាថាគ្រប់ពិធីនិងសកម្មភាពនៅក្នុងទីតាំងប្រវត្តិសាស្ត្រទាំងអស់មានមនុស្សចូលរួមគ្រប់គ្នា
- ត្រូវពិនិត្យនិងកែសម្រួលបញ្ហាអំពីព័ត៌មាននិងសេវាកម្មអតិថិជនជាប្រចាំដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងដូចជាការដាក់ប្រអប់សារសំណូមពររបស់ភ្ញៀវជាដើម
- ត្រូវប្រើប្រាស់ស្លាកសញ្ញាដែលងាយស្រួលដើម្បីជំនួយដល់ការរកទីតាំងណាមួយពិតប្រាកដ
- ចាត់គ្រប់វិធានការនិងឱកាសដើម្បីកែសម្រួលបរិស្ថានរូបវន្តសម្រាប់ទាំងអស់គ្នាដូចជាក្នុងពេលមានកម្មវិធីជួសជុលនិងថែទាំ
- ធានាថាកន្លែងដែលកែសម្រួលរួចនិងកន្លែងដែលសង់ថ្មីគឺស្ថិតក្នុងការរចនាជាសាកល

### ៣.១០.១. គោលការណ៍គ្រឹះអំពីការអភិរក្ស (Conservation Principles)



❖ ស្តង់ដានិងការណែនាំអំពីគោលការណ៍គ្រឹះអំពីការអភិរក្ស

- ធានាថាអគារប្រវត្តិសាស្ត្រអាចប្រើប្រាស់បាននៅគ្រប់ពេលវេលានិងគ្រប់ទីកន្លែង
- ធានាថាអគារប្រវត្តិសាស្ត្រទាំងអស់នៅរក្សាគោលបំណងដំបូងរបស់ខ្លួននៅគ្រប់ពេលវេលានិងទីកន្លែង
- គួរគិតអំពីការកែសម្រួលថ្មីទាំងអស់ដែលធានាដល់ការរស់រានជាប្រចាំរបស់អគារ
- ធានាថារាល់ការកែសម្រួលថ្មីគឺបានបង្កើនការចូលរួមរបស់មនុស្សគ្រប់រូបជាពិសេសជនមានពិការភាព
- ធានាថាការពង្រីកនិងការកែសម្រួលអគារប្រវត្តិសាស្ត្រទាំងអស់បានគិតពីរចនាបថដើមរបស់ខ្លួន

### ៣.១០.២. ការកែសម្រួលអគារប្រវត្តិសាស្ត្រ

(Making Changes to Historic Buildings)



❖ ស្តង់ដានិងការណែនាំអំពីការកែសម្រួលអគារប្រវត្តិសាស្ត្រ

- ប្រើវិធីសាស្ត្រនៃការសាងសង់ដែលអាចកែសម្រួលបានតិចឬច្រើន
- ប្រើប្រាស់សម្ភារៈនិងកម្លាំងមនុស្សឱ្យសមស្របទៅនឹងអគារឬទីតាំង
- កាត់បន្ថយផលប៉ះពាល់ឱ្យនៅតិចបំផុតទៅលើរចនាបថដើមនៃអគារ ឬទីតាំង
- មើលទៅឃើញថាការកែប្រែថ្មីគឺជាការអភិវឌ្ឍន៍អគារឬទីតាំងប្រកបដោយ សោភ័ណ្ឌភាពនិងចីរភាព

### ៣.១០.៣. ការឌីហ្សាញលម្អិតអំពីអគារប្រវត្តិសាស្ត្រ

(Detailed Design of Historic Buildings)



ផ្នែកនេះគ្របដណ្តប់ទៅលើធាតុសំខាន់ៗនៃទីតាំងអគារបេតិកភណ្ឌមិនគួររចនាឡើងទៅតាមស្តង់ដាដែលអាចបំផ្លាញធ្វើឱ្យខូចខាត បាត់បង់តម្លៃឬមិនសមស្របជាមួយទីតាំងអគារប្រវត្តិសាស្ត្រនោះទេ។ គ្រប់ករណីនីមួយៗត្រូវរៀបចំប្រកបដោយភាពច្នៃប្រឌិតចំពោះអគារនីមួយៗគួរតែត្រូវធ្វើឡើងដោយមានការយល់ដឹងខ្ពស់។

### ៣.១០.៣.១. ច្រកចូល ( Entrances )






❖ ស្តង់ដានិងការណែនាំអំពីច្រកចូល

- គ្រប់ផ្លូវចូលធំនៃអគារទាំងអស់ត្រូវតែឱបហ្យាញឡើងសម្រាប់ទាំងអស់គ្នា
- មិនត្រូវធ្វើជម្រាលសម្រាប់ចូលរបស់អ្នកជិះរទេះនៅខាងក្រោយអគារនោះទេ
- ផ្លូវចូលអាចប្រើប្រាស់បានគ្រប់ពេលដោយមិនធ្វើជម្រាលតែសម្រាប់ពេលបណ្តោះអាសន្ននោះទេ
- នៅតាមអគារប្រវត្តិសាស្ត្រភាគច្រើនច្រកចូលធំៗគឺធ្វើខ្ពស់ពីដីព្រោះជាចំណូលចិត្តរបស់អ្នកសាងសង់នៅពេលនោះ
- នៅតាមអគារខ្លះច្រកចូលនិងផ្នែកម្រាលខាងក្នុងគឺតម្រូវឱ្យលើកឡើងខ្ពស់ជាងផ្ទៃបរិវេណខាងក្រៅដើម្បីជៀសវាងលិចទឹកនៅរដូវភ្លៀង
- ដោយឡែកនៅតាមអគារធំៗផ្លូវចូលធ្វើខ្ពស់ ព្រោះតែគិតថាដើម្បីលើកមុខមាត់អគារហើយជាចំណែកមួយនៃខឿនទ្រដែលមានជណ្តើរចុះឡើង

- ចំណុចសំខាន់ដែលគួរពិចារណាអំពីការបង្កើនភាពអាចចេញចូលបាននៃច្រកចូលអគារប្រវត្តិសាស្ត្រគឺធានាថារាល់ការបំពាក់បរិក្ខារដែលជួយដល់ជនមានពិការភាពមិនបាត់បង់គុណតម្លៃរបស់អគារ
- នៅតាមកន្លែងដែលអាចធ្វើបានគួរបំពាក់ជម្រាលអមជាមួយជណ្តើរដើម្បីបង្កឱកាសឱ្យជនមានពិការភាពអាចចុះឡើងបានតែមិនបាត់បង់សោភ័ណ្ឌភាពនៃអគារ
- ក្នុងករណីខ្លះប្រសិនបើទំបន់ខណ្ឌមាត់ទ្វារច្រកចូលខ្ពស់ពេកគួរកែសម្រួលឱ្យបានសមរម្យ

### ៣.១០.៣.២. ទ្វារ ( Doors )





❖ ស្តង់ដានិងការណែនាំអំពីទ្វារ

- នៅតាមអគារប្រវត្តិសាស្ត្រទ្វារត្រូវបានឌីហ្សាញឡើងទៅតាមរចនាបថនៃអគារនោះ
- ទ្វារភាគច្រើនទាំងខាងក្រៅនិងខាងក្នុងអាចធ្ងន់ខ្លាំងដោយសារតែទំហំធំនិងភាពហាប់ណែននៃទ្វារទាំងនេះ ហើយជាការលំបាកសម្រាប់មនុស្សភាគច្រើនប៉ុន្តែអាចកែសម្រួលឱ្យបានប្រសើរឡើងតាមរយៈការបំពាក់ឧបករណ៍ស្វ័យប្រវត្តិឬគ្រឿងជំនួយក្នុងការបិទបើកទ្វារនោះ
- ដោយសារតែបច្ចេកវិទ្យាកាន់តែរីកចំរើនគ្រឿងជំនួយខ្លះត្រូវបានកែសម្រួលពីធំមកតូចៗ

- នៅតាមអគារមួយចំនួនទ្វារខ្លះគួរតែត្រូវចោះបើកដើម្បីសម្រួលដល់ការចេញចូលបានស្រួល
- ទ្វារសម្រាប់គេចចេញពីអគ្គិភ័យត្រូវប្រើឧបករណ៍បើកដោយស្វ័យប្រវត្តិ
- គ្រប់ទ្វារទាំងអស់ដែលមានទំនប់ខណ្ឌត្រូវធានាថារទេះជនមានពិការភាពងាយស្រួលចេញចូលបាន
- សម្រាប់អគារខ្លះកម្ពស់នៃទំនប់ខណ្ឌមាត់ទ្វារអាចខ្ពស់ទៅតាមប្រភេទនៃអគារនិងការឌីហ្សាញសំណង់នោះតែត្រូវគិតថាអ្នកជិះរទេះអាចចេញចូលបាន
- មិនត្រូវប្រើដៃទ្វារបិទបើកដោយកាច់បែបនេះទេគឺប្រើដោយកាច់បិទបើកបែបនេះ( មើលរូបខាងក្រោម )



- ការប្រើប្រាស់ខ្សែបណ្ដោះអាសន្នទាំងសងខាងទ្វារផ្ដល់នូវជម្រើសក្នុងការចុះឡើងទីខ្ពស់បាន
- ប្រសិនបើមានទំនប់ខណ្ឌមាត់ទ្វារសម្រាប់ការពារទឹកហូរចូលឬចេញជម្រើសផ្សេងទៀតគឺត្រូវការពារដោយកែសម្រួលផ្ទៃខាងក្រៅដើម្បីឱ្យស្មើងាយស្រួលចេញចូលរទេះ
- ត្រូវដាក់លូឬទុយោបង្ហូរទឹកខាងក្រៅនិងត្រូវដាក់ឆ្នុកកៅស៊ូប៉ុងនៅបាតទ្វារ

### ៣.១០.៣.៣. ជម្រាល ( Ramps )

❖ ស្តង់ដានិងការណែនាំអំពីជម្រាល



*រូបភាព១.១០.៣.៣.១. គំរូអំពីជម្រាលខាងក្រៅដែលមានកាំជណ្តើរអម*

- ត្រូវដាក់ជម្រាលនៅតាមកន្លែងដែលឡើងចុះដើម្បីអាចប្រើប្រាស់បានគ្រប់ពេលដោយឯករាជ្យ
- កន្លែងលើកដាក់ចុះឡើង ( Platform lifts ) អាចធ្វើតិចឬច្រើននិងអាចប្រើប្រាស់តាមពេលត្រូវការប្រើនិងថែទាំ
- កន្លែងលើកដាក់ចុះឡើងនេះគឺគេធ្វើឡើងសម្រាប់តែអគារណាដែលមិនមានការបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព
- ជម្រាលអាចស៊ីទីធំជាពិសេសប្រសិនបើផ្ទៃមានកម្ពស់ខ្ពស់ដែលតម្រូវឱ្យមានជម្រាលសមរម្យ
- កន្លែងលើកដាក់ចុះឡើងអាចត្រូវបានធ្វើសម្រាប់អ្នកប្រើរទេះរុញកន្លែងនេះគឺសម្រាប់មនុស្ស
- ផ្សេងៗគ្នានិងមិនមានប្រយោជន៍ដល់អ្នករុញរទេះពីក្រោយទេ
- គ្រប់ជម្រាលទាំងអស់នៅតាមអគារប្រវត្តិសាស្ត្រគួរតែមានការប្រុងប្រយ័ត្នដូចជា៖ ជ្រើរបាំងជញ្ជាំង ស៊ុមក្រវ៉ាត់ទ្វារឬជញ្ជាំងនិងផ្ទាំងជញ្ជាំងត្រូវបានធ្វើឡើងដោយយកចិត្តទុកដាក់
- ជម្រាលបណ្តោះអាសន្នជានិច្ចកាលមិនសូវសមនិងពិបាកក្នុងការរៀបចំជាពិសេសបើសិនវាអាចចល័តបាននិងត្រូវបានបំពាក់តែនៅពេលគេត្រូវការ

- ជម្រាលបណ្តោះអាសន្នមិនត្រូវបានគេគិតថាវាសមរម្យនិងមិនមែនជាដំណោះស្រាយយូរអង្វែងឡើយ
- ជម្រាលបណ្តោះអាសន្នអាចពិចារណាថាជាដំណោះស្រាយភ្លាមៗក្នុងខណៈដែលមិនទាន់មានគម្រោងធ្វើជម្រាលអចិន្ត្រៃយ៍សម្រាប់ចេញចូលអគារឬបន្ទប់បណ្តោះអាសន្ន
- ជម្រាលបណ្តោះអាសន្នគួរតែត្រូវបានឌីហ្សាញឱ្យដូចគ្នាទៅនឹងជម្រាលអចិន្ត្រៃយ៍ទាក់ទងទៅនឹងកម្ពស់ ប្រវែង ទទឹង កន្លែងសម្រាកនិងការបំពាក់បង្កាន់ដៃជាដើម

### ៣.១០.៣.៤. ជណ្តើរ ( Staircases )





❖ ស្តង់ដានិងការណែនាំអំពីជណ្តើរ

- ជណ្តើរនៅតាមអគារប្រវត្តិសាស្ត្រភាគច្រើនគឺជាកន្លែងសំខាន់ដែលបង្ហាញពីភាពពិសេសនៃអគារនោះ
- ករណីខ្លះការកែប្រែមិនសមរម្យទេទោះបីជាទំហំនិងរាងរៅជណ្តើរ ឬបង្កាន់ដៃមិនមានការបង្កលក្ខណៈងាយស្រួលក៏ដោយ
- ទោះបីជាយ៉ាងណាការកែសម្រួលឱ្យកាន់តែប្រសើរឡើងគឺនៅតែអាចទៅរួចដូចជា ការបិទម៉ូតកាំជណ្តើរឬអំពូលភ្លើងសិប្បនិម្មិត

- បង្កាន់ដៃនិងចម្រឹងរបារបង្កាន់ដៃតែងតែត្រូវបានតាក់តែងយ៉ាងប្រណិត ហើយវាជាផ្នែកមួយនៃសម្រស់របស់ជណ្តើរតែពេលខ្លះក៏ខ្ពស់ពេក ឬទាបពេក ធំពេកឬតូចពេកដែលពិបាកចាប់កាន់ជាដើម
- ករណីខ្លះបង្កាន់ដៃដែលបន្ថែមគឺឌីហ្សាញឡើងស្របទៅតាមទម្រង់បង្កាន់ដៃចាស់ពីមុន ទោះបីជាចាប់នៅខាងក្រៅជញ្ជាំងបន្ថែមឬក៏ចាប់ជាប់បង្កាន់ដៃចាស់ក៏ដោយ
- កាន់តែប្រសើរប្រសិនបើការកែសម្រួលណាដែលបង្កើតថ្មីដូចជាដាក់ជណ្តើរថ្មីនៅក្នុងអគារមួយហើយកំណត់ថាជណ្តើរថ្មីនេះជាជម្រើសប្រសើរសម្រាប់អ្នកមានតម្រូវការប្រើប្រាស់
- ជណ្តើរថ្មីនេះមិនគួរកំណត់ថាសម្រាប់តែជនមានពិការភាពចលនាទេតែគួរតែបើកឱ្យមនុស្សគ្រប់រូបអាចប្រើប្រាស់បានផង
- ជណ្តើរយោងឬជណ្តើរសម្រាប់ប្រើពេលមានអាសន្នគឺធ្វើឡើងសម្រាប់អគារដែលមានកម្ពស់ច្រើនជាងមួយជាន់ឬមានឡៅតឿជម្រើសដែលប្រសើរគឺការបំពាក់ជណ្តើរសម្រាប់ប្រើពេលមានអាសន្ន
- កន្លែងដាក់ជណ្តើរយោងនៅតាមអគារប្រវត្តិសាស្ត្រតម្រូវឱ្យមានការពិចារណាហ្មត់ចត់ដើម្បីធានាថាងាយស្រួលប្រើនៅគ្រប់ជាន់និងអាចកាត់បន្ថយការកែប្រែរចនាបថនៃអគារទាំងមូល

## ៣.១០.៣.៥. ផ្ទៃបាតនៃជណ្តើរយោងឬជណ្តើរប្រអប់

**( Platform Lifts)**



❖ ស្តង់ដានិងការណែនាំអំពីផ្ទៃបាតនៃជណ្តើរយោងឬជណ្តើរប្រអប់

*រូបភាព ៣.១០.៣.៥.១. គំរូអំពីផ្ទៃបាតនៃជណ្តើរយោងឬជណ្តើរប្រអប់*

**Figure 3.8** Platform lift.




**សម្គាល់:** ខ្នាតទាំងអស់គិតជា មម

- ធានាថាច្រកចូលធំរចនាឡើងជាសាកលនិងប្រើប្រាស់បានជាអចិន្ត្រៃយ៍
- ពិចារណាអំពីប្រសិទ្ធភាពនៃការកែសម្រួលច្រកចូលឱ្យស៊ីគ្នាជាមួយអគារ
- គិតគូរពីការកែច្នៃបរិវេណខាងក្រៅអគារដើម្បីឱ្យស្របគ្នានិងការកែសម្រួលតូចៗផ្សេងទៀត
- ពិនិត្យលើការប្រើប្រាស់និងការដាក់ត្រចៀកទ្វារឬឧបករណ៍ទ្វារផ្សេងៗសម្រាប់ទ្វារដែលធ្ងន់
- គួរប្រើប្រាស់ឧបករណ៍បើកទ្វារជាប់មិនបិទវិញសម្រាប់ទ្វារឬសម្រាប់គេចចេញពេលមានអាសន្ន
- ធានាថាទំនប់ខណ្ឌមាត់ទ្វារនិងតួទ្វារមិនកកិតគ្នា
- ត្រូវមានជម្រាលចូលទៅកាន់ផ្ទៃបាតជណ្តើរយោងឬប្រអប់ដើម្បីឱ្យគ្រប់គ្នាអាចប្រើបាន
- អាចធ្វើជម្រាលចល័តសម្រាប់សម្រួលនៅតាមទីតាំងមួយចំនួនដែលចាំបាច់
- ត្រូវដាក់បង្កាន់ដៃបន្ថែមសម្រាប់ជណ្តើរជើងដែលមានបង្កាន់ដៃហើយតែមិនអាចកែបាន
- គួរមានជណ្តើរដែលអាចជាជម្រើសសម្រាប់មនុស្សគ្រប់រូបប្រើបាន
- សូមបំពាក់តែជណ្តើរយោងឬប្រអប់ដែលគេនិយមប្រើជាពិសេសជណ្តើរសម្រាប់គេចចេញពេលមានអាសន្នដែលវាអាចកាត់បន្ថយការកែសម្រួលធំៗទៅលើអគារ
- អាចបំពាក់ឧបករណ៍លើកដាក់មនុស្សក្នុងករណីដែលមិនអាចបំពាក់ជណ្តើរយោងធំបាន

## ៣.១១. ទិដ្ឋភាពខាងក្រៅអគារ (Outdoor Access)



រូបភាព ៣.១១.១. គំរូអំពីបរិស្ថានធម្មជាតិ



រូបភាព ៣.១១.២. គំរូអំពីបរិស្ថានទិដ្ឋភាពច្នៃប្រឌិត

❖ ស្តង់ដានិងការណែនាំអំពីទិដ្ឋភាពខាងក្រៅអគារ

- ត្រូវផ្តល់ព័ត៌មានអំពីបរិស្ថានទៅតាមទម្រង់ច្រើនយ៉ាងផ្តល់លទ្ធភាពសម្រាប់អ្នកទស្សនា
- ត្រូវផ្តល់ព័ត៌មានអំពីសេវាកម្មនិងការបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព

### ៣.១១.១. ប្រភេទទិដ្ឋភាព (Types of Landscape)

#### ៣.១១.១.១. ទិដ្ឋភាពធម្មជាតិ (Natural Landscape)



រូបភាព ៣.១១.១.១.១. គំរូអំពីទិដ្ឋភាពធម្មជាតិជាមួយវត្ថុបុរាណ

❖ ស្តង់ដានិងការណែនាំអំពីទិដ្ឋភាពធម្មជាតិ

- ទិដ្ឋភាពធម្មជាតិសំដៅដល់ឧទ្យានជាតិ តំបន់បេតិកភណ្ឌធម្មជាតិ កន្លែងពិសេសនៃតំបន់អភិរក្សនិងទីតាំងធម្មជាតិដូចជា ឆ្នេរ ភ្នំនិងតំបន់ដាច់ស្រយាលផ្សេងៗទៀត
- ទោះបីជាមិនងាយស្រួលឬមិនចាំបាច់ក៏ដោយត្រូវបង្កើតឱ្យមានការបង្កលក្ខណៈងាយស្រួលនៅតំបន់ភ្នំសម្រាប់អ្នកប្រើប្រាស់រទេះដៃរឧទាហរណ៍ ក្នុងការគិតគូរលើការរៀបចំការបង្កលក្ខណៈងាយស្រួលជាសកល
- នៅតាមតំបន់ទេសភាពនីមួយៗបើមានការបង្កលក្ខណៈងាយស្រួលវាផ្តល់ឱកាសច្រើនបំផុតដល់មនុស្សដែលមានសមត្ថភាពផ្សេងៗគ្នាដើម្បីអាចចូលលេងបាន

*រូបភាព ៣.១១.១.១.២. គំរូអំពីទិដ្ឋភាពធម្មជាតិ*





- ភាគច្រើននៃអ្នកទៅលេងតាមតំបន់ដាច់ស្រយាលផ្សេងៗពួកគាត់មិនយល់ថាវាហាក់បីដូចជាផ្សងព្រេងឬឯកានោះទេពេលណាដែលតំបន់នោះមានការបង្កលក្ខណៈងាយស្រួលដល់ពួកគាត់
- លើសពីនេះទៅទៀតការទៅលេងនៅតំបន់ដាច់ស្រយាលតែម្នាក់ឯងជាទូទៅពួកគាត់មិនបានរៀបចំខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយដូចដែលទៅលក្ខណៈជាក្រុមនោះទេ
- ឧបសគ្គចម្បងដូចជា ជណ្តើរឡើងឬផ្លូវឡើងភ្នំ គួរតែអាចឡើងបានដោយមិនមានឧបសគ្គ

- ចំពោះអ្នកធ្វើផ្លូវត្រូវកែសម្រួលឱ្យមានការបង្កលក្ខណៈងាយស្រួលឱ្យបានច្រើនសម្រាប់មនុស្សគ្រប់គ្នាអាចប្រើបាន
- ចំណុចនេះមិនមែនន័យថាគ្រប់ទិដ្ឋភាពធម្មជាតិត្រូវតែមានការបង្កលក្ខណៈងាយស្រួលដូចទិដ្ឋភាពនៅតាមទីប្រជុំជននោះទេគឺមានន័យថាវាគ្រាន់តែធ្វើយ៉ាងណាឱ្យមានលក្ខណៈងាយស្រួលឬដាក់ស្លាកសញ្ញាតាមទីតាំងផ្សេងៗតាមរបៀបទីតាំងធម្មជាតិនោះ
- ចំពោះកន្លែងទីតាំងឬកន្លែងណាដែលត្រូវកែប្រែឬដែលកំពុងត្រូវបានកែសម្រួលត្រូវបង្កើតឱ្យមានការបង្កលក្ខណៈងាយស្រួលតាមដែលអាចទៅបាន
- ការកែសម្រួលទីកន្លែងគឺមិនសំដៅបន្ថែមជាឧបសគ្គនោះទេ ហើយគួរតែកែប្រែចំពោះទីកន្លែងណា ដែលមានឧបសគ្គតាមដែលអាចធ្វើទៅបាន
- ទីតាំងណាដែលមានភាពងាយស្រួលគួរតែថែទាំឱ្យបានល្អ ផ្តល់សុវត្ថិភាពនិងងាយស្រួលប្រើប្រាស់

#### ៣.១១.១.២. ទិដ្ឋភាពច្នៃប្រឌិត (Tempered Landscape)



❖ ស្តង់ដានិងការណែនាំអំពីទិដ្ឋភាពច្នៃប្រឌិត

- ទិដ្ឋភាពច្នៃប្រឌិតរួមមាន ឧទ្យានតាមជនបទ អគារប្រវត្តិសាស្ត្រ តំបន់បុរាណវិទ្យា តំបន់ដែលសម្បូររុក្ខជាតិ ឧទ្យានផ្សេងៗនិងទីតាំងវាយកូនហ្គោលដែលត្រូវមានសេវាកម្មទាំងអចិន្ត្រៃយ៍និងបណ្តោះអាសន្ន
- ទោះបីជាទិដ្ឋភាពទាំងនោះមានលក្ខណៈធម្មជាតិក៏ដោយក៏ត្រូវគ្រប់គ្រងឱ្យល្អដោយធ្វើយ៉ាងណាផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ប្រើបានគ្រប់សកម្មភាព
- កាលពីមុនមនុស្សកាប់ឆ្ការព្រៃដើម្បីធ្វើកសិកម្ម ហើយក៏បានធ្វើឱ្យមានការផ្លាស់ប្តូរនៅទិដ្ឋភាពមួយចំនួនផងដែរ
- ប្រជាជនបានដាំដើមឈើជារបងនៅលើដីការពារកុំឱ្យសត្វចូល ហើយនៅតាមតំបន់ដែលសម្បូរព្រៃត្រូវធ្វើជាជម្រក



*រូបភាព ៣.១១.១.២.១. គំរូអំពីទិដ្ឋភាពច្នៃប្រឌិតនិងតំបន់បេតិកភណ្ឌធម្មជាតិ*

- ថ្មីៗនេះមានការកែប្រែនៅតំបន់រមណីយដ្ឋានមួយចំនួនទៅតាមក្បួនខ្នាត ដូចជា៖ ការធ្វើផ្លូវ ខ្លោងទ្វាររបង ស្លាកសញ្ញាផ្សេងៗដែលងាយស្រួលអាចប្រើបាន
- លក្ខណៈពិសេសទាំងនេះគួរតែត្រូវបានរចនាឡើងជាសកលនិងផ្តល់ជូននូវឱកាសដ៏ល្អបំផុតសម្រាប់មនុស្សគ្រប់គ្នាដើម្បីចូលទៅលេងទីតាំងទាំងនោះនិងចូលរួមក្នុងសកម្មភាពផ្សេងៗទៀត
- ទិដ្ឋភាពច្នៃប្រឌិតមានអគារដែលទាក់ទងទៅនឹងទីកន្លែងធ្វើបទបង្ហាញ បង្គន់សាធារណៈនិងហាងកាហ្វេ ដែលគួរតែរចនាជាសាកលសម្រាប់ការចេញចូលនិងប្រើប្រាស់បានគ្រប់ៗគ្នា

### ៣.១១.១.៣. ទិដ្ឋភាពនៅតាមទីប្រជុំជន ( Urban Landscape )





❖ ស្តង់ដានិងការណែនាំអំពីទិដ្ឋភាពនៅតាមទីប្រជុំជន

- ទិដ្ឋភាពនៅតាមទីប្រជុំជនទាំងមូលទាមទារឱ្យបង្កើតឡើងសម្រាប់បម្រើសកម្មភាពមនុស្ស ដូច្នេះត្រូវរៀបចំឱ្យមានចញ្ចើមផ្លូវ ជណ្តើរ ជម្រាលបង្កោលការពារ ស្លាកសញ្ញា ភ្លើងបំភ្លឺ ចំណតខាងក្រៅផ្សារនិងឧទ្យានសាធារណៈផ្សេងៗ
- ការរៀបចំឡើងទាំងអស់នេះគឺសម្រាប់សកម្មភាពនៃជីវិតប្រចាំថ្ងៃក៏ដូចជាធ្វើឱ្យកន្លែងនោះមានសណ្តាប់ធ្នាប់និងភាពទាក់ទាញដោយបង្ហាញពីអត្តសញ្ញាណវប្បធម៌របស់ជាតិ
- ចំពោះការរចនាជាសកលនេះតម្រូវឱ្យរៀបចំមានការដាក់បញ្ចូលទៅក្នុងផែនការនិងដំណើរការសាងសង់ក៏ដូចជាការកែប្រែចំពោះបរិស្ថានទាំងនេះ

### ៣.១១.១.៤. ទិដ្ឋភាពនៅតាមជនបទ ( Tamed Landscape )

*រូបភាព ៣.១១.១.៤.១. គំរូអំពីទិដ្ឋភាពនៅតាមជនបទ*







*រូបភាព ៣.១១.១.៤.២. គំរូអំពីទិដ្ឋភាពនៅតាមជនបទនិងតំបន់បេតិកភណ្ឌធម្មជាតិ*

❖ ស្តង់ដានិងការណែនាំអំពីទិដ្ឋភាពនៅតាមជនបទ

- ទិដ្ឋភាពនៅតាមជនបទមានច្រើនប្រភេទនៅតាមកន្លែងមនុស្សប្រមូលផ្តុំច្រើនតាមភូមិនិងនៅទីកន្លែងប្រជុំជនដូចជា សួនកុមារ កន្លែងលេងកីឡា ឧទ្យាន ទីលានបញ្ចុះសព ផ្លូវនិងសួនច្បារ
- ទិដ្ឋភាពនៅតាមជនបទរៀបរាប់ពីកន្លែងណាដែលមនុស្សធ្វើអន្តរាគមន៍ដែលទូទៅមានសភាពដូចនៅតាមតំបន់ទីក្រុងដែរ
- ទិដ្ឋភាពធម្មជាតិនិងទិដ្ឋភាពកែច្នៃជាទូទៅត្រូវបានគេទស្សនាញឹកញាប់ទៅតាមជម្រើសនិងលក្ខណៈរបស់មនុស្សទៅតាមកម្រិតនៃឧបសគ្គជាក់ស្តែង
- នៅពេលមានគម្រោងកែសម្រួលឬក៏ការសាងសង់ថ្មីត្រូវផ្តល់ការបង្កលក្ខណៈងាយស្រួលឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន
- ជៀសវាងបង្កើតឧបសគ្គបន្ថែមនៅក្រោយពេលមានការកែសម្រួលរួច

- ធានាថាផ្លូវនិងអគារដែលមានស្រាប់ត្រូវបានថែទាំបានយ៉ាងទៀងទាត់
- ធានាថាគ្រប់អគារដែលមានរៀបចំបរិយាកាសខាងក្រៅគឺសម្រាប់បម្រើមនុស្សគ្រប់គ្នា

### ៣.១១.២. តំបន់ភ្នំ (Mountains)





❖ ស្តង់ដានិងការណែនាំអំពីតំបន់ភ្នំ

- ធានាថាមធ្យោបាយទាំងអស់ត្រូវបានថែទាំយ៉ាងប្រសើរនិងមិនមានឧបសគ្គក្នុងការប្រើប្រាស់
- ត្រូវមានផ្លូវដែលមានជម្រាលរាក់ៗនិងមានកន្លែងសម្រាកនៅតាមតំបន់មួយចំនួន
- គួរផ្តល់ឱកាសច្រើនបំផុតដើម្បីឱ្យយានយន្តគ្រប់ប្រភេទអាចចេញចូលបាន
- ត្រូវគិតពីការធ្លាក់ដុំថ្មមកបាំងផ្លូវឬគ្រោះថ្នាក់ធ្ងន់ជាងនេះ
- បង្កាន់ដៃឬនាំងការពារមានតួនាទីសំខាន់ណាស់នៅតាមទីតាំងនេះ
- ផ្លូវបត់បែនត្រូវគិតពីការបំពាក់ឧបករណ៍សុវត្ថិភាពសម្រាប់អ្នកធ្វើដំណើរ
- ស្លាកសញ្ញាត្រូវបំពាក់ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន

### ៣.១១.៣. តំបន់ដីដែលសម្បូរព្រៃឈើ (Peatlands)





- ស្តង់ដានិងការណែនាំអំពីតំបន់ដីដែលសម្បូរព្រៃឈើ
  - គួរសង់ក្តារក្រាលសម្រាប់ធ្វើដំណើរដើម្បីទស្សនាតំបន់ដីដែលសម្បូរព្រៃឈើ
  - ធានាថាគ្រប់ព័ត៌មានទាំងអស់រួមទាំងកន្លែងចតយានយន្តនិងផ្លូវចេញចូលគឺមានការបង្កលក្ខណៈងាយស្រួលសម្រាប់មនុស្សគ្រប់គ្នា
  - បង្កាន់ដៃផ្លូវត្រូវធ្វើតាមស្តង់ដាជម្រាលនិងមាំជាង
  - ត្រូវពិនិត្យឈើឱ្យបានទៀងទាត់ជៀសវាងពុកនាំឱ្យមានគ្រោះថ្នាក់ដោយថាហេតុ

### ៣.១១.៤. តំបន់ឆ្នេរ (Beaches)







- ស្តង់ដានិងការណែនាំអំពីតំបន់ឆ្នេរ
  - គួរសង់ក្តារក្រាលឬឧបករណ៍ផ្សេងសម្រាប់ធ្វើដំណើរបានតាមបណ្តោយឆ្នេរសមុទ្របូអាចចុះទៅលេងឆ្នេរខ្សាច់បានគ្រប់ៗគ្នា

- ត្រូវមានរទេះជនមានពិការភាពរក្សាទុកសម្រាប់អតិថិជនខ្ចីប្រើពេលកម្សាន្តឆ្នេរ
- ត្រូវប្រើប្រាស់ទង់ឬឧបករណ៍សំគាល់ណាមួយដែលបង្ហាញពីតំបន់ហាមឃាត់ឬតំបន់ដែលអនុញ្ញាតចេញចូលបាន
- ត្រូវមានសញ្ញាជូនដំណឹងជាសំឡេងឬសេចក្តីជូនដំណឹងនៅគ្រប់កន្លែង
- ធានាថាអ្នកសង្គ្រោះបានបណ្តុះបណ្តាលជំនាញរួមទាំងការទំនាក់ទំនងជាមួយអតិថិជនគ្រប់ប្រភេទរួមទាំងជនមានពិការភាពគ្រប់ប្រភេទនិងគ្រប់អាយុ

### ៣.១១.៥. តំបន់អភិរក្ស (Conservation Areas)





❖ ស្តង់ដានិងការណែនាំអំពីតំបន់តំបន់អភិរក្ស

- ធានាថាគ្រប់ផ្លូវនៅក្នុងតំបន់អភិរក្សទាំងអស់មនុស្សគ្រប់គ្នាអាចចេញចូលប្រើប្រាស់បាន
- បំពាក់ផ្ទាំងក្រណាត់និងអេក្រង់សម្រាប់មនុស្សដែលមានកម្រិតភ្នែកមើលឃើញផ្សេងគ្នា
- រៀបចំឱ្យមានកន្លែងអង្គុយសម្រាកសម្រាប់អ្នកប្រើប្រាស់រទេះកង់ម៉ាស៊ីនរទេះទារក អ្នកប្រើប្រាស់ឧបករណ៍ជំនួយដើរនិងអ្នកប្រើសត្វឆ្កែនាំផ្លូវ។ល។
- ត្រូវមានការជូនព័ត៌មានតាមទម្រង់ច្រើនបែបដើម្បីអាចទទួលបានព័ត៌មានគ្រប់ៗគ្នា

### ៣.១១.៦. កន្លែងគយគន់ទេសភាព (Viewing Points)





- ស្តង់ដានិងការណែនាំអំពីកន្លែងគយគន់ទេសភាព
  - ត្រូវរៀបចំឱ្យមានចំណតយានយន្តសម្រាប់មនុស្សគ្រប់រូបនៅកន្លែងគយគន់ទេសភាព
  - ធានាថាកន្លែងចៀសគ្នាឬកន្លែងឆ្លងកាត់មានស្លាកសញ្ញាច្បាស់លាស់និងប្រកបដោយសុវត្ថិភាព
  - ត្រូវមានការផ្តល់ព័ត៌មានដែលបញ្ជាក់ពីប្រភេទនៃផ្លូវនិងចំងាយទៅកាន់កន្លែងគយគន់ទេសភាព
  - គួរឱ្យមានជម្រើសសម្រាប់ការគយគន់ដោយសេរីក្នុងករណីដែលកន្លែងគយគន់ទេសភាពតូចមិនអាចចេញចូលបានទាំងអស់គ្នា
  - ធានាកាត់បន្ថយឧបសគ្គចម្បងៗជាពិសេសនៅកន្លែងដែលត្រូវឡើងទីខ្ពស់

### ៣.១១.៧. ឧទ្យានតាមជនបទ (Country Parks)





❖ ស្តង់ដានិងការណែនាំអំពីឧទ្យានតាមជនបទ

- រៀបចំចំណតនិងចំណុចបន្ថែមរបស់ចំណតឱ្យនៅជិតកន្លែងសំខាន់ៗ
- គួររៀបចំឱ្យមានចំណតរថយន្តក្រុងសាធារណៈអាចដាក់និងទទួលយកភ្ញៀវនៅកន្លែងសមស្របរបស់បរិវេណទីតាំងទាំងមូល
- ធានាដល់ការចេញចូលរថយន្តធន់ធ្ងន់ក្នុងការផ្តល់សេវាផ្សេងៗតាមរយៈការធ្វើផ្លូវឱ្យបានរឹងមាំដែលរថយន្តអាចបើកបរបាន
- ធានាថាផ្លូវទាំងអស់មានផ្ទៃដែលមនុស្សគ្រប់រូបអាចចរាចរដោយសុវត្ថិភាព
- គួររៀបចំឱ្យមានប្រព័ន្ធផ្តល់សញ្ញាសមស្របនៅក្នុងបរិវេណនៃឧទ្យានទាំងមូល
- គួរមានផែនទីនិងព័ត៌មានមគ្គុទ្ទេសក្នុងទម្រង់ច្រើនប្រភេទ

### ៣.១១.៨. តំបន់ដែលសម្បូររុក្ខជាតិនិងដើមឈើធំៗ

(Woodlands and Arboreta)



❖ ស្តង់ដានិងការណែនាំអំពីតំបន់ដែលសម្បូររុក្ខជាតិនិងដើមឈើធំៗ

- ធានាថាមានព័ត៌មានគ្រប់គ្រាន់និងគ្រប់ទម្រង់ជាមុនសម្រាប់ភ្ញៀវ
- ធានាថាស្លាកយីហោនិងព័ត៌មានងាយអាន ងាយយល់ដោយប្រើទាំងអក្សរនិងរូបសញ្ញាផង
- សម្របសម្រួលឱ្យផ្លូវទៅជិតកន្លែងសំខាន់បំផុតនៃទីតាំងតំបន់នោះ

### ៣.១១.៩. កន្លែងសម្រាកបរិភោគអាហារ (Picnic Areas)



❖ ស្តង់ដានិងការណែនាំអំពីកន្លែងសម្រាកបរិភោគអាហារ

- ត្រូវរៀបចំទីតាំងនៃកន្លែងសម្រាកបរិភោគអាហារនៅផ្ទាល់ដីក្នុងពោងនិងមានដំបូល
- ត្រូវរៀបចំទីតាំងនៃកន្លែងសម្រាកបរិភោគអាហារនៅជិតចំណតតែមិនមែននៅក្នុងចំណតទេ
- ត្រូវដាក់តុសម្រាប់បរិភោគអាហារដែលរឹង ខ្ពស់ល្មមនិងធំទូលាយសម្រាប់អ្នកប្រើប្រាស់រទេះ
- រៀបចំឱ្យមានទីធ្លាទូលាយដែលមានទទឹង២០០០ម.ម ជុំវិញតុបរិភោគអាហារ
- ត្រូវមានធុងសំរាមជាដាច់ខាតនៅក្នុងទីតាំងបរិវេណ

### ៣.១១.១០. ទីតាំងបោះជំរុំនិងឧទ្យានផ្សេងៗ (Campsites and Caravan Parks)





❖ ស្តង់ដានិងការណែនាំអំពីទីតាំងបោះជំរុំនិងឧទ្យានផ្សេងៗ

- ធានាថាទីតាំងបោះជំរុំនិងឧទ្យានផ្សេងៗត្រូវបានរៀបចំដោយមានផ្លូវចេញចូលធំទូលាយ
- ធានាថាទីកន្លែងសំខាន់ៗត្រូវបានកំណត់និងមានការបង្ហាញលក្ខណៈងាយស្រួលសម្រាប់មនុស្សគ្រប់រូប
- ធានាថាកន្លែងដាក់ប្រអប់និងព្រីភ្លើងមើលឃើញយ៉ាងច្បាស់និងមានសុវត្ថិភាព
- អាចប្រើប្រាស់ក្តារក្រាលដែលអាចលើកចេញបានសម្រាប់កន្លែងបោះជំរុំបណ្តោះអាសន្ន
- រៀបចំឱ្យមានទីធ្លាទូលាយដែលមានទទឹង២០០០ម.ម ជុំវិញកន្លែងអាំងសាច់
- ត្រូវមានចង្ក្រាននិងសម្ភារៈអាំងសាច់ដែលអាចបន្ថែមឬបន្ថយកម្ពស់បាន
- ធានាថាកន្លែងបង្កាត់ភ្លើងនិងកន្លែងដាក់បំពង់ពន្លត់ភ្លើងនៅជិតនិងងាយស្រួល

### ៣.១១.១១. ផ្លូវជាប់មាត់ទឹក (Waterways)



❖ ស្តង់ដានិងការណែនាំអំពីផ្លូវជាប់មាត់ទឹក

- ធានាថាផ្លូវជាប់តាមបណ្តោយមាត់ទឹកមានផ្ទៃមិនរអិល រឹងមាំនិងមានកម្រិតកម្ពស់ល្អ

- ត្រូវផ្តល់សញ្ញាការពារនិងប្រុងប្រយ័ត្ននៅតាមតំបន់ដែលងាយគ្រោះថ្នាក់
- ធានាថាផ្លូវ កន្លែងចត ស្ពានទំនប់ទឹកនៅក្នុងកំពង់ផែនិងដីផ្ទេរអាចឱ្យជនមានពិការភាពចេញចូលបាន
- ធានាថាចំណតយានយន្តនិងបង្គន់មាននៅជិតផ្លូវជាប់មាត់ទឹកនិងអាចប្រើបានគ្រប់គ្នា
- ត្រូវផ្តល់ព័ត៌មាននិងផែនទីក្នុងទម្រង់ច្រើនបែបដែលគ្រប់គ្នាអាចទទួលយកបាន
- បង្កាន់ដៃការពារត្រូវធ្វើដោយប្រុងប្រយ័ត្ននិងគិតពីសុវត្ថិភាពជាចម្បង

### ៣.១១.១២. តំបន់បុរាណវិទ្យា (Archaeological Sites)



❖ ស្តង់ដានិងការណែនាំអំពីតំបន់បុរាណវិទ្យា

- ត្រូវធ្វើនិងប្រើប្រាស់ផ្លូវថ្មីឬក្រាលក្តារសម្រាប់ដើរដើម្បីការពារកន្លែងអាចសឹករិចរិលឬខូចបាន
- ត្រូវប្រើប្រាស់សេវារថយន្តក្រុងពីចំណតចូលទៅក្នុងទីតាំងតំបន់បុរាណនោះ

### ៣.១១.១៣. កន្លែងរៀបចំពិធីបណ្ដោះអាសន្ន (Temporary Events)





❖ ស្តង់ដានិងការណែនាំអំពីកន្លែងរៀបចំពិធីបណ្ដោះអាសន្ន

- ធានាថាកន្លែងស្នាក់បណ្ដោះអាសន្នមានការបង្កលក្ខណៈងាយស្រួលដូចគ្នានឹងទីតាំងអចិន្ត្រៃយ៍ដែរ រួមទាំងបរិស្ថានផង
- ធានាថាផ្លូវដែលមានលក្ខណៈងាយស្រួលគឺរឹងមាំ មិនរអិលនិងមានកម្ពស់សមស្រប
- ធានាថាបន្ទប់អនាម័យនិងបរិក្ខារផ្សេងៗមានលក្ខណៈងាយស្រួលដូចបន្ទប់អនាម័យអចិន្ត្រៃយ៍ដែរ
- ប្រសិនបើទីតាំងធំត្រូវមានបង្គន់ចន្លោះពីមួយទៅមួយឱ្យទៀងទាត់ រួមទាំងផ្លូវនិងជម្រាលផងដែរ
- ត្រូវរៀបចំប្រព័ន្ធទឹកប្រើប្រាស់សម្រាប់ផ្ដល់ជូនទីតាំងបណ្ដោះអាសន្ននោះ
- ត្រូវដាក់សញ្ញានៅគ្រប់កន្លែងទាំងអស់ក្នុងបរិវេណទីតាំងដើម្បីបង្ហាញប្រាប់ពីកន្លែងនីមួយៗ
- ធានាថាបុគ្គលិកទាំងអស់ អ្នកស្ម័គ្រចិត្តទាំងអស់ អ្នករៀបចំទាំងអស់ត្រូវបានបណ្ដុះបណ្ដាលស្ដីពីជំនាញរៀបចំពិធីដែលមនុស្សគ្រប់រូបអាចចូលរួមបាន



### ៣.១១.១៤. ឧទ្យាន (Parks)





❖ ស្តង់ដានិងការណែនាំអំពីឧទ្យាន

- ធានាថាសម្ភារៈបរិក្ខារនិងគ្រឿងសង្ហារឹមនៅតាមផ្លូវត្រូវដាក់ឱ្យចំកន្លែងនៅខាងក្រៅផ្លូវធ្វើដំណើរ
- ត្រូវបំពាក់ភ្លើងនៅតាមផ្លូវនៅក្នុងឧទ្យានទាំងមូលហើយធានាថាភ្លឺគ្រប់ពេល
- សម្រួល កែច្នៃនិងបំពាក់ឧបករណ៍ដែលជនមានពិការភាពឬក្មេងពិការអាចចូលរួមលេងបាន
- សុវត្ថិភាពជាចម្បងនៅគ្រប់ទីតាំងនៃឧទ្យាន

### ៣.១១.១៥. កន្លែងបញ្ចុះសព (Cemeteries)







ស្តង់ដានិងការណែនាំអំពីកន្លែងបញ្ចុះសព

- ធានាថាផ្លូវទាំងអស់អាចប្រើប្រាស់បានគ្រប់ៗគ្នា



- ធានាថាគ្រប់ឧបករណ៍ទាំងអស់ដូចជាក្បាលរ៉ូប៊ីណេទឹកនឹងងាយប្រើប្រាស់
- ត្រូវមានចន្លោះផ្លូវអាចប្រើបាន
- គ្រប់ខឿនត្រូវមានជម្រាល

### ៣.១១.១៦. សួនកុមារ កន្លែងលេងនិងឧបករណ៍ផ្សេងៗ

(Playgrounds, Play Structures and Equipment)



❖ ស្តង់ដានិងការណែនាំអំពីសួនកុមារ កន្លែងលេងនិងឧបករណ៍ផ្សេងៗ

- ធានាថាកន្លែងលេងត្រូវបានឌីហ្សាញឡើងដើម្បីជួយអភិវឌ្ឍន៍កុមារទាំងកាយសម្បទានិងបញ្ញា
- ធានាថាកន្លែងលេងគឺអាចលេងបានទាំងអស់គ្នា
- ធានាថាឧបករណ៍សម្រាប់លេងគឺអាចលេងបានគ្រប់គ្នា
- ធានាថាកន្លែងលេងមានព័ទ្ធរបងដើម្បីការពារ
- ធានាថាច្រកទ្វារចូលទូលាយដែលមានទទឹងតិចបំផុត៩០០ម.ម និងបើកបិទជាប្រចាំ

- ត្រូវគ្របរណ្ដៅខ្សាច់ក្រោយពេលឈប់លេង
- ធានាថាផ្ទៃនៃកន្លែងលេងទន់ៗនិងមានស្តង់ដាសុវត្ថិភាពខ្ពស់

### ៣.១១.១៧. សួនច្បារនិងទីធ្លា (Gardens and Courtyards)






ស្តង់ដានិងការណែនាំអំពីសួនច្បារនិងទីធ្លា

- រៀបចំឱ្យមានសួនច្បារនៅជិតបរិវេណអគារសម្រាប់ជាកន្លែងសម្រាកលំហែឬជួបគ្នាធម្មតា (មិនផ្លូវការ)
- រៀបចំសួនច្បារដើម្បីទាក់ទាញការចាប់អារម្មណ៍បង្កើនភាពស្រស់ថ្លា
- ត្រូវរៀបចំការពារប្រព័ន្ធទឹកនិងប្រព័ន្ធផ្សេងៗទៀតដើម្បីជៀសវាងបញ្ហាឬគ្រោះថ្នាក់ផ្សេងៗកើតឡើងជាយថាហេតុនៅក្នុងសួន
- ធានាថាគ្រប់ទីធ្លានៃសួនច្បារត្រូវតែបានថែទាំការពារជាប្រចាំទើបដើមឈើឬស្លឹកឈើមិនរំខានដល់ការកម្សាន្តតាមផ្លូវក្នុងសួន
- ត្រូវបំពាក់គ្រឿងសង្ហារឹមដល់សួនច្បារបែបណាដែលសមរម្យនិងអាចប្រើប្រាស់បានដល់មនុស្សគ្រប់គ្នា

## ៣.១២. ស្លាកសញ្ញាទូទៅ (General Signage)

ស្លាកសញ្ញាមានច្រើនប្រភេទ ច្រើនទំហំ ច្រើនទ្រង់ទ្រាយ ច្រើនពណ៌និងមានខ្លឹមសារ គោលបំណងផ្សេងៗគ្នា។ ស្លាកសញ្ញាមានដាក់នៅតាមផ្លូវ ទីធ្លា

ចំណត កំពង់ផែ ព្រលានយន្តហោះ ខាងក្នុងអគារ ខាងក្រៅអគារ ក្នុងបន្ទប់ ក្រៅបន្ទប់។ល។

ស្លាកសញ្ញារួមមានសញ្ញាបង្ហាញពីទិសដៅ ព័ត៌មាន បង្ហាញពីទីតាំង ឈ្មោះ លេខផ្លូវ លេខបន្ទប់និងផែនទី។ល។

ស្លាកសញ្ញាផ្តល់ការណែនាំដល់មនុស្សដែលមានការលំបាកក្នុងការប្រាប់អ្នកដទៃអំពីអ្វីដែលពួកគេត្រូវការនិងសម្រាប់អ្នកដែលមានការលំបាកក្នុងការស្វែងរកព័ត៌មាននេះអាចនៅក្នុងករណីដែលអ្នកមិនអាចស្តាប់ឮឬមិនប្រើប្រាស់ពាក្យពេចន៍និយាយដើម្បីធ្វើការប្រាស្រ័យទាក់ទង ក្នុងករណីដែលអ្នកនិយាយភាសាផ្សេង ក្នុងករណីដែលអ្នកមិនជឿទុកចិត្តដំបូន្មានរបស់មនុស្សដទៃនិងក្នុងករណីដែលអ្នកមានការលំបាកនៅក្នុងការចងចាំនិងប្រើប្រាស់ព័ត៌មានជាភាសានិយាយ។ លើសពីនេះស្លាកសញ្ញាមានប្រយោជន៍មនុស្សគ្រប់រូបនៅពេលដែលពុំអាចស្នើសុំជំនួយពីអ្នកណាម្នាក់បាន។ សញ្ញាដែលជាក់ច្បាស់ដាក់បង្ហាញនៅច្រើនកន្លែងនិងដែលគេងាយស្រួលមើលឃើញគួរបង្ហាញនៅត្រឹមកម្ពស់ភ្នែកដើម្បីសម្គាល់ទីតាំងផ្តល់ដំបូន្មានអំពីសុវត្ថិភាពនិងផ្តល់ការណែនាំអំពីផ្លូវដែលត្រូវទៅតាម។






❖ ស្តង់ដានិងការណែនាំអំពីស្លាកសញ្ញាទូទៅ

**១. ស្លាកសញ្ញាអន្តរជាតិ (International Symbol of Accessibility)**

• គួរប្រើស្លាកសញ្ញាជនមានពិការភាពអន្តរជាតិ



• ស្លាកសញ្ញាជនមានពិការភាពជិះរទេះរាងទ្រវែងឬជ្រុង

**២. ស្លាកសញ្ញាប្រាប់ទិស (Direction Signs)**

• ត្រូវប្រើស្លាកសញ្ញាប្រាប់ទិសជាក្រាហ្វិកឬលាយលក្ខអក្សរដើម្បីបញ្ជាក់ច្បាស់អំពីទីតាំងនោះ




• ស្លាកសញ្ញាប្រាប់ទិសមិនត្រូវដាក់ច្រើនពេកទេគឺដាក់តែនៅច្រកចូល នៅមាត់ទ្វារនិងនៅទីតាំងណាដែលមានការបត់បែន

**៣. ស្លាកសញ្ញាផែនទីនិងផ្ទាំងព័ត៌មាន (Maps and Information Panels)**

• គ្រប់អាគារទាំងអស់គួរមានរូបប្លង់(ផែនទី)នៃបរិវេណអាគារទាំងមូល

• គួរផ្តល់ព័ត៌មានគ្រប់គ្រាន់(ទាំងលាយលក្ខណ៍អក្សរនិងទាំងជារូបភាព)



ដើម្បីផ្តល់ប្រយោជន៍ដល់មនុស្សគ្រប់រូប រួមទាំងអ្នកដែលមានកម្សោយផ្នែកការស្តាប់និងអ្នកដែលមានការលំបាកក្នុងការចងចាំព័ត៌មាន

- ស្លាកសញ្ញាផែនទីនិងផ្ទាំងព័ត៌មាននៅតាមច្រកចូលអគារតាមបណ្តោយផ្លូវនិងអគារសាធារណៈផ្សេងៗទៀតត្រូវដាក់នៅកម្ពស់ពី៩០០ម.មទៅ ១៨០០ម.ម



## ៤. ការបំពាក់ស្លាកសញ្ញា (Installation)

- ស្លាកសញ្ញាអាចចាប់ជាប់នឹងជញ្ជាំងអាចព្យួរនិងអាចចាប់ជាជើងបញ្ឈរឡើង
- ស្លាកសញ្ញាចាប់ជាប់ជញ្ជាំងគួរចាប់នៅកណ្តាលក្នុងកម្ពស់ពី១៤០០ម.មទៅ១៦០០ម.មពីដី
- ស្លាកសញ្ញាដែលព្យួរគួរដាក់នៅកម្ពស់តិចបំផុត២០០០ម.មពីដី
- ស្លាកសញ្ញាដែលចាប់ជាជើងបញ្ឈរដាក់នៅក្នុងកម្ពស់ពី១៤០០ម.មទៅ១៦០០ម.មពីដី
- សម្រាប់ស្លាកសញ្ញានៅខាងក្រៅត្រូវដាក់កម្ពស់២០០០ម.មពីដី



- សម្រាប់ស្លាកសញ្ញានៅខាងក្នុងត្រូវដាក់កម្ពស់១៤០០ម.ម ទៅ១៦០០ម.មពីដី
- ស្លាកសញ្ញាដែលសរសេរឈ្មោះផ្លូវនិងលេខផ្ទះត្រូវចាប់នៅកម្ពស់ខ្ពស់បំផុត២០០០ម.មទៅ២៥០០ម.ម




## ៥. ទម្រង់នៃស្លាកសញ្ញា (Shape of Signboard)

- ស្លាកសញ្ញាដែលប្រាប់ព័ត៌មានគួរតែមានរាងចតុកោណ
- ស្លាកសញ្ញាប្រកាសអាសន្នគួរមានរាងជាត្រីកោណ
- ស្លាកសញ្ញាហាមឃាត់គួរមានរាងជារង្វង់

## ៦. ពណ៌នៃស្លាកសញ្ញា (Colour)

- ពណ៌ស្លាកសញ្ញាដែលប្រើប្រាស់ជាញឹកញាប់មាន ពណ៌ស ពណ៌ខ្មៅ ពណ៌លឿង ពណ៌ក្រហម ពណ៌ខៀវនិងពណ៌បៃតង
- លាបពណ៌ដើម្បីឱ្យមានភាពខុសគ្នារវាងពណ៌ផ្ទៃនៃវត្ថុខាងក្រោយ (បើវត្ថុនៅខាងក្រោយពណ៌ខៀវត្រូវលាបស្លាកសញ្ញាពណ៌ស)
- មិនគួរលាបពណ៌ដែលលាយគ្នាដូចជាពណ៌ក្រហមជាមួយបៃតងនិងពណ៌លឿងលាយជាមួយពណ៌ខៀវ ព្រោះបណ្តាលឱ្យអ្នកដែលខ្សោយគំហើញមានការច្រឡំ

## ៧. ផ្ទៃនៃស្លាកសញ្ញា (Surface)

- ផ្ទៃរបស់ស្លាកសញ្ញាគួរតែការពារកុំឱ្យមានចំណាំងផ្លាត
- មិនត្រូវប្រើប្រាស់អក្សរលឹបចូលក្នុង លើកលែងតែដាក់ពណ៌និងអាចជំនួសដោយអក្សរផុស
- ប្លង់សំខាន់ៗសញ្ញាប្រាប់ទិស ប៊ូតុងចុចនៅតាមជណ្តើរយោងត្រូវមានអក្សរស្ទាបឬបន្ទះបើកបិទ

## ៨. អក្សរនៅលើស្លាកសញ្ញា (Lettering)

- គួរសរសេរទំហំអក្សរឱ្យសមរម្យទៅតាមចម្ងាយដែលអាចអានបាន




- ប្រៀបធៀបខ្នាតរវាងទទឹងនិងកម្ពស់របស់តួអក្សរគួរដាក់នៅចន្លោះ៣:៥ និង១:១និងប្រៀបធៀបខ្នាតរវាងកម្រាស់ទទឹងនិងកម្ពស់តួអក្សរគួរដាក់នៅ១:៥និង១:១០



- ប្រើពាក្យខ្លីៗច្បាស់លាស់( ងាយ ខ្លីនិងនិយាយចំ ចំណុច )
- សម្រាប់ស្លាកសញ្ញានៅខាងក្រៅ អក្សរត្រូវមានទំហំ( ទំហំហ្វុងក្នុងកុំព្យូទ័រ ) ១០០ម.មទៅ១៧០ម.មជាអក្សរដិតនិងមានពណ៌លេចច្បាស់
- ប្រភេទអក្សរតូចបំផុតមិនត្រូវឱ្យតូចជាង១៥ម.មនោះទេ
- តួអក្សរនិងពាក្យនីមួយៗត្រូវដកឃ្លា
- សម្រាប់ស្លាកសញ្ញានៅខាងក្នុង អក្សរត្រូវមានទំហំ( ទំហំហ្វុងក្នុងកុំព្យូទ័រ )កម្ពស់១៥ម.មទៅ៥០ម.មនិងផុសឡើង១ម.មទៅ១.៥ម.ម អក្សរដិតនិងមានពណ៌លេចច្បាស់
- មានលក្ខណៈស្របគ្នា( សញ្ញាដែលមានអត្ថន័យដូចគ្នាជានិច្ចកាលគួរបង្ហាញឱ្យឃើញតាមរបៀបដូចគ្នា )
- ស្លាកសញ្ញាគួរមានអក្សរផុសនិង/ឬអក្សរស្ទាបនិង/ឬប្លង់អគារប្រសិនបើស្លាកសញ្ញាទាំងនេះបង្ហាញពីផែនទីរបស់អគារដោយអាចឱ្យគេអាចស្ទាបដឹងបាន

### ៩. ទំហំស្លាកសញ្ញា (Size)

- សម្រាប់ស្លាកសញ្ញានៅខាងក្រៅរូបភាពត្រូវមានទំហំតូចបំផុត ៣០០ម.ម x ៣០០ម.ម
- សម្រាប់ស្លាកសញ្ញានៅខាងក្នុងរូបភាពត្រូវមានទំហំតូចបំផុត ១៥០ម.ម x ១៥០ម.ម

### ១០. ការណែនាំទូទៅអំពីស្លាកសញ្ញា (General Guide)

- មិនត្រូវដាក់នៅខាងក្រោយកញ្ចក់ព្រោះអាចមានចំណាំងផ្លាត
- អាចមើលឃើញនិងមានភាពច្បាស់លាស់( ងាយស្រួលមើលឃើញនិងអាចយល់បាន )

- មានភ្លើងបំភ្លឺត្រឹមត្រូវនៅពេលយប់
- កន្លែងនិងទីតាំងផ្តល់សេវាដែលគេអាចចេញចូលបានគួរមានសញ្ញាសម្គាល់ឱ្យបានច្បាស់លាស់ដោយមានការដាក់បង្ហាញនិមិត្តសញ្ញាអន្តរជាតិដែលបង្ហាញពីការបង្កលក្ខណៈងាយស្រួល

**១១. គំរូអំពីស្លាកសញ្ញាសំខាន់ៗមួយចំនួន (Some Important Signage)**



### ទំហំជាមធ្យមនៃអគារឬទីតាំងដែលមានលក្ខណៈងាយស្រួល

- ផ្សារទំនើប ហាងលក់រាយឧបករណ៍ចាំបាច់សម្រាប់ការរស់នៅ ៣០០ម$^{២}$ទៅ១០០០ម$^{២}$
- ហាងកាត់សក់ ហាងកែសម្ផស្ស បន្ទប់ទឹកសាធារណៈច្រើនជាង៥០០ម$^{២}$
- ទីក្រុងឬការិយាល័យតាមភូមិ ការិយាល័យសាខារបស់ប៉ូលិស ការិយាល័យប្រៃសណីយ៍
- ការិយាល័យទូរស័ព្ទនិងទូរគមនាគមន៍ មណ្ឌលសុខភាពសាធារណៈ បណ្ណាល័យសាធារណៈនិងការិយាល័យធានារ៉ាប់រងសុខភាពច្រើនជាង ១០០០ម$^{២}$
- គ្លីនិកជំងឺទូទៅ គ្លីនិកធ្មេញ គ្លីនិកឱសថបូរាណ មន្ទីរពេទ្យសម្ភព ច្រើនជាង៥០០ម$^{២}$
- មជ្ឈមណ្ឌលកុមារតាមសហគមន៍ច្រើនជាង៣០០ម$^{២}$
- ទីតាំងផ្តល់សេវា ភោជនីយដ្ឋាននិងហាងលក់បង្អែមច្រើនជាង៣០០ម$^{២}$
- សាលសម្តែង( ល្ខោន ខ្សែភាពយន្ត សាលប្រគុំតន្ត្រី សៀក។ល។) សម្រាប់តែកន្លែងទស្សនាច្រើនជាង៣០០ម$^{២}$
- ទីកន្លែងជួបជុំ( សាលអាពាហ៍ពិពាហ៍ សាលសាធារណៈ សាលសន្និសីទ )ច្រើនជាង៥០០ម$^{២}$
- សាលតាំងពិព័រណ៍( សារមន្ទីរ សារមន្ទីរសិល្បៈ សារមន្ទីរវិទ្យាសាស្ត្រ វិមានអនុស្សាវរីយ សាលតាំងពិព័រណ៍ឧស្សាហកម្ម។ល។) ច្រើនជាង៥០០ម$^{២}$
- សួនសត្វវិទ្យា សួនរុក្ខសាស្ត្រ អាងចិញ្ចឹមត្រី ច្រើនជាង៣០០ម$^{២}$

- កន្លែងប្រមូលផ្តុំសាសនា( ព្រះវិហារ ប្រាសាទ កន្លែងសូត្រធម៌ ) ច្រើនជាង៥០០ម$^{២}$
- សាលពិធីបុណ្យសពច្រើនជាង៥០០ម$^{២}$
- វិទ្យាស្ថានបណ្តុះបណ្តាល វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ វិទ្យាស្ថានអប់រំច្រើនជាង៥០០ម$^{២}$
- បណ្ណាល័យច្រើនជាង១០០០ម$^{២}$

# ផ្នែកទី៤ អំពីបរិក្ខារនៅក្នុងអគារ (FACILITIES IN BUILDINGS)





## ៤.១. តុទទួលភ្ញៀវនិងបញ្ជរផ្ដល់សេវា

(Reception Desks and Service Counters)



*រូបភាព ៤.១.១. គំរូអំពីតុទទួលភ្ញៀវដែលមានកម្ពស់សមរម្យសម្រាប់អ្នកប្រើរទេះ*

❖ ស្តង់ដានិងការណែនាំអំពីតុទទួលភ្ញៀវនិងបញ្ជរផ្ដល់សេវា

- ត្រូវគិតដល់កន្លែងចូលជង្គង់សម្រាប់អ្នកជិះរទេះចូលមករកបុគ្គលិក
- ធានាថាតុទទួលភ្ញៀវនិងបញ្ជរងាយយល់និងអាចប្រើប្រាស់បាន ទាំងនៅខាងបុគ្គលិកនិងខាងភ្ញៀវ





- តុទទួលភ្ញៀវនិងបញ្ជរផ្ដល់សេវាអាចធ្វើពីរកម្រិត ( ខ្ពស់/ទាប ) ដើម្បីឱ្យជនមានពិការភាពអាចប្រើប្រាស់បាន

*រូបភាព ៤.១.២ គំរូអំពីតុទទួលភ្ញៀវដែលឌីហ្សាញទម្រង់ផ្សេងៗគ្នា*



- កម្រិតទាបសម្រាប់ជនមានពិការភាពជិះរទេះផ្ទៃខាងលើកម្ពស់ខ្ពស់បំផុត ៧៦០ម.មនិងផ្ទៃខាងក្រោម៧០០ម.មពីដីនិងជម្រៅ៦៥០ម.មសម្រាប់ចូលជង្គង់ដើម្បីឱ្យបុគ្គលិកនិងអតិថិជនអាចអង្គុយទល់មុខគ្នាបាន

*រូបភាព ៤.១.៣. ខ្នាតគំរូនៃបញ្ជរផ្តល់សេវានៅឯតុទទួលភ្ញៀវ*



- ទទឹងតុមានទំហំ១៨០០ម.ម(តូចបំផុត១៥០០ម.ម)

*រូបភាព ៤.១.៤. ខ្នាតគំរូនៃតុទទួលភ្ញៀវឬបញ្ជរផ្តល់សេវាដែលអាចប្រើបានទាំងអស់គ្នា*



- ត្រូវដាក់នៅក្នុងស្ថានភាពជាក់លាក់មួយដែលអាចចូលមកត្រង់ពីច្រកចូលធំខាងមុខ
- ត្រូវធ្វើតុបញ្ជរដែលមានកម្ពស់ផ្សេងៗគ្នាដូចក្នុងរូប
- ត្រូវរក្សាទីធ្លាទំហំ២៤៤០ម.ម x ២៤៤០ម.មទំនេរនៅខាងមុខតុទទួលភ្ញៀវ
- ធានាថាបញ្ជរអាចមើលឃើញដោយលាបពណ៌ខុសពីគេនិងមានជម្រាលឡើងមកដោយស្រួល
- ធានាថាអេក្រង់នៃបញ្ជរត្រូវលោងស្អាតនិងមិនមានឧបសគ្គសម្រាប់ភ្ញៀវឡើយ
- គួរប្រើប្រាស់ប្រព័ន្ធបន្ថែមសំឡេងនៅជាប់ជាមួយអេក្រង់នៃបញ្ជរនោះ
- ត្រូវមានឧបករណ៍ស្តាប់នៅត្រចៀកសម្រាប់ជូនភ្ញៀវដែលស្នើនិងត្រូវមានស្លាកសញ្ញាប្រាប់ថាមានឧបករណ៍នោះផង

- ធានាឱ្យមានពន្លឺគ្រប់គ្រាន់នៅតាមបញ្ជរនីមួយៗ( ២០០លុច )និងដាក់នៅកន្លែងដែលអាចមើលឃើញមុខបុគ្គលិកផ្តល់សេវា
- កៅអីសម្រាប់អតិថិជនត្រូវមានកម្ពស់៤៥០ម.មទៅ៤៧៥ម.មនិងទទឹង៥០០ម.ម

## ៤.២. កន្លែងអង្គុយរង់ចាំ (Waiting Areas and General Seating)





❖ ស្តង់ដានិងការណែនាំអំពីកន្លែងអង្គុយរង់ចាំ

*រូបភាព ៤.២.១. ទំហំខ្នាតខ្លះៗអំពីកន្លែងអង្គុយ*






- ធានាថាគ្រប់កន្លែងអង្គុយទាំងអស់ងាយរកនិងអាចអង្គុយបានគ្រប់ៗគ្នា
- ត្រូវមានកន្លែងអង្គុយនៅគ្រប់កន្លែងទទួលភ្ញៀវនិងកន្លែងរង់ចាំ
- ត្រូវរៀបចំកន្លែងអង្គុយនៅជិតបង្គន់និងកន្លែងទទួលភ្ញៀវឬកន្លែងរង់ចាំ
- នៅតាមអគារឬចំណតមធ្យោបាយធ្វើដំណើរត្រូវផ្តល់កន្លែងអង្គុយនៅគ្រប់កន្លែងរង់ចាំ
- ធានាថាផ្លូវឬច្រកចូលទៅកាន់កន្លែងអង្គុយគ្មានឧបសគ្គ
- រៀបចំកន្លែងអង្គុយដែលមានទីធ្លាធំទូលាយនៅសងខាងកៅអីឬបង់សម្រាប់អ្នកមានរទេះទារកនិងរទេះរុញដឹកអីវ៉ាន់ អ្នកប្រើប្រាស់រទេះនិងកង់អគ្គិសនី
- ទំហំទទឹងស្លាបនិងចន្លោះរវាងកៅអីមួយទៅកៅអីមួយទៀតត្រូវអនុវត្តតាមរូបភាពខាងលើ
- ត្រូវបំពាក់កៅអីដែលមានកម្ពស់ផ្សេងៗគ្នាសម្រាប់មនុស្សផ្សេងគ្នាដែរ
- ប្រសិនបើទំហំទីតាំងតូចគួររៀបចំកៅអីនៅកៀនៗជាប់នឹងជញ្ជាំង
- ត្រូវធានាថាកៅអីសម្រាប់អង្គុយមានពណ៌ផ្សេងពីគេ

### ៤.៣. ឃ្លាំងឬកន្លែងស្តុក (Storage Facilities)





## ❖ ស្តង់ដានិងការណែនាំអំពីឃ្លាំងឬកន្លែងស្តុក

- ស្តង់ដាសម្រាប់កម្ពស់ធ្នើរនៅតាមឃ្លាំងស្តុកផ្សេងៗមានដូចខាងក្រោម៖

| កម្ពស់ធ្នើរនៅតាមបន្ទប់ឃ្លាំងនីមួយៗ | | | |
|---|---|---|---|
| | **កម្ពស់ធ្នើរ** | **ជម្រៅធ្នើរ** | **ទំហំចន្លោះពីធ្នើរមួយទៅមួយ** |
| ជិះរទេះចូលពីមុខ | ៦៥០ម.ម ទៅ ១០០០ម.ម សម្រាប់ការប្រើញឹកញាប់<br>៦៥០ម.ម ទៅ ១១៥០ម.ម សម្រាប់ការប្រើប្រាស់ម្តងម្កាល | ២២០ម.ម | ១២០០ម.ម មានកន្លែងដាក់ជង្គង់១៤០០ម.ម គ្មានកន្លែងដាក់ជង្គង់ |
| ជិះរទេះចូលពីចំហៀង | ៦៦៥ម.ម ទៅ ១០៦០ម.ម សម្រាប់ការប្រើញឹកញាប់<br>៦៣០ម.ម ទៅ១១៧០ម.ម សម្រាប់ការប្រើប្រាស់ម្តងម្កាល | ២២០ម.ម | ១២០០ម.ម |
| ដើរឬឈរចូល | ៧៥០ម.ម ទៅ ១៥០០ម.ម សម្រាប់ការប្រើប្រាស់ញឹកញាប់<br>៧០០ម.មទៅ១៦២៥ម.ម សម្រាប់ការប្រើប្រាស់ម្តងម្កាល | មិនមានថែង | ១២០០ម.ម |

- ធានាថាផ្លូវឬច្រកទៅកាន់និងចេញចូលកន្លែងស្តុកឬឃ្លាំងនៅជិតងាយស្រួលនិងគ្មានឧបសគ្គ
- ត្រូវរៀបចំឬបំពាក់សម្ភារៈកន្លែងស្តុកឬឃ្លាំងដែលរឹងមាំមានលំនឹងនិងគ្មានគែមស្រួចៗ
- ត្រូវបំពាក់ដៃកាន់ដែលមានពណ៌ផ្ទុយពីពណ៌របស់ទ្វារនិងថតធ្នើរ
- ធានាថាធ្នើរនិងដៃទ្វារគោរពតាមស្តង់ដាខាងលើ
- ធានាថាទទឹងស្លាបរវាងទ្វារនិងប្រអប់មានចន្លោះ១៤០០ម.ម

- មិនត្រូវប្រើប្រាស់ជើងតាងឬទម្រនៅក្រោមខ្សែក្រណាត់ឡើយ
- ជៀសវាងមុំនៃធ្នើរធំជាង១០០០ម.ម
- ត្រូវដាក់ទំនិញបញ្ឈរនៅលើធ្នើរដើម្បីបង្កើនភាពងាយស្រួលយកប្រើប្រាស់

### ៤.៤. ទូរស័ព្ទសាធារណៈ (Public Telephones)





❖ ស្តង់ដានិងការណែនាំអំពីទូរស័ព្ទសាធារណៈ

- រៀបចំនៅទីតាំងនៃអគារដែលបម្រើសេវាសម្រាប់សាធារណៈជន អគារសម្រាប់ធ្វើដំណើរ
- មជ្ឈមណ្ឌលទេសចរណ៍និងអគារផ្សារលក់រាយ
- ធានាថាសម្ភារៈទូរស័ព្ទទាំងអស់អាចប្រើបានទាំងអស់គ្នាដោយងាយស្រួល ងាយយល់ ទោះបីជាសេវាកម្មបង់ប្រាក់ឬមិនបង់ប្រាក់ក៏ដោយ

#### ៤.៤.១. ទូរស័ព្ទបង់ប្រាក់ (Payphones)



*រូបភាព ៤.៤.១.១. គំរូអំពីទូរស័ព្ទបង់ប្រាក់ដែលចាប់នៅកម្ពស់ផ្សេងគ្នា*




*រូបភាព ៤.៤.១.២. រូបសញ្ញាជាសកលអំពីឧបករណ៍ជំនួយការស្តាប់*

❖ ស្តង់ដានិងការណែនាំអំពីទូរស័ព្ទបង់ប្រាក់

*រូបភាព ៤.៤.១.៣. ទូរស័ព្ទសាធារណៈសម្រាប់អ្នកអង្គុយប្រើប្រាស់*



- ត្រូវដាក់ទូរស័ព្ទឱ្យមនុស្សដែលមានកម្ពស់ផ្សេងៗគ្នាអាចប្រើបាន
- ត្រូវបំពាក់ប៊ូតុងបន្ថែមឬបន្ថយសំឡេងនៅគ្រប់ទូរស័ព្ទទាំងអស់
- រៀបចំកន្លែងដែលទូលាយទំហំ ២៤០០ម.ម x ២៤០០ម.ម
- ខ្សែទូរស័ព្ទត្រូវមានប្រវែងយ៉ាងតិច១០០០ម.ម
- កម្ពស់នៃកន្លែងចាប់ទូរស័ព្ទដូចក្នុងរូបភាព
- ត្រូវដំឡើងអក្សរស្ទាបនៅចំណុចកណ្តាលនៃបន្ទះក្តារចុចដែលមានលេខ ៥ឬអក្សរផុសស្ទាបដឹងបាន
- កន្លែងដាក់កាក់ឬកាតត្រូវមានប្រហោងធំសមរម្យ
- ត្រូវបំពាក់ភ្លើងក្នុងកន្លែងប្រើទូរស័ព្ទយ៉ាងហោចណាស់២០០លុច
- ត្រូវចាប់កៅអីឬបង់ដែលអាចបត់ចុះឡើងបាននៅជិតទូរស័ព្ទ

### ៤.៤.២. ទូរស័ព្ទលើតុ (Textphones)

*រូបភាព ៤.៤.២.១. គំរូខ្លះៗអំពីទូរស័ព្ទលើតុ*







*រូបភាព ៤.៤.២.២. រូបសញ្ញាជាសកល អំពីទូរស័ព្ទលើតុ*





*រូបភាព ៤.៤.២.៣. គំរូអំពីទូរស័ព្ទលើតុដាក់ប្រើប្រាស់ជាទូរស័ព្ទបង់ប្រាក់នៅទីធ្លាសាធារណៈ*

- ស្តង់ដានិងការណែនាំអំពីទូរស័ព្ទលើតុ
- ត្រូវដាក់ទូរស័ព្ទលើតុនៅតាមគ្រប់កន្លែងទូរស័ព្ទបង់ប្រាក់
- ត្រូវដាក់ទូរស័ព្ទលើតុនៅតុទទួលភ្ញៀវនិងតាមបញ្ជរផ្តល់សេវា
- ត្រូវបណ្តុះបណ្តាលដល់បុគ្គលិកក្នុងការប្រើទូរស័ព្ទលើតុនិងចេះភ្ជាប់បន្ត
- ត្រូវមានធ្នើរសម្រាប់ទូរស័ព្ទលើតុដែលមានទំហំទទឹង២៥០ម.មនិងជម្រៅ៣៥០ម.មដែលមានផ្ទៃខាងលើទំនេរទំហំ២៥០ម.ម
- ធានាថារាល់សម្ភារៈនៃសេវាទូរស័ព្ទមានដាក់សញ្ញាបញ្ជាក់គ្រប់កន្លែង

### ៤.៤.៣. រោងទូរស័ព្ទ (Telephone Booths)

❖ ស្តង់ដានិងការណែនាំអំពីរោងទូរស័ព្ទ

*រូបភាព ៤.៤.៣.១. ប្លង់កន្លែងធ្វើរោងទូរស័ព្ទ*



- ត្រូវរៀបចំឱ្យមានរោងទូរស័ព្ទសម្រាប់ភាពឯកជននៃអ្នកប្រើប្រាស់និង ជៀសវាងសំឡេងរំខាន
- រោងទូរស័ព្ទត្រូវមានទ្វារទូលាយទំហំទទឹងតូចបំផុត៩៥០ម.ម
- ទូរស័ព្ទត្រូវមានខ្សែវែងសម្រាប់ងាយយកចេញមកប្រើនិងដាក់ទៅវិញ
- ត្រូវមានតុឬធ្នើរដើម្បីឱ្យអ្នកប្រើដៃស្តាំឬអ្នកប្រើដៃឆ្វេងអាចប្រើបានគ្រប់គ្នា
- ត្រូវដាក់សញ្ញាដែលប្រាប់ពីទីតាំងនៃកន្លែងទូរស័ព្ទនីមួយៗឱ្យបានច្បាស់

### ៤.៥. ម៉ាស៊ីនប្រើកាក់និងកាត (Coin and Card-Operated Machines)







❖ ស្តង់ដានិងការណែនាំអំពីម៉ាស៊ីនប្រើកាក់និងកាត

- គ្រប់ម៉ាស៊ីនប្រើកាក់និងកាតទាំងអស់ត្រូវរៀបចំឱ្យរទេះជនមានពិការភាព ចេញចូលនិងចុះឡើងបាន
- ត្រូវដាក់ម៉ាស៊ីនណាដែលងាយយល់និងងាយប្រើ
- ដាក់ម៉ាស៊ីននៅតាមទីតាំងណាដែលសមស្របបំផុត
- ត្រូវដាក់សញ្ញាឱ្យបានច្បាស់អំពីទីតាំងម៉ាស៊ីនយកសំបុត្រនិងអេធីអឹម

- រៀបចំទីតាំងដែលទូលាយមានទំហំ២៤០០ម.ម x ២៤០០ម.មសម្រាប់ប្រើម៉ាស៊ីន
- មិនត្រូវប្រើជើងតាងផ្ទះកល់ទូម៉ាស៊ីនទេ
- ធានាថារាល់ស្លាកសញ្ញាដាក់ចង្អុលបង្ហាញត្រូវតែច្បាស់និងងាយយល់បំផុត
- ត្រូវប្រើអក្សរទំហំលេខ១៦ដោយប្រើទាំងអក្សរតូចនិងអក្សរធំ
- ប្រើប្រាស់លេខដើម្បីជាជំនួយបន្ថែមនៅកន្លែងណាដែលសមស្រប
- សូមផ្តល់ការណែនាំជាអក្សរស្ទាបផង
- ធានាថាប៊ូតុងងាយប្រើទោះបីមានតែដៃម្ខាងក៏អាចប្រើបាន
- ធានាថាប៊ូតុងចុចទាំងអស់មានកម្រាស់យ៉ាងហោចណាស់២០ម.មនិងលេខមកលើបន្តិច
- ប៊ូតុងចុចទាំងអស់មិនត្រូវតឹងពេកទេគឺមានកម្លាំង១៩.៥០
- ត្រូវមានពន្លឺគ្រប់គ្រាន់គឺយ៉ាងហោចណាស់២០០លុច
- ត្រូវមានក្រដាសណែនាំសម្រាប់ការប្រើប្រាស់ទាំងអស់
- ត្រូវមានដំបូលគ្រប់កន្លែងទូរស័ព្ទដែលដាក់ខាងក្រៅទាំងអស់
- បើមានទ្វារត្រូវមានទទឹងតូចបំផុត៩០០ម.មនិងងាយបើកបិទ

### ៤.៥.១. ម៉ាស៊ីនទុកនិងលក់សំបុត្រ

(Ticket Dispensers and Vending Machines)

❖ ស្តង់ដានិងការណែនាំអំពីម៉ាស៊ីនទុកនិងលក់សំបុត្រ

*រូបភាព ៤.៥.១.១. កម្ពស់ប៊ូតុងបញ្ជាចុចយកសំបុត្រនិងទំនិញពីម៉ាស៊ីន*




**កំណត់ចំណាំ៖**

- ប៊ូតុងបញ្ជានិងប្រហោងដាក់កាក់ត្រូវដាក់កម្ពស់៧៥០មមទៅ១២០០មមពីដី
- កន្លែងលូកយកទំនិញត្រូវធំទូលាយដាក់បញ្ឈរកម្ពស់៤០០មមពីដី

**សម្គាល់៖** ខ្នាតទាំងអស់គិតជា មម

- ត្រូវមានកម្ពស់ដូចរូបខាងលើនេះ
- ធានាថាមានទីធ្លាគ្រប់គ្រាន់ដែលរទេះអាចចេញចូលប្រើប្រាស់បាន
- ត្រូវមានការណែនាំជាអក្សរឬសំឡេងដែលសាមញ្ញងាយយល់និងធ្វើតាមបានគ្រប់គ្នា

## ៤.៥.២.ម៉ាស៊ីនដកនិងដាក់ប្រាក់ដោយស្វ័យប្រវត្តិ

(Automated Teller Machines(ATMs)



❖ ស្តង់ដានិងការណែនាំអំពីម៉ាស៊ីនដកនិងដាក់ប្រាក់ដោយស្វ័យប្រវត្តិ

*រូបភាព ៤.៥.២.១. ទំហំខ្នាតខ្លះៗនៃម៉ាស៊ីនដកនិងដាក់ប្រាក់ដោយស្វ័យប្រវត្តិ*




- គ្រប់ម៉ាស៊ីនដកនិងដាក់ប្រាក់ដោយស្វ័យប្រវត្តិទាំងអស់ត្រូវរៀបចំឱ្យរទេះជនមានពិការភាពចេញចូលនិងចុះឡើងបាន
- ធានាថារាល់ស្លាកសញ្ញាទាំងអស់ត្រូវតែមើលឃើញច្បាស់ពីមុខនិងពីចំហៀង
- ត្រូវដាក់ភ្លើងនៅតាមស្លាកសញ្ញាដើម្បីអាចមើលឃើញនៅពេលយប់
- ត្រូវឱ្យមានកន្លែងទំនេរទំហំ២៤០០ម.ម x ២៤០០ម.មនិងអាចចេញចូលចុះឡើងបាន
- ត្រូវដាក់ភ្លើងនៅត្រង់កន្លែងយ៉ាងតិច២០០លុច

- ធានាថាទូអេធីអឹមដែលនៅខាងក្រៅត្រូវមានដំបូល
- កញ្ចក់អេក្រង់ដែលណែនាំត្រូវតែមើលឃើញច្បាស់
- ត្រូវធានាថាមានកន្លែងចេញចូលនិងមិនទើសជើងសម្រាប់ជនមានពិការភាពជិះរទេះប្រើប្រាស់
- ធានាថាបន្ទះកញ្ចក់អេក្រង់ត្រូវបានដាក់ទេរល្មមអាចប្រើប្រាស់បានគ្រប់ៗគ្នា
- ត្រូវរៀបចំការណែនាំដែលសាមញ្ញនិងងាយយល់
- ធានាថាអក្សរនៅក្នុងអេក្រង់មានទំហំ១៨និងមានពណ៌ច្បាស់ងាយអាន
- ធានាថាគ្រប់ប៊ូតុងចុចងាយបញ្ជាបានមិនស្ទឹកមិនគាំង
- ត្រូវដំឡើងភាសាដែលមនុស្សភាគច្រើនប្រើប្រាស់និងងាយយល់គ្រប់គ្នា
- ធានាថាពន្លឺនៅលើអេក្រង់គឺពី២០០ទៅ៣០០លុច
- ធានាថាកាត ប្រាក់និងក្រដាសព័ត៌មានវិក័យបត្រមានទំហំធំល្មមអាចយកមកអានបាន
- ត្រូវបំពាក់សម្ភារៈដែលបោះពុម្ពជាអក្សរធំៗ
- បើមានទ្វារត្រូវតូចបំផុត៩០០ម.មអាចបើកបិទដោយងាយស្រួល

## ៤.៦. ផ្ទះបាយនិងកន្លែងទទួលទានអាហារ

(Kitchen and Refreshment Facilities)



*រូបភាព ៤.៦.១. គំរូអំពីផ្ទះបាយដែលឪហ្សាញសមរម្យនិងងាយស្រួលប្រើប្រាស់*

❖ ស្តង់ដានិងការណែនាំអំពីផ្ទះបាយនិងកន្លែងទទួលទានអាហារ

- ត្រូវរៀបចំនៅជិតកន្លែងសម្រាប់ទទួលទានអាហារនិងកន្លែងអង្គុយធ្វើការ
- ត្រូវរៀបចំរបៀបបើកគ្រប់ច្រកដើម្បីសម្រួលការចេញចូលពីកន្លែងចម្អិនអាហារនិងកន្លែងអង្គុយ
- ត្រូវគិតពីកម្ពស់ចង្ក្រាននិងកន្លែងចូលជើងសម្រាប់អ្នកជិះរទេះផង
- កន្លែងទុកចានឬឧបករណ៍ប្រើប្រាស់ត្រូវរៀបចំឱ្យបានត្រូវកន្លែងនិងអាចយកប្រើបានងាយ
- ត្រូវមានពន្លឺនិងខ្យល់ចេញចូលបានស្រួល

### ៤.៦.១. កន្លែងដាក់អាហារនិងកន្លែងចម្អិន

(Layout and Work Surfaces)

❖ ស្តង់ដានិងការណែនាំអំពីកន្លែងដាក់អាហារនិងកន្លែងចម្អិន

*រូបភាព ៤.៦.១.១. ការរៀបចំផ្ទះបាយដែលមើលពីលើឃើញ*






*រូបភាព២.៦.១.២.  ផ្ទះបាយដែលធ្វើម៉ូតសងខាងមានកម្ពស់ស្មើគ្នា*




- ត្រូវរៀបចំផ្ទៃនៃកន្លែងធ្វើការដូចបង្ហាញក្នុងរូបភាព
- ធានាថាកន្លែងចម្អិនអាហារត្រូវមានកម្ពស់៩០០ម.មនិងកៅអីឬបង់អង្គុយមានកម្ពស់៧៦០ម.ម
- ត្រូវធានាថាទាំងកន្លែងចម្អិននិងកន្លែងដាក់អាហារមានប្រហោងខាងក្រោមសម្រាប់អ្នកជិះរទេះប្រើ
- គួរគិតអំពីកន្លែងខ្លះអាចបន្ថែមបន្ថយកម្ពស់បានសម្រាប់មនុស្សដែលមានកម្ពស់ខុសគ្នា

- រៀបចំឱ្យមានទីធ្លាដែលមានអង្កត់ផ្ចិត២៤០០ម.មរវាងកន្លែងដែលមានរាងជាអក្សរអិលនិងអក្សរយូ
- ត្រូវរៀបចំឱ្យមានទីធ្លាដែលមានទទឹង១១០០ម.មនៅចុងសងខាងកន្លែងដាក់អាហារ
- រៀបបំពាក់ចង្ក្រានដែលនៅជាប់ៗគ្នាដើម្បីសម្រួលដល់ការចម្អិន
- អាចគិតគូរបន្ថែមកន្លែងចម្អិនដោយបំពាក់បន្ទះកម្រាលដែលអាចដកចេញនិងដាក់ចូលវិញបាន
- ត្រូវធានាថាផ្ទៃកន្លែងចម្អិនអាហារមានពណ៌ខុសពីពណ៌ជញ្ជាំងនិងកម្រាលឥដ្ឋ

### ៤.៦.២. ឃ្លាំងស្តុកនៅក្នុងផ្ទះបាយនិងកន្លែងទទួលទានអាហារសម្រន់

(Storage in Kitchen and Refreshment Areas)



*រូបភាព ៤.៦.២.១. គំរូអំពីទូដាក់ចាន ទូទឹកកក និងម៉ាស៊ីនដុតនំដែលឪហ្សាញបានល្អ*



*រូបភាព ៤.៦.២.២. គំរូអំពីទូដាក់ចានដែលសមស្របសម្រាប់ជនមានពិការភាព*

❖ ស្តង់ដានិងការណែនាំអំពីឃ្លាំងស្តុកនៅក្នុងផ្ទះបាយនិងកន្លែងទទួលទានអាហារសម្រន់

- ធានាថាឃ្លាំងស្តុកមានសុវត្ថិភាពពេលប្រើប្រាស់ជាពិសេសស្រួលរកវត្ថុផ្សេងៗ
- ត្រូវរៀបចំឱ្យមានកន្លែងបើកឡើងលើបាននិងធ្នើរដែលបត់ទៅចំហៀងបាន
- ត្រូវមានរទេះកង់សម្រាប់ងាយរុញដឹកអីវ៉ាន់
- បំពាក់ធ្នាក់ដៃសម្រាប់ចាប់កាន់ដែលងាយប្រើប្រាស់និងមានពណ៌ខុសពីថតធ្នើរនិងទ្វារមុខ
- ធានាថាទ្វារទូដាក់ចាន កែវ ពែង ត្រូវមានត្រចៀកដែលអាចបើកបាន ១៨០ដឺក្រេ

### ៤.៦.៣. កន្លែងលាងចាននិងឧបករណ៍ផ្ទះបាយ (Sinks and Appliances)

❖ ស្តង់ដានិងការណែនាំអំពីកន្លែងលាងចាននិងឧបករណ៍ផ្ទះបាយ

- កន្លែងលាងចានគួរដាក់នៅទីតាំងកណ្តាលដោយមិនជិតជាង៤៦០ម.ម ពីជញ្ជាំងឬទូសម្រាប់ដាក់ចាន
- ចាននៃកន្លែងលាងចាននៅផ្ទះបាយត្រូវដាក់នៅកម្ពស់ទាបដែលមនុស្សអង្គុយកៅអីអាចប្រើប្រាស់បានដោយមិនជ្រៅជាង១៥០ម.ម
- ដោយសារតែជង្គង់និងជើងរបស់អ្នកប្រើរទេះអាចទៅដល់កន្លែងលាងចាន ដូច្នេះផ្ទៃនៅខាងក្រោមចានគួរតែទូលាយនិងមិនគួរស្រួចដែលអាចឱ្យមុតជើងបាន
- បំពង់បង្ហូរទឹកនិងកាកសំណល់នានាដែលស្ថិតនៅផ្ទៃខាងក្រោមកន្លែងលាងចានត្រូវដាក់នៅជាប់ជញ្ជាំងខាងក្រោយតាមដែលអាចធ្វើទៅបានដើម្បីកុំឱ្យប៉ះពាល់ដល់កន្លែងចូលជើងជង្គង់

- បំពង់ទឹកក្ដៅគួរដាក់នៅឆ្ងាយតាមដែលអាចធ្វើទៅបានដែលជៀសវាងប៉ះពាល់ដោយយថាហេតុ
- កន្លែងលាងចាននិងឧបករណ៍ផ្ទះបាយត្រូវដាក់នៅកម្ពស់ឱ្យសមស្របទៅនឹងបំពង់បង្ហូរទឹកនិងកន្លែងបង្ហូរកាកសំណល់ផ្សេងៗហើយគួរតែកំណត់មិនឱ្យលេចទាំងផ្នែកខាងក្រោមនិងខាងលើ
- ក្បាលរ៉ូប៊ីណេត្រូវដាក់ឱ្យចំពាក់កណ្ដាលកន្លែងលាងចានក្នុងការបង្ហូរទឹក
- កន្លែងតភ្ជាប់ក្បាលរ៉ូប៊ីណេគួរតែដាក់ឱ្យខ្ពស់ល្មមអាចកាច់បង្ហូរទឹកបាន
- ការប្ដូរបែបនេះវាជាតម្រូវការសម្រាប់អ្នកកាន់របស់ប្រើប្រាស់មកត្រងយកទឹក
- ក្បាលរ៉ូប៊ីណេត្រូវចាប់នៅកន្លែងដែលងាយស្រួលបិទបើកទឹកគឺដាក់នៅចំហៀងមិនត្រូវដាក់ខាងក្រោយចានលាងទេ
- កន្លែងចាប់កាច់បិទបើកទឹកត្រូវងាយស្រួលប្រើប្រាស់សម្រាប់គ្រប់គ្នាហើយមើលឃើញច្បាស់ល្អនិងអាចប្រើតែដៃម្ខាងបាន
- ដើម្បីឱ្យមានសុវត្ថិភាពកន្លែងផ្ដល់ទឹកក្ដៅមិនគួរដាក់លើសពី៤០អង្សារសេទេ
- កន្លែងក្បាលរ៉ូប៊ីណេបាញ់ទឹកពេលបើកគួរសម្រួលមិនឱ្យទឹកបាញ់ខ្ទាតចេញនិងប៉ះពាល់ដល់អ្នកប្រើប្រាស់ឬខ្ទាតចេញមកលើផ្ទៃនោះទេ



*រូបភាព២.៦.៣.១. គំរូអំពីកន្លែងលាងចានដែលសមស្របសម្រាប់ជនមានពិការភាពនិងមានកម្ពស់អាចផ្លាស់ប្ដូរបានដែលធុងលាងចានអាចលើកឡើងនិងទម្លាក់ចុះទៅតាមតម្រូវការអ្នកប្រើប្រាស់*

- ជើងចង្ក្រានហ្គាសនិងម៉ាស៊ីនកម្តៅអាហារត្រូវដាក់ផ្សេងគ្នាទាំងកម្ពស់និងចន្លោះពីគ្នាឱ្យបានសមរម្យ
- ជើងចង្ក្រានសេរ៉ាមិក( ប្រើភ្លើង )មានការនិយមប្រើដោយសារតែស្រួលដាក់ឆ្នាំងឬខ្ទះចម្អិនអាហារ
- កន្លែងចម្អិនអាហារទាំងចង្ក្រានឬម៉ាស៊ីនកម្តៅអាហារគួរតែទប់កម្តៅបានដែលងាយលើកឆ្នាំងឬខ្ទះដោយផ្ទាល់បាន



*រូបភាព ៤.៦.៣.២. គំរូអំពីចង្ក្រានអគ្គិសនីដែលងាយស្រួលសម្រាប់ជនមានពិការភាព*

- ផ្នែកខាងក្រោមនៃចង្ក្រានហ្គាសត្រូវដាក់នៅឱ្យខ្ពស់ជាងជង្គង់
- ហ្គាសនៃចង្ក្រានត្រូវងាយស្រួលបិទបើក សុវត្ថិភាពនិងដាក់នៅពីមុខកុំដាក់នៅចំហៀងដើម្បីឱ្យអ្នកប្រើប្រាស់ងាយស្រួលកាច់បើកបិទហើយមិនបង្កគ្រោះថ្នាក់នៅពេលបើក
- ចង្ក្រានអគ្គិសនីត្រូវមានសញ្ញាបញ្ជាក់ថាវានៅក្តៅទោះបីបានបិទភ្លើងហើយក៏ដោយ
- អ្នកប្រើប្រាស់ចង្ក្រានហ្គាសត្រូវអាចបើកដោយខ្លួនឯងតែដៃម្ខាងបាន
- ម៉ាស៊ីនកម្តៅអាហារដែលមានកន្លែងអង្គុយត្រូវធ្វើឱ្យគែមខាងក្រោមកម្ពស់៧៦០ម.មពីដី

- ម៉ាស៊ីនកម្ដៅអាហារដែលមានកន្លែងឈរត្រូវធ្វើឱ្យតែមខាងក្រោមមានកម្ពស់៨៥០ម.មពីដី
- ទ្វាររបស់ម៉ាស៊ីនកម្ដៅអាហារត្រូវដាក់ទ្វារតែម្ខាងនិងអាចបើកបានកម្រិត១៨០ដឺក្រេ ព្រោះវាមិនបង្កឱ្យចង្អៀតនិងមិនមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់
- ទ្វារតែម្ខាងរបស់ម៉ាស៊ីនកម្ដៅអាហារគួរតែជាបន្ទះដែកដែលធន់នឹងកម្ដៅលាតសន្ធឹងយ៉ាងហោចណាស់២៥០ម.មនៃទទឹងទាំងមូល
- ធ្នើរឬបន្ទះទ្រត្រូវអាចទ្រទម្ងន់ចានឬថាសធ្ងន់ៗបាន

*រូបភាព ៤.៦.៣.៣. គំរូអំពីផ្ទះបាយដែលឌីហ្សាញសមស្របសម្រាប់ជនមានពិការភាព*



- កន្លែងបិទបើករបស់ម៉ាស៊ីនកម្ដៅអាហារត្រូវដាក់នៅចន្លោះពី៧៥០ម.ម និង១០៥០ម.មពីដីនិងដាក់តួម៉ាស៊ីនមិនឱ្យខ្ពស់ជាង១២០០ម.មនោះទេ

- កន្លែងបិទបើកត្រូវតែមើលឃើញច្បាស់ សាមញ្ញ ងាយស្រួលបើកបិទដោយដៃម្ខាងបាន
- ម៉ាស៊ីនកម្តៅអាហារដោយអគ្គិសនីត្រូវចាប់ឱ្យជាប់នៅនឹងមួយកន្លែងដែលផ្នែកខាងក្រោមវាមិនត្រូវលើសពី៨៥០ម.មពីដីឡើយ
- កន្លែងបិទបើកនៅផ្នែកខាងលើមិនត្រូវលើសពី១១៥០ម.មពីដីនិងត្រូវមានលក្ខណៈងាយស្រួលយល់និងប្រើប្រាស់

### ៤.៦.៤. កុងតាក់និងព្រីភ្លើង (Switches and Socket Outlets)

❖ ស្តង់ដានិងការណែនាំអំពីកុងតាក់និងព្រីភ្លើង

*រូបភាព ៤.៦.៤.១. ការចាប់កុងតាក់និងព្រីភ្លើង*



- ធានាថាកុងតាក់និងព្រីភ្លើងអាចមើលឃើញច្បាស់ពេលប្រើប្រាស់
- មិនត្រូវដាក់កុងតាក់និងព្រីភ្លើងខ្ពស់ជាង១០០០ម.មពីកម្រាលឥដ្ឋការ៉ូទេ និងត្រូវរក្សាទុកប្រហោងដាក់ជើងសម្រាប់អ្នកជិះរទេះ
- អាចដាក់កុងតាក់និងព្រីភ្លើងបែរទៅរកខាងមុខឬជញ្ជាំង បើសិនមិនមានប្រហោងសម្រាប់ដាក់ជើងអ្នកជិះរទេះ
- ត្រូវដាក់កុងតាក់និងព្រីភ្លើងនៅលើរបស់ដែលអាចបន្ថែមឬបន្ថយបានដោយការប្រុងប្រយ័ត្នបំផុត
- ធានាថាប្រអប់កុងតាក់និងព្រីភ្លើងមានពណ៌ផ្ទុយគ្នានិងពណ៌ជញ្ជាំង

### ៤.៧. បង្អួច (Windows)





❖ ស្តង់ដានិងការណែនាំអំពីបង្អួច



*រូបភាព ៤.៧.១. ទីតាំងនៃផ្ទាំងកញ្ចក់បង្អួច*

- បង្អួចមានសារៈសំខាន់នៅតាមអគារនីមួយៗដែលអាចឱ្យពន្លឺនិងខ្យល់ចេញចូលបានគ្រប់គ្រាន់
- ទីតាំង ទំហំ ប្រភេទ ម៉ូដែល ម៉ូដ រចនាបថ ទម្រង់និងចំនួននៃបង្អួចនៅតាមបន្ទប់ឬអគារនីមួយៗមានលក្ខណៈផ្សេងៗគ្នាទៅតាមតម្រូវការ រួមមានពន្លឺ ខ្យល់ចេញចូល គ្រឿងផ្សំ សន្តិសុខ សុវត្ថិភាព ភាពឯកជន សម្រស់ ភាពរឹងមាំនិងតម្លៃ។ល។




- ប្រសិនបើបង្អួចបើកដោយដៃត្រូវតែងាយស្រួលបិទបើកនិងសមរម្យបំផុតសម្រាប់ជនមានពិការភាព
- មិនត្រូវមានកូនបង្អួចនៅលើទ្វារដែលមានកម្ពស់ពីដីពី៩០០ម.មនិង១២០០ម.ម
- បំពាក់ដៃកាន់និងគន្លឹះបង្អួចដែលសមរម្យអាចប្រើបានដោយដៃម្ខាងងាយយល់ ងាយប្រើនិងដាក់កម្ពស់ពីដី៨០០ម.មទៅ១០០០ម.ម





- កម្លាំងរបស់បង្អួចពេលបិទនិងពេលបើកមិនត្រូវលើសពី៥.៥ញូតុនទៅ ៨ញូតុន
- ឧបករណ៍បើកបង្អួចដោយអគ្គិសនីអាចបំពាក់បានក្នុងករណីដែល ឧបករណ៍បើកដោយដៃមិនអាចបើកបានឬនៅឆ្ងាយពីដៃពេក ហើយ ឧបករណ៍បញ្ជាបើកបង្អួចនោះត្រូវដាក់ក្នុងកម្ពស់៧៥០ម.មទៅ ១០០០ម.មពីដី
- ដាក់គន្លឹះប្រើដៃដោយត្រូវការកម្លាំងដៃតិចអាចបើកបិទបាន
- ធានាថាបង្អួចមិនមានឧបសគ្គនិងគ្រោះថ្នាក់អ្វីកើតឡើងនៅពេល ប្រើឡើយ





- ធានាថាបង្អួចនៅជាន់ទី១និងជាន់ខាងលើបន្តបន្ទាប់មិនត្រូវបើកលើសពី១០០ម.មឡើយ
- គួរបំពាក់ឧបករណ៍ប្រើអគ្គិសនីបញ្ជាពីចម្ងាយសម្រាប់បើកនិងបិទប្រសិនបើបង្អួចនៅខ្ពស់ឬឆ្ងាយផុតពីដៃ



*រូបភាព ៤.៧.២. បង្អួចដែលមានពន្លឺចេញចូលបានល្អ*

## ៤.៨. គំនិតច្នៃប្រឌិតសម្រាប់ថ្នាក់រៀនមេត្រី

(Appropriate Concept in an Inclusive Class)

❖ ស្តង់ដានិងការណែនាំអំពីគំនិតច្នៃប្រឌិតសម្រាប់ថ្នាក់រៀនមេត្រី

- កុមារដែលប្រើរទេះរុញត្រូវការកន្លែងបន្ថែមខ្លះដើម្បីផ្លាស់ទីនិងផ្ទេរពីរទេះរុញទៅកៅអី





- គួរជ្រើសរើសកន្លែងអង្គុយសម្រាប់ពួកគេដោយប្រុងប្រយ័ត្ន។ ពិភាក្សាជាមួយពួកគេអំពីទីតាំងដែលសមស្របជាងគេ
- ដើម្បីបង្កើនការចូលរួមរបស់កុមារពិការនៅក្នុងថ្នាក់រៀន សូមកុំឱ្យពួកគេអង្គុយនៅតុឆ្ងាយពីមិត្តរួមថ្នាក់ដទៃទៀតឬអង្គុយតែឯង
- មិនគួរមានឧបសគ្គក្នុងថ្នាក់រៀនដើម្បីឱ្យពួកគេទៅកាន់តុរបស់ពួកគេនិងទៅកាន់ក្តារខៀននោះទេ
- រៀបចំថ្នាក់រៀនដើម្បីផ្តល់ទីកន្លែងគ្រប់គ្រាន់ឱ្យសិស្សប្រើរទេះរុញអាចផ្លាស់ទីជុំវិញបាន
- ពេលខ្លះចាំបាច់ត្រូវបន្ទាបកម្ពស់ក្តារខៀនសម្រាប់កុមារដែលប្រើរទេះរុញដើម្បីឱ្យពួកគេអាចសរសេរបានដែរ





- ប្រសិនបើអាចនៅមុខក្តារខៀនត្រូវធ្វើជម្រាលតាមស្តង់ដាដើម្បីឱ្យកុមារអាចចូលរួមបាន
- នៅក្នុងថ្នាក់រៀនទាំងមូលត្រូវធានាថាកុមារប្រើប្រាស់រទេះអាចចល័តទីបានគ្រប់ទីកន្លែង

- ត្រូវធានាថាកុមារដែលខ្សោយគំហើញត្រូវបានឱ្យអង្គុយចម្ងាយសមរម្យពីក្ដារខៀន

 

# ផ្នែកទី៥ អំពីបរិក្ខារអនាម័យ (SANITARY FACILITIES)





របៀបផ្លាស់ទីចុះឡើងរវាងរទេះនិងចានបង្គន់



## ៥.១. បន្ទប់ទឹកសម្រាប់ភេទតែមួយ (Single-Sex Toilets)



*រូបភាព ៥.១.១. គំរូអំពីបង្គន់សម្រាប់ភេទតែមួយ និងបន្ទប់ទឹកបុរស/ស្ត្រី*

❖ ស្តង់ដានិងការណែនាំអំពីបង្គន់សម្រាប់ភេទតែមួយ

- រៀបចំឱ្យត្រូវកន្លែងចំពោះបន្ទប់ងូតទឹក បង្គន់នោមបុរសនិងកន្លែងលាងដៃ
- រៀបចំចានបង្គន់ដែលអាចប្រើបានសម្រាប់ទាំងអស់គ្នា
- ត្រូវរចនាបន្ទប់សម្រាប់អ្នកពិការដែលពិបាកធ្វើចលនាអាចប្រើបាន
- បន្ថែមទំហំបន្ទប់សម្រាប់អ្នកត្រូវការទីធ្លាធំទូលាយ
- ដាក់ត្រចៀកទ្វារដែលត្រូវគ្នានិងទ្វារសមស្រប
- ត្រូវបំពាក់បាសាំងសម្រាប់លាងដៃដែលមានកម្ពស់ផ្សេងៗគ្នា
- បាសាំងលាងដៃត្រូវមានប្រដាប់បិទបើកឬគន្លឹះស្វ័យប្រវត្តិ
- ធានាថាក្នុងចំណោមបង្គន់នោម២មានបង្គន់នោម១ដែលរចនាឡើងសម្រាប់ជនមានពិការភាពដែលជិះរទេះ
- ត្រូវមានផ្ទាក់ដៃដែលសមរម្យបំផុតនៅតាមបង្គន់នោមសម្រាប់ជនមានពិការភាព

### ៥.១.១. កន្លែងងូតទឹកក្នុងបង្គន់

(Accessible Toilet Cubicles)



❖ ស្តង់ដានិងការណែនាំអំពីកន្លែងងូតទឹកក្នុងបង្គន់

*រូបភាព ៥.១.១.១. ទំហំខ្នាតនៃកន្លែងងូតទឹកដែលសមស្របសម្រាប់ជនមានពិការភាពផ្នែកចលនា*




*រូបភាព ៥.១.១.២. ការដាក់ផ្ទាក់ដៃនៅតាមកន្លែងងូតទឹកសម្រាប់ជនមានពិការភាពផ្នែកចលនា*



- ត្រូវដាក់ធុងសំរាមមួយនៅក្នុងបន្ទប់ងូតទឹកនេះ
- បន្ទប់ត្រូវមានទំហំតូចបំផុត៩០០ម.ម x ៩២០ម.ម
- រក្សាកន្លែងទំនេរសម្រាប់បត់បែនរទេះទំហំ៩០០ម.ម x ៩០០ម.មដែលមិនគិតពីទីធ្លានៃចានបង្គន់និងទីធ្លាសម្រាប់ការបិទបើកទ្វារ
- ចានបង្គន់ត្រូវដាក់កម្ពស់៤៨០ម.មពីដី

### ៥.១.២. កន្លែងងូតទឹកដែលទូលាយ (Enlarged Cubicles)

❖ ស្តង់ដានិងការណែនាំអំពីកន្លែងងូតទឹកដែលទូលាយ

*រូបភាព ៥.១.២.១. កន្លែងងូតទឹកទូលាយសម្រាប់ជនមានពិការភាពដែលត្រូវការទីធ្លាបន្ថែម*




- កន្លែងងូតទឹកដែលទូលាយអាចឱ្យមនុស្សគ្រប់រូបប្រើប្រាស់បានស្រួល
- កន្លែងងូតទឹកដែលទូលាយត្រូវមានទំហំ១២០០ម.ម
- រក្សាទីធ្លាទំនេរសម្រាប់បត់រទេះ៩០០ម.ម x ៩០០ម.ម
- បាសាំងលាងដៃត្រូវដាក់កម្ពស់ចន្លោះពី៦៨០ម.មទៅ៩០០ម.មពីដី

### ៥.១.៣. បង្គន់នោមសម្រាប់បុរស (Urinals)

*ឧទាហរណ៍៖ បង្គន់នោមសម្រាប់កុមារដែលមានរបាំងបែងចែក*



*ឧទាហរណ៍៖ ចានបង្គន់នោមដែលមានទ្នាក់ដៃ*





- ស្តង់ដានិងការណែនាំអំពីបង្គន់នោមសម្រាប់បុរស



*រូបភាព ៥.១.៣.១. ការរៀបចំបង្គន់នោមសមស្របសម្រាប់បុរស*




- បង្គន់នោមសម្រាប់បុរសត្រូវចាប់ឬដាក់កម្ពស់ពី៣៨០ម.មទៅ៥០០ម.ម
- ត្រូវរក្សាទីធ្លាទំនេរទំហំ៩០០ម.ម x ១៤០០ម.ម
- បង្គន់នោមមួយគួរមានបង្កោលសម្រាប់ចាប់កាន់ប្រវែង៥០០ម.មពីចានបង្គន់នោមដោយមានរបារទប់ទ្រូងកម្ពស់១១០០ម.មទៅ ១២០០ម.មសម្រាប់មនុស្សពេញវ័យនិង៧០ម.ម សម្រាប់កុមារ
- ដំឡើងនៅសងខាង៖៦០០ម.មចន្លោះបង្កោលនិងនៅខាងមុខចានបង្គន់នោមដើម្បីជួយដល់ជនមានពិការភាព ដែលមានការលំបាកក្នុងការដើរ ឬឈរ (ឧទាហរណ៍៖ អ្នកដែលប្រើឈើច្រត់ជាដើម)
- បង្កោលខាងមុខគឺដើម្បីទប់ទ្រូងបង្កោលចំហៀងគឺសម្រាប់ឱ្យអ្នកប្រើប្រាស់កាន់ទប់ខ្លួននៅពេលឈរ
- ចានបង្គន់នោមប្រភេទចាប់ជាប់នឹងជញ្ជាំងដែលមានគែមទ្រវែងដាក់នៅកម្ពស់ខ្ពស់បំផុតត្រឹម៤៣០ម.មចាប់គិតពីដី
- គួរមានទីធ្លាស្រឡះទំហំ៧៦០ម.ម x ១២២០ម.មនៅខាងមុខចានបង្គន់ដើម្បីឱ្យគេអាចចូលពីខាងមុខបាន

- គ្រប់បង្គន់ទាំងអស់ត្រូវមានរូបបង្ហាញ (បុរសរាងត្រីកោណនិង ស្រីរាងមូល) ដាក់លើបន្ទះនិងមានអក្សរស្ទាបព្យួរនៅជាប់នឹងទ្វារ។

### ៥.២. បង្គន់សម្រាប់ភេទច្រើន (Unisex Toilets)



❖ ស្តង់ដានិងការណែនាំអំពីបង្គន់សម្រាប់ភេទច្រើន

- ធានាថាបង្គន់សម្រាប់ភេទច្រើនសមស្របសម្រាប់អ្នកនៅក្នុងអគារ ប្រសិនបើមានតែមួយ
- ធានាថាអង្កត់ផ្ចិតបន្ទប់មានទំហំយ៉ាងតិចទទឹង២៣០០ម.ម x បណ្តោយ ២៥០០ម.ម
- បន្ថែមបាសាំងលាងដៃបញ្ឈរដែលមានតែមកម្ពស់ពី៧៨០ម.មទៅ ៨០០ម.មដែលមានសាប៊ូលាងដៃនិងម៉ាស៊ីនសម្ងួតដៃឬកន្សែងជូតដៃ

#### ៥.២.១. បង្គន់សម្រាប់ភេទច្រើនប្រើប្រាស់បាន (Unisex Accessible Toilet)

*រូបភាព ៥.២.១.១. គំរូអំពីទ្វារនៃបង្គន់សម្រាប់ភេទច្រើនរួមទាំងស្លាកសញ្ញា*





*រូបភាព ៥.២.១.២. គំរូអំពីទ្វារនៃបង្គន់សម្រាប់ភេទច្រើន*

❖ ស្តង់ដានិងការណែនាំអំពីបង្គន់សម្រាប់ភេទច្រើនប្រើប្រាស់បាន

- បង្គន់សម្រាប់ភេទច្រើនប្រើប្រាស់បាន( ត្រូវបានគេហៅថាបង្គន់ដែលអាចបង្កលក្ខណៈងាយស្រួលសម្រាប់អ្នកប្រើរទេះរុញ )គឺត្រូវបានរចនាឡើងដើម្បីឱ្យស្របនឹងតម្រូវការរបស់អ្នកប្រើរទេះដោយមានឯករាជ្យភាព ប៉ុន្តែវាក៏ត្រូវបានបំពាក់ដើម្បីសម្របទៅតាមលក្ខខណ្ឌជាក់ស្តែងរបស់ជនមានពិការភាពចលនា ហើយវាប្រហែលជាមានបុគ្គលខ្លះមានតម្រូវការបន្ថែមទៀត ឧទាហរណ៍៖ បន្ថែមទំហំធ្នាក់ដៃជំនួយនិងការបញ្ចូលកន្លែងលាងដៃ
- បន្ទប់គួរមានទំហំទទឹង១៨០០ម.ម x បណ្តោយ២៥០០ម.ម

*រូបភាព ៥.២.១.៣. បង្គន់សម្រាប់ភេទច្រើនដែលសមស្របនិងផ្ទេរចុះឡើងនៅខាងស្តាំដៃ*



*រូបភាព ៥.២.១.៤. បង្គន់សម្រាប់ភេទច្រើនដែលសមស្របនិងផ្ទេរចុះឡើងនៅខាងឆ្វេងដៃ*



- បង្គន់ដែលបង្កលក្ខណៈងាយស្រួលគួរតែដាក់បាសាំងលាងដៃនៅកន្លែងណាដែលអ្នកជិះរទេះអាចប្រើបាន
- ជាធម្មតាបាសាំងលាងដៃមានរាងតូច(ប្រហែល៤៥០ម.ម x ៣០០ម.ម) ដូច្នេះហើយវាមិនត្រូវការកន្លែងធំនិងមិនមែនជាឧបសគ្គសម្រាប់អ្នកប្រើប្រាស់រទេះទេ
- ប្រសិនបើបន្ទប់ធំគួរតែដាក់ចានលាងដៃឱ្យធំផងដែរ
- ទីតាំងនៃបាសាំងលាងដៃគឺវាមានសារៈសំខាន់ណាស់ដែលអាចឱ្យអ្នកលាងនិងសម្ងួតដៃមុននឹងសម្រួលសម្លៀកបំពាក់
- ដូចគ្នាដែរទីតាំងដាក់សាប៊ូ កន្លែងព្យួរក្រដាសនិងកន្សែងអនាម័យគួរតែដាក់នៅកន្លែងណាដែលអ្នកជិះរទេះអាចឈោងយកប្រើបាន

- កម្ពស់នៃបាសាំងលាងដៃគួរតែដាក់ឱ្យអាចប្រើបានទាំងអ្នកឈរនិងអ្នកអង្គុយលើរទេះដែលតែមមានកម្ពស់៧២០ម.មទៅ៧៤០ម.មពីដីនិងមានកន្លែងទំនេរខាងក្រោមសម្រាប់ដាក់ជង្គង់ដែលអាចឱ្យអ្នកអង្គុយប្រើប្រាស់បាន
- ប្រព័ន្ធផ្គត់ផ្គង់ទឹកនិងបំពង់បង្ហូរកាកសំណល់គួរតែបត់ទៅជិតជញ្ជាំងដើម្បីពង្រីកកន្លែងឱ្យបានទូលាយនៅខាងក្រោមបាសាំង
- ក្បាលរ៉ូប៊ីណេត្រូវដាក់នៅផ្នែកខាងនៃចានបាសាំងដែលជិតចានបង្គន់បំផុត
- ក្បាលរ៉ូប៊ីណេត្រូវមានដងកាច់កាន់បញ្ឈរឬចំហៀងឬស្វ័យប្រវត្តិ ឧទាហរណ៍៖ ប្រព័ន្ធសេនស័រ
- គួរជៀសវាងក្បាលរ៉ូប៊ីណេឬកន្លែងកាច់ទឹកនៅកណ្ដាល ព្រោះនាំឱ្យរំខានដល់ការសម្អាតដប/កំប៉ុងទឹកនោម
- ទំហំប្រវែង៧៥០ម.មពីចុងខាងមុខនៃចានបង្គន់ទៅជញ្ជាំងផ្នែកខាងក្រោយគឺសមរម្យណាស់ ខ្ទាតនេះអាចជួយអ្នកប្រើប្រាស់រទេះផ្ទេរខ្លួនពីរទេះទៅចំហៀងចានបង្គន់ស្របជាមួយជញ្ជាំងនិងខាងមុខរទេះស្របទៅនិងខាងមុខនៃចានបង្គន់
- អ្នកប្រើរទេះខ្លះអាចផ្ទេរខ្លួនទៅចំហៀងចានបង្គន់តែម្ដងដែលមិនចាំបាច់ត្រូវការខិតមុខខិតក្រោយអំឡុងពេលដែលគាត់ផ្ទេរខ្លួន



*រូបភាព ៥.២.១.៥. គំរូអំពីឡាវ៉ាបូលាងដៃដែលមានរ៉ូប៊ីណេមុខងារច្រើន កន្លែងដាក់សាប៊ូលាងដៃ កន្លែងដាក់ក្រដាសជូតដៃនិងធ្នាក់ដៃ*



*រូបភាព ៥.២.១.៦. គំរូអំពីបង្គន់សម្រាប់ភេទច្រើនដែលសមស្របនិងផ្ទេរចុះឡើងនៅខាងស្តាំដៃ*

### ៥.២.២. ចានបង្គន់និងបាសាំងទឹក (WC Pans and Cisterns)

❖ ស្តង់ដានិងការណែនាំអំពីចានបង្គន់និងបាសាំងទឹក

- បង្គន់ដែលប្រើអាងទឹកបង្អប់ងាយស្រួលថែរក្សាត្រូវបានកាត់បន្ថយប្រវែង ៧៥០ម.មពីមុខចានបង្គន់ទៅផ្នែកខាងក្រោយនៃជញ្ជាំងឬកន្លែងទំនេរនៅចំហៀងសងខាងចានបង្គន់
- រាល់ការកាត់បន្ថយនៅទំហំកន្លែងសម្រាប់ផ្ទេរខ្លួន វាផ្តល់ការលំបាកដល់អ្នកប្រើរទេះដែលវាអាចផ្ទេរខ្លួនឃើតហើយវាក៏អាចប៉ះពាល់ដល់ការបង្វិលរទេះឬអាចប៉ះទៅនឹងចុងនៃធ្នាក់ដៃដែលនៅជិតចានបង្គន់
- បង្គន់គួរមានកម្ពស់កៅអីដែលអាចផ្លាស់ប្តូរបានដែលបង្កភាពងាយស្រួលដល់អ្នកប្រើប្រាស់ក្នុងការសម្អាតខ្លួនរបស់គាត់នៅពេលអង្គុយលើចានបង្គន់

- ចានបង្គន់គួរតែរឹងមាំហើយភ្ជាប់ទៅនឹងកម្រាលឥដ្ឋប្រសើរជាងភ្ជាប់ទៅនឹងជញ្ជាំង
- កន្លែងអង្គុយគួរតែមានភាពរឹងមាំហើយត្រូវទៅនឹងអ្នកដែលមានបញ្ហាលំនឹងដងខ្លួនជួយសម្រួលដល់ការផ្ទេរខ្លួន
- សណ្ឋាននៃបង្គន់គួរផ្តល់ឱ្យមានកន្លែងសម្រាប់ដាក់ចុងជើងនៅខាងក្រោមដើម្បីជួយសម្របសម្រួលឱ្យអ្នកប្រើប្រាស់ក្នុងការផ្ទេរខ្លួនទៅមុខ ហើយវាសមល្មមសម្រាប់អ្នកប្រើប្រាស់បុរស
- គម្របនៃចានបង្គន់គួរតែចាប់ឱ្យបានជាប់ជៀសវាងគ្រោះថ្នាក់ ព្រោះវានឹងត្រូវបានប្រើប្រាស់ជាបង្អែកខ្នងខណៈពេលដែលកំពុងបន្ទោបង់
- គម្របខ្លះងាយនឹងរង្គើរនិងបាក់បែកនៅពេលកំពុងប្រើប្រាស់ ដូច្នេះបញ្ហានេះគួរជៀសវាង
- ទោះបីជាអាងទឹកនៃចានបង្គន់ទាបឬខ្ពស់ឬដាក់ខាងក្នុងត្រូវរៀបចំឱ្យមានបន្ទះបង្អែកជានិច្ចកាល
- កំហុសជាទូទៅគឺការដាក់ចានបង្គន់នៅកន្លែងកាច់ជ្រុងនៃបន្ទប់បង្គន់ ហើយដាក់កន្លែងចុចទឹកនៅជិតជញ្ជាំងដែលខុសទីតាំងសមរម្យរបស់វា
- ប្រសិនបើកន្លែងកាច់ទឹកនៅខុសទីតាំងមនុស្សជាច្រើននឹងពិបាករកប្រើប្រាស់ ហើយបង្គន់នឹងមិនបានកាច់ទឹកដែលជាហេតុធ្វើឱ្យបាត់បង់អនាម័យ
- កន្លែងកាច់ទឹកគួរតែដាក់នៅផ្នែកដែលអ្នកប្រើប្រាស់ផ្ទេរខ្លួន ដូច្នេះវានឹងត្រូវបានរកឃើញដោយងាយស្រួលហើយគេពិតជានិងកាច់ទឹកនៅពេលគេផ្ទេរចុះពីបង្គន់
- ប្រដាប់កាច់ទឹកគួរតែមានដៃដូចរាងវែកដូច្នេះវាងាយស្រួលសម្រាប់អ្នកមានបញ្ហាដៃ

- បច្ចុប្បន្ននេះការផលិតអាងបង្គន់ដែលមានប្រដាប់កាច់ទឹកសម្រាប់បង្គ លក្ខណៈងាយស្រួលក្នុងការប្រើប្រាស់ដែលប៊ូតុងពីរមានមុខងារផ្សេងគ្នា
- មិនគួរបំពាក់ប្រព័ន្ធដែលប៊ូតុងពីរមានមុខងារផ្សេងគ្នាដែលតម្រូវឱ្យប្រើម្រាមដៃមួយ
- ប្រព័ន្ធដែលល្អគឺអាងទឹកបង្គន់ដែលមានប្រដាប់កាច់ទឹកធូរងាយកាច់បង្ហូរទឹក
- អាចប្រើប៊ូតុងរុញមានទំហំធំល្មមដែលសមស្របទៅនឹងប្រអប់ដៃ កែងដៃអាចកាច់បាននិងតម្រូវឱ្យចុចតែបន្តិច ប្រសិនបើកន្លែងណាដែលត្រូវបានប្រើប៊ូតុងនេះត្រូវដាក់នៅកន្លែងដែលអាចចុចបានយ៉ាងងាយទោះបីគេបានផ្ទេរចុះពីបង្គន់ហើយក៏ដោយ

### ៥.២.៣. បង្គន់ភេទច្រើនដែលទូលាយនិងមានបាសាំងលាងដៃ

(Enlarged Unisex Toilet with Standing Height Washbasin)

❖ ស្តង់ដានិងការណែនាំអំពីបង្គន់ភេទច្រើនដែលទូលាយនិងមានបាសាំងលាងដៃ

- ប្រសិនបើមានកន្លែងទូលាយ ចូរទុកកន្លែងទំនេរដោយរចនាឡើងឱ្យមានសម្រាប់អ្នកអង្គុយនិងអ្នកឈរ ដើម្បីឆ្លើយតបទៅមនុស្សគ្រប់ប្រភេទនិងភាគច្រើនដែលចូលមកក្នុងអគារនោះ
- បង្គន់ភេទច្រើនដែលទូលាយនិងមានបាសាំងខ្ពស់គួរមានទំហំ ២៣០០ម.ម x ២៥០០ម.ម
- បន្ទប់ដែលមានទីតាំងនៅតាមកាច់ជ្រុងត្រូវបន្ថែមអាងទឹកឱ្យខ្ពស់
- កន្លែងដែលមានប្លង់លើសពីមួយ ការរចនាអាចមានច្រើនជម្រើសក្នុងការធ្វើបង្គន់ភេទច្រើន

*រូបភាព ៥.២.៣.១. គំរូអំពីបង្គន់ភេទច្រើនដែលទូលាយនិងមានបាសាំងលាងដៃដាក់បញ្ឈរ*




- បង្គន់ភាគច្រើនដែលទូលាយនិងមានបាសាំងលាងដៃគួរតែមានទំហំធំនៅតាមកន្លែងកាច់ជ្រុងនៃបង្គន់ដើម្បីសម្រួលដល់ការលាងដៃឬការលាងសម្អាតរាងកាយនិងការលាងសម្អាតឧបករណ៍ថែរក្សាផ្ទាល់ខ្លួនផ្សេងៗ
- បាសាំងគួរតែដាក់នៅកម្ពស់គែមខាងលើពី៧៨០ម.មទៅ៨០០ម.ម សម្រាប់អ្នកឈរហើយវាមិនផ្តល់ផលវិបាកក្នុងការផ្ទេររទេះនោះទេ
- កន្លែងដាក់សាប៊ូលាងដៃនិងឧបករណ៍សម្ងួតដៃត្រូវដាក់នៅជិតបាសាំងលាងដៃ

### ៥.២.៤. បង្គន់សម្រាប់គ្រួសារ (Family Toilets)



*រូបភាព ៥.២.៤.១. គំរូអំពីបង្គន់សម្រាប់គ្រួសារ*

❖ ស្តង់ដានិងការណែនាំអំពីបង្គន់ជាលក្ខណៈគ្រួសារ

- រៀបចំបន្ទប់ធំទូលាយសមរម្យសម្រាប់មនុស្សមួយក្រុមតូចប្រើប្រាស់
- បន្ថែមបង្គន់មួយឬច្រើនទៀតបើទីតាំងសមរម្យ
- បំពាក់កន្លែងលាងដៃនិងម៉ាស៊ីនសម្ងួតដៃឬកន្សែងជូតដៃ
- រៀបចំឱ្យមានកន្លែងផ្លាស់សម្លៀកបំពាក់ទារកផង
- ធានាថាបន្ទប់សមរម្យសម្រាប់អ្នកជិះរទេះ អ្នកមានកូនខ្ចី ជនមានពិការភាពគំហើញនិងជនមានពិការភាពដែលប្រើប្រាស់ឧបករណ៍ជំនួយដើរ

### ៥.២.៥. កន្លែងផ្លាស់សម្លៀកបំពាក់ទារក (Baby-Changing Facilities)

*រូបភាព ៥.២.៥.១. គំរូអំពីកន្លែងសម្រាប់ផ្លាស់ប្តូរសម្លៀកបំពាក់ទារក*





❖ ស្តង់ដានិងការណែនាំអំពីកន្លែងផ្លាស់សម្លៀកបំពាក់ទារក

- រៀបចំកន្លែងផ្លាស់សម្លៀកបំពាក់ទារកសម្រាប់ភេទច្រើន
- ត្រូវបន្ថែមកន្លែងផ្លាស់សម្លៀកបំពាក់ទារកនៅតាមបង្គន់បុរសនិងបង្គន់ស្ត្រី
- បំពាក់តុផ្លាស់សម្លៀកបំពាក់ទារកដែលមានកម្ពស់២ផ្សេងគ្នា
- បន្ថែមកន្លែងលាងដៃនិងម៉ាស៊ីនសម្ងួតដៃឬកន្សែងជូតដៃ
- ដាក់ធុងសំរាមសម្រាប់ចោលខោទឹកនោមទារក
- រៀបចំឱ្យមានកន្លែងបំបៅទារកផ្សេងពីនេះ

## ៥.៣. បន្ទប់ទឹកសម្រាប់អ្នកត្រូវការជំនួយ

(Toilets for People who Need Assistance)

❖ ស្តង់ដានិងការណែនាំអំពីបង្គន់សម្រាប់អ្នកត្រូវការជំនួយ

- ធានាថាបន្ទប់ត្រូវមានអង្កត់ផ្ចិតទទឹង២៧០០ម.ម x បណ្តោយ ២៥០០ម.ម
- ត្រូវដាក់បាសាំងលាងដៃដែលអាចឱ្យអ្នកជិះរទេះចូលប្រើបាន
- ដាក់វាំងននសម្រាប់បាំងបង្គន់នីមួយៗ

### ៥.៣.១. បន្ទប់ទឹកសម្រាប់ភេទច្រើនប្រើប្រាស់មានអ្នកជំនួយ

(Unisex Peninsular-Arrangement Toilet for Assisted Use)

❖ ស្តង់ដានិងការណែនាំអំពីបង្គន់សម្រាប់ភេទច្រើនប្រើប្រាស់មានអ្នកជំនួយ

- បង្គន់សម្រាប់អ្នកប្រើប្រាស់មានអ្នកជំនួយជាបង្គន់ដែលអាចប្រើបានទាំងសងខាងដែលចានបង្គន់ត្រូវស្ថិតនៅចំកណ្តាលនៃទំហំបង្គន់
- ការរៀបចំចានបង្គន់ត្រូវឱ្យអ្នកប្រើប្រាស់រទេះអាចផ្ទេរចុះឡើងបានទាំងសងខាងដោយផ្តល់ទំហំនិងត្រូវមានទីទំនេរសម្រាប់អ្នកជួយផង
- ចំពោះបង្គន់ដែលរៀបចំឡើងដោយដាក់ចាននៅចំផ្នែកកណ្តាលវាផ្តល់នូវលក្ខណៈងាយស្រួលក្នុងការផ្ទេរខ្លួននៅគ្រប់ជ្រុងទាំងអស់ដោយបង្គន់ទាំងអស់នោះគួរធ្វើនៅមន្ទីរពេទ្យកន្លែងស្នាក់នៅនិងមជ្ឈមណ្ឌលកីឡា ឬកន្លែងកំសាន្តផ្សេងៗ
- ការមិនបានដាក់ផ្ទាក់ដៃនៅជាប់នឹងចានបង្គន់ឬជាប់នឹងជញ្ជាំងឱ្យបានមាំមានន័យថាមិនមានការគាំទ្រគ្រប់គ្រាន់សម្រាប់អ្នកប្រើប្រាស់ដោយឯករាជ្យ
- ទំហំទាំងមូលរបស់បន្ទប់បង្គន់ទទឹង២៧០០ម.ម x បណ្តោយ ២៥០០ម.ម

*រូបភាព ៥.៣.១.១. បង្គន់សម្រាប់ភេទច្រើនដែលរៀបចំនៅចំកណ្តាល សម្រាប់អ្នកប្រើប្រាស់ដែលត្រូវការជំនួយ*




- សម្រាប់អាងទឹកនៅក្នុងបង្គន់ដែលដាក់នៅចំកណ្តាលត្រូវដាក់នៅឆ្ងាយពីចានបង្គន់
- បង្គន់ដែលដាក់ចាននៅចំកណ្តាលអ្នកប្រើមិនអាចលាងដៃបាននោះទេ ខណៈពេលអង្គុយនៅលើចានបង្គន់ហើយអាងទឹកដែលដាក់ឆ្ងាយដើម្បីធានាឱ្យមានទំហំល្មមសម្រាប់អ្នកជំនួយនៅផ្នែកទាំងសងខាងនៃចានបង្គន់
- គែមខាងលើអាងទឹកគួរដាក់នៅកម្ពស់ពី៧២០ម.មទៅ៨៤០ម.មពីដីដើម្បីឱ្យសមស្របចំពោះអ្នកដែលអង្គុយហើយមានទំហំទូលាយក្នុងការដាក់ជង្គង់ខាងក្រោមចាន
- គួរដាក់វាំងនននៅជុំវិញចានបង្គន់ដើម្បីឱ្យមានភាពឯកជនទាំងអ្នកប្រើនិងអ្នកជំនួយ



រូបភាព ៥.៣.១.២ គំរូអំពីការរៀបចំទីតាំងបង្គន់សម្រាប់ភេទច្រើននៅចំកណ្ដាលសម្រាប់អ្នកប្រើប្រាស់ត្រូវការជំនួយ

### ៥.៣.២. បង្គន់សម្រាប់ភេទច្រើនប្រើប្រាស់មានបង់និងឧបករណ៍ស្ទូចដែលអាចផ្លាស់ប្តូរបាន (Unisex Peninsular-Arrangement Toilet with Adjustable Changing Bench and Hoist Facilities)



រូបភាព ៥.៣.២.១. គំរូអំពីបង្គន់សម្រាប់ភេទច្រើននៅចំកណ្ដាលដែលមានឧបករណ៍ស្ទូចលើកដាក់ជនមានពិការភាព



រូបភាព ៥.៣.២.២. គំរូអំពីបង្គន់សម្រាប់ភេទច្រើននៅចំកណ្ដាលដែលមានកន្លែងផ្លាស់ប្តូរសម្លៀកបំពាក់ដោយជំនួយ



រូបភាព ៥.៣.២.៣. គំរូអំពីកន្លែងផ្លាស់ប្តូរសម្លៀកបំពាក់ដែលមានជំនួយ

❖ ស្តង់ដានិងការណែនាំអំពីបង្គន់សម្រាប់ភេទច្រើនមានបង់និងប្រដាប់ស្ទូចដែលអាចផ្លាស់ប្តូរបាន

- ធានាថាបន្ទប់ត្រូវមានអង្កត់ផ្ចិតយ៉ាងហោចទទឹង៣៥០០ម.ម x បណ្តោយ ២៥០០ម.ម
- បំពាក់បង់អង្គុយដែលមានកម្ពស់អាចបន្ថែមឬបន្ថយបាន
- ដាក់ក្រដាសអនាម័យនៅគ្រប់បង្គន់
- រៀបចំកន្លែងដែលអាចលើកមនុស្សបានដោយចាប់ជាប់ពិដានឬធ្វើចល័តបាន
- ត្រូវដាក់វាំងននគ្រប់បង្គន់ដើម្បីធានាភាពឯកជនរបស់មនុស្សគ្រប់រូប
- បំពាក់ឧបករណ៍លាងដៃនិងម៉ាស៊ីនសម្ងួតដៃឬកន្សែងជូតដៃ
- ដាក់ធុងសំរាមដែលសមរម្យបំផុតគ្រប់បន្ទប់

## ៥.៤. បន្ទប់ទឹកនិងបន្ទប់ងូតទឹក (Shower Rooms and Bathrooms)



*រូបភាព ៥.៤.១. គំរូអំពីផ្កាឈូកងូតទឹកដែលឌីហ្សាញបានសមរម្យ*

❖ ស្តង់ដានិងការណែនាំអំពីបន្ទប់ទឹកនិងបន្ទប់ងូតទឹក

- ធានាថាបន្ទប់ទឹកមានអង្កត់ផ្ចិត២៣០០ម.ម x ២៥០០ម.ម
- បំពាក់ផ្កាឈូកងូតទឹកតាមកម្ពស់សមរម្យ

- ប្រើប្រាស់ក្បាលផ្កាឈូកងូតទឹកដែលអាចដោះចេញបាន
- ធានាថាប៊ូតុង/ឧបករណ៍កំណត់កម្តៅទឹកងាយប្រើប្រាស់
- ត្រូវដាក់កៅអីជ័រដែលអាចបត់បាននៅក្នុងបន្ទប់ងូតទឹក
- ត្រូវបន្ថែមកៅអីបត់បានសម្រាប់កន្លែងជូតខ្លួន
- ត្រូវដាក់ធ្នាក់ដៃឱ្យបានសមរម្យបំផុត
- ត្រូវចាប់រាំងននគ្រប់បន្ទប់ងូតទឹកដើម្បីធានាភាពឯកជនរបស់អ្នកប្រើប្រាស់
- ប្រើប្រាស់ឧបករណ៍បន្ទប់ទឹកដែលសមស្របដូចជាកន្លែងព្យួរកន្សែង ទំពក់ព្យួរខោអាវនិងកញ្ចក់
- ធានាថាផ្ទៃកម្រាលការ៉ូក្នុងកន្លែងងូតទឹកអាចហូរទឹកបានល្អនិងមិនរអិល



*រូបភាព ៥.៤.២. គំរូអំពីអាងងូតទឹកដែលជនមានពិការភាពជិះរទេះអាចប្រើបាន*

## ៥.៤.១. ផ្កាឈូកងូតទឹកដែលអាចប្រើបានដោយខ្លួនឯង

(Self-Contained Accessible Shower)



*រូបភាព ៥.៤.១.១. គំរូអំពីផ្កាឈូកងូតទឹកនិងកៅអីដែលអាចបត់បាន*

❖ ស្តង់ដានិងការណែនាំអំពីផ្កាឈូកងូតទឹកដែលអាចប្រើបានដោយខ្លួនឯង

- ផ្កាឈូកងូតទឹកដែលអាចប្រើដោយខ្លួនឯងត្រូវបានរចនាឡើងសម្រាប់ការប្រើប្រាស់ឯករាជ្យគួរតែមានទំហំ២៣០០ម.ម x ២៥០០ម.ម
- ផ្កាឈូកងូតទឹកដែលអាចប្រើបានគ្រប់គ្នាគួរតែដាក់បញ្ចូលថាសទឹកផ្កាឈូកងូតទឹកដែលអាចបាញ់ទឹកបានជុំវិញជញ្ជាំងខាងនិងសើមបានពេញបន្ទប់តែត្រូវធានាថាទឹកហូរទៅលូចេញអស់មិនដក់ដែលផ្ទៃនៃបន្ទប់គឺមិនគួរលើសពីជម្រាល១/៥០
- ផ្កាឈូកងូតទឹកគឺអាចបញ្ជាការបិទបើកទឹកបានដូចជា ចេញតិចឬច្រើនតូចឬធំ តាមចំណង់រួមទាំងទឹកក្តៅទឹកត្រជាក់ផង។ រាល់ការរចនាប្រព័ន្ធប្រើប្រាស់នេះត្រូវគិតដល់អ្នកមានបញ្ហាគំហើញផង

*រូបភាព ៥.៤.១.២. ការរៀបចំផ្កាឈូកងូតទឹកដែលអាចប្រើបានដោយខ្លួនឯង*



- ចានឬធុងងូតទឹកក៏អាចប្រើបានផងដែរដែលដាក់នៅលើកម្រាលមានស្រាប់ជំនួសផ្កាឈូកងូតទឹក
- នៅក្នុងបន្ទប់ងូតទឹកទាំងអស់រៀបឥដ្ឋឬសម្ភារៈក្រាលគួរតែមិនងាយមុតនិងមិនរអិលនៅគ្រប់ពេលទាំងពេលសើមនិងពេលស្ងួត
- នៅជុំវិញខាងក្រោមផ្កាឈូកងូតទឹកគួរតែមានទំហំ១២០០ម.ម x ១០០០ម.មនិងទូលាយទាំងសងខាងនិងទីធ្លាទូលាយសម្រាប់អ្នកជិះរទេះផ្លាស់ប្តូរចេញចូលបានដែលមានអង្កត់ផ្ចិត១៨០០ម.ម



*រូបភាព ៥.៤.១.៣. គំរូអំពីបន្ទប់ទឹកដែលសមស្របនិងមានចានបង្គន់នៅខាងក្នុងបន្ទប់*

- ក្បាលផ្កាឈូកងូតទឹកដែលអាចសម្រួលបានគួរចាប់នៅលើជញ្ជាំងនៅខាងលើកៅអីងូតទឹក
- ក្បាលផ្កាឈូកងូតទឹកសម្រាប់ងូតទឹកគួរតែដាក់នៅកម្ពស់ចន្លោះពី ១២០០ម.មទៅ២២០០ម.មពីដីនិងឧបករណ៍បញ្ជាដាក់នៅចន្លោះពី៧៥០ម.មនិង១២០០ម.មពីដី

- សីតុណ្ហភាពទឹកមិនគួរលើសពី៤០អង្សាសេទេ ឧបករណ៍បញ្ជាកម្តៅទឹកក្តៅតិចឬក្តៅខ្លាំងគឺត្រូវច្បាស់លាស់ងាយប្រើនិងដាក់នៅកម្ពស់អាចប្រើបានទាំងអស់គ្នា
- កៅអីប្លាស្ទិកដែលអាចបត់ចុះក្រោមបានមានបង្អែកដាច់ឬបង្អែកជាប់ គួរតែមានសម្រាប់ងូតទឹកនិងត្រូវចាប់ឱ្យបានជាប់មាំនិងមានលំនឹងល្អ
- ត្រូវដាក់កៅអីបែរមុខទៅជញ្ជាំងប្រវែង៦៥០ម.មដើម្បីងាយស្រួលផ្ទេរចុះឡើងរទេះកៅអីត្រូវមានកម្ពស់៤៥០ម.មទៅ៤៨០ម.មនិងមានទទឹង៥០០ម.ម
- ត្រូវមានកៅអីដែលអាចបត់ចុះក្រោមបានទុកបំរុងមួយទៀតដាក់នៅឆ្ងាយពីផ្កាឈូកងូតទឹកសម្រាប់អ្នកអង្គុយពេលជូតខ្លួននិងផ្លាស់សំលៀកបំពាក់ដែលកៅអីទាំងអស់ត្រូវធានាត្រឹមត្រូវនិងមានសុវត្ថិភាពក្នុងការប្រើប្រាស់
- វាំងននមួយឬពីរនៃផ្កាឈូកងូតទឹកគួរតែត្រូវបានផ្តល់ឱ្យយ៉ាងពេញលេញដើម្បីបាំងផ្ទៃផ្កាឈូកងូតទឹកនិងបង្គោលរូតវាំងននប៉ុន្តែមិនគួររំខានដល់ការប្រើប្រាស់ផ្កាឈូកងូតទឹកទេ
- វាំងននផ្កាឈូកងូតទឹកផ្តល់នូវភាពឯកជនដល់មនុស្សម្នាក់ដែលកំពុងប្រើផ្កាឈូកងូតទឹក បើសិនជាដៃគូក៏នៅក្នុងបន្ទប់ដែលអាចជួយរក្សាសម្ភារៈមិនឱ្យទទឹកផងដែរ
- សម្ភារៈក្នុងបន្ទប់រួមទាំងកន្លែងព្យួរកន្សែង សំលៀកបំពាក់និងកញ្ចក់ គួរតែត្រូវបានផ្តល់ជូនកៅអី បង្កាន់ដៃនិងគ្រឿងផ្សេងៗទៀតទាំងអស់គួរតែមានពណ៌ផ្ទុយគ្នាជាមួយផ្ទៃបាតនិងជញ្ជាំង

## ៥.៤.២. ផ្កាឈូកងូតទឹកនៅក្នុងបង្គន់ (Accessible Shower with WC)



*រូបភាព ៥.៤.២.១. គំរូអំពីផ្កាឈូកងូតទឹកនៅក្នុងបង្គន់ដែលគ្មានធ្នាក់ដៃនិងទុយោនៅខាងក្រៅ*

❖ ស្តង់ដានិងការណែនាំអំពីផ្កាឈូកងូតទឹកនៅក្នុងបង្គន់

*រូបភាព ៥.៤.២.២. ប្លង់អំពីបន្ទប់ងូតទឹកសមស្របដែលមានចានបង្គន់*




**ចំណុចសំខាន់ៗ៖**

A. ធ្នាក់ដៃផ្តេកមានអង្កត់ផ្ចិតទំហំ ៣៥មម

B. ខ្សែទាញពេលមានអាសន្ន

C. កៅអីដែលអាចបត់បាន

D. ធ្នាក់ដៃដែលអាចបត់ចុះក្រោមបាន

E. កំរាលបន្ទប់ងូតទឹក

F. ធ្នាក់ដៃបញ្ឈរមានអង្កត់ផ្ចិតទំហំ ៣៥មម

G. ធ្នើសម្រាប់ដាក់ចំណាយកកម្ពស់ ៨៥០មម

H. អាងស្តុកទឹកបង្គន់អាចដាក់ខ្នើយបង្អែក

I. ធ្នាក់ដៃផ្តេកជួយក្នុងការបើកបិទទ្វារ

J. ទំពក់ព្យួរសម្លៀកបំពាក់ដាក់នៅកម្ពស់ ១០៥០មមទៅ១៣០០មម

K. ធ្នាក់ដៃព្យួរកន្សែង

L. ចានលាងដៃ

**សម្គាល់៖** ខ្នាតទាំងអស់គិតជាម.ម



*រូបភាព ៥.៤.២.៣. ជម្រើសផ្សេងទៀតនៃប្លង់អំពីផ្តាឈូកងូតទឹកដែលប្រើដោយខ្លួនឯងនិងចានបង្គន់*




- បន្ទប់ត្រូវមានអង្កត់ផ្ចិត២៧០០ម.ម x ២៨០០ម.ម
- ត្រូវមានបាសាំងលាងដៃទូលាយដែលមានគន្លឹះបិទបើកសមរម្យ

### ៥.៤.៣. ផ្កាឈូកងូតទឹកនិងបង្គន់សម្រាប់ភេទច្រើនប្រើប្រាស់មានអ្នកជំនួយ

(Shower and Peninsular Arrangement WC for Assisted Use)

❖ ស្តង់ដានិងការណែនាំអំពីផ្កាឈូកងូតទឹកនិងបង្គន់សម្រាប់ភេទច្រើនប្រើប្រាស់មានអ្នកជំនួយ

- ផានាថាបន្ទប់មានទំហំ២៥០០ម.ម x ៣១០០ម.ម

*រូបភាព ៥.៤.៣.១. ផ្កាឈូកងូតទឹកនិងការរៀបចំចានបង្គន់នៅចំកណ្តាល សម្រាប់អ្នកប្រើប្រាស់ដែលត្រូវការជំនួយ*




## ៥.៤.៤. បន្ទប់ទឹកសម្រាប់អ្នកអាចប្រើប្រាស់ខ្លួនឯងបាន

(Bathroom for Independent Use)

❖ ស្តង់ដានិងការណែនាំអំពីបន្ទប់ទឹកសម្រាប់អ្នកអាចប្រើប្រាស់ខ្លួនឯងបាន

- ផានាថាបន្ទប់ត្រូវមានអង្កត់ផ្ចិត៣០០០ម.ម x ២៥០០ម.ម

*រូបភាព ៥.៤.៤.១. បន្ទប់ទឹកសម្រាប់អ្នកអាចប្រើប្រាស់ខ្លួនឯងបាននិងផ្នែកមួយនៃកម្ពស់និងប្លង់មេ*




- ត្រូវមានកៅអីចល័តសម្រាប់ជាតម្រូវការពេលងូតទឹក
- ធានាថាម៉ាស៊ីនងូតទឹកដាក់នៅកន្លែងដែលអាចប្រើបាន
- ត្រូវបំពាក់ឧបរណ៍បិទបើកដែលងាយប្រើប្រាស់
- បន្ថែមបាសាំងលាងដៃដែលទូលាយនិងមានគន្លឹះប្រើងាយស្រួល
- ប្រើប្រាស់ឧបករណ៍បន្ទប់ទឹកដែលសមស្របដូចជាកន្លែងព្យួរកន្សែង ទំពក់ព្យួរខោអាវនិងកញ្ចក់

## ៥.៤.៥. ចានសម្រាប់លាងដៃ(ឡាវ៉ាបូ) (Washbasin)










❖ ស្តង់ដានិងការណែនាំអំពីចានសម្រាប់លាងដៃ( ឡាវ៉ាបូ )

- ចានសម្រាប់លាងដៃទំហំ៥២០ម.មនិង៤១០ម.ម
- បំពាក់ដោយគែមខាងលើបំផុតកម្ពស់៧០០ម.មទៅ៨០០ម.មពីដី
- ផ្ទៃសម្រាប់ដាក់ជង្គង់យ៉ាងហោចណាស់មានទទឹង៧៦០ម.មនិងជម្រៅ២០០ម.មនិងមានកម្ពស់៦៥០ម.មទៅ៦៨០ម.មនៅខាងក្រោមចានលាងដៃ
- ជៀសវាងដាក់ចានលាងដៃនៅកាច់ជ្រុងដែលនាំឱ្យពិបាកចូលប្រើប្រាស់
- គួរប្រើរ៉ូប៊ីណេប្រភេទកាច់ប្រសើរជាងប្រភេទចុច
- គែមខាងក្រោមរបស់កញ្ចក់៩០០ម.មទៅ១០០០ម.មពីផ្ទៃបាតកញ្ចក់រាងទេរមកខាងមុខបន្តិច

## ៥.៤.៦. បង្គន់និងចានលាងដៃសម្រាប់កុមារនៅសាលារៀនឬមណ្ឌលសុខភាព

(Toilet and Washbasin for Children at Schools and Health Facilities)

❖ ស្តង់ដានិងការណែនាំអំពីបង្គន់និងចានលាងដៃសម្រាប់កុមារនៅសាលារៀនមណ្ឌលសុខភាព







- ធានាថាបង្គន់នៅកន្លែងដែលស្អាតពុំមានដើមឈើនិងគុម្ពោតព្រៃហើយមានភ្លើងបំភ្លឺគ្រប់គ្រាន់ដើម្បីកុំឱ្យកុមារមានការភ័យខ្លាចនិងទទួលរងការបៀតបៀន
- ធានាថាបង្គន់មានទីតាំងដែលអាចស្រែកឮដល់និងអាចមើលឃើញពីសាលារៀនឬអគារសាធារណៈដទៃទៀតដើម្បីឱ្យកុមារអាចស្រែកហៅសុំឱ្យគេជួយ
- ធានាថាបង្គន់ផ្តល់នូវភាពឯកជនជាពិសេសសម្រាប់ក្មេងស្រី





- ខ្នាតផ្សេងៗទៀតដូចគ្នានឹងបង្គន់សម្រាប់មនុស្សពេញវ័យខាងលើដែរ លើកលែងតែបង្គោលផ្ដេកសម្រាប់ទាញដែលត្រូវមានប្រវែងយ៉ាងហោចណាស់៦០០ម.មនិងកម្ពស់៥០០ម.មទៅ៥៥០ម.មនៅខាងក្នុងទ្វារ
- ធានាថាបង្គន់ចែកដាច់ពីគ្នារវាងកុមារានិងកុមារី
- ធាថាបង្គន់មានអនាម័យ
- ធានាថាបង្គន់អាចប្រើប្រាស់បានគ្រប់គ្នារួមទាំងកុមារពិការគ្រប់ប្រភេទផង
- កន្លែងលាងដៃសាធារណៈត្រូវមានកម្ពស់ខ្ពស់បំផុត៦០០ម.មដែលអ្នកជិះរទេះអាចចេញចូលនិងប្រើបានដែលមានក្បាលរ៉ូប៊ីណេទឹកងាយស្រួលប្រើ
- រៀបចំកន្លែងលាងដៃនៅទីតាំងសមស្របមានដំបូលនិងផ្លូវសមស្របសម្រាប់មនុស្សគ្រប់គ្នា
- ប្រសិនបើធ្វើនៅលើខឿនជៀសវាងលិចទឹករដូវវស្សាត្រូវមានជម្រាលសម្រាប់អ្នកជិះរទេះផង

### ៥.៤.៧ .បង្គន់បែបទីក្រុង (City Toilet)




❖ ស្តង់ដានិងការណែនាំអំពីបង្គន់បែបទីក្រុង

បង្គន់បែបទីក្រុងដូចគ្នានឹងបង្គន់សម្រាប់មនុស្សពេញវ័យខាងលើដែរ លើកលែងតែៈ

- ផ្នែកខាងលើបំផុតរបស់បង្គន់៣០០ម.មទៅ៣៥០ម.មចាប់គិតពីផ្ទៃបាត
- ទំហំចានបង្គន់ៈ បណ្តោយ៤២០ម.ម ទទឹង១២៥ម.មនៅខាងមុខពង្រីកទទឹង២០០ម.មនៅផ្នែកខាងក្រោយ
- ចានបង្គន់ដែលមានទំហំធំពេកអាចធ្វើឱ្យកុមារភ័យខ្លាចធ្លាក់ដែលធ្វើឱ្យពួកគេមិនចង់ទៅបង្គន់
- បង្គោលសម្រាប់ចាប់កាន់កម្ពស់៥០០ម.មទៅ៥៥០ម.មពីដីបន្តប្រវែង២០០ម.មនៅខាងមុខបង្គន់
- នៅខាងជញ្ជាំងបង្គោលសម្រាប់ចាប់កាន់ត្រូវមានរាងជាអក្សរអិល (L)
- បង្គោលផ្តេកកម្ពស់៥០០ម.មចាប់គិតពីផ្ទៃបាតប្រវែង៦០០ម.មនិងអង្កត់ផ្ចិតក្រៅ៣៨ម.ម
- បង្គោលបញ្ឈរ៥០០ម.មចាប់គិតពីផ្ទៃបាតប្រវែង៧០០ម.មនិងអង្កត់ផ្ចិតក្រៅ៣៨ម.ម

## ៥.៤.៨. បង្គន់បែបជនបទ (Local Toilet)





❖ ស្តង់ដានិងការណែនាំអំពីបង្គន់បែបជនបទ

បង្គន់បែបជនបទដូចគ្នានឹងបង្គន់សម្រាប់មនុស្សពេញវ័យខាងលើដែរ លើកលែងតែ៖

- ធ្នាក់ដៃកម្ពស់៥០០ម.មទៅ៥៥០ម.ម ដាក់នៅខាងមុខសម្រាប់ទប់ខ្លួននៅពេលប្រើបង្គន់និងសងខាងដើម្បីជួយពេលអង្គុយចោងហោងនិងក្រោកឈរ
- ពិចារណាដាក់បំពង់ឬស្សី/ឈើ/ទីបបញ្ឈរភ្ជាប់ពីផ្ទៃបាតដល់ពិដានដាក់ខាងមុខបង្គន់សម្រាប់ទប់ខ្លួនដើម្បីជួយពេលអង្គុយចោងហោងនិងក្រោកឈរ



- ប្រើប្រាស់ចានបង្គន់ទាបដែលមានប្រហោងនៅចំកណ្តាលសម្រាប់ដាក់លើបង្គន់ប្រសិនបើកុមារមិនអាចអង្គុយចោងហោងបាន



- កុំដាក់ប្រហោងធំពេកដោយសារតែកុមារអាចភ័យខ្លាចធ្លាក់ចុះទៅក្នុងបង្គន់ហើយពិបាកទៅបង្គន់

### ៥.៤.៩. បង្គន់ដែលមានលក្ខណៈច្នៃប្រឌិតថ្មី (Toilet Innovation in Rural Areas)

❖ ស្តង់ដានិងការណែនាំអំពីបង្គន់ដែលមានលក្ខណៈច្នៃប្រឌិតថ្មី

បង្គន់ដែលមានលក្ខណៈច្នៃប្រឌិតថ្មីនៅតាមតំបន់ជនបទនិងលំនៅឋានឯកជនត្រូវមាន៖

- ធុងសម្រាប់ស្តុកទឹក
- ធុងដែលមានជើងទ្រសម្រាប់ងាយស្រួលដួសទឹកចេញពីកន្លែងអង្គុយលើបង់
- បង់សម្រាប់អង្គុយលាងសម្អាត
- រក្សាភាពឯកជនដោយប្រើប្រាស់សម្ភារៈធម្មជាតិដោយបាំងផ្ទាំងសម្រាប់បិទបាំង
- កៅអីកម្ពស់ទាបដែលអាចឡើងបានពីផ្ទៃបាត ប្រសិនបើពួកគេត្រូវវារ ឬរំកិលដោយសារតែកន្លែងនេះ មិនសមស្របសម្រាប់ចូលរទេះរុញឡើយ
- ចានលាងដៃដែលមានទំហំធំស្ថិតនៅជាប់ (ងាយឈោងដល់) នឹងអ្នកប្រើប្រាស់ដែលអង្គុយលើកៅអី
- បំពង់ទឹករត់កាត់តាមប្រហោងទៅកាន់កន្លែងលាងសម្អាតពីធុងទឹកធំខាងក្រៅដើម្បីកុំឱ្យគេចាំបាច់ទៅដងទឹក។

### ៥.៥. កន្លែងផ្លាស់សម្លៀកបំពាក់ (Changing Areas)




❖ ស្តង់ដានិងការណែនាំអំពីកន្លែងផ្លាស់សម្លៀកបំពាក់

- ធានាថាកន្លែងផ្លាស់សម្លៀកបំពាក់មានសញ្ញាបង្ហាញច្បាស់លាស់
- រៀបចំកន្លែងផ្លាស់សម្លៀកបំពាក់នៅតាមកន្លែងដែលសមរម្យ
- រៀបចំកន្លែងនិងឧបករណ៍ដែលអាចប្រើប្រាស់បានមនុស្សគ្រប់គ្នាក្នុងអគារ

### ៥.៥.១. កន្លែងដែលគេអាចផ្លាស់ប្តូរសម្លៀកបំពាក់ដោយខ្លួនឯងបាន

(Self-Contained Accessible Changing Area)

❖ ស្តង់ដានិងការណែនាំអំពីកន្លែងដែលគេអាចផ្លាស់ប្តូរសម្លៀកបំពាក់ដោយខ្លួនឯងបាន

*រូបភាព ៥.៥.១.១. ផ្នែកមួយនៃកម្ពស់ប្លង់និងកម្ពស់កន្លែងដែលគេអាចផ្លាស់ប្តូរសម្លៀកបំពាក់ដោយខ្លួនឯងបាន*



- ធានាថាបន្ទប់មានអង្កត់ផ្ចិត២៥០០ម.ម x ២៣០០ម.ម
- ត្រូវដាក់ស្លាកសញ្ញាបង្ហាញប្រសិនបើកន្លែងផ្លាស់ប្តូរសម្លៀកបំពាក់មានច្រើនជាង១
- ត្រូវមានកៅអីដែលអាចបត់បាន
- ត្រូវបំពាក់ផ្នាក់ដៃដែលសមរម្យបំផុត
- ប្រើប្រាស់ឧបករណ៍បន្ទប់ទឹកដែលសមស្របដូចជាកន្លែងព្យួរកន្សែង ទំពក់ព្យួរខោអាវនិងកញ្ចក់

### ៥.៥.២. កន្លែងដែលគេអាចផ្លាស់ប្តូរសម្លៀកបំពាក់និងផ្កាឈូកងូតទឹករួមគ្នា

(Communal Changing and Shower Areas)



❖ ស្តង់ដានិងការណែនាំអំពីកន្លែងដែលគេអាចផ្លាស់ប្តូរសម្លៀកបំពាក់និងផ្កាឈូកងូតទឹករួមគ្នា

- ត្រូវធានាភាពឯកជនសម្រាប់កន្លែងងូតទឹកនិងផ្លាស់ប្តូរសម្លៀកបំពាក់នៅកន្លែងប្រើរួមគ្នា
- ធានាថាផ្កាឈូកសម្រាប់ងូតជម្រះក្រោយពេលហែលទឹកនៅអាងហែលទឹកអាចប្រើបានចំពោះមនុស្សគ្រប់គ្នា
- ត្រូវដាក់ផ្កាឈូកងូតទឹកនៅទីតាំងដែលគ្រប់គ្នាអាចយកប្រើបាន
- ត្រូវធានាថាទឹកហូរចេញអស់ល្អនិងកម្រាលមិនរអិល

- ដាក់ផ្កាឈូកងូតទឹកនិងកន្លែងដូរខោអាវនៅក្នុងបង្គន់សម្រាប់ភេទមួយ និងបន្ថែមនៅក្នុងបង្គន់សម្រាប់ច្រើនភេទ

## ៥.៦. លំនៅឋាន (Dwellings)



### ៥.៦.១. បង្គន់លំនៅឋាន (Dwelling Toilets)

❖ ស្តង់ដានិងការណែនាំអំពីបង្គន់លំនៅឋាន

- នៅតាមលំនៅឋានបង្គន់មួយដែលអាចប្រើការបានសម្រាប់អ្នកស្នាក់នៅ និងភ្ញៀវទាំងអស់រួមទាំងអ្នកប្រើរទេះរុញ ឪពុកម្តាយរុញរទេះទារក អ្នកដែលខ្សោយគំហើញ អ្នកប្រើឈើច្រត់ឬអ្នកត្រូវការជំនួយផ្សេងៗត្រូវធ្វើផ្លូវចូលបង្គន់ដោយដាក់កម្រាលឱ្យបានត្រឹមត្រូវ
- បង្គន់ត្រូវមានទំហំបណ្តោយ១១០០ម.មxទទឹង៧០០ម.ម ដោយមានទំហំទូលាយនៅខាងមុខចានបង្គន់ហើយត្រូវកំណត់ទីតាំងចានបង្គន់ឱ្យចំកណ្តាលដោយគិតពីផ្នែកម្ខាងនៃជញ្ជាំងប្រវែង៥០០ម.មនិង១០០០ម.ម ពីទីតាំងផ្សេងៗទៀតដោយគិតពីបច្ចេកទេសនៃការផ្ទេរខ្លួន
- ចំពោះទំហំបន្ទប់ទូទៅមានទទឹង១៨០០ម.ម x ១៥០០ម.មដែលមានទំហំទូលាយសម្រាប់ដាក់ចានបង្គន់ដោយផ្នែកខាងក្រោយលយចេញប្រវែង៧០០ម.ម
- អាងទឹកត្រូវដាក់នៅទីតាំងទូលាយងាយចេញចូលនិងប្រើប្រាស់ ទំហំ១១០០ម.ម x ៧០០ម.ម

- បន្ទប់គួរតែដាក់ទ្វារដែលបើកចេញក្រៅដើម្បីឱ្យទីធ្លាសម្រាប់បន្លាស់ទីនិងចេញចូលគ្មានទើសទែងដោយសារតែសន្លឹកទ្វារ

*រូបភាព ៥.៦.១.១. ការរៀបចំទីធ្លាសម្រាប់បង្គន់តាមជនបទ*




- កន្លែងដែលបើកចេញមកក្រៅគួរតែបើកទៅរកជញ្ជាំងដើម្បីកុំមានគ្រោះថ្នាក់និងឧបសគ្គផ្សេងដល់អ្នកប្រើប្រាស់

*រូបភាព ៥.៦.១.២. ប្លង់បង្គន់និងកន្លែងងូតទឹកនៅតាមជនបទ*



- កន្លែងសម្រាប់ផ្កាឈូកងូតទឹកគួរមានទំហំយ៉ាងហោចណាស់ ១០០០ម.ម x ១០០០ម.មនិងទំហំបន្ទប់ទទឹង១៨០០ម.ម x បណ្ដោយ២០០០ម.ម

*រូបភាព ៥.៦.១.៣. ប្លង់បង្គន់នៅតាមជនបទ*




### ៥.៦.២. បន្ទប់ទឹកតាមផ្ទះ (Domestic Bathrooms)

❖ ស្តង់ដានិងការណែនាំអំពីបន្ទប់ទឹកតាមផ្ទះ

*រូបភាព ៥.៦.២.១. ខ្នាតបន្ទប់ទឹកតាមផ្ទះ*



- ត្រូវរៀបចំបន្ទប់ដែលអាចប្រើបានសម្រាប់មនុស្សគ្រប់គ្នា
- បំពាក់ទ្វារបើកចូលក្នុងដែលរចនាឡើងសម្រាប់ងាយប្រើ
- បន្ទប់ងូតទឹកត្រូវទូលាយសមរម្យ
- ធានាថាជញ្ជាំងមាំអាចចាប់ផ្ទាក់ដៃបានដោយសុវត្ថិភាព
- សូមគិតអំពីការបំពាក់ឧបករណ៍បន្ថែមនៅពេលខាងមុខ
- ត្រូវប្រើក្បាលផ្កាឈូកងូតទឹកដែលអាចដកនិងដាក់បាន
- ត្រូវរៀបចំផ្កាឈូកងូតទឹកដែលអ្នកប្រើអាចយកប្រើតាមចិត្ត
- ត្រូវមានបាសាំងលាងដៃទូលាយដែលអ្នកជិះរទេះអាចប្រើបាន
- ប្រើគន្លឹះបិទបើក
- ត្រូវប្រើប្រាស់ឧបករណ៍ដែលដូចៗគ្នានៅគ្រប់កន្លែងក្នុងអគារ
- ត្រូវបង្កប់ឬការពារទុយោទាំងអស់

## ៥.៧. លម្អិតអំពីការឌីហ្សាញបរិក្ខារនិងទីកន្លែងអនាម័យ

(Detailed Design of Sanitary Facilities)

### ៥.៧.១. ឧបករណ៍បន្លឺសំឡេងរោទិ៍ជាជំនួយ (Assistance Alarms)



*រូបភាព ៥.៧.១.១. គំរូអំពីខ្សែទាញពេលមានអាសន្នដែលមានកងពណ៌ក្រហមពីរនៅក្នុងបន្ទប់ទឹកសម្រាប់ភេទច្រើនដែលផ្ទេរចុះឡើងពីខាងផ្សេង*



*រូបភាព ៥.៧.១.២. គំរូអំពីបន្ទះភ្លើងឆ្នូតៗច្រើនពណ៌សម្រាប់ប្រកាសអាសន្ន*



*រូបភាព ៥.៧.១.៣. ជម្រើសផ្សេងទៀតនៃគំរូអំពីបន្ទះភ្លើងឆ្នូតៗច្រើនពណ៌សម្រាប់ប្រកាសអាសន្ន*

❖ ស្តង់ដានិងការណែនាំអំពីឧបករណ៍បន្លឺសំឡេងរោទិ៍ជាជំនួយ

- ត្រូវមានឧបករណ៍បន្លឺសំឡេងរោទិ៍ជាជំនួយនៅគ្រប់បង្គន់ បន្ទប់ទឹក បន្ទប់ងូតទឹកនិងបន្ទប់ផ្លាស់សម្លៀកបំពាក់ដែលបានឌីហ្សាញសម្រាប់អ្នកអាចប្រើខ្លួនឯងបាន
- ត្រូវដាក់ខ្សែទាញទៅតាមគំនូសសញ្ញាលម្អិត
- នៅតាមបន្ទប់ទឹកនិងកន្លែងងូតទឹកដែលសមស្របគួរបំពាក់ខ្សែទាញពេលមានអាសន្នចំនួន២ដោយ១ដាក់នៅកន្លែងងូតទឹកនិង១ទៀតដាក់នៅជិតចានបង្គន់និងអាចប្រើបានក្នុងករណីមានអ្នកដួល
- គ្រប់ខ្សែទាញពេលមានអាសន្នទាំងអស់ត្រូវដាក់ពណ៌ក្រហមនិងលាតសន្ធឹងជុំវិញបន្ទប់
- គួរដាក់កងពណ៌ក្រហមចំនួន២ដែលមានអង្កត់ផ្ចិត៥០ម.ម ដោយ១ដាក់នៅចុងបញ្ចប់នៃខ្សែនិង១ទៀតដាក់នៅកម្ពស់ពី៨០០ម.មទៅ ១០០០ម.ម
- គួរបន្ថែមសញ្ញាដែលអាចមើលឃើញនិងស្តាប់បាននៅក្នុងនិងក្រៅបន្ទប់ដែលមានសំឡេងរោទិ៍
- គួរដាក់ប៊ូតុងបញ្ជានៅកន្លែងដែលសមរម្យបំផុត

- ធានាថាបុគ្គលិកត្រូវបានបណ្តុះបណ្តាលក្នុងការជួយនៅពេលមានតម្រូវការ

### ៥.៧.២. ទំពក់ព្យួរសម្លៀកបំពាក់ (Clothes Hooks)



*រូបភាព ៥.៧.២.១. គំរូអំពីទ្វារដែលមានទំពក់ព្យួរសម្លៀកបំពាក់*

❖ ស្តង់ដានិងការណែនាំអំពីទំពក់ព្យួរសម្លៀកបំពាក់

- ទំពក់ព្យួរសម្លៀកបំពាក់ត្រូវបំពាក់នៅគ្រប់បន្ទប់អនាម័យនិងបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់
- ត្រូវភ្ជាប់ទៅនឹងកន្លែងនិងកម្ពស់ដែលសមរម្យបំផុតទៅតាមគំនូសសញ្ញាលម្អិត
- ធានាថាទំពក់សម្លៀកបំពាក់មានពណ៌ផ្ទុយពីពណ៌ជញ្ជាំងនិងទ្វារ
- ទំពក់ភ្លោះសម្រាប់ព្យួរអាវធំគួរចាប់នៅកម្ពស់ពី១០៥០ម.មទៅ១៧០០ម.មពីដី

### ៥.៧.៣. ទ្វារនិងគន្លឹះទ្វារ (Doors and Locks)

*រូបភាព ៥.៧.៣.១. ការបិទបើកទ្វារដែលមានត្រចៀកច្រើន*





*រូបភាព ៥.៧.៣.២. គំរូអំពីគន្លឹះដៃទ្វារ*

❖ ស្តង់ដានិងការណែនាំអំពីទ្វារនិងគន្លឹះទ្វារ

*រូបភាព ៥.៧.៣.៤. គ្រឿងផ្សំរបស់ទ្វារ*




- គ្រប់ទ្វារនៃបង្គន់ កន្លែងងូតទឹកនិងបន្ទប់ទឹកដែលសមស្របរួមទាំងទ្វារដែលមានតែមួយសន្លឹកឬទ្វាររុញបើកបិទទៅចំហៀងត្រូវអាចបើកបានតិចបំផុត៩៥០ម.ម
- សោទ្វារទាំងអស់គួរតែងាយប្រើប្រាស់ដោយដៃតែម្ខាងដោយមិនបាច់ប្រើចលនាប្រអប់និងម្រាមដៃសម្រាប់ជនមានពិការភាពដែលមានកម្សោយចលនាប្រអប់ដៃនិងម្រាមដៃ

- សោទ្វារគួរដាក់នៅកម្ពស់៨០០ម.មទៅ១០០០ម.មពីដី
- ដៃទ្វាររាងអក្សរ (L) ត្រូវបានគេប្រើប្រាស់ជាញឹកញាប់
- ត្រូវបំពាក់ទ្វារដែលបើកចេញក្រៅនៅគ្រប់ទីតាំងដែលសមស្រប
- ធានាថាទ្វារដែលបើកចេញក្រៅមិនទៅរំខានដល់ផ្លូវជាពិសេសទ្វារគេចចេញពេលមានអាសន្ន
- ត្រូវបំពាក់បង្កាន់ដៃនៅទទឹងទ្វារដែលបើកចេញក្រៅ
- ត្រូវបំពាក់សញ្ញាសង្គ្រោះសម្រាប់ទ្វារដែលបើកចូលក្នុង
- ចូរប្រើប្រាស់គន្លឹះទ្វារដែលងាយចាប់កាន់
- ធានាថាគន្លឹះទ្វារងាយប្រើប្រាស់
- ធានាថាសញ្ញាគន្លឹះទ្វារដែលមានមនុស្សប្រើនិងគ្មានមនុស្សប្រើដាក់បានត្រឹមត្រូវដើម្បីបញ្ជាក់ថាបន្ទប់ខាងក្នុងទំនេរឬរវល់
- មិនត្រូវប្រើដៃទ្វារបិទបើកដោយកាច់បែបនេះទេគឺប្រើដោយកាច់បើកបែបនេះ

### ៥.៧.៤. ការបន្លឺសំឡេងរោទិ៍ពេលមានអគ្គិភ័យ (Fire Alarm)



❖ ស្តង់ដានិងការណែនាំអំពីការបន្លឺសំឡេងរោទិ៍ពេលមានអគ្គិភ័យ






- នៅគ្រប់បង្គន់សម្រាប់ភេទតែមួយ បង្គន់រួម បន្ទប់ងូតទឹកដោយខ្លួនឯង កន្លែងងូតទឹកនិងបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់ត្រូវបំពាក់ឧបករណ៍បន្លឺសំឡេងរោទិ៍ពេលមានអគ្គិភ័យដែលមានសញ្ញាអាចមើលឃើញនិងស្តាប់បាន
- ត្រូវដាក់ឧបករណ៍បន្លឺសំឡេងរោទិ៍ពេលមានអគ្គិភ័យដែលអាចមើលឃើញនិងស្តាប់បាននៅគ្រប់ទីតាំងអនាម័យដូចជាបន្ទប់ទឹកនិងបង្គន់។ល។

### ៥.៧.៥. ផ្ទាក់ដៃ (Grabrails)



*រូបភាព ៥.៧.៥.១. គំរូអំពីផ្ទាក់ដៃចាប់ជាប់ទ្វារ*

❖ ស្តង់ដានិងការណែនាំអំពីផ្ទាក់ដៃ

*រូបភាព ៥.៧.៥.២. ផ្ទាក់ដៃ*




- ធ្នាក់ដៃគឺបំពាក់សម្រាប់ជួយទប់លំនឹងដងខ្លួនអ្នកប្រើប្រាស់គ្រប់ទីកន្លែងទាំងអស់នៅពេលអង្គុយចុះ ងើបឈរឡើង ផ្ទេរចុះឡើងពីរទេះនិងពេលផ្លាស់ប្តូរសម្លៀកបំពាក់
- ធានាថាធ្នាក់ដៃត្រូវបានដាក់យ៉ាងត្រឹមត្រូវតាមគំនូសសញ្ញាលម្អិត
- ត្រូវប្រើប្រាស់របារជាបំពង់ទីបដែលមានអង្កត់ផ្ចិតពី៣២ម.មទៅ៣៥ម.ម និងចាប់ឃ្លាតពីជញ្ជាំងប្រវែងពី៥០ម.មទៅ៦០ម.ម
- ត្រូវប្រើបំពង់ទីបដែលមានផ្ទៃសមរម្យងាយស្រួលចាប់កាន់ជាពិសេសពេលសើម
- ត្រូវតែធានាថាធ្នាក់ដៃចាប់យ៉ាងជាប់ដោយសុវត្ថិភាពទៅនឹងជញ្ជាំង

### ៥.៧.៦. ឧបករណ៍ផ្លុំសម្ងួតសក់ (Hair Dryers)



❖ ស្តង់ដានិងការណែនាំអំពីឧបករណ៍ផ្តុំសម្ងួតសក់

- ក្នុងករណីដាក់ឧបករណ៍ផ្តុំសម្ងួតសក់ច្រើនត្រូវដាក់កម្ពស់ផ្សេងៗគ្នា
- ឧបករណ៍ផ្តុំសម្ងួតសក់ត្រូវដាក់នៅកម្ពស់ពី៧៥០ម.មទៅ១២០០ម.មពីដី
- ត្រូវដាក់ឧបករណ៍ផ្តុំសម្ងួតសក់សម្រាប់អ្នកប្រើប្រាស់បានទាំងក្នុងស្ថានភាពឈរនិងអង្គុយ
- ធានាថាឧបករណ៍បញ្ជាត្រូវបានដាក់នៅកន្លែងនិងកម្ពស់សម្រាប់អ្នកប្រើគ្រប់គ្នា
- ត្រូវរៀបចំកន្លែងអង្គុយដោយចាំបាច់
- ត្រូវរៀបចំឱ្យមានទីទូលាយសម្រាប់អ្នកប្រើរទេះចេញចូល
- ត្រូវបំពាក់កញ្ចក់ដែលអាចបន្ថែមបន្ថយកម្ពស់បានសម្រាប់ការប្រើប្រាស់ឧបករណ៍នេះ

### ៥.៧.៧. ឧបករណ៍សម្ងួតដៃ (Hand-Drying Facilities)

*រូបភាព ៥.៧.៧.១. គំរូអំពីឧបករណ៍សម្ងួតដៃដែលដាក់នៅកម្ពស់ផ្សេងៗគ្នា*





❖ ស្តង់ដានិងការណែនាំអំពីឧបករណ៍សម្ងួតដៃ

- ត្រូវដាក់ឧបករណ៍សម្ងួតដៃនៅកម្ពស់ពី៨០០ម.មទៅ១២០០ម.មពីដី និងស្របទៅតាមកន្លែងលាងដៃ

- សម្រាប់បង្គន់ បន្ទប់ទឹកនិងបន្ទប់ងូតទឹកត្រូវដាក់ឧបករណ៍សម្ងួតដៃដែលអ្នកប្រើរទេះអាចប្រើបាន
- ត្រូវបំពាក់បន្ថែមកន្លែងដាក់ក្រដាសនិងកន្សែងជាមួយនឹងឧបករណ៍សម្ងួតដៃ
- ត្រូវកំណត់សំឡេងនៃឧបករណ៍សម្ងួតដៃក្នុងករណីមានច្រើននៅកន្លែងតែមួយ

### ៥.៧.៨. ឧបករណ៍កម្តៅ (Heating)



❖ ស្តង់ដានិងការណែនាំអំពីឧបករណ៍កម្តៅ

- ឧបករណ៍កម្តៅអាចបំពាក់នៅតាមទីតាំងដែលចាំបាច់និងមិនរំខាន
- ត្រូវចាប់ឧបករណ៍កម្តៅនៅកម្ពស់សមស្រប
- ធានាថាបន្ទប់កម្តៅត្រូវរៀបចំឱ្យបានត្រឹមត្រូវ
- ធានាថាកម្រិតកម្តៅក្នុងបន្ទប់មិនលើសពី៤០ដឺក្រេ

### ៥.៧.៩. អំពូលភ្លើង (Lighting)



❖ ស្តង់ដានិងការណែនាំអំពីអំពូលភ្លើង

- អំពូលដែលដាក់នៅក្នុងបន្ទប់ទឹកត្រូវមានកម្រិតពន្លឺ២០០លុច
- អំពូលដែលដាក់នៅក្នុងបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់និងកន្លែងងូតទឹកត្រូវមានកម្រិត២០០លុចទៅ៣០០លុច
- កុងតាក់បិទបើកអំពូលភ្លើងត្រូវដាក់នៅកម្ពស់ពី៩០០ម.មទៅ១២០០ម.មពីដីនិងឆ្ងាយពីគែមទ្វារ១៥០ម.ម
- ត្រូវរៀបចំឱ្យមានកម្រិតពន្លឺសមរម្យ
- ត្រូវបំពាក់ឧបករណ៍ផ្ទុកថាមពលនិងថែមអំពូលភ្លើងដែលភ្លឺដោយស្វ័យប្រវត្តិ
- ត្រូវកំណត់ម៉ោងឱ្យបានត្រឹមត្រូវសម្រាប់អំពូលភ្លើងដែលភ្លឺដោយស្វ័យប្រវត្តិ
- ធានាថាខ្សែភ្លើងត្រូវដាក់បានយ៉ាងត្រឹមត្រូវ
- ជៀសវាងប្រើអំពូលដែលមានភ្លើងពណ៌អ៊ុលត្រាវីយ៉ូឡេ( ស្វាយ )

### ៥.៧.១០. សោសុវត្ថិភាព (Lockers)

❖ ស្តង់ដានិងការណែនាំអំពីសោសុវត្ថិភាព

- សោសុវត្ថិភាពដែលសមរម្យមានទំហំទទឹង៣០០ម.ម x ជម្រៅ៦០០ម.ម x កម្ពស់១២០០ម.ម
- ត្រូវចាប់សោសុវត្ថិភាពនៅកម្ពស់ពី៤០០ម.មទៅ៨០០ម.មពីដី
- ត្រូវបំពាក់សោសុវត្ថិភាពនៅទីតាំងសមរម្យបំផុត
- ត្រូវដាក់សោសុវត្ថិភាពដែលមានទំហំផ្សេងគ្នានិងកម្ពស់ផ្សេងគ្នា
- ធានាថាសោសុវត្ថិភាពគ្រប់ទ្វារគឺងាយស្រួលប្រើ
- ត្រូវធានាថាកន្លែងចាក់នៃមេសោនិងកូនសោងាយស្រួលប្រើ
- ត្រូវប្រើប្រព័ន្ធលេខដែលច្បាស់លាស់ងាយចំណាំ

### ៥.៧.១១. កញ្ចក់ឆ្លុះមុខ (Mirrors)



*រូបភាព ៥.៧.១១.១. គំរូអំពីកញ្ចក់ឆ្លុះមុខចាប់ជាប់ជញ្ជាំងទល់មុខបាសាំងលាងដៃក្នុងបង្គន់*

❖ ស្តង់ដានិងការណែនាំអំពីកញ្ចក់

- នៅតាមបន្ទប់ទឹកសម្រាប់ភេទតែមួយត្រូវបំពាក់កញ្ចក់ឆ្លុះមុខដែលអាចប្រើប្រាស់បានដោយមនុស្សដែលមានកម្ពស់ផ្សេងៗ
- នៅតាមបង្គន់ដែលសមស្របត្រូវបំពាក់កញ្ចក់ឆ្លុះមុខនៅនឹងជញ្ជាំងទល់មុខបាសាំងលាងដៃនិងលាតសន្ធឹងពី៦០០ម.មទៅ១៦០០ម.មពីដី
- ក្នុងករណីដែលកញ្ចក់ចាប់នៅខាងលើបាសាំងលាងដៃដែលមានកម្ពស់លើសពី១៦០០ម.មទៅ១៨០០ម.មពីដី ហើយអាចបត់ទ្រេតទៅមុខបានដែលអាចប្រើប្រាស់បានមនុស្សគ្រប់កម្ពស់និងអ្នកជិះរទេះគ្រប់គ្នា
- មិនត្រូវបំពាក់កញ្ចក់ទំហំប៉ុននឹងជញ្ជាំងទេព្រោះនាំឱ្យច្រឡំ
- ត្រូវដាក់កញ្ចក់នៅគ្រប់បង្គន់និងកន្លែងផ្លាស់ប្តូរសម្លៀកបំពាក់ក្នុងកម្ពស់សមស្រប
- ជៀសវាងដាក់កញ្ចក់ដែលពេញមួយជំហរឬកញ្ចក់ដែលអាចធ្វើឱ្យច្រឡំ

### ៥.៧.១២. ធ្នើរ (Shelves)



❖ ស្តង់ដានិងការណែនាំអំពីធ្នើរ

- នៅក្នុងបង្គន់គួរមានធ្នើរ២ជាន់៖ ជាន់ទី១ដាក់នៅកម្ពស់៩៥០ម.ម ពីដីនិងជាន់ទី២ដាក់នៅកម្ពស់៧០០ម.មពីដីដែលមានទំហំ២០០ម.ម x ៤០០ម.មដាក់នៅទល់មុខបាសាំងលាងដៃ
- ត្រូវដាក់ធ្នើរនៅគ្រប់បង្គន់ បន្ទប់ទឹក បន្ទប់ងូតទឹកទៅតាមគំនូសសញ្ញាលម្អិត

### ៥.៧.១៣. ស្លាកសញ្ញា (Signage)

*រូបភាព ៥.៧.១៣.១. គំរូអំពីស្លាកសញ្ញានៅតាមបន្ទប់អនាម័យ*









*រូបភាព ៥.៧.១៣.២. គំរូអំពីស្លាកសញ្ញានៅតាមបង្គន់សម្រាប់ភេទតែមួយ*

❖ ស្តង់ដានិងការណែនាំអំពីស្លាកសញ្ញា

- រាល់បន្ទប់អនាម័យត្រូវមានស្លាកសញ្ញាបង្ហាញឱ្យបានច្បាស់លាស់
- ធានាថាកន្លែងទីតាំងអនាម័យងាយស្រួលរក
- ត្រូវប្រើនិមិត្តសញ្ញានិងសញ្ញាផុស
- ធានាថាកន្លែងដែលចុចឬប៉ះប្រើងាយមើលនិងមានលេខចំណាំ

### ៥.៧.១៤. កន្លែងដាក់សាប៊ូ (Soap Dispensers)



❖ ស្តង់ដានិងការណែនាំអំពីកន្លែងដាក់សាប៊ូ

- កន្លែងដាក់សាប៊ូត្រូវចាប់ជាប់ជញ្ជាំងនៅពីលើបាសាំងលាងដៃ ធ្នើរឬតុដាក់អីវ៉ាន់
- កន្លែងដាក់សាប៊ូត្រូវមានប៊ូតុងធំៗសម្រាប់ចុចយកសាប៊ូ
- បង្គន់សម្រាប់តែភេទមួយត្រូវដាក់ធ្នើរដាក់សាប៊ូនៅកម្ពស់ល្មមសម្រាប់អ្នកប្រើងាយយក
- នៅគ្រប់បង្គន់ទាំងអស់ត្រូវដាក់ឧបករណ៍ដាក់របស់ផ្សេងៗដែលអ្នកប្រើរទេះអាចយកបាន

- ត្រូវតែមានឧបករណ៍ដោយមិនត្រូវដាក់របស់ប្រើប្រាស់ផ្សេងៗផ្ទាល់នៅនិងឥដ្ឋឡើយ
- ធានាថាឧបករណ៍ដាក់របស់ប្រើប្រាស់ផ្សេងៗក្នុងបន្ទប់ទឹកឬបង្គន់ងាយស្រួលប្រើ

### ៥.៧.១៥. ផ្ទៃបាត (Surfaces)



❖ ស្តង់ដានិងការណែនាំអំពីផ្ទៃបាត

- ផ្ទៃបាត ជញ្ជាំង ទ្វារ ឧបករណ៍អនាម័យ ធ្នាក់ដៃនិងឧបករណ៍ផ្សេងៗទៀត គួរតែងាយស្រួលសម្អាតនិងងាយស្រួលមើលសម្រាប់អ្នកខ្សោយគំហើញ
- ត្រូវរៀបចំផ្ទៃបាតដែលរឹងមាំមានកម្ពស់(ខ្នងអណ្តើក)និងមិនរអិល
- ជៀសវាងប្រើផ្ទៃដែលរលោងពេកនិងចាំង
- ត្រូវរៀបឥដ្ឋសម្រាប់ជនមានពិការភាពភ្នែកនៅគ្រប់កន្លែងទាំងអស់
- ត្រូវធានាថាការឌីហ្សាញផ្នែកខាងក្នុងប្រកបដោយការទាក់ទាញ

### ៥.៧.១៦. កន្លែងពង្រួតក្រដាសអនាម័យ (Toilet Paper Dispensers)



❖ ស្តង់ដានិងការណែនាំអំពីកន្លែងព្យួរក្រដាសអនាម័យ

- កន្លែងព្យួរក្រដាសអនាម័យគួរតែដាក់នៅទីតាំងណាដែលងាយស្រួលយកក្នុងបន្ទប់ទឹក ហើយអាចប្រើប្រាស់បានទាំងអ្នកអង្គុយកៅអីនិងអ្នកដែលឈរផងដែរ ដោយងាយស្រួលប្រើប្រាស់ដោយដៃម្ខាងនិងអ្នកដែលមានដៃខ្សោយឬមានបញ្ហាចលនាដៃផ្សេងៗ
- ប្រសិនបើកន្លែងព្យួរក្រដាសអនាម័យជុំវង្វង់មូលត្រូវធានាថាមានគន្លាក់ដែលទាញក្រដាសរួចកាត់ក្រដាសបានដោយស្រួលទៅតាមប្រវែងដែលចង់បានឬអាចប្រើក្រដាសជាសន្លឹកធំៗជំនួសបាន
- រនាំងនៅក្នុងបង្គន់អនាម័យសម្រាប់ភេទតែមួយត្រូវដាក់ក្រដាសអនាម័យកុំឱ្យប៉ះពាល់ដល់ការបិទបើកទ្វារ

### ៥.៧.១៧. ម៉ាស៊ីនលក់ទំនិញ (Vending Machines)



❖ ស្តង់ដានិងការណែនាំអំពីម៉ាស៊ីនលក់ទំនិញ

- គ្រប់ម៉ាស៊ីនលក់ទំនិញទាំងអស់ត្រូវតែមើលឃើញច្បាស់និងងាយប្រើប្រាស់
- ប៊ូតុងបញ្ជាទាំងអស់ត្រូវរៀបចំឱ្យជនមានពិការភាពខ្សោយគំហើញអាចប្រើប្រាស់បាន

- ត្រូវដាក់ម៉ាស៊ីននៅកម្ពស់ពី៧៥០ម.មទៅ១២០០ម.មពីដី
- នៅខាងក្រោមប៊ូតុងបញ្ជាត្រូវរក្សាចន្លោះប្រហោងកម្ពស់៤៥០ម.ម សម្រាប់ចូលប្រអប់ជើង
- ត្រូវដាក់ម៉ាស៊ីនលក់ទំនិញឱ្យស្មើគ្នាទាំងនៅកន្លែងសម្រាប់ភេទមួយ និងភេទច្រើន
- ត្រូវអនុវត្តន៍តាមការណែនាំប្រើប្រាស់ឱ្យបានហ្មត់ចត់

### ៥.៧.១៨. ធុងសំរាម (Waste Disposal)



❖ ស្តង់ដានិងការណែនាំអំពីធុងសំរាម

- ត្រូវដាក់ធុងសំរាមនៅគ្រប់បង្គន់អនាម័យទាំងអស់
- នៅតាមបង្គន់អនាម័យជនមានពិការភាពត្រូវដាក់ធុងសំរាមនៅចន្លោះ ចានបង្គន់និងជញ្ជាំង
- ធានាថាធុងសំរាមនីមួយៗងាយស្រួលប្រើប្រាស់និងធំទូលាយល្មម
- ធានាថាធុងសំរាមសម្រាប់ដាក់សំរាមទូទៅត្រូវបានដាក់ចំកន្លែងនិង ងាយស្រួលរក

### ៥.៧.១៩. ប្រព័ន្ធទឹក (Water Supply)



❖ ស្តង់ដានិងការណែនាំអំពីប្រព័ន្ធទឹក

- ទឹកសម្រាប់ប្រើប្រាស់នៅបាសាំងលាងដៃមិនត្រូវមានកម្តៅលើសពី៤0អង្សារសេដើម្បីសុវត្ថិភាព
- កម្រិតសម្ពាធទឹកនៅតាមក្បាលទុយោនីមួយៗត្រូវតែអាចសម្រួលបានតាមតម្រូវការ
- ធានាថាបាសាំងលាងដៃត្រូវគ្នាជាមួយក្បាលតំណ

### ៥.៧.២០. អណ្តូងស្នប់ (Hand Pump)

❖ ស្តង់ដានិងការណែនាំអំពីអណ្តូងស្នប់



- អណ្តូងស្នប់ត្រូវធ្វើនៅកន្លែងដែលមានអ្នកប្រើប្រាស់ច្រើននិងធ្វើនៅលើទីធ្លាសមរម្យទៅតាមចំនួននៃអ្នកប្រើប្រាស់




- ខឿននៃបរិវេណអណ្តូងអាចធ្វើទាបឬខ្ពស់ទៅតាមទីតាំងជាក់ស្តែង (ជៀសវាងលិចទឹករដូវវស្សាដែលមិនអាចប្រើបានឬខូច)
- អាចប្រើប្រាស់អណ្តូងស្នប់ជាកន្លែងយកទឹកទៅប្រើប្រាស់ឬបោកគក់នៅទីនេះបាន
- ត្រូវសង់កន្លែងអង្គុយសម្រាប់អ្នកមិនអាចឈរបាន



- ត្រូវធ្វើកន្លែងបង្ហូរទឹកជៀសវាងទឹកដក់នៅលើកម្រាលអណ្ដូងដែលនាំឱ្យរអិលនិងឆាប់ខូច
- អណ្ដូងស្នប់ត្រូវធ្វើលើផ្ទៃទំហំតូចបំផុត២០០០ម.ម x ១៧៥០ម.ម (មិនគិតពីកន្លែងបង្ហូរទឹកចេញនិងជម្រាលចុះឡើង)
- បរិវេណនៃអណ្ដូងត្រូវធ្វើឱ្យយ៉ាងណាមិនរអិលនិងត្រូវមានគែមព័ទ្ធជុំវិញដូចជម្រាលដែរ
- កន្លែងបង្ហូរទឹកចេញមានទំហំ១០០ម.មទៅ៣០០ម.មអាស្រ័យទៅតាមចំនួនអ្នកប្រើប្រាស់និងបណ្ដោយវែងឬខ្លីទៅតាមស្ថានភាពដី




- អាចបំពាក់បង្កាន់ដៃជុំវិញបរិវេណអណ្ដូងស្នប់ទៅតាមខ្នាតបង្កាន់ជម្រាល
- ត្រូវធ្វើជម្រាលតភ្ជាប់ពីផ្លូវដែលជនមានពិការភាពអាចប្រើបានដើម្បីឡើងចុះទៅបរិវេណអណ្ដូងស្នប់ទៅតាមខ្នាតជម្រាលអមដោយបង្កាន់ដៃផង
- ត្រូវធ្វើកៅអីអង្គុយសម្រាប់ប្រើប្រាស់ក្នុងបរិវេណអណ្ដូងដែលចាប់ជាប់ឬចល័តបានទំហំ៤៥០ម.ម x ៤៥០ម.ម កម្ពស់៤៥០ម.មទៅ៤៨០ម.ម
- ដៃសប់អាចធ្វើពីដែកឬឈើទៅតាមស្ថានភាពជាក់ស្ដែងដែលមានទំហំអង្កត់ផ្ចិត៣០ម.មទៅ៥០ម.មនិងមានប្រវែងបណ្ដោយ១០៥០ម.ម ដែលងាយស្រួលសប់ ដាក់ប្រេងឱ្យគួរពេលសប់)

- ត្រូវដាក់ដៃសប់នៅកម្ពស់១០០០ម.ម



- បំពង់ចេញទឹកអាចធ្វើប្រវែងពី៣០០ម.មទៅ៦០០ម.មចេញពីបំពង់ទឹក ដោយប្រើប្រាស់ទុយោទំហំ៣០០ម.មទៅ៤៥០ម.មនិងត្រូវដាក់ កម្ពស់៦០០ម.មទៅ៧០០ម.មពីដី
- ត្រូវធ្វើឱ្យទីធ្លានៅខាងមុខនិងជុំវិញបំពង់នេះទំនេរ
- ដើម្បីឱ្យចំណោញទីធ្លាពេលប្រើអណ្តូងត្រូវធ្វើខឿនដែលទុកបំពង់ទុយោ នៅកៀន








### ៥.៧.២១. អណ្តូងយោង (Tube Wells)

❖ ស្តង់ដានិងការណែនាំអំពីអណ្តូងយោង

- អណ្តូងយោងគឺជាប្រភពទឹកមួយប្រភេទដែលគេជីកនិងដាក់លូចូលទៅក្នុងដីជ្រៅឬរាក់ទៅតាមតំបន់និងការចង់បាន
- អាចប្រើប្រាស់អណ្តូងយោងជាកន្លែងយកទឹកទៅប្រើប្រាស់ឬបោកគក់នៅទីនេះបាន




- អណ្តូងយោងត្រូវធ្វើនៅកន្លែងដែលមានអ្នកប្រើប្រាស់ច្រើននិងធ្វើនៅលើទីធ្លាសមរម្យទៅតាមចំនួននៃអ្នកប្រើប្រាស់
- អណ្តូងយោងមួយប្រើប្រាស់បានអាចធ្វើពីថ្ម ដែកនិងឈើ
- ខឿននៃបរិវេណអណ្តូងអាចធ្វើទាបឬខ្ពស់ទៅតាមទីតាំងដាក់ស្តែង (ជៀសវាងលិចទឹករដូវវស្សាដែល មិនអាចប្រើបានឬខូច)




- ដើម្បីឱ្យចំណោញទីធ្លាពេលប្រើអណ្តូងត្រូវធ្វើខឿនដែលទុកលូអណ្តូងនៅកៀន
- អណ្តូងស្នប់ត្រូវធ្វើលើផ្ទៃទំហំតូចបំផុត២២០០ម.ម x ២៤០០ម.ម (មិនគិតពីកន្លែងបង្ហូរទឹកចេញនិងជម្រាលចុះឡើង)
- កន្លែងបង្ហូរទឹកចេញមានទំហំ១០០ម.មទៅ៣០០ម.មអាស្រ័យទៅតាមចំនួនអ្នកប្រើប្រាស់និងបណ្តោយវែងឬខ្លីទៅតាមស្ថានភាពដី
- លូទឹកត្រូវដាក់លៀនមកខាងលើកម្ពស់៨០០ម.ម
- អាចបំពាក់បង្កាន់ដៃជុំវិញបរិវេណអណ្តូងស្នប់ទៅតាមខ្នាតជម្រាល



- ត្រូវធ្វើជម្រាលតភ្ជាប់ពីផ្លូវដែលជនមានពិការភាពអាចប្រើបានដើម្បីឡើងចុះទៅបរិវេណអណ្តូងស្នប់ទៅតាមខ្នាតជម្រាលអមដោយបង្កាន់ដៃផង
- លូទឹកអាចប្រើប្រាស់លូទំហំអង្កត់ផ្ចិតពី៥០០ម.មទៅ១០០០ម.ម
- ត្រូវធ្វើកៅអីអង្គុយសម្រាប់ប្រើប្រាស់ក្នុងបរិវេណអណ្តូងដែលចាប់ជាប់ឬចល័តបានទំហំ
- ៤៥០ម.ម x ៤៥០ម.មកម្ពស់៤៥០ម.មទៅ៤៨០ម.ម

**អំពីប្រព័ន្ធយោងទឹកៈ**

- រ៉ុកដែកទំហំអង្កត់ផ្ចិត១៣០ម.ម
- របារដែលដាក់ពីបង្គោលម្ខាងទៅម្ខាងទំហំអង្កត់ផ្ចិត២០ម.ម
- ចាប់បង្គោលឈើឬដែកសងខាងលូអណ្តូងទំហំ១០០ម.ម x ១០០ម.មកម្ពស់១៧០០ម.មទៅ១៨០០ម.មពីដី
- ខ្សែដែលងាយប្រើនិងមានទំហំសមរម្យមាំនិងមិនក្តៅដៃ
- ធ្វើកន្លែងសម្រាប់ចងកន្ទុយខ្សែក្រោយពេលប្រើ
- ធុងទឹកដែលមានចំណុះ៥លីត្រទៅ១០លីត្រ អាស្រ័យទៅតាមភាគច្រើននៃអ្នកប្រើប្រាស់
- អាចច្នៃឧបករណ៍យោងទឹកផ្សេងៗទៀតដែលងាយស្រួលសម្រាប់ជនមានពិការភាព



### ៥.៧.២២. កំពង់ទឹកនៅទន្លេ បឹងនិងស្រះ (Ports)



❖ ស្តង់ដានិងការណែនាំអំពីកំពង់ទឹកនៅទន្លេ បឹងនិងស្រះ

- គេអាចប្រើប្រាស់ទឹកទន្លេ បឹងនិងស្រះបានដោយធ្វើដូចអណ្តូងស្នប់ឬអណ្តូងយោងនៅមាត់ទន្លេ បឹងនិងស្រះនោះបានខុសគ្នាត្រង់ប្រភពទឹកផ្សេងគ្នាគឺអ្នកប្រើប្រាស់ទឹកមិនបានចុះទៅក្នុងទន្លេ បឹងនិងស្រះផ្ទាល់ទេ ដោយគ្រាន់តែរៀបចំកន្លែងនិងប្រព័ន្ធដែលអាចសប់ឬយោងយកទឹកមកប្រើនៅខាងលើបាន



- កំពង់អាចធ្វើពីថ្ម ដែកនិងឈើទៅតាមស្ថានភាពជាក់ស្តែងនិងទាប ឬខ្ពស់ទៅតាមតំបន់និងទីតាំងនៃកំពង់នោះ
- ត្រូវចេះជ្រើសរើសឧបករណ៍ដែលត្រូវនិងស្ថានភាពទីតាំងដើម្បីអាចប្រើប្រាស់បានយូរ



# ឯកសារយោង


១. ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ http://www.mlmupc.gov.kh/

២. ការរចនាជាសាកល (Universal Design 2012) http://www.universaldesign.ie/Built-Environment/Building-for-Everyone/

៣. អង្គការសហប្រជាជាតិ UN Enable http://www.un.org/esa/socdev/enable/designm/index.html

៤. សៀវភៅណែនាំខែធ្នូ ឆ្នាំ២០០៨និងឯកសារព័ត៌មានគោលស្ដីពីលទ្ធភាពចេញចូល ខែធ្នូ ឆ្នាំ២០១៥ របស់អង្គការ Handicap International Federation – Cambodian Thailand Program

៥. Accessibility Design Guide: Universal design principles for Australia's Aid Program A companion volume to Development for All: Towards a Disability-Inclusive Australian Aid Program 2009-2014 www.ausaid.gov.au

៦. Accessible Components for the Built Environment: Technical Guidelines Embracing Universal Design 2014 of UNICEF https://www.unicef.org/cambodia/

៧. Guide for Convenience Facility for the Disabled, Republic of Korea https://elaw.klri.re.kr/eng_service/lawView.do?hseq=37706&lang=ENG

៨. Accessibility Guideline Book 2015 of Phnom Penh Center for Independent Living (PPCIL) http://www.ppcil.org/

៩. Promoting Access to the Built Environment Guidelines, November 2006 of CBM https://www.cbm.org/Cambodia-267853.php

## ឧបសម្ព័ន្ធ

## នៃប្រកាសរួមលេខ ២៨៤ ស.អ.ល/ហ.ប.ក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨

## ការដាក់ឱ្យអនុវត្តនូវបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

## បង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព

## សន្ទានុក្រម

**១-ស្តង់ដា** សំដៅដល់ឯកសារដែលត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀងគ្នានិងបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច ដែលមានលក្ខណៈជាក្បួន ជាគោលការណ៍ណែនាំ ឬជាចរិកលក្ខណៈសម្រាប់សកម្មភាព ឬជាលទ្ធផលដើម្បីទុកសម្រាប់ប្រើប្រាស់ជារួម ឬជាបន្តបន្ទាប់សំដៅធានាសម្រេចឱ្យបានដល់ចំណុចប្រសើរបំផុតនៃបរិបទមួយ។

**២-ជនមានពិការភាព** សំដៅដល់ជនមានពិការភាពទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬ សតិបញ្ញាបណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅឬសកម្មភាពនានាប្រចាំថ្ងៃ ដូចជាជនមានពិការភាពរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកលនិងប្រភេទពិការផ្សេងៗទៀតដែលនាំឱ្យមានលក្ខណៈមិនប្រក្រតី។

**៣-ចិញ្ចើមផ្លូវ** សំដៅដល់ផ្នែកសងខាងនៃទ្រូវផ្លូវនៅក្នុងទីប្រជុំជន ដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ដាំដើមឈើ និងបង្កប់បរិក្ខារបម្រើផលប្រយោជន៍សេវាសាធារណៈ។

**៤-ផ្លូវថ្មើរជើង** សំដៅដល់ផ្នែកមួយនៃផ្លូវថ្នល់ដែលធ្វើឬរៀបចំឡើងសម្រាប់ឱ្យមនុស្សដើរប្រកបដោយសុវត្ថិភាព។

**៥-គន្លងផ្លូវ** សំដៅដល់ចំណែកមួយនៃទ្រូងផ្លូវ ទុកសម្រាប់ឱ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍។

**៦-ផ្លូវរាជធានី និងផ្លូវក្រុង** សំដៅដល់ផ្លូវដែលស្ថិតក្នុងបរិវេណភូមិសាស្ត្ររាជធានី ខេត្ត ដោយរួមមាន ទ្រូង ផ្លូវ ចិញ្ចើមផ្លូវ និងផ្លូវថ្មើរជើង។

**៧-ទីកន្លែងសាធារណៈ** សំដៅដល់បរិវេណ ទីតាំង អគារ និងមធ្យោបាយដឹកជញ្ជូននានា ដែលជាកម្មសិទ្ធិរដ្ឋសាធារណៈ ឬឯកជនដែលបើកទូលាយនិងផ្តល់សេវាដល់សាធារណជនទូទៅជាអាទិ៍ ÷ ក្រសួង ស្ថាប័ន មន្ទីរ ផ្លូវថ្នល់ កន្លែងលំហែលកាយ មជ្ឈមណ្ឌលវប្បធម៌ កន្លែងលេងកីឡា កន្លែងកម្សាន្ត គ្រឹះស្ថានអប់រំ សណ្ឋាគារ មន្ទីរពេទ្យ មណ្ឌលសុខភាព អាហារដ្ឋាន ប្រព័ន្ធដឹកជញ្ជូន។

**៨-ហេដ្ឋារចនាសម្ព័ន្ធ** គឺជាប្រព័ន្ធ សេវាកម្ម សម្ភារ បរិក្ខា ឬឧបករណ៍ជាមូលដ្ឋានដែលត្រូវការសម្រាប់ប្រើប្រាស់ប្រតិបត្តិការ និងគាំទ្រក្នុងសកម្មភាពនៃជីវិតរស់នៅប្រចាំថ្ងៃប្រកបដោយប្រសិទ្ធភាព (ដូចជា អគារ ផ្លូវថ្នល់ សេវាកម្មដឹកជញ្ជូន ថាមពល។ល។)

**៩-អគារលំនៅឋាន** សំដៅដល់សំណង់អគារដែលមានមុខងារចម្បងបម្រើដល់ការស្នាក់នៅជាបណ្តោះអាសន្ននិងអចិន្ត្រៃយ៍មានដូចជាអគារលំនៅឋានដាច់ (ភូមិគ្រឹះនិងពាក់កណ្តាលភូមិគ្រឹះ) លំនៅឋានជាប់

(ផ្ទះល្វែងនិងផ្ទះជាប់គ្នា) អគារស្នាក់នៅរួមប្រភេទប្រណិត អគារស្នាក់នៅរួមប្រភេទមធ្យម អគារស្នាក់នៅរួមប្រភេទធម្មតា។

**១០-អគារពាណិជ្ជកម្ម** សំដៅដល់សំណង់អគារដែលមានមុខងារចម្បងសម្រាប់បម្រើវិស័យធុរកិច្ច និងសេវាកម្មនានា មានដូចជា អគារការិយាល័យ ធនាគារ រោងកុន រោងល្ខោន ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន ក្លឹបកម្សាន្ត សណ្ឋាគារ ហាងលក់ដូរ ផ្សារ ផ្សារទំនើប ស្ថានីយប្រេងឥន្ធនៈ និងអគារពាណិជ្ជកម្មផ្សេងៗ។ល។

**១១-អគារឧស្សាហកម្ម** សំដៅដល់សំណង់អគារដែលមានមុខងារចម្បងបម្រើដល់វិស័យឧស្សាហកម្មខ្នាតធំ និងសេវាកម្មដែលមានជាតិពុលខ្ពស់ដូចជា រោងចក្រ រោងសិប្បកម្មខ្នាតធំ ឃ្លាំង យានដ្ឋាន និងអគារផ្ទុកទំនិញផ្ទាល់ខ្លួន។ល។

**១២-អគារសិក្សាធិការ អប់រំ និងកីឡា** សំដៅដល់សំណង់អគារដែលមានមុខងារចម្បងបម្រើការសិក្សាអប់រំបណ្ដុះបណ្ដាល សិក្សាធិការ និងកីឡា រួមមាន អគារគ្រឹះស្ថានឧត្ដមសិក្សា មធ្យមសិក្សា បឋមសិក្សា មជ្ឈមណ្ឌលកីឡា មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ វិទ្យាស្ថានសិក្សាស្រាវជ្រាវ សាលាជំនាញឯកទេស សាកលវិទ្យាល័យ មហាវិទ្យាល័យ និងសាលាមតេយ្យសិក្សា ។ល។

**១៣-អគារសុខាភាព** សំដៅដល់សំណង់អគារដែលមានមុខងារចម្បងបម្រើសេវាសុខភាពប្រជាពលរដ្ឋទូទៅ រួមមានអគារមន្ទីរសុខាភិបាល មន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យប្រតិបត្តិ មណ្ឌលសុខភាព ប៉ុស្ដិ៍សុខភាព គ្លីនិកឯកជន មន្ទីរពេទ្យពហុព្យាបាល និងក្លឹបហាត់ប្រាណសុខភាព។

**១៤-អគារកម្សាន្ត** សំដៅដល់សំណង់អគារដែលមានមុខងារចម្បងបម្រើការសេវាកម្សាន្តមានដូចជា សាលមហោស្រព សាលប្រជុំ សាលពិធី រោងភាពយន្ត សាលជួបជុំ។

**១៥-អគាររដ្ឋបាលនិងសេវាសាធារណៈ** សំដៅដល់សំណង់អគារដែលមានមុខងារចម្បងបម្រើដល់វិស័យរដ្ឋបាលនិងសេវាសាធារណៈដូចជា ទីស្ដីការក្រសួង ស្ថាប័ន មន្ទីរ អង្គភាព សាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ សាលារៀន មន្ទីរពេទ្យ បណ្ណាល័យ មណ្ឌលសុខភាព ប្រៃសណីយ៍។ល។

**១៦-អគារវប្បធម៌និងសាសនា** សំដៅដល់សំណង់អគារដែលមានមុខងាចម្បងបម្រើដល់វិស័យប្រវត្តិសាស្ត្រ សិល្បៈ វប្បធម៌ កីឡា លំហែ និងសាសនា ដូចជា ប្រាសាទ វត្តអារាម វិហារសាសនា សាលារៀន សារមន្ទីរ ទីលានកីឡា កន្លែងសិប្បកម្មចម្លាក់ សាលាឆទាន ពុទ្ធិកសាកលវិទ្យាល័យ។ល។

**១៧-អគារទេសចរណ៍** សំដៅដល់សំណង់អគារដែលមានមុខងារចម្បងបម្រើដល់វិស័យទេសចរណ៍និងកម្សាន្តរួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន អហារដ្ឋាន កន្លែងកម្សាន្ត និងរមណីយដ្ឋាន។ល។

**១៨-អគារដឹកជញ្ជូន** សំដៅដល់សំណង់អគារដែលមានមុខងារចម្បងបម្រើដល់សេវាកម្មនៃវិស័យដឹកជញ្ជូន និងគមនាគមន៍មានជាអាទិ៍ ស្ថានីយរថភ្លើង ព្រលានយន្តហោះ ស្ថានីយរថយន្ត កំពង់ចម្លង កំពង់ផែ កំពង់ផែស្ងួត ឃ្លាំង មជ្ឈមណ្ឌលទូរគមនាគមន៍ មជ្ឈមណ្ឌលចែកចាយទំនិញនិងភស្តុភារកម្ម។ល។

**១៩-ទីកន្លែងលំហសាធារណៈនិងផ្ទៃបៃតង** សំដៅដល់ទីន្លែងឬទីធ្លាដែលរៀបចំសម្រាប់បម្រើដល់សារណជនទូទៅដូចជាការសម្រាក ការលំហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់ សួនច្បារ ទីធ្លាកម្សាន្ត។ល។

**២០-តំបន់រដ្ឋបាលនិងសេវាសាធារណៈ** សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យរដ្ឋបាលនិងសេវាសាធារណៈ ដូចជាទីស្តីការក្រសួង ស្ថាប័ន មន្ទីរ អង្គភាព សាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ សាលារៀន មន្ទីរពេទ្យ បណ្ណាល័យ មណ្ឌលសុខភាព ប្រៃសណីយ៍ ។ល។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

**២១-តំបន់លំហសាធារណៈនិងផ្ទៃបៃតង** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលំហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជា ឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់ សម្រាប់បម្រើដល់សាធារណជន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យនេះ។

# កសាងនិងកែសម្រួលសម្រាប់មនុស្សគ្រប់រូប

"Design for Everyone"

